សៀវភៅ

# ប្រស្នាធម្មវិភាគ

# ពុទ្ធ-វិសជ្ជនា

រៀបរៀង

បណ្ឌិត ឈឹម ទូច

ជំនួយអ្នកសិក្សាធម្មវិន័យថ្នាក់ ត្រី

ការផ្សាយរបស់
បណ្ណាគារភ្នំពេញ ៥៩ ប៉ាស្ទ័រ

ភាគ ១ ភាគ ២

២

# ប្រស្នាធម្មវិភាគ

========

## នមត្ថុ សុគតស្ស

សូមនមស្ការ ចំពោះព្រះសុគត (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ) ដោយគោរព ។

បុច្ឆា- សួរថា៖ ធម៌ ប្រែដូចម្ដេច ?

វិស្សជ្ជនា- ឆ្លើយថា៖ ប្រែថា៖ សភាវៈដែលទ្រទ្រង់នូវសត្វហៅថាធម៌ ដូចបទវិគ្គហថា សត្តេ ធារេតីតិ ធម្មោ (សភាវោ) (សភាវៈ) ទ្រទ្រង់នូវសត្វទាំងឡាយ ឈ្មោះថាធម៌។

បុ. ធម៌ដែលទ្រទ្រង់នូវសត្វនោះ តើទ្រទ្រង់បានសត្វពួកណាខ្លះ ?

វិ. ធម៌ដែលទ្រទ្រង់នូវសត្វនោះ ទ្រទ្រង់បានមនុស្សលោក ទេវលោក និងព្រហ្មលោក ។

បុ. ពួកសត្វកើតនៅក្នុងអបាយភូមិបានអ្វីទ្រទ្រង់ ?

វិ. សត្វដែលកើតនៅក្នុងអបាយភូមិបានអកុសលកម្ម ទ្រទ្រង់ ?

បុ. ពាក្យថាធម៌នេះ ហៅបានតែខាងកុសលឬទេ? ឬហៅបានខាងអកុសលដែរ ?

វិ. ពាក្យថាធម៌នេះ ហៅបានចំពោះតែខាងកុសលម្យ៉ាង, ចំណែកខាងអកុសល ហៅថាធម៌មិនបានទេ ។

បុ. បើមិនហៅថាធម៌ទេ ហេតុអ្វីក៏មានន័យច្រើនម្លេះ ដូចយ៉ាង អកុសលាធម្មា ធម៌ទាំងឡាយជាអកុសល ចាបធម្មា ធម៌ទាំងឡាយដ៏លាមក, ទុច្ចរិតា ធម្មា ធម៌ទាំងឡាយជាទុច្ចរិត តណ្ហា ធម្មា ធម៌ទាំងឡាយមានពណ៌ខ្មៅជាដើម បើដូច្នោះ ពាក្យទាំងនោះមិនខុសទៅហើយឬ ?

វិ. ពិតមែនតែមានមកដូច្នោះ ប៉ុន្តែសុទ្ធតែជាអំពើអកុសលៗ ទាំងនេះហើយដែលលុបធម៌ ឱ្យទៅជាអធម៌ គឺមិនមែនធម៌នោះ ។

បុ. ធម៌ទាំងប្រាំបីម៉ឺនបួនពាន់ព្រះធម្មក្ខន្ធ រាប់អកុសលធម៌ចូលដែរឬទេ ?

វិ. ត្រង់បទអក្ខរៈ ព្យញ្ជនៈ គាថា ដែលព្រះអង្គទ្រង់សំដែង អំពីអំពើបាបទាំងប៉ុន្មានរាប់ចូលក្នុងធម្មក្ខន្ធ ត្រង់អំពើបាប ដែលនាំសត្វទៅអបាយនោះ រាប់ចូលក្នុងធម្មក្ខន្ធមិនបានទេ ។

បុ. ត្រង់ធម៌និងអធម៌ទាំងពីរម៉ាត់នេះ ចូរអាងពុទ្ធភាសិត មកមើល ?

វិ. ពុទ្ធភាសិតក្នុងគម្ពីរធម្មបទដ្ឋកថាសំដែងថា ៖

ន ហិ ធម្មោ អធម្មោ ច    ឧភោ សមវិបាកិនោ
អធម្មោ និរយំ នេតិ    ធម្មោ បាបេតិ សុគតឹ ។

ប្រែថាៈ សភាវៈពីរយ៉ាងគឺធម៌ ១, អធម៌ ១ ឱ្យផលមិនស្មើគ្នាទេ អធម៌តែងនាំសត្វទៅកាន់នរក, ធម៌តែងនាំសត្វទៅកាន់សុគតភព ។ ត្រង់ពាក្យថាអធម៌នេះ ប្រែថាមិនមែនធម៌ បានសេចក្ដីថា អំពើណាដែលនាំសត្វទៅកាន់ទុគ្គតិភព ហៅថាអធម៌ទាំងអស់ ព្រោះហេតុនោះ បានជាចាត់អកុសលទាំងអស់មិនហៅថាធម៌ទេ ។

បុ. ដូចជាអលោភៈ អទោសៈ អមោហៈ ហេតុដូចម្ដេចក៏ចាត់ជាកុសលធម៌ដែរ ?

វ. បានជាចាត់ជាកុសលធម៌នោះ ព្រោះលោភៈ ទោសៈ មោហៈ ជាតួអកុសលធម៌ កាលបើអៈនៅខាងដើម បដិសេធរបស់អាក្រក់ទៅជាល្អវិញ បើកាលណារបស់ល្អនៅខាងចុងមានអៈនៅខាងដើម បដិសេធល្អនោះទៅជាអាក្រក់វិញ ។

បុ. ពាក្យថាធម៌នេះ សំដៅយកធម៌ណាខ្លះ? ទើបហៅថាធម៌?

វិ. ពាក្យថាធម៌ សំដៅយកអដ្ឋង្គិកមគ្គទាំង ៨, ធម៌ណាដែលសង្គ្រោះចូលក្នុងអដ្ឋង្គិកមគ្គទាំង ៨ បាន ធម៌នោះឈ្មោះថាធម៌ទាំងអស់ ធម៌ណាសង្គ្រោះចូលក្នុងអដ្ឋង្គិកមគ្គមិនបាន ធម៌នោះឈ្មោះថាអធម៌ ។

បុ. រឿងអកុសលធម៌ ដែលថាមិនមែនធម៌នោះ ព្រះអង្គមានសំដែងក្នុងព្រះសូត្រណាខ្លះ ? ចូរអាងទាញសូត្រនោះមកមើល ?

វិ. ត្រង់រឿងនេះ ព្រះអង្គទ្រង់សំដែងទុកក្នុងគោតមីសូត្រចំពោះព្រះនាងមហាបជាបតិគោតមីថាៈ

សរាគាយ ធម៌ណាប្រព្រឹត្តទៅ ដើម្បីតម្រេក;

សំយោគាយ ធម៌ណាប្រព្រឹត្តទៅ ដើម្បីប្រកបដោយទុក្ខ;

អាចយាយ ធម៌ណាប្រព្រឹត្តទៅ ដើម្បីសន្សំកិលេស;

មហិច្ឆតាយ ធម៌ណាប្រព្រឹត្តទៅ ដើម្បីប្រាថ្នាធំ;

អសន្តុដ្ឋិយា ធម៌ណាប្រព្រឹត្តទៅ ដើម្បីមិនសន្តោស ចំពោះរបស់តាមមានតាមបាន;

សង្គណិកាយ ធម៌ណាប្រព្រឹត្តទៅ ដើម្បីច្រឡូកច្រឡំ ដោយពួកដោយគណៈ;

កោសជ្ជាយ ធម៌ណាប្រព្រឹត្តទៅ ដើម្បីសេចក្តីខ្ជិលច្រអូស;

ទុព្ភរតាយ ធម៌ណាប្រព្រឹត្តទៅ ដើម្បីគេចិញ្ចឹមក្រ ។

ធម៌ទាំងនេះ គប្បីដឹងថា មិនមែនជាធម៌ជាវិន័យ មិនមែនជាពាក្យប្រៀនប្រដៅរបស់តថាគតទេ ។ ហេតុនេះ ទើបចាត់ថាអកុសលធម៌ទាំងអស់ មិនហៅថាធម៌ទេ ព្រោះអាងសូត្រនេះ ។

---

# ទុក្កៈ ពួក ២

## ធម៌មានឧបការៈច្រើន ២ យ៉ាង

១-សតិ សេចក្ដីរឭបាន;

២-សម្បជញ្ញៈ សេចក្ដីដឹងខ្លួន ។

បុ. សតិនិងសម្បជញ្ញៈ ទាំងពីរនេះមានលក្ខណៈផ្សេងគ្នាដូចម្ដេចខ្លះ ?

វិ. មានលក្ខណៈផ្សេងគ្នាដូច្នេះ គឺសតិមានលក្ខណៈរក្សាបុគ្គលមិនឱ្យប្រមាទភ្លាំងភ្លាត់ភ្លេចខ្លួន, សម្បជញ្ញៈ មានលក្ខណៈឱ្យដឹងខ្លួនក្នុងវេលាធ្វើ វេលានិយាយ វេលាគិតនូវកិច្ចានុកិច្ច ដែលត្រូវធ្វើ ត្រូវនិយាយ ត្រូវគិតនោះៗ មិនឱ្យខូចខាត ដូចជាមាតាបិតាចាំហាមប្រាមបុត្រធីតាមិនឱ្យធ្វើអំពើអាក្រក់ផ្សេងៗ ឱ្យតាំងនៅក្នុងអំពើល្អតែម៉្យាងដូច្នោះ ។

បុ. ហេតុដូចម្ដេចបានជាលោកចាត់ សតិ និងសម្បជញ្ញៈថាជាធម៌មានឧបការៈច្រើន ? ចូរអធិប្បាយ !

វិ. បានជាលោកចាត់ធម៌ទាំងពីរនេះ ថាមានឧបការៈច្រើននោះ ព្រោះបណ្ដាកុសលធម៌ទាំងអស់ ដែលស្ថិតនៅបាន

ព្រោះអាស្រ័យមានសតិនិងសម្បជញ្ញៈទាំងពីរនេះជាមូលដ្ឋាន បើប្រាសចាកធម៌ទាំងពីរហើយ កុសលធម៌ទាំងអស់មិនអាចនឹងស្ថិតនៅបានឡើយ, សតិនេះជាតួអប្បមាទធម៌ គ្រាន់តែវេវចនៈផ្លាស់ប្តូរពាក្យគ្នាហៅប៉ុណ្ណោះ បានជាព្រះអង្គ កាលទៀបនឹងបរិនិព្វានទ្រង់បន្លឺឧទានវាចាជាទីបំផុតថាៈ អប្បមាទេន សម្បាទេថ អ្នកទាំងឡាយចូរញុំាងអប្បមាទធម៌ ឱ្យសម្រេច គឺថាៈ ចូរកុំប្រហែសធ្វេសឡើយ, ព្រះអង្គមានព្រះពុទ្ធដីកាប៉ុណ្ណោះ ហាក់ដូចជាចប់ធម៌ទាំងប្រាំបីម៉ឺនបួនពាន់ព្រះធម្មក្ខន្ធ គឺព្រះអង្គទ្រង់ប្រមើលមើលទៅឃើញតែសតិនេះហើយដែលជាធម៌មានឧបការៈច្រើន ជាងកុសលធម៌ទាំងអស់ បានជាចាត់សតិនិងសម្បជញ្ញៈនេះ ថាជាធម៌មានឧបការៈច្រើន ។

ម៉្យាងទៀត ដូចជាការងារក្នុងបច្ចុប្បន្ននេះ បើបុគ្គលណាប្រាសចាកសតិនិងសម្បជញ្ញៈទាំងពីរនេះហើយ ការងារនោះមុខជាភ្លាំងភ្លាត់ខូតខាតមិនបានសម្រេច ដូចជាអ្នកបើកកប៉ាល់ជាដើម មនុស្សអ្នកជិះទាំងប៉ុន្មាន ស្លាប់រស់នៅលើអ្នក

បើកនោះទាំងអស់ សតិទុកដូចជាអ្នកបើក កុសលធម៌ទាំង-អស់ដូចជាអ្នកជិះដូច្នោះ ។

ម៉្យាងវិញទៀត ដូចជាមនុស្សពិការអវយវៈដៃឬជើង ភ្នែកត្រចៀកជាដើម បើខូចខ្លះនៅខ្លះគង់មានប្រយោជន៍តិចច្រើនខ្លះមិនខាន បើអវយវៈទាំងអស់នៅគ្រប់គ្រាន់ តែបើខូចសតិគឺឆ្កួតហើយ មនុស្សនោះទៅជាឥតប្រយោជន៍គ្មានបានការអ្វីបន្តិចបន្តួចសោះ បានជាថាសតិនេះមានឧបការៈច្រើន ។ សតិនិងសម្បជញ្ញៈជាធម្មជាតប្រាសចាកគ្នាមិនបាន ប្រៀបដូចជាអាខ្វាក់អាខ្វិន តែងពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកលះបង់ចោលគ្នាមិនបានដូច្នោះ ។

---

## លោកបាលធម៌ ២ យ៉ាង

១-ហិរិ សេចក្តីខ្មាសបាប;

២-ឱត្តប្បៈ សេចក្តីក្រែងខ្លាចបាប ។

បុ. លោកបាលធម៌ប្រែដូចម្តេច ?

វិ. លោកបាលធម៌ ប្រែថា ធម៌រក្សាលោក ។

បុ. លោកនោះមានប៉ុន្មាន ? គឺអ្វីខ្លះ ?

វិ. លោកនោះមាន ៣ គឺ សង្ខារលោក ១, សត្តលោក ១, ឱកាសលោក ១ ។

បុ. ធម៌រក្សាលោកនោះ បានដល់លោកពួកណា ?

វិ. រក្សាបានតែសត្តលោកម្យ៉ាង ឯលោកទាំងពីរនោះ ធម៌នេះមិនត្រូវរក្សាទេ ។

បុ. សត្តលោកនោះ តើលោកដូចម្តេច ?

វិ. សត្តលោកនោះ បានដល់ពួកសត្វនរក, ប្រេត, តិរច្ឆាន, មនុស្ស, ទេវតា, ព្រហ្ម, ឈ្មោះសត្តលោក ។

បុ. លោកបាលធម៌ រក្សាសត្តលោកនេះ រក្សាសត្តលោកចំពូកណាខ្លះ ?

វិ. រក្សាសត្តលោកនោះ គឺរក្សាបានតែមនុស្សលោក និងទេវលោកចំពូកខ្លះ ប៉ុណ្ណោះ ។

បុ. ហេតុអ្វីបានជានរក, ប្រេត, តិរច្ឆាន និងព្រហ្ម ធម៌នេះមិនត្រូវរក្សាផង ។

វិ. នរក, ប្រេត, តិរច្ឆាន បានជាធម៌ទាំងពីរនេះរក្សាមិនបាន ព្រោះមានអកុសលកម្មខ្លាំងពេក ធម៌ទាំងនេះមិនអាចនឹង

ជួយរក្សាបានទេ; ចំណែកព្រហ្មលោក សោយតែបីតិដែលកើតអំពីឈាន ផុតវិស័យដែលធម៌ទាំងពីរនេះនឹងត្រូវរក្សាបាន ព្រោះធម៌ទាំងពីរនេះជាហេតុនាំឱ្យកើតសីល, ព្រហ្មជាន់លើផុតរក្សាសីលហើយ; នរក, ប្រេត, តិរច្ឆាន រក្សាសីលមិនកើតបានជាធម៌នេះមិនត្រូវរក្សាសត្វចំពូកនោះៗទេ ។

បុ. ហិរិនិងឱត្តប្បៈនេះ មានសេចក្តីផ្សេងគ្នាដូចម្តេច ?

វិ. មានសេចក្តីផ្សេងគ្នាយ៉ាងនេះ គឺហិរិ ប្រែថា អៀន, ខ្មាស, ខ្មើម; ឱត្តប្បៈ ប្រែថា ខ្លាច, តក់ស្លុត, ភ័យ; ធម៌ទាំងពីរនេះប្រៀបដូចជាដែកពីរដុំ ដែកមួយដុំត្រជាក់ទេ ប៉ុន្តែប្រឡាក់លាមក, ដែកមួយដុំទៀតក្តៅ; ដែកមួយត្រជាក់តែប្រឡាក់លាមកនោះ បុគ្គលមិនហ៊ានកាន់ ព្រោះខ្មើម ដូចជាហិរិ; ដែកមួយដុំក្តៅ បុគ្គលមិនហ៊ានកាន់ ព្រោះខ្លាចក្តៅ ដូចឱត្តប្បៈ ។

បុ. ដូចជាមនុស្សប្រព្រឹត្តធ្វើអំពើអាក្រក់ផ្សេងៗ ហើយអៀនខ្មាសព្រោះខ្លាចគេដឹង គេឮ តើចាត់ជាលោកបាលធម៌បានដែរឬទេ ?

វិ. ចាត់ជាលោកបាលធម៌មិនបានទេ ដែលចាត់ជាលោក-បាលធម៌បាននោះ ចំពោះតែអៀនខ្មាសអំពើទុច្ចរិត ហើយមិនហ៊ានប្រព្រឹត្តធ្វើខ្លាចធ្លាក់ទៅអបាយ ។

បុ. ហិរិ ចែកជាប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

វិ. ហិរិ ចែកជា ៤ យ៉ាងគឺៈ ១-ជាតឹ បច្ចវេក្ខិត្វា ពិចារណាឃើញជាតិ; ២-វយំ បច្ចវេក្ខិត្វា ពិចារណាឃើញវ័យ; ៣-សូរភាវំ បច្ចវេក្ខិត្វា ពិចារណាឃើញសេចក្តីក្លៀវក្លា; ៤-ពហុស្សច្ចំ បច្ចវេក្ខិត្វា ពិចារណាឃើញខ្លួនជាពហុស្សូត ។

បុ. ចូរអធិប្បាយហិរិទាំង ៤ យ៉ាងនេះមកមើល ?

វិ. អធិប្បាយថាៈ **ជាតឹ បច្ចវេក្ខិត្វា** ពិចារណាឃើញជាតិនោះ គឺពិចារណាឃើញថា ខ្លួនកើតមកជាមនុស្សមានជាតិខ្ពង់ខ្ពស់ មិនគួរទៅប្រព្រឹត្តធ្វើបាបកម្មផ្សេងៗ ដូចជាមនុស្សថោកទាប ឬសត្វតិរច្ឆាននោះទេ ពិចារណាឃើញដូច្នេះហើយក៏វៀរចាកនូវបាបកម្មនោះៗ ទៅ, **វយំ បច្ចវេក្ខិត្វា** ពិចារណាឃើញវ័យនោះ គឺខ្លួនចូលក្នុងមជ្ឈិមវ័យ ឬបច្ឆិមវ័យហើយពិចារណាឃើញថាៈ អាត្មាអញមានវ័យកន្លងហើយ មិនគួរនឹងធ្វើបាបកម្មផ្សេងៗ ដូចជានៅក្មេងសោះ ពិចារណាឃើញយ៉ាង

នេះហើយ ក៏លះបង់នូវបាបកម្មនោះៗ ទៅ, **សុរតោទំបច្ចវេក្ខិត្វា** ពិចារណាឃើញសេចក្ដីក្ដៀវក្លានោះ គឺខ្លួនជាមនុស្សមានបណ្ដាស័ក្ដិ មានទ្រព្យសម្បត្តិ ឬក៏មានជាតិជាក្សត្រ ទៅកាន់ទីប្រជុំណាៗ តែងមានសេចក្ដីក្ដៀវក្លាអង់អាចជាងគេ មានគេកោតខ្លាចក្រាបសំពះច្រើន ក៏នឹកឃើញថា អាត្មាអញនេះគ្មានសីលសោះ ហើយក៏រក្សាសីលឡើង; **ពាហុសច្ចំ បច្ចវេក្ខិត្វា** ពិចារណាឃើញថាខ្លួនជាពហុស្សូតនោះ គឺខ្លួនជាអ្នកចេះដឹងច្រើនជាងគេ ហើយទៅប្រព្រឹត្តធ្វើអំពើលាមកផ្សេងៗ ក៏នឹកដល់ការចេះដឹងនោះ ក៏អៀនខ្មាសមិនហ៊ានធ្វើអំពើលាមកនោះៗ ។ ហិរិទាំង ៤ នេះ ជាអជ្ឈត្តិកសមុដ្ឋាន មានដែនកើតអំពីខ្លួនឯង ជាអត្តាធិប្បតេយ្យ ប្រារព្ធខ្លួនជាធំ ។

បុ. ឱត្តប្បៈនោះចែកចេញជាប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

វិ. ឱត្តប្បៈនោះចែកចេញជា ៤ យ៉ាងគឺៈ **១-បរានុវាទភយ** ភ័យអំពីពាក្យតិះដៀលបុគ្គលដទៃ, **២-អត្តានុវាទភយ** ភ័យអំពីការតិះដៀលខ្លួនឯងបាន, **ទុគ្គតិភយ** ភ័យខ្លាចធ្លាក់ទៅទុគ្គតិ, **៤-ទណ្ឌភយ** ភ័យអំពីអាជ្ញារបស់ស្ដេច ។

បុ. អធិប្បាយឱត្តប្បៈទាំង ៤ យ៉ាងនោះមកមើល ?

វិ. អធិប្បាយថា **បរានុវាទភយ** ភ័យអំពីពាក្យតិះដៀល បុគ្គលដទៃនោះ គឺខ្លួនឯងប្រព្រឹត្តអាក្រក់ដោយហេតុណាមួយ ខ្លាចគេតិះដៀលហើយក៏មិនហ៊ានប្រព្រឹត្តអំពើនោះៗ, **អត្តានុ-វាទភយ** ភ័យអំពីការតិះដៀលខ្លួនឯងបាននោះ គឺឃើញទោសខ្លួនឯង ដែលបានប្រព្រឹត្តខុសពីថ្ងៃមុនមក នឹកឡើងក្តៅក្រហាយអន្ទះអន្ទែងក្នុងចិត្ត ហើយក៏ខ្លាចអំពើអាក្រក់នោះមិនហ៊ានធ្វើ, **ទុគ្គតិភយ** ភ័យខ្លាចធ្លាក់ទៅទុគ្គតិនោះ ព្រោះឃើញទោសក្នុងអបាយពិតប្រាកដ, ទណ្ឌភយ ភ័យអំពីអាជ្ញារបស់ស្ដេចនោះ គឺមិនហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់ផ្សេងៗ មានលួចគេជាដើម ព្រោះខ្លាចជាប់គុកច្រវាក់ ។ ឱត្តប្បៈទាំង ៤ នេះជាពហិទ្ធាសមុដ្ឋាន មានដែនកើតពីខាងក្រៅ ជាលោកា-ធិប្បតេយ្យ ប្រារព្ធយកលោកជាធំ ។

បុ. លោកបាលធម៌ ប្រែថា ធម៌រក្សាលោកនោះ តើរក្សាដូចម្ដេចទៅ ធម៌រក្សាមនុស្ស ឬមនុស្សរក្សាធម៌ ?

វិ. លុះតែមនុស្សទៅប្រព្រឹត្ត ទើបធម៌រក្សាមនុស្ស សមដូចពុទ្ធភាសិតសំដែងថាៈ

**ធម្មោ ហវេ រក្ខតិ ធម្មចារឹ ធម្មោ សុចិណ្ណោ សុខមាវហាតិ**
**ឯសានិសំសោ ធម្មេ សុចិណ្ណេ ន ទុគ្គតឹ គច្ឆតិ ធម្មចារី ។**

ធម៌ហ្នឹងឯងរមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ ធម៌ដែលបុគ្គលសន្សំហើយ រមែងនាំមកនូវសេចក្តីសុខ, កាលបើបុគ្គលសន្សំធម៌ដោយប្រពៃហើយ រមែងបាននូវអានិសង្សបែបនេះមិនខាន បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិឡើយ។

ធម៌ទាំងពីរប្រការនេះ រមែងគ្រប់គ្រងរក្សាលោក (គឺពួកសត្វ) ឱ្យជាគណៈ ជាក្រុមនៅជាសុខសប្បាយ ដូចមាតាបិតារក្សាបុត្រធីតាឱ្យបានសេចក្តីសុខ វៀរមិនឱ្យបៀតបៀនគ្នានិងគ្នាដូច្នោះ ។

---

# ធម៌ធ្វើឱ្យល្អ ២ យ៉ាង

១-ខន្តី សេចក្តីអត់ធន់;

២-សោរច្ចៈ សេចក្តីស្ងប់ស្ងៀម ។

បុ. ខន្តីនិងសោរច្ចៈ មានលក្ខណៈផ្សេងគ្នាដូចម្តេច ?

វ. មានលក្ខណៈផ្សេងគ្នាយ៉ាងនេះ គឺសេចក្ដីអត់ធន់ទ្រាំទ្រនឹងអក្កោសវត្ថុទាំង ៩ យ៉ាង ដែលមកប៉ះពាល់ ឬក៏អត់ធន់សេចក្ដីលំបាក អត់ធន់សេចក្ដីឈឺចិត្ត ជាលក្ខណៈរបស់ខន្តី ។ សេចក្ដីរីករាយស្រស់របស់មានចិត្តល្អ មិនសំដែងអាការឱ្យប្រាកដ ក្នុងកាលអ្នកដទៃប្រមាថមើលងាយជាលក្ខណៈរបស់សោរច្ចៈ ។

បុ. ហេតុដូចម្ដេចបានជាចាត់ ខន្តី និង សោរច្ចៈនេះថាជាធម៌ធ្វើឱ្យល្អ ?

វិ. បានជាលោកចាត់ធម៌ទាំងពីរនេះថា ជាធម៌ធ្វើឱ្យល្អនោះ ព្រោះថាបើបុគ្គលណាមានធម៌ទាំងពីរនេះ ប្រចាំនៅក្នុងខន្ធសន្តានហើយ ទោះបីបុគ្គលនោះទៅនៅទីណា កន្លែងណា រមែងបានសេចក្ដីសុខចំរើន បានកេរ្តិ៍ឈ្មោះល្អ នឹងអាចធ្វើអ្នកដទៃឱ្យល្អបានថែមទៀតផង ដូចយ៉ាងនាងឧត្តរា នាងមានធម៌ខន្តីនៅក្នុងខន្ធសន្តាន នាងអាចញ៉ាំងនាងសិរិមាឱ្យបានសម្រេចមគ្គផលថែមទៀត ។ អាក្រក់នោះមិនមែនអាក្រក់តែឈ្មោះទេ សូម្បីរូបរាងក៏អាក្រក់ដែរ ដូចមានក្នុងចូឡកម្មវិភង្គ-សូត្រសំដែងថាៈ មនុស្សដែលមានរូបអាក្រក់ មកពីមាន

សេចក្ដីក្រោធ ដូចយ៉ាងនាងបញ្ចបាបាជាដើម នាងមានរូបអាក្រក់យ៉ាងនេះមកពីមិនមានខន្ដីនិងសោរច្ចៈ បានជាលោកចាត់ថាជាធម៌ធ្វើឱ្យល្អ គឺធ្វើឱ្យល្អក្នុងលោកនេះនិងលោកខាងមុខ ។

---

## បុគ្គលរកបានដោយកម្រ ២ យ៉ាង

១-**បុព្វការី** អ្នកធ្វើឧបការៈមុន;

២-**កតញ្ញូ** កតវេទី អ្នកដឹងឧបការៈដែលគេធ្វើហើយធ្វើតបវិញ ។

បុ. បុព្វការី បានដល់បុគ្គលណាខ្លះ? មានប៉ុន្មានយ៉ាង? អ្វីខ្លះ ?

វិ. បុព្វការី បានដល់អ្នកដែលបានផ្ដួចផ្ដើមទំនុកបំរុងមុនឈ្មោះថាបុព្វការីៗ នេះមាន ៤ យ៉ាងគឺៈ មាតាបិតាជាបុព្វការីរបស់បុត្រធីតា ១, គ្រូឧបជ្ឈាយាចារ្យជាបុព្វការីរបស់អន្ដេវាសិក ១, ព្រះរាជាជាបុព្វការីរបស់ប្រជារាស្ដ្រ ១, ព្រះសម្ពុទ្ធជា

បុព្វការីរបស់ពួកពុទ្ធបរិស័ទ ១ ។ ម្យ៉ាងទៀត អ្នកដទៃទេ ប៉ុន្តែគេបានទំនុកបម្រុងខ្លួនមុន ក៏ហៅថាឧបការីបានដែរ ។

បុ. បុព្វការីបុគ្គល ដូចយ៉ាងព្រះពុទ្ធចុះ គួរចាត់ថារកបានដោយកម្រមែន ចុះដូចយ៉ាងមាតាបិតាគ្រូឧបជ្ឈាយាចារ្យជាដើម ហេតុអ្វីក៏លោកចាត់ថារកបានដោយកម្រដែរ ? ព្រោះហេតុអ្វី ?

វិ. បានជាលោកចាត់ថារកបានដោយកម្រដែរនោះ គឺបុព្វការីបុគ្គលទាំងនោះ កម្រនឹងបានជួយទំនុកបំរុងទៅតាមគន្លងធម៌ ដូចយ៉ាងមាតាបិតា មានចិត្តស្នេហាដល់បុត្រធីតាជាទីបំផុត តែមិនសង្គ្រោះទៅតាមសង្គហធម៌ទាំង ៥ ម្ល៉ោះហើយកូននោះ ក៏ប្រព្រឹត្តធ្វើអំពើអាក្រក់ផ្សេងៗ បានសេចក្ដីទុក្ខទៅខាងមុខ, ចំណែកគ្រូទំនុកបម្រុងកូនសិស្សមិនសូវស្មោះត្រង់ ច្រើនតែប្រកបដោយអគតិធម៌ទាំង ៤ មិនសង្គ្រោះទៅតាមសង្គហធម៌ ដែលត្រូវសង្គ្រោះនោះៗ, ចំណែកខាងព្រះរាជាច្រើនតែមិនប្រកបដោយទសពិធរាជធម៌ ១០ យ៉ាង, ចំណែកអ្នកដទៃ បើជួយទំនុកបម្រុងគិតតែទារយកប្រយោជន៍ផ្ទាល់ខ្លួន កម្រនឹងមានអ្នកណាជួយទំនុងបំរុងដោយស្មោះ

ត្រង់, បុព្វការីទាំងនេះមកពីតណ្ហាគ្របសង្កត់ បានជាលោកចាត់ថារកបាយដោយកម្រ ។

បុ. ចុះកតញ្ញូ កតវេទី នោះ ហេតុអ្វីក៏លោកចាត់ថារកបានដោយកម្រដែរ ?

វិ. បានជាលោកចាត់ថារកបានដោយកម្រដែរនោះ ព្រោះមានអវិជ្ជាគ្របសង្កត់មិនឱ្យដឹងឧបការគុណ ដែលអ្នកដទៃបានធ្វើដល់ខ្លួននោះៗ ទុកជាឱ្យផែនដីសោយរាជ្យក៏បុគ្គលអកតញ្ញូនោះនៅតែរករឿងរកទោសផ្សេងៗ បានជាលោកចាត់ថារកបានដោយកម្រ ។

បុគ្គលរកបានដោយកម្រទាំងពីរពួកនេះដូចបានវិស្សជ្ជនាមកនេះ ។

ចប់ទុកៈ ពួក ២

---

# តិកៈ ពួក ៣

## រតនៈ ៣ យ៉ាង

## ព្រះពុទ្ធ ១, ព្រះធម៌ ១, ព្រះសង្ឃ ១,

១-លោកអ្នកប្រដៅពួកជនឱ្យប្រតិបត្តិល្អដោយកាយវាចាចិត្ត តាមធម្មវិន័យ ហៅថា ព្រះពុទ្ធ;

២-ធម្មវិន័យ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហៅថាព្រះធម៌;

៣-ពួកជនដែលបានស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធហើយប្រតិបត្តិល្អតាមធម្មវិន័យ ហៅថា ព្រះសង្ឃ ។

បុ. ចូរអធិប្បាយ រតនៈ ទាំងបីយ៉ាងនោះមកមើល ?

វិ. រតនៈ ប្រែថា កែវ ដែលជាវត្ថុនាំឱ្យកើតសេចក្តីត្រេកអរ តែរតនៈក្នុងទីនេះសំដៅយកព្រះពុទ្ធ ១, ព្រះធម៌ ១, ព្រះសង្ឃ ១ ព្រោះអាចធ្វើឱ្យកើតសេចក្តីជ្រះថ្លាត្រេកអរ ដល់អ្នកដែលជ្រះថ្លា អ្នកដែលដល់នូវរតនៈទាំង ៣ នេះ ជាទីពឹងទីរលឹកហើយ រមែងរួចចាកទុក្ខទាំងពួង ។

# គុណរបស់ព្រះរតនៈ ៣ យ៉ាង

១-ព្រះពុទ្ធទ្រង់ត្រាស់ដឹងប្រពៃ ដោយព្រះអង្គជាមុន ហើយប្រដៅអ្នកដទៃឱ្យដឹងតាមផង;

២-ព្រះធម៌រក្សាអ្នកប្រតិបត្តិ មិនឱ្យធ្លាក់ទៅក្នុងទីអាក្រក់;

៣-ព្រះសង្ឃ លោកប្រតិបត្តិល្អតាមពាក្យប្រដៅរបស់ព្រះពុទ្ធ ហើយប្រដៅអ្នកដទៃឱ្យធ្វើតាមផង ។

បុ. ចូរអធិប្បាយគុណរបស់ព្រះរតនៈទាំង ៣ យ៉ាងនោះមកមើល ?

វិ. ការដឹងអរិយសច្ចៈ ៤ គឺទុក្ខសច្ច ១, សមុទសច្ច ១, និរោធសច្ច ១, មគ្គសច្ច ១ ហៅថា ត្រាស់ដឹងប្រពៃ ព្រះអង្គមិនគ្រូអាចារ្យណានឹងប្រៀនប្រដៅ ទ្រង់ជ្រួតជ្រាបដោយព្រះបញ្ញាញាណរបស់ព្រះអង្គឯង ហៅថា ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ហើយទើបប្រដៅអ្នកដទៃ ឱ្យត្រាស់ដឹងតាមក្នុងសច្ចធម៌ទាំង ៤ យ៉ាងនោះ ។

ព្រះធម៌តែងរក្សាគ្រប់គ្រងអ្នកប្រតិបត្តិ មិនឱ្យធ្លាក់ទៅទីអាក្រក់ សមដូចពុទ្ធភាសិតសំដែងថា:

៨ ទុក្កតី កច្ចតិ ជម្មចារី បុគ្គលអ្នកប្រព្រឹត្តធម៌រមែងមិនធ្លាក់ទៅកាន់ទុគ្គតិភពឡើយ ។

ស្ថានទីអាក្រក់ក្នុងបច្ចុប្បន្ន បានដល់គុកច្រវាក់ជាដើម ភពខាងមុខបានដល់នរក ប្រេត អសុរកាយ តិរច្ឆាន ។

ព្រះធម្មវិន័យ ដែលព្រះសម្ពុទ្ធទ្រង់ត្រាស់សំដែង និងបញ្ញត្តទុក ព្រះសង្ឃលោកប្រតិបត្តិមិនឱ្យខុសផ្លូវធម្មវិន័យនោះ ហើយប្រៀនប្រដៅអ្នកដទៃឱ្យប្រតិបត្តិតាមដូច្នោះផង ។

## អាការៈដែលព្រះពុទ្ធទ្រង់ប្រដៅ ៣ យ៉ាង

**១-អភិញ្ញាយៈ** ទ្រង់ប្រដៅដើម្បីឱ្យអ្នកស្តាប់ដឹងពិតឃើញពិត ក្នុងធម៌ដែលគួរដឹងគួរឃើញ;

**២-សនិទានៈ** ទ្រង់ប្រដៅមានហេតុ កាលអ្នកស្តាប់ត្រិះរិះតាមរមែងឃើញពិតបាន;

**៣-សប្បាដិហារៈ** ទ្រង់ប្រដៅជាអស្ចារ្យ គឺកាលអ្នកស្តាប់ប្រតិបត្តិតាម រមែងសម្រេចប្រយោជន៍ តាមគួរដល់សេចក្តីប្រតិបត្តិ ។

បុ. ចូរអធិប្បាយអាការៈដែលព្រះពុទ្ធទ្រង់ប្រដៅ ៣ យ៉ាង នោះមកមើល ?

វិ. ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងបើកចំហ មិនមានបិទបាំង អាស្រ័យព្រះមហាករុណាទិគុណ ប្រព្រឹត្តទៅក្នុងពពួកសត្វទាំងឡាយ តាំងព្រះហឫទ័យប្រៀនប្រដៅសត្វមែនៗ ដើម្បីដឹងពិត ឃើញពិតក្នុងធម៌ដែលគួរដឹង គួរឃើញ គឺសុចរិតជាកិច្ចគួបំពេញ ទុច្ចរិតជាកិច្ចគួរលះបង់ ។

ព្រះអង្គទ្រង់ប្រៀនប្រដៅ មានហេតុផលល្មមគ្រប់គ្រាន់ដល់អ្នកស្តាប់ៗ ហើយពិចារណាត្រិះរិះតាម រមែងឃើញពិតដឹងពិតតាមធម៌ដែលខ្លួបពិចារណានោះៗ ។ អ្នកប្រព្រឹត្តតាមធម៌ដែលព្រះអង្គទ្រង់សំដែងនោះ រមែងទទួលប្រយោជន៍ដ៏សមគួរដល់សេចក្តីប្រតិបត្តិ តាំងអំពីជាន់ទាបរហូតដល់ជាន់ខ្ពស់ជាទីបំផុត គឺបានវិមុត្តិជាអកាលិកោ ជាធម៌ឱ្យផលមិនមានកំណត់ពេលវេលា ត្រូវទទួលផលក្នុងវេលាដែលខ្លួនបានប្រតិបត្តិនោះ ។

# ឱវាទរបស់ព្រះពុទ្ធ ៣ យ៉ាង

១-សព្វបាបស្ស អករណំ មិនឱ្យធ្វើបាបទាំងពួង គឺឱ្យវៀរចាកទុច្ចរិតប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត;

២-កុសលស្សូបសម្បទា ឱ្យញុំាងកុសលឱ្យដល់ព្រម គឺឱ្យប្រកបសុចរិតប្រព្រឹត្តល្អដោយកាយវាចាចិត្ត;

៣-សចិត្តបរិយោទបនំ ឱ្យជម្រះចិត្តរបស់ខ្លួនឱ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្ត មានលោភៈ ទោសៈ មោហៈជាដើម។

បុ. ឱវាទ ប្រែថា ដូចម្ដេច ?

វិ. ប្រែថា ពាក្យប្រៀនប្រដៅ ។

បុ. ឱវាទ និង សាសនៈ ដែលប្រែថាពាក្យប្រៀនប្រដៅដែរ តើមានសេចក្ដីផ្សេងគ្នាដូចម្ដេច ? ចូរអធិប្បាយ !

វិ. មានសេចក្ដីផ្សេងគ្នាយ៉ាងនេះគឺ ឱវាទបានខាងការប្រៀនប្រដៅចំពោះមុខ ដូចជាព្រះអង្គទ្រង់ឱ្យប្រជុំពួកភិក្ខុ ហើយព្រះអង្គទ្រង់សម្ដែងឱវាទប្បាតិមោក្ខជាដើម ហៅថាឱវាទៗ នេះបានតែព្រះអង្គសំដែងដោយព្រះអង្គឯងម៉្យាង មិនទូទៅដល់សាវ័កដទៃទៀយ ។ ចំណែកសាសនៈនោះ បាន

ដល់ការប្រៀនប្រដៅជាសាធារណៈទូទៅ បានដល់ពាក្យប្រៀនប្រដៅខាងក្រៅក៏ហៅថាសាសនៈដែរ ពុទ្ធោវាទក៏ហៅថាសាសនៈដែរ ពួកសាវ័កដទៃប្រៀនប្រដៅក៏ហៅថាសាសនៈបានដែរ ។ សេចក្ដីផ្សេងគ្នាដូចវិស្សជ្ជនាមកនេះ ។

បុ. ពាក្យដែលហាមមិនឱ្យធ្វើអំពើបាបនោះ ដូចម្ដេច? ចូរវាប់ !

វិ. អំពើបាបនោះ បានដល់អកុសលធម៌ទាំងអស់ គឺអកុសលកម្មបថ ១០, អកុសលមូល ៣, អកុសលចិត្ត ១២, អកុសលចេតសិក ១៤ ឈ្មោះថាបាប; អំពើបាបទាំងអស់នេះហើយ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាមមិនឱ្យធ្វើ ។

បុ. កុសលស្សូបសម្បទា ឱ្យញុំាងកុសលឱ្យដល់ព្រមនោះតើកុសលពួកណាខ្លះ ?

វិ. ពាក្យថា ឱ្យញុំាងកុសលឱ្យដល់ព្រមនោះដូច្នេះគឺកុសលកម្មបថ ១០, កាមាវចរកុសល ៨, រូបាវចរកុសល ៥, អរូបាវចរកុសល ៤, លោកុត្តរកុសល ៤, រហូតដល់ព្រះអរហត្ត ឈ្មោះថាឱ្យញុំាងកុសលឱ្យដល់ព្រម ។

បុ. សចិត្តបរិយោទបនំ ឱ្យជម្រះចិត្តរបស់ខ្លួនឱ្យផូរផង់នោះ តើដូចម្ដេច?

វិ. ត្រង់នេះ គឺជំរះចិត្តរបស់ខ្លួនឱ្យប្រាសចាកនីវរណធម៌ទាំង ៥ និងឧបក្កិលេសធម៌ ១៦ ឱ្យស្អាតពីខន្ធសន្ដាន ឈ្មោះថាញ៉ាំងចិត្តរបស់ខ្លួនឱ្យផូរផង់ ។

## ទុច្ចរិត ៣ យ៉ាង

១-កាយទុច្ចរិត ប្រព្រឹត្តអាក្រក់ដោយកាយ;

២-វចីទុច្ចរិត ប្រព្រឹត្តអាក្រក់ដោយវាចា;

៣-មនោទុច្ចរិត ប្រព្រឹត្តអាក្រក់ដោយចិត្ត ។

បុ. កាយទុច្ចរិត បានសេចក្ដីដូចម្ដេច? មានប៉ុន្មានយ៉ាង? ចូររាប់!

វិ. កាយទុច្ចរិត គឺ អំពើដែលប្រព្រឹត្តអាក្រក់ដោយកាយមាន ៣ យ៉ាងគឺ សម្លាប់សត្វ ១, លួចទ្រព្យគេ ១, ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ។

បុ. វចីទុច្ចរិត បានសេចក្ដីដូចម្ដេច? មានប៉ុន្មានយ៉ាង? ចូររាប់!

វិ. វចីទុច្ចរិត គឺអំពើដែលប្រព្រឹត្តអាក្រក់ដោយវាចា មាន ៤ យ៉ាង គឺនិយាយពាក្យកុហក ១, និយាយពាក្យញុះញង់ ១, និយាយពាក្យចាក់ដោតគេ ១, និយាយពាក្យរោយរាយឥតប្រយោជន៍ ១ ។

បុ. មនោទុច្ចរិត បានសេចក្ដីដូចម្ដេច? មានប៉ុន្មានយ៉ាង? ចូររាប់ !

វិ. មនោទុច្ចរិត គឺអំពើដែលប្រព្រឹត្តអាក្រក់ដោយចិត្ត មាន ៣ យ៉ាង គឺលោភៈ ចង់បានរបស់គេ ១, ព្យាបាទ, ប្រទូស្តគេ ១, មិច្ឆាទិដ្ឋិ ឃើញខុសចាកគន្លងធម៌ ១ ។

បុ. មិច្ឆាទិដ្ឋិ ដែលរាប់ចូលក្នុងអកុសលកម្មបថនេះ បានដល់មិច្ឆាទិដ្ឋិពួកណា?

វិ. មិច្ឆាទិដ្ឋិដែលរាប់ចូលក្នុងអកុសលកម្មបថនោះ បានដល់និយតមិច្ឆាទិដ្ឋិទាំង ៣ ។

បុ. និយតមិច្ឆាទិដ្ឋិទាំង ៣ នោះ តើអ្វីខ្លះ? ចូររាប់មកមើល

វិ. និយតមិច្ឆាទិដ្ឋិទាំង ៣ នោះគឺ អកិរិយទិដ្ឋិ សេចក្ដីឃើញថាអំពើដែលធ្វើនោះឥតអំពើ ១, អហេតុកទិដ្ឋិ សេចក្ដីឃើញថាឥតហេតុ ១, នត្ថិកទិដ្ឋិ សេចក្ដីឃើញថាគ្មាន ១ ។

មិច្ឆាទិដ្ឋិទាំង ៣ នេះ ទើបចាត់ចូលក្នុងអកុសលកម្មបថ ក្រៅអំពីនេះមិនចាត់បញ្ចូលផងទេ ។

ប. ទុច្ចរិត អកុសល និងបាបទាំង ៣ នេះ សេចក្ដីផ្សេងគ្នាដូចម្ដេច? ចូរអធិប្បាយ !

វិ. សេចក្ដីផ្សេងគ្នាដូច្នេះ ទុច្ចរិត បានដល់ការកំពុងប្រព្រឹត្តធ្វើនូវអំពើអាក្រក់ទាំងប៉ុន្មានដោយកាយវាចាចិត្ត ត្រង់ចិត្តដែលជាអកុសលកើតឡើងហើយនាំកាយវាចាចិត្ត ឱ្យប្រព្រឹត្តធ្វើនូវអំពើអាក្រក់ផ្សេងៗ នោះ ឈ្មោះថាអកុសល, អកុសលនេះច្រើនប្រើផ្លូវចិត្តដោយច្រើន ដូចអកុសលចិត្ត ១២ ជាដើម, ចំណែកទុច្ចរិត ការប្រព្រឹត្តគ្រប់ទ្វារទាំង ៣, ចំណែកអកុសលច្រើនប្រើតែមនោទ្វារ, ផលដែលកើតមកអំពីការប្រព្រឹត្តអាក្រក់នោះៗ ហៅថាបាប ឧបមាដូចមនុស្សល្ងង់ធ្វើការងារធម្មតាមនុស្សល្ងង់ធ្វើការពុំដែលបានល្អទេ ត្រង់ការងារដែលមិនល្អនោះ ជាផលកើតមកអំពីមនុស្សល្ងង់ អកុសលប្រែថា

មិនឆ្លាស់ ទុកដូចជាមនុស្សល្ងង់ ត្រង់ធ្វើការងារនោះៗ ទុកដូចជាទុច្ចរិត ការងារដែលមិនស្អាតដូចជាបាប មានសេចក្តីឧបមេយ្យដូច្នេះឯង ។

---

## សុចរិត ៣ យ៉ាង

១-កាយសុចរិត ប្រព្រឹត្តល្អដោយកាយ;

២-វចីសុចរិត ប្រព្រឹត្តល្អដោយវាចា;

៣-មនោសុចរិត ប្រព្រឹត្តល្អដោយចិត្ត ។

បុ. កាយសុចរិតនោះដូចម្តេច? មានប៉ុន្មានយ៉ាង? ចូររាប់!

វិ. កាយសុចរិតនោះ គឺអំពើដែលប្រព្រឹត្តល្អដោយកាយ មាន ៣ យ៉ាងគឺ វៀរចាកសម្លាប់សត្វ ១, វៀរចាកលួចទ្រព្យគេ ១, វៀរចាកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ។

បុ. វចីសុចរិតនោះតើដូចម្តេច? មានប៉ុន្មានយ៉ាង? ចូររាប់!

វិ. វចីសុចរិតនោះ គឺអំពើដែលប្រព្រឹត្តល្អដោយវាចា មាន ៤ យ៉ាងគឺ: វៀរចាកនិយាយពាក្យកុហកគេ ១, វៀរចាក

និយាយពាក្យញុះញង់គេ ១, វៀរចាកនិយាយពាក្យចាក់ដោតគេ ១, វៀរចាកនិយាយពាក្យរោយរាយឥតប្រយោជន៍ ១ ។

បុ. មនោសុចរិតនោះ តើដូចម្ដេច? មានប៉ុន្មានយ៉ាង? ចូររាប់!

វិ. មនោសុចរិតនោះគឺៈ អំពើដែលប្រព្រឹត្តល្អដោយចិត្ត មាន ៣ យ៉ាងគឺៈ មិនលោភចង់បានរបស់គេ ១, មិនព្យាបាទប្រទូស្តគេ ១, ឃើញត្រូវតាមគន្លងធម៌ ១ ។

---

## អកុសលមូល ៣ យ៉ាង

១-លោភៈ លោភចង់បានរបស់គេ;

២-ទោសៈ គិតប្រទូស្តគេ;

៣-មោហៈ វង្វេងមិនដឹងពិត ។

បុ. អកុសលមូលអធិប្បាយដូចម្ដេច ?

វិ. អកុសលមូល គឺឫសអកុសល គឺកុសលទាំងអស់ កើតមកអាស្រ័យអំពីឫសទាំង ៣ នេះ ប្រៀបឧបមាដូចដើមឈើ

ដែលមានផ្កាផ្លែមែកស្លឹកទៅបាន ក៏អាស្រ័យមកអំពីមានឫស ទាំង ៣ នេះដូច្នោះដែរ ។

បុ. អកុសលមូលទាំង ៣ នេះ ណាមានទោសធ្ងន់ជាង ណា?

វិ. អកុសលមូលទាំង ៣ នេះ លោភៈមានទោសស្រាល តែលះបានដោយកម្រ, ទោសៈ មានទោសធ្ងន់ តែលះបាន ដោយងាយ, មោហៈ មានទោសធ្ងន់ ហើយលះបានដោយ កម្រទៀត ។

## កុសលមូល ៣ យ៉ាង

**១-អលោភៈ** មិនលោភចង់បានរបស់គេ;

**២-អទោសៈ** មិនគិតប្រទូស្តរ៉ាយគេ;

**៣-អមោហៈ** មិនវង្វេង ។

បុ. ចូរអធិប្បាយកុសលមូលទាំង ៣ នេះមកមើល ?

វិ. មនុស្សដែលមានចិត្តជ្រះថ្លា រមែងចែករបស់ខ្លួនឱ្យអ្នក ដទៃតាមសមគួរ ឬក៏ជាអ្នកសន្តោសត្រេកអរចំពោះបច្ច័យ តាមបានតាមមាន ឈ្មោះថាជាអ្នកមិនមានសេចក្តីលោភ ។

អ្នកដែលមានមេត្តាចិត្ត គិតអាណិតអាសូរ មិនបៀតបៀនអ្នកដទៃឱ្យមានសេចក្ដីក្ដៅក្រហាយ ឈ្មោះថាជាអ្នកមិនមានទោសៈ ។ ភាពជាអ្នកមិនវង្វេងភ្លាំងភ្លាត់ស្មារតី ដឹងហេតុការណ៍ទាន់តាមធម្មតា រហូតដឹងដល់ធម៌ជាន់ខ្ពស់គឺអរិយសច្ច ៤ ប្រការ ឈ្មោះថាជាអ្នកមិនវង្វេង, ដែលពោលមកនេះ ជាបុគ្គលាធិដ្ឋាន ។ ចំណែកធម្មាធិដ្ឋាន គប្បីជ្រាបដោយសំដែងលើកធម៌ឡើងជាទីតាំង, បរិយាយរបស់លក្ខណៈធម៌ ដូចជាសេចក្ដីមិនលោភ មានលក្ខណៈត្រេកអរចំពោះវត្ថុជារបស់ខ្លួនដូច្នេះជាដើម ។ គុណគឺសេចក្ដីល្អដទៃៗ ដែលនឹងកើតឡើងក៏អាស្រ័យដោយធម៌ទាំង ៣ ប្រការនេះជាឫសគល់ ជាដើមចម, ហេតុនេះគួរណាស់តែអ្នកប្រព្រឹត្តធម៌ គប្បីអប់រំឱ្យកើតមានឡើងក្នុងខន្ធសន្ដានកុំខាន ។

## សប្បុរិសប្បញ្ញត្តិ ៣ យ៉ាង

**១-ទាន** ឱ្យវត្ថុរបស់ខ្លួនដើម្បីប្រយោជន៍អ្នកដទៃ;

**២-បព្វជ្ជា** កាន់ភេទបួសដើម្បីជាឧបាយវៀរចាកធម៌សម្រាប់គ្រហស្ថ;

**៣-មាតាបិតុបដ្ឋាន** ប្រតិបត្តិមាតាបិតាតាមគន្លងធម៌ ។

បុ. ចូរអធិប្បាយបញ្ញត្តិរបស់សប្បុរសទាំង ៣ យ៉ាងនោះមកមើល ?

វិ. សប្បុរស គឺមនុស្សល្អ មានសន្ដានចិត្តស្ងប់រម្ងាប់ចាកបាបអកុសល ពិចារណាឃើញធម៌ ៣ ប្រការនេះ ប្រព្រឹត្តទៅក្នុងផ្លូវដែលត្រូវ, គួរប្រកបឱ្យមានឡើង, ដើម្បីសេចក្ដីសុខសេចក្ដីចម្រើនដល់ខ្លួនក្នុងលោកនេះ និងលោកខាងមុខ ទើបព្រះអង្គទ្រង់បញ្ញត្តិទុក, មួយទៀតទុកជាការចងមេត្រចិត្តប្រព្រឹត្តទៅក្នុងផ្លូវមេត្តា ករុណា អនុគ្រោះដល់គ្នានឹងគ្នា ។ មួយវិញទៀត ជាឧបាយវៀរចាកអាឃាតព្យាបាទបៀតបៀនគ្នា ព្រោះអ្នកដែលកាន់ភេនបួសត្រូវតាមធម៌វិន័យជាគ្រឿងប្រព្រឹត្ត ។

មួយវិញទៀត ប្រតិបត្តិមាតាបិតារបស់ខ្លួនឱ្យជាសុខគុណបែបនេះ បុគ្គលណាបំពេញឱ្យមានជានិច្ចតាមឋានៈរបស់ខ្លួន បុគ្គលនោះឈ្មោះថា តកញ្ញូ កតវេទី ។

# អបណ្ណកប្បដិបទា ៣ យ៉ាង

**១-ឥន្ទ្រិយសំវរៈ** សង្រួមឥន្ទ្រីយ ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត មិនឱ្យមានសោមនស្សទោមនស្ស ក្នុង វេលាដែលឃើញរូប ឮសម្លេង ធុំក្លិន ស្រូបរស កាយពាល់ត្រូវ ដឹងធម្មារម្មណ៍ដោយចិត្ត;

**២-ភោជនេ មត្តញ្ញុតា** ស្គាល់ប្រមាណក្នុងការបរិភោគ អាហារតែល្មមសមគួរ មិនច្រើនមិនតិច;

**៣-ជាគរិយានុយោគៈ** ប្រកបសេចក្តីព្យាយាមដើម្បី ជម្រះចិត្តឱ្យបរិសុទ្ធហ្មត់ចត់ មិនឃើញដល់ការដេកច្រើន ។

បុ. អបណ្ណកប្បដិបទា ប្រែដូចម្តេច ?

វិ. អបណ្ណកប្បដិបទា ប្រែថា ការប្រតិបត្តិមិនខុស ។

បុ. ហេតុដូចម្តេចបានប្រតិបត្តិមិនខុស? ចូរអធិប្បាយ មកមើល!

វិ. ធម៌ទាំង ៣ ប្រការនេះ បានជាឈ្មោះថាការប្រតិបត្តិ មិនខុស ព្រោះអាចនឹងនាំអ្នកប្រព្រឹត្តឱ្យសម្រេចផល គឺសេចក្តី សុខនិងប្រយោជន៍ដទៃៗ តាមត្រូវការ តួយ៉ាងដូចជាបុគ្គល

សង្រួមឥន្ទ្រីយទាំង ៦ មិនមានទោមនស្សសោមនស្ស ចំពោះអារម្មណ៍នោះៗ រមែងឱ្យកើតសេចក្ដីសុខ មិនសោកសៅក្នុងការជួបប្រទះអារម្មណ៍ ដែលមិនជាទីពេញចិត្ត ឬអារម្មណ៍ជាទីពេញចិត្ត ហើយវិបត្តិទៅដោយការណានីមួយ ។

ការដឹងប្រមាណក្នុងអាហារ ក៏រាប់ថាជាគុណប្រយោជន៍យ៉ាងសំខាន់ ព្រោះអ្នកប្រតិបត្តិធម៌ក្នុងព្រះពុទ្ធសាសនា ឬក៏ប្រកបការងារក្នុងផ្លូវលោកក៏ដោយ ការដឹងប្រមាណក្នុងអាហារ ទើបប្រកបការងារនោះៗ ទៅបានដោយពេញទី ព្រោះថាបើបរិភោគហួសប្រមាណ ក៏នឹងធ្វើឱ្យតប់ប្រមល់ចាក់ច្រាស់ខ្ជិលច្រអូស បើបរិភោគតិចពេកក៏នឹងធ្វើឱ្យល្ងឹងល្ងើយស្រេកឃ្លាន ចិត្តក៏រវើរវាយ, ការដឹងប្រមាណក្នុងអាហារដ៏ល្មមល្អទើបមានប្រយោជន៍ដូចបានពោលមកហើយ ។

អ្នកដែលបំពេញសេចក្តីព្យាយាម មិនគួរដេកច្រើនទេ, ព្រោះការដេកច្រើនជាសត្រូវដល់សេចក្តីព្យាយាម លោកពោលថា គួរឱ្យមានសតិភ្ញាក់រលឹកជានិច្ច, ដូចសេះដែលនាយសារថីវាយដោយរំពាត់ដូច្នោះ; កាលបើមិនឃើញដល់ការដេកច្រើនហើយ ក៏តាំងចិត្តប្រកបដោយសេចក្តីព្យាយាម អាច

ជម្រះចិត្តឱ្យផូរផង់ចាកកិលេសជាគ្រឿងសៅហ្មង តាមសេចក្តីប្រាថ្នារបស់ខ្លួន ។

## បុញ្ញកិរិយាវត្ថុ ៣ យ៉ាង

**១-ទានមយៈ** បុណ្យសម្រេចដោយការបរិច្ចាគទាន;

**២-សីលមយៈ** បុណ្យសម្រេចដោយការរក្សាសីល;

**៣-ភាវនាមយៈ** បុណ្យសម្រេចដោយការចម្រើនភាវនា ។

បុ. បុញ្ញកិរិយាវត្ថុ ប្រែដូចម្តេច ?

វិ.បុញ្ញកិរិយាវត្ថុ ប្រែថា វត្ថុជាទីតាំងនៃការបំពេញបុណ្យ។

បុ. ចូរអធិប្បាយបុញ្ញកិរិយាវត្ថុទាំង ៣ នេះមកមើល ?

វិ. ការបរិច្ចាគទាន រក្សាសីល និងការចម្រើនភាវនា ហៅថាការបំពេញបុណ្យ ។

ពាក្យថា ‹‹បុណ្យ›› បានដល់ធម្មជាតិដែលជម្រះចិត្តឱ្យហ្មត់ចត់បរិសុទ្ធ ដូចជាអ្នកដែលបំពេញទាន រមែងមានសេចក្តីរីករាយ ថាខ្លួនបានធ្វើកិច្ចដ៏ប្រពៃ, អ្នករក្សាសីល រមែងមានសេចក្តីត្រជាក់ចិត្ត មិនមានវិប្បដិសារីក្តៅក្រហាយ ព្រោះកាយវាចា រមែងមានរបៀបរៀបរយល្អ មិនមានទោស អ្នកដែល

ចម្រើនភាវនា រមែងពិចារណាឃើញសេចក្តីពិត ព្រមទាំងបាន ទទួលសេចក្តីសុខដ៏សុខុម ។

មួយទៀត ពាក្យថា ‹‹បុណ្យ›› នេះ បានទាំងហេតុទាំង ផល គឺអលោភៈ អទោសៈ អមោហៈ ហៅថាបុណ្យជាហេតុ, សេចក្តិល្អ ដែលកើតអំពីសេចក្តីមិនលោភ មិនក្រោធ មិនវង្វេង ហៅថា បុណ្យជាផល ។

ន័យមួយទៀត ពាក្យថា ‹‹បុណ្យ›› នេះជាឈ្មោះនៃ សេចក្តីសុខ សេចក្តីរីករាយសប្បាយចិត្តក្តី, សេចក្តីត្រជាក់ចិត្ត ក្តី, ជាពាក្យវេវចនៈ ផ្លាស់ប្តូរគ្នានឹងសេចក្តីសុខដែលកើតអំពី ការធ្វើនូវអំពើដែលប្រាសចាកទោសគ្រប់យ៉ាង រួមឱ្យខ្លីមក ហៅថាបុណ្យ ។

បុ. ទាន សីល ភាវនា ទៅបរលោកខាងមុខឱ្យសម្រេច ប្រយោជន៍យ៉ាងណាខ្លះ ?

វិ. ទានទៅជាតិមុខឱ្យសម្រេចបានភោគសម្ប័ទ និង បរិវារសម្ប័ទ, សីលឱ្យសម្រេចបានរូបល្អនិងអាយុវែង, ភាវនា ឱ្យមានប្រាជ្ញា សេចក្តីផ្សេងគ្នាដូច្នេះ ។

បុ. ទានសីលឱ្យសម្រេចភោគសម្ប័ទនិងរូបសម្ប័ទ ល្មមឃើញបាន ដូចជាទៅលើត្រកូលអ្នកមានទ្រព្យសម្បត្តិស្រាប់ គួរថាអានិសង្សទាន, រូបសម្ប័ទកើតឡើងមានរូបល្អស្រាប់ គួរថាអានិសង្សសីល អានិសង្សទានសីល គួរឱ្យឃើញបានមែនៗ, ចុះដូចអានិសង្សភាវនា ថាកើតឡើងជាតិណាៗ មានប្រាជ្ញា ដល់កើតឡើងមិនឃើញមានប្រាជ្ញា បើថាភាវនាឱ្យមានប្រាជ្ញា ចាំរៀនសូត្រធ្វើអ្វីទៀត បើប្រាជ្ញាមានស្រាប់ហើយ ?

វិ. ប្រាជ្ញាមានមែន អានិសង្សទាំង ៣ នេះខុសគ្នា គឺអានិសង្សទានសីល ជារូបធម៌សម្រាប់ឃើញដោយមំសចក្ខុ, ចំណែកអានិសង្សភាវនា ជាអរូបធម៌ សម្រាប់ឃើញដោយញាណចក្ខុ ឯប្រាជ្ញានេះបានជាត្រូវរៀនសូត្រទៀតនោះ ប្រៀបឧបមាដូចកាំបិតមុតយកទៅកប់ទុកក្នុងជ្រាំ ដល់រើសយកមកត្រូវតែសំលៀងសិន ទើបអាចយកទៅកាប់ឈើព្រៃបាន ដូចជាទារកដែលកើតក្នុងផ្ទៃនៃមាតាចំនួន ១០ ខែ ប្រាជ្ញានោះ ក៏អប្បរស្មីបាត់អស់ទៅ លុះប្រសូតចេញមកធំឡើង ត្រូវតែទៅ

ស្វែងរករៀនទៀត ទើបប្រាជ្ញានោះមានឡើងវិញដដែល ក៏មានឧបមេយ្យដូច្នោះដែរ ។

បុ. ទាន សីល ភាវនា ណាមានកម្លាំងជាងណា ?

វិ. ទាននិងសីល មានកម្លាំងខ្សោយជាងភាវនា អាចឱ្យសម្រេចបានតែមគ្គ ៣ ជាន់ក្រោម, ចំណែកភាវនា អាចឱ្យសម្រេចបានមគ្គ ១ ខាងលើ គឺអរហត្តមគ្គ ។

បុ. គ្រាន់តែធ្វើទាន រក្សាសីល ឬមានភាវនាដែរ ដែលឱ្យសម្រេចមគ្គ ៣ ខាងក្រោមនោះ, ចំណែកភាវនានោះ គ្រាន់តែចំរើនភាវនាមួយប៉ុណ្ណោះឬ ដែលអាចឱ្យសម្រេចមគ្គ ១ ខាងលើបាន ឬក៏មានធ្វើទានរក្សាសីលដែរ ?

វិ. ដែលឱ្យសម្រេចមគ្គ ៣ ខាងក្រោមនោះ ដោយកម្លាំងទានសីលច្រើនជាងភាវនាដែរ ប៉ុន្តែតិចតួចស្តួចស្តើង នេះបានច្រើនប៉ែកខាងគ្រហស្ថ ដូចអនាថបិណ្ឌិកសេដ្ឋីនិងនាងវិសាខាជាដើម នេះឱ្យសម្រេចមគ្គ ១ ខាងក្រោម គឺសោតាបត្តិមគ្គ ជាមគ្គទី ១, មគ្គទី ៣ ដូចធម្មិកឧបាសក ដែលបានសម្រេចអនាគាមិមគ្គ ចំណែកភាវនាក៏គង់មានទានសីលដែរ តែដល់ភាវនានេះឆ្លងផុតទានសីលទៅហើយ កម្លាំងភាវនានេះនាំឱ្យ

សម្រេចអរហត្តមគ្គ បានខាងប៉ែកបព្វជិតដោយច្រើន ចំណែកខាងគ្រហស្ថមានដែរ តែតិចតួចស្តួចស្តើងណាស់ ក្នុងព្រះពុទ្ធ-សាសនាសមណៈគោតមយើងនេះ ឃើញមានតែ ៣ រូបគឺ ព្រះបាទសុទ្ធោទនៈជាពុទ្ធបិតា ១, សន្តតិមហាមត្ត ១, ពាហិយៈ ១ នេះឃើញបានសម្រេចអរហត្តខាងគ្រហស្ថ តែមិនតាំងនៅអស់មួយជីវិតទេ ។

បុ. ហេតុអ្វីបានជាគ្រហស្ថ បានសម្រេចអរហត្តហើយមិនតាំងនៅអស់មួយជីវិត ?

វិ. គ្រហស្ថបានសម្រេចអរហត្តហើយ មិនតាំងនៅអស់មួយជីវិតនោះ ព្រោះខ្លួនជាហិនភេទ ភេទថោកទាប នៅបានយ៉ាងយូរត្រឹម ៧ ថ្ងៃ លុះតែចេញបព្វជ្ជា ទើបតាំងនៅអស់មួយជីវិតបាន ។

## សាមញ្ញលក្ខណៈ ៣ យ៉ាង

**១-អនិច្ចតា** សភាពជារបស់មិនទៀង;

**២-ទុក្ខតា** សភាពជាទុក្ខ;

**៣-អនត្តតា** សភាពមិនមែនជារបស់ខ្លួន ។

បុ. សាមញ្ញលក្ខណៈទាំង ៣ យ៉ាងនេះ មានសេចក្ដីអធិប្បាយដូចម្ដេច?

វិ. ឧបាទិន្នកសង្ខារ គឺសង្ខារដែលមានវិញ្ញាណគ្រប់គ្រងដូចជាមនុស្សនិងសត្វតិរច្ឆានជាដើម, សូម្បីមានពណ៌សម្បុរខ្មៅ ស វែង ខ្លី ខ្ពស់ ទាបផ្សេងគ្នាយ៉ាងណាក៏ដោយចុះ រមែងធ្លាក់ទៅក្នុងអំណាចលក្ខណៈទាំង ៣ យ៉ាងគឺ មិនទៀង ជាទុក្ខ ជាអនត្តា ស្មើគ្នាទាំងអស់ ។

អនុបាទិន្នកសង្ខារ គឺសង្ខារដែលមិនមានវិញ្ញាណគ្រប់គ្រង គឺជារបស់ដែលមនុស្សតាក់តែងឡើង ដូចជាកុដិ វិហារ សាលាជាដើម រមែងធ្លាក់ទៅក្នុងអំណាចនៃលក្ខណៈ ៣ យ៉ាងដូចគ្នា សាមញ្ញលក្ខណៈ ប្រែថាលក្ខណៈស្មើគ្នា; ត្រៃលក្ខណៈ ប្រែថា លក្ខណៈ ៣ រួមសេចក្ដីទៅថា សង្ខារទាំងអម្បាលនេះ មានលក្ខណៈស្មើគ្នាទាំង ៣ គឺ មិនទៀង ជាទុក្ខ ជាអនត្តា ដូចគ្នាទាំងអស់ ។

<u>ចប់តិកៈពួក ៣</u>

# ចតុក្កៈ ពួក ៤

## វុឌ្ឍិធម៌ ៤ យ៉ាង

**១-សប្បុរិសូបសំសេវៈ** សេពគប់សប្បុរស គឺលោកប្រព្រឹត្តល្អដោយកាយវាចាចិត្ត;

**២-សទ្ធម្មស្សវនៈ** ស្តាប់ពាក្យប្រៀនប្រដៅរបស់លោកដោយគោរព;

**៣-យោនិសោមនសិការៈ** ត្រិះរិះឱ្យស្គាល់របស់អាក្រក់ដោយឧបាយដែលត្រូវ;

**៤-ធម្មានុធម្មប្បដិបត្តិ** ប្រព្រឹត្តធម៌សមគួរដល់ធម៌ ដែលបានត្រិះរិះឃើញហើយ ។

បុ. វុឌ្ឍិធម៌ ប្រែថាដូចម្តេច ?

វិ. ប្រែថា ធម៌ជាគ្រឿងចម្រើន ។

បុ. ចូរអធិប្បាយវុឌ្ឍិធម៌ទាំង ៤ នោះមកមើល តើចំរើនដូចម្តេច ?

វិ. ការសេពគប់សមាគមនឹងសប្បុរស គឺលោកអ្នកប្រព្រឹត្តល្អដោយកាយវាចាចិត្តនោះ ជាហេតុឱ្យបានស្តាប់ពាក្យប្រៀន

ប្រដៅរបស់លោក, ការបានឮបានស្ដាប់ជាហេតុឱ្យសេចក្ដីគិត ឬជាហេតុឱ្យមានគំនិត, កាលបើដឹងខុសត្រូវហើយ ជាហេតុឱ្យប្រព្រឹត្តធម៌ដ៏សមគួរដល់ធម៌ គេចវេះចៀសវាងអំពីផ្លូវអាក្រក់ខិលខូច ជាឧបាយបណ្ដុះបណ្ដាលសេចក្ដីចំរើនដល់ខ្លួនទាំងអស់ ដូច្នេះធម៌ទាំង ៤ ប្រការនេះ ទាក់ទងអាស្រ័យគ្នាដោយហេតុនឹងផល គួរសាធុជនប្រកបឱ្យមានបរិបូណ៌ឡើង រមែងបានសេចក្ដីចម្រើនតាមសមគួរដល់ការប្រតិបត្តិ, ការសេពសមាគមចាត់ជាការសំខាន់មួយ ជាហេតុខាងដើមគួរជ្រើសរើសគប់នឹងលោកជាសប្បុរស ដូចបានពោលមកហើយ ព្រោះការសេពគប់សម្ពគ្នា អាចជ្រួតជ្រាបនិស្ស័យចិត្តថ្លើម រហូតដល់សេចក្ដីប្រព្រឹត្តឱ្យដូចគ្នាបាន ។

## ចក្កធម៌ ៤ យ៉ាង

**១-បដិរូបទេសវាសៈ** នៅក្នុងប្រទេសដ៏សមគួរ;

**២-សប្បុរិសូបសំសេវៈ** សេពគប់សប្បុរស;

**៣-អត្តសម្មាបណិធិ** តាំងខ្លួនដោយប្រពៃ;

**៤-បុព្វេកតបុញ្ញតា** ជាអ្នកបានធ្វើបុណ្យទុកមកពីក្នុងកាលមុន ។

បុ. ចក្កធម៌ ប្រែដូចម្ដេច ?

វិ. ប្រែថា ធម៌វិលទៅដូចជាកង់ចក្រ ។

បុ. ចូរអធិប្បាយចក្កធម៌ទាំង ៤ យ៉ាងនោះមកមើល ?

វិ. ទីឋានដ៏សមគួរ ដល់ការប្រកបកិច្ចធុរៈរបស់ខ្លួនក្ដី ស្រួសសប្បាយដល់ការនៅក្ដី ឈ្មោះថាប្រទេសដ៏សមគួរ តែក្នុងទីនេះសំដៅយកប្រទេសដែលមានសប្បុរស, លោកអ្នកដែលមានសេចក្ដីចេះដឹង និងមានសមត្ថភាពឆ្លៀវឆ្លាសសិល្បសាស្ត្រផ្សេងៗ ដឹកនាំប្រៀនប្រដៅប្រជាជន ឱ្យសេចក្ដីអាក្រក់ប្រព្រឹត្តសេចក្ដីល្អ ឱ្យមានសន្ដានស្ងប់រម្ងាប់ចាកបាបធម៌ ឱ្យបំពេញឬតាំងខ្លួននៅក្នុងសុចរិតធម៌ ឈ្មោះថា សប្បុរស, ការនៅក្នុងប្រទេសដែលមានលោកសប្បុរសដូច្នេះ ចាត់ថាជាមង្គលនាំឱ្យកើតសេចក្ដីសុខចំរើនគ្រប់យ៉ាង ព្រោះជាហេតុឱ្យបានសមាគមសេពគប់ជាមួយនឹងសប្បុរស ការសេពគប់រាប់រកនូវបុគ្គលដូច្នេះ រមែងជឿស្ដាប់ពាក្យប្រៀនប្រដៅរបស់លោក; ការតម្កល់ខ្លួនទុកឱ្យល្អក្នុងផ្លូវត្រូវ ប្រកបដោយ

សុចរិតធម៌ និងការគ្រប់គ្រងរក្សាចិត្តរបស់ខ្លួន រមែងបានសេចក្ដីសុខចម្រើនគ្រប់យ៉ាង; ការបំពេញកុសលសុចរិតទុកក្នុងភពដែលកន្លងទៅហើយ ឈ្មោះថាភាពជាអ្នកបានធ្វើបុណ្យទុកក្នុងកាលមុន ។

ធម៌ ៤ ប្រការនេះ កាលបើមានគ្រប់គ្រាន់បរិបូណ៌នៅក្នុងខន្ធសន្ដានបុគ្គលណាមួយហើយ រមែងធ្វើបុគ្គលនោះឱ្យបានដល់នូវសេចក្ដីចម្រើនតាមវត្ថុបំណង ដូចរថដែលនាំទៅកាន់ទីដែលត្រូវទៅបានដូច្នោះឯង ។

បុ. ធម៌ទាំង ៤ យ៉ាងនេះ បើខ្វះណានីមួយហៅថាចក្កធម៌បានឬទេ ?

វិ. ធម៌ទាំង ៤ នេះ បើខ្វះណានីមួយមិនហៅថាចក្កធម៌ទេ ឧបមាដូចជាកង់រថយន្ត បើខ្វះណាមួយ ប្រើការមិនកើតដូច្នោះ ។

## អគតិ ៤ យ៉ាង

**១-ឆន្ទាគតិ** លំអៀងព្រោះស្រឡាញ់;

**២-ទោសាគតិ** លំអៀងព្រោះស្អប់;

**៣-មោហាគតិ** លំអៀងព្រោះល្ងង់;

**៤-ភយាគតិ** លំអៀងព្រោះខ្លាច ។

បុ. ចូរអធិប្បាយធម៌ទាំង ៤ យ៉ាងនោះមកមើល ?

វិ. ការប្រព្រឹត្តឱ្យល្អៀងឃ្លៀងឃ្លាតពីធម៌ គឺប្រព្រឹត្តមិនត្រង់តាមសេចក្តីពិត ហៅថា អគតិ តាមអដ្ឋកថានៃធម្មបទលោកពណ៌នាទុកជាតួយ៉ាងដូច្នេះថា អ្នកវិនិច្ឆ័យនូវក្តី គឺកាត់ក្តីបើតាំងនៅក្នុងឆន្ទាគតិ អាស្រ័យសេចក្តីស្រឡាញ់ហើយរមែងនិយាយខុសច្បាប់មិនខាន តែងវិនិច្ឆ័យឱ្យញាតិឬមិត្ររបស់ខ្លួនដែលមានសេចក្តីខុសឆ្គង ដែលគួរឱ្យចាញ់ត្រឡប់ទៅជាឈ្នះវិញបាន ។ បើតាំងនៅក្នុងទោសាគតិ អាស្រ័យសេចក្តីស្អប់ រមែងវិនិច្ឆ័យឱ្យមនុស្សដែលមានពៀរនឹងខ្លួនដែលជាមនុស្សមានសេចក្តីខុស ដែលគួរឱ្យចាញ់ត្រឡប់ទៅជាឈ្នះវិញបាន ។ បើតាំងនៅក្នុងមោហាគតិ ធ្វើជាឡិបឡុបនាយអាយនិយាយបង្កាច់ថាមនុស្សនេះឈ្នះ, មនុស្សនេះចាញ់ ។ បើតាំងនៅក្នុងភយាគតិ អាស្រ័យសេចក្តីខ្លាច រមែងវិនិច្ឆ័យឱ្យមនុស្សដែលមានយសស័ក្តិ ដែលមានសេចក្តីខុសគួរឱ្យចាញ់ត្រឡប់ទៅជាឈ្នះវិញបាន ការប្រព្រឹត្តដូច្នេះ ហៅថា ប្រព្រឹត្តលំអៀងធម៌ ។

ចំណែកអ្នកដែលវៀរចាកធម៌ ៤ ប្រការ ដូចបានពោលមកហើយនេះ តែងកាត់សេចក្ដីដ៏សមគួរដល់កំហុស រក្សាធម៌ជាធំបរិបូណ៌ដោយបញ្ញា ដំកល់នៅក្នុងធម៌ ឈ្មោះថា ប្រព្រឹត្តយុត្តិធម៌ ។

បុ. អគតិធម៌ ៤ យ៉ាងនេះ មានគ្រប់រូបមនុស្សទូទៅ ឬក៏មិនមានគ្រប់ទេ ?

វិ. អគតិធម៌ទាំង ៤ យ៉ាងនេះ មិនមានគ្រប់រូបមនុស្សទេ ច្រើនតែមានចំពោះអ្នកធំៗ ជាងគេ អ្នកតូចមិនសូវមានទេ ។

## អន្តរាយរបស់ភិក្ខុសាមណេរបួសថ្មី ៤ យ៉ាង

១-អត់ធន់ចំពោះពាក្យទូន្មានមិនបាន ខ្ជិលធ្វើតាម;

២-ជាមនុស្សឃើញតែការបរិភោគជាប្រមាណ អត់ធន់សេចក្ដីស្រេកឃ្លានមិនបាន;

៣-ត្រេកអរក្នុងកាមគុណ ចង់បានសេចក្ដីសុខលើសលប់ឡើងទៅ;

៤-ស្រឡាញ់ស្ត្រីភាព ។

បុ. អន្តរាយរបស់ភិក្ខុសាមណេរបួសថ្មី ៤ យ៉ាងនោះ មានសេចក្ដីអធិប្បាយដូចម្ដេច ?

វិ. ធម្មតាបុថុជ្ជន ដែលមានកិលេសត្រាំនៅក្នុងខន្ធសន្ដានតែងមានសេចក្ដីប្រព្រឹត្តិខុសផ្លូវជានិច្ច ត្រូវអាស្រ័យការអប់រំហើយហាមប្រាមសេចក្ដីអាក្រក់ជានិច្ច ទើបប្រព្រឹត្តឱ្យត្រូវតាមគន្លងធម៌បាន ។

បើភិក្ខុសាមណេរដែលបួសថ្មី ជាទំនាស់ដល់កិច្ចដែលត្រូវអត់ធន់ ចំពោះពាក្យប្រៀនប្រដៅដោយពិត ព្រោះឃើញដល់សេចក្ដីលំបាក មិនមានសេចក្ដីព្យាយាម ខ្ជិលច្រអូស, បើគ្មានសេចក្ដីព្យាយាមទេ នឹងតាំងនៅក្នុងភេទជាព្រហ្មចារិយមិនបាន មិនមានសេចក្ដីចម្រើនដល់ព្រះពុទ្ធសាសនា ទីបំផុតត្រូវលាសិក្ខាបទ វិលត្រឡប់មកកាន់ហីនភេទវិញ ទើបឈ្មោះថាអន្តរាយ ។

អ្នកបួសត្រូវដេកក្នុងវេលាដែលគួរដេក បរិភោគឬឆាន់នូវអាហារតាមកំណត់ ដែលព្រះអង្គទ្រង់បញ្ញត្តទុក មិនត្រូវធ្វើសេចក្ដីក្រវល់ក្រវាយរនះរនាតក្នុងការបរិភោគហួសហេតុ អត់ទ្រាំសេចក្ដីស្រេកឃ្លានមិនបាន មិនត្រូវធ្វើការខ្វល់ខ្វាយឱ្យ

ទាល់តែដល់ថ្នាក់ប្រព្រឹត្តអនាចារ ខុសចាកច្បាប់ព្រះវិន័យឡើយ ។

អ្នកបួសកាលបើមិនធ្វើចិត្តឱ្យភ្លើតភ្លើនក្នុងកាមគុណ គឺរូប, សម្លេង, រស, សម្ផស្ស, មានសេចក្ដីប្រាថ្នាចង់បានសេចក្ដីសុខលើសលប់ឡើងទៅ ព្រមទាំងមិនស្រឡាញ់ស្រី បើប្រតិបត្តិបានដូច្នេះ ក៏នឹងមានសេចក្ដីចម្រើនលូតលាស់ដុះ-ដាលក្នុងព្រះពុទ្ធសាសនាទៅបាន ព្រហ្មចរិយធម៌ក៏នឹងស្ថិតនៅបានយូរអង្វែង ជាការប្រតិបត្តិត្រូវតាមព្រះពុទ្ធបំណងត្រឡប់ទៅជាប្រព្រឹត្តផ្ទុយគ្នាទៅវិញ ក៏នឹងក្លាយទៅជាអន្តរាយតែម៉្យាង ។

ហេតុនេះ ភិក្ខុសាមណេរដែលបួសថ្មី ត្រូវប្រុងប្រយ័ត្នកុំឱ្យអន្តរាយទាំង ៤ យ៉ាងនេះ ចូលមកញាំញីគ្រប់សង្កត់បាន, ក្នុងទីនេះលោកមិនបានពោលដល់ភិក្ខុសាមណេរដែលបួសចាស់ទេ ព្រោះភិក្ខុសាមណេរដែលបួសចាស់ៗ លោកធ្លាប់ប្រុងប្រយ័ត្នតាំងពីខ្លួនលោកនៅជាភិក្ខុសាមណេរថ្មីម្ល៉េះ ។

# បធានៈ ៤ យ៉ាង

១-សំវរប្បធានៈ ព្យាយាមប្រយ័ត្នមិនឱ្យបាបកើតឡើងក្នុងសន្ដាន;

២-បហានប្បធានៈ ព្យាយាមលះបាបដែលកើតឡើងហើយ;

៣-ភាវនាបធានៈ ព្យាយាមញ៉ាំងកុសលឱ្យកើតឡើងក្នុងសន្ដាន;

៤-អនុរក្ខនាបធានៈ ព្យាយាមរក្សាកុសលដែលកើតឡើងហើយ មិនឱ្យសាបសូន្យទៅវិញ ។

បុ. បធានៈ ប្រែដូចម្ដេច ?

វិ. បធានៈ ប្រែថា សេចក្ដីព្យាយាម ។

បុ. បធានៈ ប្រែថា សេចក្ដីព្យាយម វីរិយៈ ប្រែថា សេចក្ដីព្យាយាមដែរ ជាគរិយានុយោគៈ ប្រែថា សេចក្ដីព្យាយាមដែរ ឧដ្ឋានៈ ក៏ប្រែថា សេចក្ដីព្យាយាមដែរ តើព្យាយាមទាំង ៤ នេះមានសេចក្ដីផ្សេងគ្នាដូចម្ដេច ? ចូរអធិប្បាយ!

វិ. ព្យាយាមទាំង ៤ នេះ ផ្សេងគ្នាដូច្នេះ ចំណែកបធានៈ សេចក្តីព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត បានខាងភាវនា, វីរិយៈ សេចក្តីព្យាយាមផ្លូវកាយវាចា, ជាគរិយានុយោគៈ សេចក្តីព្យាយាមមិនដេកលក់ គឺភ្ញាក់រលឹករឿយៗ, ឧដ្ឋានៈ សេចក្តីព្យាយាមក្រោកឡើងចាត់ចែងការងារជាបច្ចុប្បន្ន សេចក្តីផ្សេងគ្នាដូចវិស្សជ្ជនាមកនេះ ។

បុ. ចូរអធិប្បាយបធានៈទាំង ៤ នោះឱ្យពិស្តារមកមើល?

វិ. សេចក្តីព្យាយាមក្នុងទីនេះ បំណងយកសេចក្តីព្យាយាមប្រព្រឹត្តទៅក្នុងផ្លូវចិត្ត ការដែលមិនភ្លេចខ្លួន មានស្មារតីប្រុងប្រយ័ត្នគ្រប់ខណៈ មិនឱ្យឱកាសដល់សេចក្តីអាក្រក់ ឬមិនបណ្តោយឱ្យសេចក្តីអាក្រក់កើតឡើង មានសេចក្តីព្យាយាមចាស់ក្លា មិនគិតដល់សេចក្តីលំបាកដោយហេតុណាមួយយ៉ាងនេះ ហៅថា សំវរប្បធានៈ ។

បើមានសេចក្តីភ្លាំងភ្លាត់ក្នុងពេលខ្លះម្តងមួយកាល ព្រោះខ្លួនមានសតិមិនបរិបូណ៌ សេចក្តីអាក្រក់បានឱកាសកើតឡើងក្នុងខន្ធសន្តានបាន ហើយក៏មិនព្រងើយកន្តើយបណ្តោយឱ្យសេចក្តីអាក្រក់នោះ កើតឡើងហួសកាលនោះទេ តាំងសេចក្តី

ព្យាយាមដើម្បីកំចាត់បង់នូវអកុសល ដែលកើតឡើងនោះ ឱ្យឃ្លាតឆ្ងាយពីខន្ធសន្តាន យ៉ាងនេះហៅថា មហានប្បធានៈ ។

ការព្យាយាមអប់រំបំពេញកុសល គឺសេចក្តីល្អដទៃៗ ឱ្យមានច្រើនក្នុងខន្ធសន្តានដោយឧបាយផ្សេងៗ ស្រេចហើយតែកុសលកើតឡើងមានដោយឧបាយយ៉ាងណា ក៏ខំប្រឹងព្យាយាមដោយឧបាយយ៉ាងនោះ យ៉ាងនេះហៅថា ភាវនាបធានៈ ។

ការព្យាយាមរក្សាកុសល ដែលខ្លួនអប់រំឱ្យកើតក្នុងខន្ធ-សន្តានហើយ ក៏ខំព្យាយាមមិនឱ្យសាបសូន្យទៅវិញ យ៉ាងនេះហៅថា អនុរក្ខនាបធានៈ ។

សេចក្តីព្យាយាមទាំង ៤ យ៉ាងនេះ កាលបើបុគ្គលបានបំពេញឱ្យបរិបូណ៌ក្នុងខន្ធសន្តានហើយ រមែងបានសេចក្តីសុខកាយសប្បាយចិត្ត រុងរឿងក្នុងព្រះពុទ្ធសាសនា អស់កាលជាអង្វែងមិនខាន ។

# អធិដ្ឋានធម៌ ៤ យ៉ាង

**១-បញ្ញា** ដឹងរបស់ដែលគួរដឹង;

**២-សច្ចៈ** សេចក្ដីពិតក្នុងចិត្ត គឺតាំងចិត្តនឹងធ្វើអ្វី ក៏ធ្វើពិត;

**៣-ចាគៈ** លះរបស់ដែលជាសត្រូវដល់សេចក្ដីពិតក្នុងចិត្ត;

**៤-ឧបសមៈ** ស្ងប់ចិត្តចាករបស់ដែលជាសត្រូវចំពោះសេចក្ដីស្ងប់ ។

បុ. អធិដ្ឋាន ប្រែដូចម្ដេច ?

វិ. អធិដ្ឋាន ប្រែថា ធម៌ដែលគួរតាំងទុកក្នុងចិត្ត ។

បុ. ក្នុងពួកធម៌ដទៃៗ ច្រើនដាក់បញ្ញានៅខាងចុងជាដរាប ហេតុអ្វីក៏ក្នុងអធិដ្ឋានធម៌នេះ ដាក់បញ្ញានៅខាងដើមវិញ ?

វិ. ក្នុងអធិដ្ឋានធម៌នេះ បានជាដាក់បញ្ញានៅខាងដើម ព្រោះបញ្ញានេះចាក់ធ្លុះនូវអរិយសច្ចទាំង ៤ ប្រការ ដូចសម្មា-ទិដ្ឋិក្នុងអដ្ឋង្គិកមគ្គនេះ បញ្ញារមែងចាក់ធ្លុះនូវអរិយសច្ចទាំង ៤ បានជានៅខាងដើម ចំណែកបញ្ញាជាលោកិយតែនៅខាងចុង ជាដរាប ។

បុ. ចូរអធិប្បាយអធិដ្ឋានទាំង ៤ នោះមកមើល ?

វិ. សេចក្តីដឹងរបស់ដែលគួរដឹងនោះ មានសេចក្តីថា សិល្បវិជ្ជាណា ដែលប្រាសចាកទោសគ្រប់យ៉ាង ព្រមទាំងបណ្តាលឱ្យកើតប្រយោជន៍ដល់អ្នកដឹង ហើយប្រតិបត្តិតាមសិល្បសាស្ត្រវិជ្ជានោះ រមែងដឹងក្នុងបញ្ចក្ខន្ធគឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ រហូតដល់ការដឹងអរិយសច្ច ៤ បានដ៏សមគួរដល់បញ្ញា ។ ឯបញ្ញាមានពីរយ៉ាងគឺ លោកិយបញ្ញា ដឹងក្នុងបរស់ដែលជាវិស័យរបស់លោក ១, លោកុត្តរបញ្ញា ដឹងក្នុងរបស់ដែលផុតចាកវិស័យរបស់លោក ១ ។ បញ្ញា សេចក្តីដឹងនេះ លោកចាត់ជាអធិដ្ឋានធម៌ ។

សច្ចៈ សេចក្តីតាំងចិត្តគិត គឺកាលប្រើបញ្ញាពិចារណាឃើញរបស់អ្វី ដែលជាប្រយោជន៍ដល់ខ្លួនហើយ មានសេចក្តីតាំងចិត្តមុតមាំ មិនផុនទ្រាន់នឿយណាយថយក្រោយ ដើម្បីប្រព្រឹត្តឱ្យបានសម្រេចផល ដែលខ្លួនប្រាថ្នាមិនលះបង់ចោល ប្រឹងប្រែងស៊ូលះបង់សាច់ឈាមប្តូរយកផលប្រយោជន៍ ដែលខ្លួនត្រូវការ សច្ចៈនេះ លោកចាត់ថាអធិដ្ឋានធម៌ ។

ការលះនូវនីវរធម៌ខ្លះ ដែលមានលក្ខណៈសង្ស័យក៏ដោយការព្យាយាមដុតបំផ្លាញនូវកិលេសាសវៈដទៃ ដែលជាសឹក

សត្រូវដល់សេចក្ដីពិតក្នុងចិត្តនោះ ឈ្មោះថា ចាគៈៗ នេះចាត់ជាអធិដ្ឋានធម៌ ។

កិលេសាសវៈណា ដែលធ្វើចិត្តឱ្យរើរវាយក្ដៅក្រហាយក្រវល់ក្រវាយមានប្រការផ្សេងៗ មិនឱ្យចិត្តស្ងប់រម្ងាប់បាន ការព្យាយាមធ្វើវិត្ត ឱ្យស្ងប់រម្ងាប់ចាករបស់ដែលជាសត្រូវដល់សេចក្ដីស្ងប់ដោយឧបាយដ៏សមគួរនោះ ឈ្មោះថាឧបសមៈៗ នេះចាត់ជាអធិដ្ឋានធម៌ ។

## ឥទ្ធិបាទ ៤ យ៉ាង

**១-ឆន្ទៈ** ចូលស្រឡាញ់ក្នុងកិច្ចការនោះៗ;

**២-វីរិយៈ** ព្យាយាមប្រកបកិច្ចការនោះៗ;

**៣-ចិត្តៈ** យកចិត្តទុកដាក់ក្នុងកិច្ចការនោះៗ មិនលះដាក់ធុរៈ;

**៤-វិមំសា** ឧស្សាហ៍ត្រិះរិះពិចារណារកហេតុផល ក្នុងកិច្ចការនោះៗ ។

បុ. ឥទ្ធិបាទ ប្រែថាដូចម្ដេច ?

វិ. ឥទ្ធិបាទ ប្រែថា គុណធម៌ជាជំហរឱ្យសម្រេចប្រយោជន៍ ឬប្រែថា ជើងសម្រាប់ដើរទៅកាន់ទីជិតឆ្ងាយបានធម៌ទាំង ៤ នេះ ដូចជាជើងសម្រាប់ដើរតាមផ្លូវអដ្ឋង្គិកមគ្គទៅកាន់ព្រះនិព្វានបានក៏យ៉ាងនោះដែរ ។

បុ. ឆន្ទៈ, តណ្ហា, ឥច្ឆា, បត្ថនា និងកាមៈ ទាំង ៥ ស័ព្ទនេះ ប្រែថា សេចក្តីប្រាថ្នា តើសេចក្តីប្រាថ្នាផ្សេងគ្នាដូចម្តេច? ចូរអធិប្បាយ !

វិ. ទាំង ៥ ស័ព្ទនេះ ប្រែថា សេចក្តីប្រាថ្នាដូចគ្នាមែន ប៉ុន្តែមានសេចក្តីបំណងផ្សេងគ្នា, ចំណែកឆន្ទៈនិងកាមៈ ទាំង ២ ស័ព្ទនេះ ប្រើបានទាំងកុសលទាំងអកុសល, ចំណែកកុសលដូចឆន្ទិទ្ធិបាទ អកុសលដូចកាមច្ឆន្ទៈ, កាមៈកុសល ដូចសិក្ខាកាមៈ អកុសលដូចកាមគុណ, ចំណែកតណ្ហាជាអកុសលសុទ្ធ, ឥច្ឆាគឺសេចក្តីប្រាថ្នាមិនចង់ឱ្យគេស្មើនឹងខ្លួនគឺចង់ឱ្យគេវិនាស, ចំណែកបត្ថនាបានខាងកុសល ដូចបាលីថា ឥច្ឆិតំ បត្ថិតំ ជាដើម សេចក្តីផ្សេងគ្នាដូចវិស្សជ្ជនាមកនេះ។

បុ. ចូរអធិប្បាយឥទ្ធិបាទទាំង ៤ នោះមកមើល ?

រ៊ិ. បុគ្គលត្រូវតម្កល់នូវឥទ្ធិបាទធម៌ទាំង ៤ យ៉ាងនេះ ទើបសម្រេចប្រយោជន៍បាន បើខ្វះខាតអង្គណាមួយហើយ ក៏មិនអាចសម្រេចផលប្រយោជន៍តាមត្រូវការបានឡើយ, ដូចជាបុគ្គលមានសេចក្ដីពេញចិត្ត នៅក្នុងរបស់ណាមួយយ៉ាងវិសេស តែមិនបានចុះដៃធ្វើមិនបានប្រព្រឹត្តដើម្បីឱ្យបានសម្រេចរបស់វិសេសនោះទេ, តើនឹងមានប្រយោជន៍អ្វី? ការសិក្សារៀនសូត្រ នឹងសម្រេចប្រយោជន៍សមតាមបំណងក៏ដោយ, ដំណើរការចិញ្ចឹមជីវិតយ៉ាងណានីមួយ ដើម្បីជួបប្រទះជោគវាសនា គឺការបានទ្រព្យសម្បត្តិក៏ដោយ វត្ថុទាំងនេះក៏ព្រោះតែមនុស្សទាំងនោះដំកល់ខ្លួននៅក្នុងឥទ្ធិបាទទាំង ៤ នេះឯង ។

មួយទៀត បុគ្គលដែលបរិបូណ៌ដោយធម៌ ៤ ប្រការនេះ បើប្រាថ្នានិព្វានសម្បត្តិ ក៏អាចសម្រេចតាមបំណងបានមិនខាន សូម្បីព្រះពុទ្ធជាម្ចាស់ ក៏ទ្រង់ត្រាស់សំដែងចំពោះព្រះអានន្ទថា ម្នាលអានន្ទ ឥទ្ធិបាទធម៌ទាំង ៤ ប្រការនេះ កាលបើបុគ្គលអប់រំចំរើនឱ្យច្រើនក្នុងសន្ដានហើយ ទោះមានសេចក្ដី

ប្រាថ្នានឹងឱ្យអាយុសង្ខារស្ថិតនៅអស់កប្ប (១) មួយ ក៏នឹងសម្រេចតាមបំណងមិនខាន ធម៌នេះឯងជាគ្រឿងមង្គលបង្ហាញឱ្យឃើញច្បាស់ថា ឥទ្ធិបាទធម៌ទាំង ៤ ប្រការនេះ មានអំណាច អាចឱ្យអ្នកដែលបានបំពេញជួបប្រទះនឹងវត្ថុបំណងដែលខ្លួបប៉ុនប៉ងទុកមក មិនឱ្យហួសវិស័យបាន ។

## គួរធ្វើសេចក្តីមិនប្រមាទក្នុងទី ៤ ស្ថាន

**១-កាយទុច្ចរិតប្បហានៈ** ក្នុងការលះកាយទុច្ចរិត ប្រព្រឹត្តកាយសុចរិត;

**២- វចីទុច្ចរិតប្បហានៈ** ក្នុងការលះវចីទុច្ចរិត ប្រព្រឹត្តវចីសុចរិត;

**៣-មនោទុច្ចរិតប្បហានៈ** ក្នុងការលះមនោទុច្ចរិត ប្រព្រឹត្តមនោសុចរិត;

**៤-មិច្ឆាទិដ្ឋិប្បហានៈ** ក្នុងការលះសេចក្តីយល់ខុស ធ្វើសេចក្តីយល់ត្រូវ ។

[1] បានដល់អាយុកប្ប គឺអាយុក្ខ័យរបស់មនុស្ស ។

បុ. ចូរអធិប្បាយអំពីការគួរធ្វើសេចក្តីមិនប្រមាទក្នុងទី ៤ ស្ថាននោះមកមើល ?

វិ. សេចក្តីមិនប្រមាទ បានដល់សេចក្តីមិនស្រវឹងវង្វេងក្នុង លាភ យស សរសើរ សុខ វ័យ សេចក្តីមិនមានរោគ និងជីវិត មានសតិប្រចាំនៅគ្រប់ៗ ឥរិយាបថ មិនបានភ្លេចភ្លាំង ក្នុងការ លះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត និងសេចក្តីយល់ខុស ការៈលះសេចក្តីអាក្រក់បានហើយ គប្បីប្រឹងព្យាយាមបំពេញ សេចក្តីល្អ គឺកាយសុចរិត វចីសុចរិត មនោសុចរិត និងសេចក្តី យល់ត្រូវតាមគន្លងធម៌ ។

## គួរប្រយ័ត្នចិត្តកុំវង្វេងក្នុងទី ៤ ស្ថាន

**១-រជនីយៈ** កុំត្រេកអរក្នុងអារម្មណ៍ដែលនាំឱ្យមានតម្រេក;

**២-ទោសនីយៈ** កុំខឹងក្នុងអារម្មណ៍ដែលនាំឱ្យខឹង;

**៣-មោហនីយៈ** កុំវង្វេងក្នុងអារម្មណ៍ដែលនាំឱ្យវង្វេង;

**៤-មទនីយៈ** កុំស្រវឹងក្នុងអារម្មណ៍ដែលនាំឱ្យស្រវឹង ។

បុ. ចូរអធិប្បាយការប្រយ័ត្នចិត្តកុំឱ្យវង្វេងក្នុងទី ៤ ស្ថាននោះមកមើល ?

វិ. អារម្មណ៍ដែលជាទីតាំងនៃសេចក្ដីតម្រេកនោះ បានដល់រូប សម្លេង ក្លិន រស សម្ផស្ស ដែលជាទីស្រឡាញ់ ជាទីប្រាថ្នា ជាទីពេញចិត្ត ។ អារម្មណ៍ដែលជាទីតាំងនៃសេចក្ដីក្រោធខឹងនោះ ក៏បានដល់កាមគុណ ៥ យ៉ាងគឺៈ រូប សម្លេង ក្លិន រស សម្ផស្ស នេះដែរ តែថាជាអារម្មណ៍មិនជាទីស្រឡាញ់ មិនជាទីប្រាថ្នា មិនជាទីពេញចិត្ត ។

កាមសុខ គឺសុខដែលអំពីការសេពកាម ឈ្មោះថាអារម្មណ៍ជាទីតាំងនៃសេចក្ដីស្រវឹង ។ លាភ យស សរសើរ សុខ ឈ្មោះថាអារម្មណ៍ជាទីតាំងនៃសេចក្ដីស្រវឹង ។ការរវាំងប្រយ័ត្ន ក៏គឺការតម្កល់ស្មារតី ឃាត់ឃាំងរាំងរាមិនឱ្យចិត្តរវើរវាយទៅតាមអារម្មណ៍នោះៗ បញ្ញាពិចារណាឱ្យឃើញដល់លក្ខណៈនិងប្រភេទនៃអារម្មណ៍តាមសេចក្ដីពិត មិនបណ្ដោយចិត្តឱ្យកើតតម្រេក ក្រោធខឹង វង្វេង និងស្រវឹងនោះឡើយ ។

# បារិសុទ្ធិសីល ៤ យ៉ាង

**១-បាតិមោក្ខសំវរសីល** សីលគឺការសង្រួមក្នុងព្រះបាតិមោក្ខ គឺវៀរចាកទោសដែលទ្រង់ហាម ហើយធ្វើតាមឱវាទដែលទ្រង់អនុញ្ញាតទុកមក;

**២-ឥន្ទ្រិយសំវរសីល** សីលគឺការសង្រួមកឥន្ទ្រីយទាំង ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត មិនឱ្យស្អប់ មិនឱ្យ ស្រឡាញ់ក្នុងវេលាឃើញរូប ស្តាប់សម្លេង ធុំខ្លិន ស្រូបរស កាយពាល់ត្រូវ ដឹងអារម្មណ៍ដោយចិត្ត;

**៣-អាជីវបារិសុទ្ធិសីល** សីលដែលបរិសុទ្ធដោយការចិញ្ចឹមជីវិតវៀរចាកបាបធម៌ ៥ និងអនេសនៈ ២១;

**៤-បច្ចយសន្និស្សិតសីល** សីលដែលអាស្រ័យដោយបច្ច័យ, ឯបច្ច័យនោះមាន ៤ យ៉ាង គឺៈ ចីវរ ១, បិណ្ឌបាត ១, សេនាសនៈ ១, គិលានភេសជ្ជៈ ១ មិនបរិភោគដោយតណ្ហា។

បុ. បាតិមោក្ខសំវរសីល បរិសុទ្ធដោយធម៌អ្វី ?

វិ. បាតិមោក្ខសំវរសីល បរិសុទ្ធដោយសទ្ធាចេតសិក ។

បុ. ឥន្ទ្រិយសំវរសីល បរិសុទ្ធដោយធម៌អ្វី ?

វិ. បរិសុទ្ធដោយសតិចេតសិក ។

បុ. អាជីវបារិសុទ្ធិសីល បរិសុទ្ធដោយធម៌អ្វី ?

វិ. បរិសុទ្ធដោយវីរិយចេតសិក ។

បុ. បច្ចយសន្និស្សិតសីល បរិសុទ្ធដោយធម៌អ្វី ?

វិ. បរិសុទ្ធដោយបញ្ញាចេតសិក ។

បុ. ចូរអធិប្បាយបារិសុទ្ធិសីលទាំង ៤ នោះមកមើល?

វិ. ការមិនប្រព្រឹត្តកន្លងព្រះវិន័យ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តទុកក្នុងព្រះបាតិមោក្ខតាំងអំពីបារាជិក ៤ រហូតដល់សេក្ខិយវត្ត ៧៥ ហៅថា សង្រួមក្នុងព្រះបាតិមោក្ខ ។

មួយទៀត ការមិនប្រព្រឹត្តខុស ដូចជាវត្តផ្សេងៗ មានកិច្ចវត្តជាដើម វៀរនូវបញ្ញត្តដែលព្រះអង្គទ្រង់ហាម ធ្វើតាមច្បាប់ដែលព្រះអង្គអនុញ្ញាតទុកមក ទាំងនេះក៏អនុលោមចូលក្នុងបាតិមោក្ខសំវរសីល ។

ការដំកល់សតិសង្រួមរវាំងឥន្ទ្រិយទាំង ៦ មានភ្នែកជាដើម មិនឱ្យកើតសោមនស្ស ទោមនស្ស ក្នុងវេលាដែលជួបប្រទះនូវអារម្មណ៍ទាំងឡាយ មានឃើញរូបដោយភ្នែកជាដើម ហៅថាឥន្ទ្រិយសំវរសីល ។

ការចិញ្ចឹមជីវិតដោយត្រឹមត្រូវ វៀរចាកការលួងបញ្ឆោតគេ ហើយចិញ្ចឹមជីវិត ដូចជាអ្នកឧត្តរិមនុស្សធម្មដែលមិនមានក្នុងខ្លួនជាដើម និងវៀរចាកការចិញ្ចឹមជីវិតខុសផ្លូវធម៌ ដែលជាទំនាស់ដល់ព្រះវិន័យ ដែលព្រះសម្ពុទ្ធទ្រង់បញ្ញត្តទុកមក ហៅថា អាជីវបារិសុទ្ធិសីល ។

សីលដែលអាស្រ័យបច្ច័យនោះគឺ ក្នុងវេលាដែលបរិភោគប្រើប្រាស់បច្ច័យទាំង ៤ ណានីមួយ គប្បីពិចារណាជាមុនសិន ដូចជាបរិភោគប្រើប្រាស់ចីវរជាដើម គប្បីពិចារណាថា អាត្មាអញស្លៀកដណ្តប់សំពត់ចីវរនេះ ដើម្បីស្និតស្នាងរាងកាយក៏ទេ ស្លៀកដណ្តប់ដើម្បីបន្ទោបង់នូវត្រជាក់និងក្តៅ ដើម្បីការពារសម្ផស្សមកប៉ះពាល់ គឺខ្យល់និងកំដៅថ្ងៃ និងសត្វមូសស្រួយជាដើម និងស្លៀកដណ្តប់ដើម្បីការពារនូវសេចក្តីអៀនខ្មាស ប៉ុណ្ណោះឯង មិនបរិភោគដោយអំណាចនៃតណ្ហាទេ យ៉ាងជាដើម ហៅថា បច្ចយសន្និស្សិតសីល ។

# អារក្ខកម្មដ្ឋាន ៤ យ៉ាង

**១-ពុទ្ធានុស្សតិ** រលឹកដល់គុណព្រះពុទ្ធដែលមានក្នុងព្រះអង្គ និងគុណដែលទ្រង់សង្គ្រោះដល់អ្នកដទៃ;

**២-មេត្តា** ផ្សាយមេត្តាចិត្តគិតឱ្យមនុស្សទាំងឡាយ បានសុខគ្រប់គ្នា;

**៣-អសុភៈ** ពិចារណារាងកាយខ្លួន និងអ្នកដទៃឱ្យឃើញថាជារបស់បដិក្កូលគួរខ្ពើមរអើម;

**៤-មរណស្សតិ** នឹកដល់សេចក្តីស្លាប់ដែលនឹងមានមកដល់ខ្លួន ។

បុ. ចូរអធិប្បាយអារក្ខកម្មដ្ឋានទាំង ៤ នោះមកមើល ?

វិ. គុណរបស់ព្រះពុទ្ធជាម្ចាស់នោះមានច្រើនណាស់ តែបើពោលដោយខ្លីមាន ៣ ប្រការគឺៈ បញ្ញាគុណ ១, វិសុទ្ធិគុណ ១, ករុណាគុណ ១ ។

ព្រះប្រាជ្ញារបស់ព្រះអង្គជ្រួតជ្រាបរបស់ពិតគឺ អរិយសច្ចដោយចំពោះព្រះអង្គ មិនមានគ្រូអាចារ្យដឹកនាំប្រៀនប្រដៅព្រះអង្គឡើយ នេះហៅថា បញ្ញាគុណ គឺគុណជាចំណែក

អត្ថហិតសម្បត្តិ ។ កាលដែលព្រះអង្គ មានព្រះទ័យបរិសុទ្ធិចាកកិលេសាសវៈ ព្រមទាំងវាសនា ហៅថា វិសុទ្ធិគុណ គឺគុណមានចំណែកអត្តហិតសម្បត្តិ មាននៅក្នុងព្រះអង្គ ។ កាលដែលព្រះអង្គមានព្រះមហាករុណាគុណ អាណិតអាសូរសត្វ ទ្រង់យាងសម្តែងធម៌ទេសនាប្រៀនប្រដៅ ដោយសមគួរដល់បុព្វបនិស្ស័យ ហៅថា ករុណាគុណ គឺគុណជាចំណែកបរហិតសម្បត្តិ មានដល់សត្វដទៃ ។

ការរលឹកដល់គុណព្រះពុទ្ធជាម្ចាស់ ដែលមាននៅក្នុងព្រះអង្គ និងគុណដែលទ្រង់អនុគ្រោះដល់អ្នកដទៃដូច្នេះ ហៅថា ពុទ្ធានុស្សតិ ។ មេត្តាស័ព្ទនេះ បើពោលដោយព្យញ្ជនៈ បានដល់សេចក្តីស្និទ្ធស្នាល គឺសេចក្តីស្រឡាញ់ប្រាថាករាគៈ បើពោលដោយអត្ថ បានដល់ការប្រាថ្នាសេចក្តីសុខចំរើនដល់អ្នកដទៃ ការផ្សាយមេត្តាចិត្ត ដោយចោះចំពោះមនុស្សនេះ, មនុស្សនោះ, ពួកនេះ, ពួកនោះ ហៅថា ឧទ្ទិស្សផរណា; ផ្សាយមេត្តាចិត្តដោយទូទៅមិនចោះចំពោះ មិនមានកំណត់ ហៅថា អនោទិស្សផរណា រួមសេចក្តីទៅថា មានចិត្តគិតឱ្យ

សត្វទាំងពួងមានសេចក្ដីសុខ សេចក្ដីចម្រើនគ្រប់ៗគ្នា ហៅថា មេត្តា ។

ការពិចារណារាងកាយខ្លួននិងអ្នកដទៃ តាំងអំពីសក់ រោម ក្រចក, ធ្មេញ, ស្បែក ជាដើម តាមអាការៈ ៣២ ប្រការ ឱ្យឃើញថាជារបស់មិនស្អាតស្មោកគ្រោក, គួរខ្ពើម បើនៅមិនឃើញថាជារបស់បដិក្កូល ក៏គប្បីពិចារណាដោយពណ៌សម្បុរសណ្ឋានទ្រង់ទ្រាយ ទីកើតទីនៅ ទាល់តែប្រាកដឱ្យឃើញថាជារបស់មិនគួរប្រាថ្នា យ៉ាងនេះជាដើម ហៅថា អសុភៈ ។

ការនឹកដល់សេចក្ដីស្លាប់ ដែលនឹងមានមកដល់ខ្លួនដោយការគិតថា យើងត្រូវស្លាប់ដោយពិត ឬថាសង្ខារទាំង-ឡាយមិនទៀងទាត់ឡើយ កើតឡើងហើយក៏រលត់ទៅវិញ ដូច្នេះជាដើម ទាលតែកើតចិត្តសង្វេគ ហៅថា មរណស្សតិ ។

បុ. អារក្ខកម្មដ្ឋាន ប្រែដូចម្ដេច ?

វិ. អារក្ខកម្មដ្ឋាន ប្រែថា កម្មដ្ឋានដែលបុគ្គលគប្បីរក្សារឿយៗ ឬរក្សាជានិច្ច ។

បុ. កម្មដ្ឋានទាំងអស់មាន ៤0 ហេតុអ្វីក៏លោកតែរក្សាកម្មដ្ឋានទាំង ៤ នេះជានិច្ច តើមានគុណវិសេសដូចម្ដេច ?

វិ. កម្មដ្ឋានទាំង ៤ នេះ បានជាព្រះអង្គឱ្យចំរើនជានិច្ចនោះ ដើម្បីនឹងទប់នូវសេចក្ដីអន្តរាយរបស់ភិក្ខុ-សាមណេរ ។

## ព្រហ្មវិហារ ៤ យ៉ាង

**១-មេត្តា** សេចក្ដីប្រាថ្នាចង់ឱ្យគេបានសុខ;

**២-ករុណា** សេចក្ដីអាណិតគិតជួយឱ្យគេរួចចាកទុក្ខ;

**៣-មុទិតា** សេចក្ដីត្រេកអរតាមក្នុងវេលាដែលគេបានល្អ;

**៤-ឧបេក្ខា** សេចក្ដីតាំងចិត្តជាកណ្ដាល មិនឱ្យមានទោមនស្ស សោមនស្ស ក្នុងវេលាដែលគេបានសេចក្ដីវិបត្តិ ។

បុ. ព្រហ្មវិហារ ប្រែដូចម្ដេច ?

វិ. ព្រហ្មវិហារ ប្រែថា ធម៌ជាគ្រឿងនៅរបស់ព្រហ្ម ។

បុ. ព្រហ្មវិហារក៏មាន ៤ អប្បមញ្ញាក៏មាន ៤ មានមេត្តាជាដើមដូចគ្នា តើសេចក្ដីផ្សេងគ្នាដូចម្ដេច ?

វិ. ព្រហ្មវិហារនេះ បានដល់ការផ្សាយទូទៅមិនចំពោះក៏មាន ចំពោះគណៈបក្សពួកក៏មាន ដូចជាមាតាបិតាផ្សាយចំពោះបុត្រធីតាជាដើម, ចំណែកអប្បមញ្ញា ផ្សាយទូទៅមិន

ចំពោះ បានដល់ពួកព្រហ្ម ដែលចំរើនឈាន ឈ្មោះថា អប្បមញ្ញា ។

បុ. ចូរអធិប្បាយព្រហ្មវិហារទាំង ៤ យ៉ាងនោះមកមើល ?

វិ. មេត្តា បើពោលដោយព្យញ្ជនៈ បានដល់សេចក្តីស្និទ្ធ-ស្នាល គឺស្រឡាញ់ប្រាសចាករាគៈ; បើពោលដោយអត្ថបាន ដល់ការប្រាថ្នាសេចក្តីសុខចំរើនដល់អ្នកដទៃ ការផ្សាយមេត្តា ចិត្តដោយចោះចំពោះមនុស្សនេះ មនុស្សនោះ ពួកនេះ ពួក នោះ ហៅថាឧទ្ទិស្សផរណា, ការផ្សាយមេត្តាចិត្ត ដោយទូទៅ មិនមានចោះចំពោះ មិនមានកំណត់ហៅថាអនោទិស្សផរណា រួមសេចក្តីទៅថា មានចិត្តចង់ឱ្យសត្វទាំងពួងបានសេចក្តីសុខ ចម្រើនគ្រប់ៗរូប ហៅថា មេត្តា ។

ករុណា បើពោលដោយព្យញ្ជនៈ បានដល់សេចក្តីញាប់ ញ័រក្នុងចិត្ត ដែលឃើញអ្នកដទៃ បានសេចក្តីទុក្ខព្រួយក្តៅ ក្រហាយ, បើពោលដោយអត្ថបានដល់ការប្រាថ្នាសេចក្តីសុខ ចម្រើនដល់អ្នកដទៃ ។

មុទិតា បើពោលដោយព្យញ្ជនៈបានដល់សេចក្តីរីករាយ បើពោលដោយអត្ថ បានដល់ការត្រេកអរ ដែលឃើញអ្នកដទៃបានសេចក្តីល្អ ។

ឧបេក្ខា បើពោដោយព្យញ្ជនៈ បានដល់សេចក្តីព្រងើយកន្តើយ បើពោលដោយអត្ថ បានដល់កិរិយាដាក់ខ្លួនជាកណ្តាល ក្នុងកាលដែលនឹងផ្សាយមេត្តាករុណា ទៅរកបុគ្គលដែលមិនសមគួរ ដូចជាមានចិត្តជួយចោរជាដើម ។

## សតិប្បដ្ឋាន ៤ យ៉ាង

**១-កាយានុបស្សនា** សតិរលឹកពិចារណាកាយជាអារម្មណ៍ថា កាយនេះគ្រាន់តែជាកាយប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ ជាយើង ជាគេឡើយ;

**២-វេទនានុបស្សនា** សតិរលឹកពិចារណាវេទនា គឺសេចក្តីសុខទុក្ខ ឧបេក្ខាជាអារម្មណ៍ថា វេទនានេះគ្រាន់តែជាវេទនាប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ ជាយើង ជាគេឡើយ;

**៣-ចិត្តានុបស្សនា** សតិរលឹកពិចារណាចិត្តដែលសៅហ្មង និងផូរផង់ជាអារម្មណ៍ថា ចិត្តនេះគ្រាន់តែជាចិត្តប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ ជាយើង ជាគេឡើយ ។

**៤-ធម្មានុបស្សនា** សតិរលឹកពិចារណាធម៌ជាកុសលដែលកើតឡើងជាមួយនឹងចិត្តជាអារម្មណ៍ថា ធម៌នេះគ្រាន់តែជាធម៌ប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ ជាយើង ជាគេឡើយ ។

បុ. សតិប្បដ្ឋាន ប្រែដូចម្ដេច ?

វិ. ប្រែថា ធម្មជាតិជាទីតាំងនៃសតិគួរតាំងនៅមាំ ឈ្មោះថា សតិប្បដ្ឋាន ។

បុ. ចូរអធិប្បាយសតិប្បដ្ឋាន ៤ យ៉ាងនោះមកមើល ?

វិ. ការចម្រើនធម៌ទាំង ៤ ប្រការនេះ ក្នុងទីនេះត្រូវមានសតិជាទីតាំងបំណងតាមប្រភេទរបស់អារម្មណ៍ ឯប្រភេទរបស់អារម្មណ៍នោះ លោកចែកជា ៤ យ៉ាងគឺៈ កាយ បានដល់រូប ១, វេទនា បានដល់ការសោយអារម្មណ៍ ១, ចិត្ត បានដល់ការគិតនឹក ១, ធម្មៈ បានដល់សភាពដែលកើតជាមួយនឹងចិត្ត ១; ការដំកល់សតិពិចារណាអារម្មណ៍ ដែលមកប្រាកដចំពោះ

មុខ និងតាមធម្មតារបស់អារម្មណ៍តែក្នុងមួយគ្រាៗ ព្រោះសញ្ញាតិរបស់អារម្មណ៍ជាចំណែកល្អដែលជាទីពេញចិត្ត នឹងជាចំណែកអាក្រក់ដែលមិនជាទីពេញចិត្ត ក៏កើតឡើងហើយតែងសូន្យទៅវិញដូចគ្នាទាំងអស់ ចំណែកល្អចង់ឱ្យគង់នៅយូរ ចំណែកមិនល្អចង់ឱ្យអន្តរធានវិនាសទៅ ដោយឆាប់រហ័ស ទោះបីយ៉ាងណាក៏ដោយ កើតឡើងហើយក៏សូន្យទៅវិញដូចគ្នា កិរិយាមិនបណ្ដោយសតិ ដឹងដល់ប្រភេទរបស់អារម្មណ៍នោះៗ ដូច្នេះឈ្មោះថាសតិប្បដ្ឋាន ។ ក្នុងមហាសតិប្បដ្ឋាន-សូត្រ លោកពោលថា អ្នកដែលចម្រើនសតិប្បដ្ឋាន ត្រូវប្រកបដោយអង្គ ៣ គឺ មានសតិ ១ មានសម្បជញ្ញៈ ១ មានសេចក្ដីព្យាយាម ១ ទើបអាចនាំអភិជ្ឈា និងទោមនស្សឱ្យថយចេញទៅបាន ។

បុ. សតិប្បដ្ឋានទាំង ៤ នេះ លុះតែចំរើនគ្រប់ទាំង ៤ ទើបបានសម្រេច ឬមួយក៏ចំរើនតែណាមួយបានសម្រេចដែរ ?

វិ. សតិប្បដ្ឋានទាំង ៤ នេះ មិនចាំបាច់ចំរើនគ្រប់ទាំង ៤ នោះទេ ចំរើនតែណាមួយក៏គង់សម្រេចប្រយោជន៍បានដែរ ប្រៀបដូចជាព្រះរាជវាំង មានទ្វារ ៤ ទុកជាចូលទៅតាមទ្វារ

ណាក៏គង់ដល់ប្រាសាទដូច្នោះ ។ កាយានុបស្សនាទុកដូចជាទិសខាងកើត វេទនានុបស្សនា ទុកដូចជាទិសខាងត្បូង ចិត្តា-នុបស្សនា ទុកដូចជាទិសខាងលិច ធម្មានុបស្សនា ទុកដូចជាទិសខាងជើង អដ្ឋង្គិកមគ្គ ទុកដូចជាផ្លូវដែលចូលទៅតាមទ្វារប្រាសាទទុកដូចជាព្រះនិព្វាន ។

## ធាតុកម្មដ្ឋាន ៤ យ៉ាង គឺៈ

**១-បឋវីធាតុ** ធាតុដី;

**២-អាបោធាតុ** ធាតុទឹក;

**៣-តេជោធាតុ** ធាតុភ្លើង;

**៤-វាយោធាតុ** ធាតុខ្យល់ ។

បុ. បឋវីធាតុៗ ដូចម្តេច ? មានប៉ុន្មានយ៉ាង? អ្វីខ្លះ ?

វិ. បឋវីធាតុ គឺធាតុណាដែលមានលក្ខណៈរឹងឈ្មោះថាបឋវីធាតុៗ នោះ ដែលជាខាងក្នុងមាន ១៩ គឺ **កេសា** សក់, **លោមា** រោម, **នខា** ក្រចក, **ទន្តា** ធ្មេញ, **តចោ** ស្បែក, **មំសំ** សាច់, **ន្ហារូ** សរសៃ, **អដ្ឋិ** ឆ្អឹង, **អដ្ឋិមិញ្ជំ** ខួរក្នុងឆ្អឹង, **វក្កំ** ទាច, **ហទយំ** បេះដូង, **យកនំ** ថ្លើម, **កិលោមកំ** វាវ, **បិហកំ** ក្រពះ,

**បច្ចាសំ** សួត, **អន្តំ** ពោះវៀនធំ, **អន្តគុណំ** ពោះវៀនតូច, **ឧទរិយំ** អាហារថ្មី, **ករីសំ** អាហាចាស់ ។

បុ. អាបោធាតុៗ ដូចម្ដេច? មានប៉ុន្មានយ៉ាង? អ្វីខ្លះ?

វិ. អាបោធាតុ គឺធាតុណាដែលមានលក្ខណៈរាវជ្រួតជ្រាបឈ្មោះថា អាបោធាតុៗ នោះ ដែលនៅខាងក្នុងមាន ១២ គឺ **បិត្តំ** ប្រមាត់, **សេម្ហំ** ស្លេស្ម៍, **បុព្វោ** ខ្ទុះ, **លោហិតំ** ឈាម, **សេទោ** ញើស, **មេទោ** ខ្លាញ់ខាប់, **អស្សុ** ទឹកភ្នែក, **វសា** ខ្លាញ់រាវ, **ខេឡោ** ទឹកមាត់, **សិង្ឃនិកា** ទឹកសម្បោរ, **លសិកា** រំអិល, **មុត្តំ** ទឹញមូត្រ ។

បុ. តេជោធាតុៗ ដូចម្ដេច? មានប៉ុន្មានយ៉ាង? អ្វីខ្លះ?

វិ. តេជោធាតុ គឺធាតុណាដែលមានលក្ខណៈក្ដៅឈ្មោះថា តេជោៗ នោះដែលជាខាងក្នុងមាន ៤ គឺៈ

១-សន្តប្បត្តិ ភ្លើងដែលញុំាងកាយឱ្យក្ដៅ;

២-ជិរណេគ្គិ ភ្លើងដែលញុំាងកាយឱ្យទ្រុឌទ្រោម;

៣-បរិណាមគ្គិ ភ្លើងដែលញុំាងកាយឱ្យក្រហល់ក្រហាយ;

៤-បរិទយគ្គិ ភ្លើងដែលញុំាងអាហារឱ្យរលួយ ។

បុ. វាយោធាតុៗ ដូចម្ដេច? មានប៉ុន្មានយ៉ាង? អ្វីខ្លះ?

វិ. វាយោធាតុ គឺធាតុដែលមានលក្ខណៈបក់ទៅបក់មក ឈ្មោះថាវាយោធាតុៗ នោះដែលជាខាងក្នុងមាន ៦ យ៉ាងគឺៈ

**១-ឧទ្ធង្គមវាត** ខ្យល់បក់ឡើងលើ;

**២-អធោគមវាត** ច្យល់បក់ចុះក្រោម;

**៣-កុច្ឆិសយវាត** ខ្យល់បក់ក្នុងពោះ;

**៤-កោដ្ឋាសយវាត** ខ្យល់បក់ក្នុងពោះវៀន;

**៥-អង្គមង្គានុសារីវាត** ខ្យល់បក់តាមរាងកាយ;

**៦-អស្សាសបស្សាសវាត** ខ្យល់ដកដង្ហើមចេញចូល ។ សេចក្តីកំណត់រាងកាយនេះឱ្យឃើញថា គ្រាន់តែជាធាតុ ៤ គឺៈ ដី, ទឹក, ភ្លើង, ខ្យល់ប្រជុំគ្នាប៉ុណ្ណោះ មិនមែនយើង មិនមែនរបស់យើង ដូច្នេះហៅថា ធាតុកម្មដ្ឋាន ។

## អរិយសច្ច ៤ យ៉ាង

**១-ទុក្ខសច្ច** ទុក្ខ ១២ កង;

**២-សមុទយសច្ច** ហេតុដែលនាំឱ្យកើតទុក្ខ ១២ កង គឺតណ្ហាទាំង ៣;

**៣-និរោធសច្ច** សេចក្ដីរំលត់ទុក្ខទាំង ១២ កង គឺព្រះនិព្វាន;

**៤-មគ្គសច្ច** ឧបាយរំលត់នូវតណ្ហាទាំង ៣ ។

បុ. អរិយសច្ចទាំង ៤ នេះមានចែកដូចម្ដេចទៀតដែរឬ ?

វិ. អរិយសច្ចទាំង ៤ នេះ មានចែកជាកុសល អកុសល និងអព្យាកតៈ ។

បុ. អរិយសច្ចទាំង ៤ នេះ ណាចាត់ចូលក្នុងកុសល? ណាចាត់ចូលក្នុងអកុសល? ណាចាត់ចូលក្នុងអព្យាកតៈ ?

វិ. ទុក្ខសច្ច ជាកុសលខ្លះ អកុសលខ្លះ ជាអព្យាកតខ្លះ, សមុទយសច្ច ជាអកុសលសុទ្ធ, និរោធសច្ច ជាអព្យាកត, មគ្គសច្ច ជាកុសល ។

បុ. ចូរអធិប្បាយទុក្ខសច្ចដែលចាត់ជាកុសល ជាអកុសល ជាអព្យាកតៈនោះមកមើល?

វិ.ទុក្ខសច្ច ជាកុសលនោះ ដូចជាសេចក្ដីទុក្ខលំបាកក្នុងកិច្ចការរៀនសូត្រក្ដី ទុក្ខលំបាកព្រោះចំរើនសមណធម៌ក្ដី ដូចចក្ខុបាលត្ថេរជាដើម មានសេចក្ដីទុក្ខលំបាកមែន តែអំពើនោះជាកុសល ដូច្នេះឈ្មោះថា ទុក្ខសច្ច ជាកុសល, ទុក្ខសច្ច ជា

អកុសលនោះ ដូចយ៉ាងប្រព្រឹត្តធ្វើបញ្ចវេរាទាំង ៥ ជាដើម បានសេចក្ដីលំបាកផ្សេងៗ ហើយថែមទាំងអំពើនោះជាអកុសលទៀត ដូច្នេះ ឈ្មោះថា ទុក្ខសច្ចជាអកុសល, ទុក្ខសច្ចជាអព្យាកតនោះ ដូចជាព្រះខីណាស្រព លោកខំដើរចង្រ្កមភាវនា បានសេចក្ដីទុក្ខលំបាកផ្សេងៗ មគ្គផលអ្វីក៏មិនបាន ព្រោះលោកលះបុណ្យបានអស់ហើយ ដូច្នេះ ឈ្មោះថា ទុក្ខ-សច្ចជាអព្យាកតៈ ។

បុ. សមុទយសច្ច ជាអកុសលសុទ្ធនោះដូចម្ដេច ?

វិ. សមុទយសច្ច ជាអកុសលសុទ្ធនោះ បានដល់តណ្ហាទាំង ៣ គឺ កាមតណ្ហា សេចក្ដីប្រាថ្នាក្នុងកាម ១, ភវតណ្ហា សេចក្ដីប្រាថ្នាក្នុងភព បានដល់សស្សតទិដ្ឋិ ១, វិភវតណ្ហា សេចក្ដីប្រាថ្នាក្នុងការប្រាសចាកភព បានដល់ឧច្ឆេទទិដ្ឋិ ១ បានជាថាសមុទយសច្ចនេះ ជាអកុសលសុទ្ធ ។

បុ. និរោធសច្ច ជាអព្យាកតនោះ ដូចម្ដេច?

វិ. និរោធសច្ចជាអព្យាកតនោះ បានដល់ព្រះនិព្វាន ទើបលោកចាត់ជាអព្យាកត ។

បុ. មគ្គសច្ច ជាកុសលនោះ ដូចម្ដេច ?

វិ. មគ្គសច្ចជាកុសលនោះ បានដល់អដ្ឋង្គិកមគ្គទាំង ៨ ជាផ្លូវសម្រាប់ដើរទៅកាន់ព្រះនិព្វាន ទើបលោកចាត់ជាកុសល ។

បុ. អរិយសច្ចទាំង ៤ នេះ បើខ្វះណាមួយ ហៅថាអរិយសច្ចបានឬទេ ?

វិ. អរិយសច្ចទាំង ៤ នេះ បើខ្វះណាមួយ ហៅថាអរិយសច្ចមិនបានទេ ប្រៀបដូចជាកង់រថយន្ត បើខ្វះកង់ណាមួយ ប្រើការមិនកើតដូច្នោះ ។

ចប់ចតុក្កៈពួក ៤

---

## បញ្ចកៈ ពួក ៥

### អនន្តរិយកម្ម ៥ យ៉ាង

**១-មាតុឃាត** សម្លាប់មាតា;

**២-បិតុឃាត** សម្លាប់បិតា;

**៣-អរហន្តឃាត** សម្លាប់ព្រះអរហន្ត;

**៤-លោហិតុប្បាទ** ប្រទូស្តព្រះពុទ្ធអង្គ រហូតដល់ញុំាងព្រះលោហិតឱ្យពុរពង ឬជាំដាំ;

**៥-សង្ឃភេទ** ញុំាងសង្ឃឱ្យបែកគ្នា ។

បុ. អនន្តរិយកម្ម ប្រែដូចម្តេច ?

វិ. ប្រែថា កម្មមានទម្ងន់ប្រមាណមិនបាន ឬថាកម្មឱ្យផលជាលំដាប់ គឺបន្ទាប់អំពីជាតិនេះទៅ ត្រូវទទួលទុក្ខទោសខានមិនបាន អ

បុ. ចូរអធិប្បាយអនន្តរិយកម្ម ៥ យ៉ាងនោះមកមើល ?

វិ. អធិប្បាយថា មនុស្សណាដែលហ៊ានសម្លាប់មាតាបិតារបស់ខ្លួនហើយ មនុស្សនោះតែងសម្លាប់អ្នកដទៃ ក្នុងកាលដែលខ្លួនទាស់ចិត្ត ដោយឥតកោតញញើតមិនខាន យ៉ាងនេះឈ្មោះថាជាអ្នកទម្លាយបំផ្លាញត្រកូលរបស់ខ្លួន ។

មនុស្សណាដែលហ៊ានសម្លាប់ព្រះអរហន្ត លោកជាអ្នកមានកាយវាចាចិត្តបរិសុទ្ធ មិនបានគិតប្រទូស្តដល់អ្នកឯណានីមួយ ដែលជាទីគោរពរាប់អានរបស់មហាជន មនុស្សនោះតែងសម្លាប់អ្នកដទៃដែលមានចិត្តមិនស្ងប់រម្ងាប់បាន ដោយឥតកោតញញើតមិនខាន យ៉ាងនេះ ឈ្មោះថា ទម្លាយបំផ្លាញទីគោរពរាប់អានរបស់មហាជន ។

មនុស្សណា ដែលប្រទូស្តព្រះសាស្តារបស់ខ្លួនឯងបាន ហើយ អ្នកនោះអស់លក្ខណ៍ អស់គោលខាងផ្លូវសាសនា ដូចជាមនុស្សគិតប្រទូស្តស្តេចផែនដីរបស់ខ្លួនដូច្នោះ ភិក្ខុដែលធ្វើសង្ឃឱ្យបែកជាពួក សូម្បីតែគណៈរបស់ខ្លួនទុំះបំបែកបាន ហើយ តែងគិតបំបែកគណៈដទៃទៀតមិនខាន ទុកដូចជាមនុស្សញុះញង់បំបែកសាមគ្គីធម៌របស់ខ្លួបឯង ។

កម្មទាំង ៥ យ៉ាងនេះជាបាបធ្ងន់ ឃាត់សួគ៌ ឃាត់និព្វាន តាំងនៅក្នុងស្ថានបារាជិករបស់អ្នកកាន់ព្រះពុទ្ធសាសនា ហាមមិនឱ្យធ្វើយ៉ាងដាច់ខាត ។

## អភិណ្ហប្បច្ចវេក្ខណៈ ៥ យ៉ាង

**១-ជរាធម្មោម្ហិ** អាត្មាអញមានសេចក្តីចាស់ជរាជាធម្មតា មិនកន្លងសេចក្តីចាស់ជរាបានឡើយ;

**២-ព្យាធិធម្មោម្ហិ** អាត្មាអញមានសេចក្តីឈឺចាប់ជាធម្មតា មិនកន្លងសេចក្តីឈឺចាប់បានឡើយ;

**៣-មរណធម្មោម្ហិ** អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់បានឡើយ;

**៤-សព្វេហិ មេ បិយេហិ** អាត្មាអញមានសេចក្តីព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ជាទីគាប់ចិត្តទាំងអស់;

**៥-កម្មស្សកោម្ហិ** អាត្មាអញមានកម្មជារបស់ខ្លួន អាត្មាអញធ្វើកម្មល្អនឹងបានផលល្អ ធ្វើកម្មអាក្រក់នឹងបានដល់ផលអាក្រក់ ។

បុ. អភិណ្ហប្បច្ចវេក្ខណៈ ប្រែដូចម្តេច?

វិ. ប្រែថា ធម៌សម្រាប់គ្រហស្ថ បព្វជិតគួរពិចារណារឿយៗ ។

បុ. ចូរអធិប្បាយអភិណ្ហប្បច្ចវេក្ខណៈទាំង ៥ យ៉ាងនោះមកមើល ?

វិ. ការពិចាណាដល់សេចក្តីចាស់ ជាហេតុឱ្យលះសេចក្តីស្រវឹងក្នុងវ័យ គឺសេចក្តីសម្គាល់ថាខ្លួននៅជាកំលោះក្រមុំនៅឡើយ; ការពិចារណាដល់សេចក្តីឈឺ ជាហេតុនាំឱ្យលះសេចក្តីស្រវឹងក្នុងសេចក្តីសំគាល់ថា ខ្លួនមិនមានរោគ; ការពិចារណាដល់សេចក្តីស្លាប់ ជាហេតុឱ្យលះសេចក្តីស្រវឹងក្នុងជីវិត; ការពិចារណាក្នុងធម៌ទី ៤ ក៏ដើម្បីនឹងឱ្យលះសេចក្តីសម្គាល់ក្នុងសម្បត្តិ ដែលមានវិញ្ញាណនិងឥតវិញ្ញាណថាជា

របស់ស្ថិតស្ថេរចីរកាលទៅបាន; ការពិចារណាក្នុងធម៌ទី ៥ ក៏ដើម្បីនឹងឱ្យលះសេចក្ដីអាក្រក់ ហើយប្រព្រឹត្តសេចក្ដីល្អ មិនជឿប្រកាន់លទ្ធិដទៃៗ ក្រៅអំពីកម្មផល; សរុបសេចក្ដីទៅថា ការពិចារណាក្នុងធម៌ទី ៥ នេះ មានប្រយោជន៍មិនឱ្យវង្វេងភ្លេចស្មារតីក្នុងការលះសេចក្ដីអាក្រក់ ចេះប្រព្រឹត្តសេចក្ដីល្អគ្រប់យ៉ាង ។

## វេសារជ្ជករណធម៌ ៥ យ៉ាង

**១-សទ្ធា** ជឿរបស់ដែលគួរជឿ;

**២-សីល** រក្សាកាយវាចាឱ្យរៀបរយល្អ;

**៣-ពាហុសច្ច** ជាអ្នកសិក្សារៀនសូត្រច្រើន;

**៤-វីរិយារម្ភៈ** ប្រារព្ធសេចក្ដីព្យាយាម;

**៥-បញ្ញា** ដឹងរបស់ដែលគួរដឹង ។

បុ. វេសារជ្ជករណធម៌ ប្រែដូចម្ដេច ?

វិ. ប្រែថា ធម៌ធ្វើឱ្យក្លាហាន ។

បុ. ចូរអធិប្បាយវេសារជ្ជករណធម៌ទាំង ៥ យ៉ាងនោះមកមើល ?

វ. សេចក្ដីជឿក្នុងទីនេះ សំដៅយកសេចក្ដីជឿ ដែលបានត្រិះរិះពិចារណាហេតុផលដោយសព្វគ្រប់ហើយ ដែលហៅថា សទ្ធាញាណសម្បយុត្ត; ការរក្សាសីលតាមភូមិរបស់ខ្លួន គឺ សីល ៥ សីល ៨ សីល ១០ សិក្ខាបទ ២២៧ ប្រភេទណានីមួយក៏ដោយចុះ ហ្វឹកហ្វឺនហាត់ពត់កាយវាចាឱ្យរៀបរយល្អ មិនឱ្យមានទោមនស្ស ហៅថាសីល; ភាពជាអ្នកបានសិក្សាសិល្បសាស្ត្រទាំងផ្លូវលោកផ្លូវធម៌ មានសេចក្ដីចេះដឹងច្រើន ហៅថា ពាហុសច្ច, ការបំពេញសេចក្ដីព្យាយាម គឺតាំងសេចក្ដីព្យាយាមមិនមានឈប់ មានសេចក្ដីក្លាហានមោះមុតមិនខ្លាចឧបស័គ្គណាមួយ ដែលមាននៅក្នុងចន្លោះៗ បំណងផលគឺការបានសម្រេចជាទីបំផុត តែគប្បីចូលចិត្តថា សេចក្ដីព្យាយាមក្នុងទីនេះ សំដៅយកការប្រព្រឹត្តិទៅក្នុងផ្លូវលោក ផ្លូវធម៌ ដែលមិនមានទោស ដែលបណ្ឌិតមិនគប្បីតិះដៀល ហៅថា វិរិយារម្ភ; ការចេះដឹងសិល្បសាស្ត្រក្នុងផ្លូវលោកផ្លូវធម៌ ដែលប្រាសចាកទោស ហៅថា បញ្ញា ។

ធម៌ទាំង ៥ នេះ រមែងមានសេចក្ដីក្លាហានមិនរួញរា អង់អាចក្នុងការចូលទៅកាន់ទីប្រជុំ មានសមត្ថភាពអាចដោះ

សេចក្តីសង្ស័យរបស់អ្នកដទៃបាន ដោយឆាប់រហ័ស ព្រោះហេតុនោះ ទើបលោកឱ្យឈ្មោះថា វេសារជ្ជករណធម៌ ។

## អង្គនៃភិក្ខុ ៥ យ៉ាង

១-សង្រួមក្នុងព្រះបាតិមោក្ខ គឺវៀរចាកទោសដែលទ្រង់ហាម ធ្វើតាមច្បាប់ដែលទ្រង់អនុញ្ញាត;

២-សង្រួមឥន្ទ្រិយ គឺប្រយ័ត្នភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត មិនឱ្យសោមនស្ស ទោមនស្ស គ្រប់សង្កត់ចិត្តក្នុងវេលាដែលបានជួបប្រទះអារម្មណ៍មានរូបារម្មណ៍ជាដើម;

៣-ជាអ្នកមិននិយាយសប្បាយហេហា;

៤-នៅក្នុងសេនាសនៈស្ងាត់;

៥-មានសេចក្តីឃើញត្រូវ ។

បុ. ចូរអធិប្បាយអង្គនៃភិក្ខុទាំង ៥ យ៉ាងនោះមកមើល ?

វិ. កុលបុត្រដែលមានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា បានលះបង់គេហដ្ឋានចូលមកឧបសម្ប័ទក្នុងធម៌វិន័យ បាននាមថាភិក្ខុ គួរតាំងនៅក្នុងធម៌ទាំង ៥ ប្រការនេះយ៉ាងតឹងរ៉ឹង ព្រោះខ្លួនឯងជាអ្នកចូលមកកាន់ធម្មវិន័យ បើមិនសិក្សា

ប្រតិបត្តិតាមចរិយាវត្តរបស់ភិក្ខុទេ អាចប្រព្រឹត្តកន្លងវិន័យ មានទោសដាច់ចាកភិក្ខុភាវៈ ។

ការសង្រួមក្នុងព្រះបាតិមោក្ខ ជាហេតុឱ្យបរិសុទ្ធសីល, ការសង្រួមនូវឥន្ទ្រិយជាហេតុឱ្យចិត្តស្ងប់រម្ងាប់ មិនរវើរវាយ រាយមាយ គួរជាមនុស្សស្ងប់ស្ងៀម សមរម្យជាសមណសារូប, ការនៅក្នុងសេនាសនៈស្ងាត់ ជាហេតុឱ្យបានកាយវិវេក សមគួរដល់ការបំពេញសមណធម៌, មានសេចក្ដីឃើញត្រូវជាហេតុឱ្យប្រតិបត្តិត្រង់តាមគន្លងបាន ។

កាលបើភិក្ខុប្រកបដោយធម៌ទាំង ៥ ប្រការនេះហើយ រមែងបានសេចក្ដីសុខចំរើនលូតលាស់ ក្នុងព្រះពុទ្ធសាសនាដោយពិតប្រាកដមិនខាន ។

## អង្គនៃធម្មកថិក ៥ យ៉ាង

**១-អនុបុព្វីកថំ កថេស្សាមិ** អាត្មាអញនឹងសំដែងតាមលំដាប់ មិនច្រូតកាត់ពេកឱ្យខូចសេចក្ដី;

**២-បរិយាយទស្សាវីកថំ កថេស្សាមិ** អាត្មាអញនឹងសំដែងលើកយកហេតុផលមកអាងណែនាំឱ្យអ្នកស្ដាប់ចូលចិត្ត;

**៣-អនុទ្ទយតំ កថំ កថេស្សាមិ** អាត្មាអញនឹងសំដែងតាំងចិត្តមេត្តាឱ្យជាប្រយោជន៍ដល់អ្នកស្តាប់;

**៤- ន អាមិសន្តរោ កថំ កថេស្សាមិ** អាត្មាអញនឹងមិនសម្តែងធម៌ ព្រោះឃើញអាមិស;

**៥-អត្តានញ្ច អនុបហច្ច កថំ កថេស្សាមិ** អាត្មាអញនឹងសម្តែងធម៌ មិនលើកខ្លួន បន្តុះបង្អាប់អ្នកដទៃ ។

បុ. ចូរអធិប្បាយអង្គធម្មកថិកទាំង៥ យ៉ាងនោះមកមើល?

វិ. អង្គទី ១ ការសំដែងធម៌តាមលំដាប់ តាំងអំពីជាន់ទាបរហូតដល់ជាន់ខ្ពស់ មិនកាត់លោះឱ្យខូចខាតសេចក្តី ទោះបីសំដែងដោយសង្ខេបឬពិស្តារក៏ដោយ ស្រេចហើយតែឱកាសនិងវេលាឱ្យ កុំឱ្យតែខូតខាតត្រង់សេចក្តីដែលសំខាន់ៗ ខ្វែងប្រទាស់គ្នា ដោយហេតុផល ។

អង្គទី ២ ធម្មកថិកត្រូវសំដែងអាងហេតុផល ដឹកនាំចង្អុលបង្ហាញព្រមដោយឧបមាឧបមេយ្យ ឱ្យអ្នកស្តាប់ចូលចិត្តជាក់លាក់ មិនឱ្យមានសន្ទិះសង្ស័យ សម្តែងកម្មផលនិងផលនៃកម្មឱ្យអ្នកស្តាប់ឃើញច្បាស់ ដូចជាសម្លឹងឃើញវត្ថុផ្សេងៗ ជារបស់ក្នុងលោកនេះ ដោយភ្នែកបានដូច្នោះឯង ។

អង្គទី ៣ ធម្មកថិកត្រូវតាំងមេត្តាចិត្ត ប្រាថ្នានឹងឱ្យអ្នកស្តាប់បានទទួលប្រយោជន៍មែនៗ ដោយវិធីធ្វើទុកក្នុងចិត្តថាធ្វើដូចម្តេចហ្ន៎! ជនពួកនេះអាចដឹងច្បាស់តាមធម៌ រួចហើយគេនឹងបានសេចក្តីសុខយ៉ាងនេះយ៉ាងនោះ ។

អង្គទី ៤ ធម្មកថិកគួរជាអ្នកធ្ងន់ក្នុងធម៌ គោរពក្នុងធម៌ បំណងប្រកាសសាសនធម៌ជាទីតាំង ដើម្បីឱ្យព្រះសទ្ធម្មផ្សាយទូលាយទៅក្នុងសាវកមណ្ឌល ដើម្បីប្រយោជន៍អនុគ្រោះ និងសេចក្តសុខដល់ជនពួកច្រើន, មិនធ្ងន់ក្នុងលាភសក្ការៈ គឺឃើញដល់គ្រឿងអាមិស, បើបំណងលាភជាធំ កាលឃើញគ្រឿងអាមិសច្រើន ក៏នឹងសំដែងដោយពេញចិត្ត បើឃើញមានគ្រឿងអាមិសតិច ក៏នឹងសម្តែងដោយមិនពេញចិត្ត ដូចជាឈ្នួលឬគូលីធ្វើការងារល្អ តែក្នុងកាលបានថ្លៃឈ្នួលច្រើន អាការៈដូច្នេះ ខុសលក្ខណៈរបស់ធម្មកថិក ។

អង្គទី ៥ ធម្មកថិកមិនគប្បីកាន់យកការសំដែងធម៌ ដោយលើកខ្លួនឯង បន្តុះបង្អាប់អ្នកដទៃដោយចេតនាអាក្រក់ ហើយមិនគប្បីលើកខ្លួន សង្កត់សង្កិនលោកដទៃក្នុងវិធីសំដែងធម៌ ។ ធម្មកថិកដែលតាំងនៅក្នុងធម៌ទាំងអម្បាលនេះ ចាត់ជាធម្ម-

កថិកដ៏ល្អ ជាសិរីនៃសាសនា ជាទីសរសើរនៃបណ្ឌិតទាំងឡាយ ។

## ធម្មស្សវនានិសង្ស ៥ យ៉ាង

**១-អស្សុតំ សុណាតិ** រមែងបានស្ដាប់ធម៌ដែលមិនទាន់បានស្ដាប់;

**២-សុតំ បរិយោទបេតិ** ធម៌ណាដែលធ្លាប់ស្ដាប់ហើយ តែមិនទាន់ចូលចិត្ត នឹងចូលចិត្តច្បាស់ឡើង;

**៣-កង្ខំ វិហនតិ** រមែងកំចាត់បង់នូវសេចក្ដីសង្ស័យបាន;

**៤-ទិដ្ឋឹ ឧជុំ ករោតិ** រមែងធ្វើសេចក្ដីឃើញ ឱ្យច្បាស់ត្រង់តាមការណ៍ពិត;

**៥-ចិត្តមស្ស បសីទតិ** ចិត្តអ្នកស្ដាប់នោះរមែងជ្រះថ្លា ។

បុ. ចូរអធិប្បាយសម្មស្សវនានិសង្ស គឺអានិសង្សនៃការស្ដាប់ធម៌ទាំង ៥ យ៉ាងនោះមកមើល ?

វិ. អ្នកស្ដាប់ដែលនឹងបានទទួលនូវអានិសង្សគ្រប់ទាំង ៥ យ៉ាងនេះ ត្រូវតាំងចិត្តស្ដាប់ បញ្ជូនក្រសែចិត្តទៅតាមធម៌ មិនបណ្ដោយចិត្តឱ្យរវើរវាយ មានសុភាសិតជាគ្រឿងដាស់តឿនសតិថា សុស្សូសំ លភតេ បញ្ញំ ប្រែថា ការស្ដាប់ដោយល្អ

រមែងបានបញ្ញា; ការតាំងចិត្តស្តាប់ដូច្នេះ រមែងសម្រេចប្រយោជន៍នៃការស្តាប់ គឺបានទទួលអានិសង្សដូចពោលមកហើយ ។

ម្យ៉ាងទៀត វាចាជាសុភាសិត រមែងបានផលដល់អ្នកស្តាប់ហើយគោរព ដូចជាផ្កាឈើ ដែលមានទ្រង់ទ្រាយសណ្ឋានល្អ ទាំងពណ៌សម្បុរក៏ល្អ ក្លិនក៏ក្រអូប រមែងជ្រួតជ្រាបទៅក្នុងកាយរបស់អ្នកទ្រទ្រង់ដូច្នោះ ។

## ពលធម៌ ៥ យ៉ាង

១-សទ្ធា សេចក្តីជឿ;

២-វីរិយៈ សេចក្តីព្យាយាម;

៣-សតិ សេចក្តីរលឹកបាន;

៤-សមាធិ សេចក្តីតាំងចិត្តខ្ជាប់;

៥-បញ្ញា សេចក្តីដឹងស្គាល់ការណ៍ខុសត្រូវ ។

ឫ. ពល ប្រែដូចម្តេច?

វិ. ប្រែថា ធម៌ជាកម្លាំង គឺជាកម្លាំងក្នុងកិច្ចការរបស់ខ្លួន ។

បុ. ចូរអធិប្បាយ ពលធម៌ទាំង ៥ យ៉ាងនោះមកមើល ?

វិ. ពលធម៌ទាំង ៥ យ៉ាងនេះ ជាគ្រឿងឧបត្ថម្ភចិត្តឱ្យមានកម្លាំង បុគ្គលដែលនឹងប្រកបកិច្ចការអ្វីៗ ក៏ដោយ ត្រូវមានកម្លាំងកាយ កម្លាំងចិត្តប្រកបគ្នា ទើបបានសម្រេចផលតាមសេចក្ដីប្រាថ្នារបស់ខ្លួនមិនខាន ។

ចំណែកអ្នកប្រតិបត្តិធម៌ ដែលនឹងបានសម្រេចផលបានក៏ត្រូវតែមានកម្លាំងចិត្ត គឺសេចក្ដីជឿ, សេចក្ដីព្យាយាម, សេចក្ដីរលឹកបាន, សេចក្ដីតាំងចិត្តខ្ជាប់ និងសេចក្ដីដឹងស្គាល់ហេតុការណ៍ខុសត្រូវ, បានជាហៅថាពលៈនោះ ព្រោះជាកម្លាំងក្នុងកិច្ចការរសប់ខ្លួន ដូចជាសទ្ធាជាធំក្នុងការជឿ វីរិយៈជាធំក្នុងការព្យាយាមជាដើម ។

ម៉្យាងទៀត ធម៌ទាំងអម្បាលនេះ ទាក់ទង់នៅក្នុងពោធិ-បក្ខិយធម៌ទាំង ៣៧ ប្រការ ដែលជាកម្លាំងធំឱ្យអ្នកបំពេញកុសលបានសម្រេចសម្បត្តិជាន់ខ្ពស់ គឺលោកុត្តរធម៌ តាមបំណងរបស់ខ្លួនប្រាកដ ។

# នីវរណធម៌ ៥ យ៉ាង

១-កាមច្ឆន្ទៈ ស្រឡាញ់ចូលចិត្តក្នុងអារម្មណ៍មានរូបារម្មណ៍ជាដើម ដែលជាទីគាប់ចិត្ត;

២-ព្យាបាទៈ ចងចិត្តគុំគួនអ្នកដទៃ;

៣-ថីនមិទ្ធៈ ដំណើរដែលចិត្តរួញថយ នឹងដំណើរងងុយងោកងក់;

៤-ឧទ្ធច្ចកុក្កុច្ចៈ ដំណើរដែលចិត្តរាយមាយ និងរសាប់រសល់;

៥-វិចិកិច្ឆា សេចក្តីសង្ស័យមិនចេះដាច់ស្រេច ។

បុ. នីវរណធម៌ ប្រែដូចម្តេច ?

វិ. ប្រែថា ធម៌ជាគ្រឿងរាំងរាហាមចិត្តមិនឱ្យបានសេចក្តីល្អ ហៅថា នីវរណៈ ។

បុ. ចុះកាមច្ឆន្ទៈចែកជាប៉ុន្មានយ៉ាង ?

វិ. កាមច្ឆន្ទៈ ចែកជា ៥ យ៉ាងគឺៈ

**១-បរិយេសនច្ឆន្ទៈ** សេចក្ដីប្រាថ្នាក្នុងការស្វែងរកនូវកាមគុណ;

**២-បដិលាភច្ឆន្ទៈ** សេចក្ដីប្រាថ្នាក្នុងការបានចំពោះនូវកាមគុណ;

**៣-បរិភោគច្ឆន្ទៈ** សេចក្ដីប្រាថ្នា ក្នុងការប្រើប្រាស់នូវកាមគុណ;

**៤-សន្និធច្ឆន្ទៈ** សេចក្ដីប្រាថ្នាក្នុងការសន្សំកាមគុណ;

**៥-វិស្សជ្ជនច្ឆន្ទៈ** សេចក្ដីប្រាថ្នាលះបង់នូវវត្ថុផ្សេងៗ ដើម្បី ទំនុងបម្រុងកាមគុណ ។

បុ. កាមច្ឆន្ទៈ ត្រូវរម្ងាប់ដោយធម៌អ្វី ?

វិ. កាមច្ឆន្ទៈ ត្រូវរម្ងាប់ដោយកាយគតាសិតកម្មដ្ឋាន និងអសុភកម្មដ្ឋាន ។

បុ. ព្យាបាទៈ ត្រូវរម្ងាប់ដោយធម៌អ្វី ?

វិ. ព្យាបាទៈ កើតឡើង ត្រូវរម្ងាប់ដោយការចំរើនមេត្តា ។

បុ. ថីនមិទ្ធៈ កើតឡើង ត្រូវរម្ងាប់ដោយធម៌អ្វី ?

វិ. ថីនមិទ្ធៈ កើតឡើង ត្រូវរម្ងាប់ដោយការចំរើនពុទ្ធគុណគឺសេចក្ដីល្អរបស់ខ្លួន ។

បុ. ឧទ្ធច្ចកុក្កុច្ចៈ កើតឡើង ត្រូវរម្ងាប់ដោយធម៌អ្វី ?

វិ. ឧទ្ធច្ចកុក្កុច្ចៈ កើតឡើង ត្រូវរម្ងាប់ដោយការសម្លឹងមើលកសិណ ដើម្បីធ្វើឱ្យចិត្តនៅហ្នឹង ។

បុ. វិចិកិច្ឆា កើតឡើង ត្រូវរម្ងាប់ដោយធម៌អ្វី ?

វិ. វិចិកិច្ឆា កើតឡើង ត្រូវរម្ងាប់ដោយការចំរើននូវធាតុកម្មដ្ឋាន ។

បុ. ចូរអធិប្បាយនីវរណធម៌ទាំង ៥ យ៉ាងនោះមកមើល ?

វិ. នីវរណៈទាំង ៥ នេះ សូម្បីនីវរណៈណាមួយក៏ដោយចុះ កាលបើគ្របសង្កត់ចិត្តបានហើយ រមែងធ្វើអោយទឹកចិត្តកករល្អក់ ប្រើការមិនកើត, កាមច្ឆន្ទៈ ដូចជាទឹកថ្លាមានព្រាំឬមន្ទិលនៅពីលើ, ព្យាបាទ ដូចជាទឹកកំពុងពុះ, ថីនមិទ្ធ ដូចជាទឹកមានចកឬសារាយនៅពីលើ, ឧទ្ធច្ចកុក្កុច្ច ដូចជាទឹករលក, វិចិកិច្ឆា ដូចជាទឹកដែលគេយកដីទៅចាក់ឱ្យកករល្អក់; ទឹកជាប្រក្រតីគេអាចឆ្លុះបញ្ចាំងមើលស្រមោលមុខឃើញ បើមន្ទិលទាំងនោះមកគ្របសង្កត់ ធ្វើឱ្យទឹកកករល្អក់ហើយ បុគ្គលមិនអាចឆ្លុះមើលបានឡើយ យ៉ាងណា, ចំណែកនីវរណធម៌ទាំង ៥ ក៏ធ្វើទឹកចិត្តសត្វឱ្យកករល្អក់ប្រើការមិនកើតដូច្នោះដែរ ។

# ខន្ធ ៥

កាយចិត្តនេះចែកចេញជា ៥ កង ហៅថា ខន្ធ ៥ គឺៈ រូប ១, វេទាន ១, សញ្ញា ១, សង្ខារ ១, វិញ្ញាណ ១ ។

១-ធាតុ ៤ គឺ ដី, ទឹក, ភ្លើង, ខ្យល់ ប្រជុំគ្នាជាកាយនេះ ហៅថា រូប ។

២-ការកំណត់ដឹងអារម្មណ៍ជាសុខ គឺសប្បាយកាយ សប្បាយចិត្ត ឬជាទុក្ខ មិនសប្បាយកាយ មិនសប្បាយចិត្ត ឬឧបេក្ខា គឺព្រងើយកន្តើយ មិនសុខ មិនទុក្ខ ហៅថា វេទនា ។

៣-សេចក្តីកំណត់សម្គាល់ចាំបាន គឺចាំរូប, សំឡេង, ក្លិន, រស, ផោដ្ឋព្វ, ធម្មារម្មណ៍ អារម្មណ៍ដែលកើតចំពោះចិត្ត ហៅថា សញ្ញា ។

៤-ចេតសិកធម៌ គឺអារម្មណ៍ដែលកើតរលត់ជាមួយចិត្ត, ចំណែកខាងល្អ ហៅថា កុសល ខាងអាក្រក់ ហៅថាអកុសល, ខាងកណ្តាលមិនអាក្រក់មិនល្អ ហៅថា ព្យាក្រិត; រួមទាំង ៣ យ៉ាងនេះហៅថា សង្ខារ ។

៥-សេចក្តីដឹងអារម្មណ៍ ក្នុងវេលាដែលអាយតនៈខាងក្រៅមានរូបជាដើម មប៉ះអាយតនៈខាងក្នុងមានភ្នែកជាដើម ហៅថា វិញ្ញាណ ។

ខន្ធ ៥ នេះ ហៅដោយបំព្រួញថា នាមរូប ។ វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ, រួមចូលគ្នាជានាម ឬជានាមធម៌; ឯរូបគង់នៅជារូប ឬជារូបធម៌ ។

បុ. ខន្ធ ប្រែដូចម្តេច ?

វិ. ប្រែថា កងឬគំនរ គឺកងឬគំនររូប, វេទនា, សញ្ញា, សង្ខារ និង វិញ្ញាណ ។

បុ. រូប ប្រែដូចម្តេច ?

វិ. រូប ប្រែថា ធម្មជាតិដែលវិនាសទៅដោយវិរោធិប្បច្ច័យ មានក្តៅហួសប្រមាណ ត្រជាក់ហួសប្រមាណជាដើម ។

បុ. វេទនា ប្រែដូចម្តេច ?

វិ. វេទនា ប្រែថា ធម្មជាតិសោយនូវអារម្មណ៍ជាសុខខ្លះ ជាទុក្ខខ្លះ មិនសុខមិនទុក្ខ ហៅថា ឧបេក្ខាខ្លះ ។

បុ. សញ្ញា ប្រែដូចម្តេច ?

វិ. សញ្ញា ប្រែថា សេចក្តីចាំរូប ចាំសម្លេងជាដើមបាន ។

## ៩៥

បុ. សង្ខារ ប្រែដូចម្តេច ?

វិ. សង្ខារ ប្រែថា ធម្មជាតិតាក់តែង បានដល់ការគិតដែលកើតឡើងជាមួយនឹងចិត្ត សង្ខារក្នុងទីនេះ មានសេចក្តីបំណងផ្សេងគ្នានឹងសង្ខារក្នុងសាមញ្ញលក្ខណៈ តែសូម្បីមានសេចក្តីផ្សេងគ្នាក៏ដោយចុះ ក៏គង់មានលក្ខណៈស្មើគ្នា គឺមិនទៀង ជាទុក្ខ ជាអនត្តា ដូចគ្នា ។

បុ. វិញ្ញាណ ប្រែដូចម្តេច ?

វិ. វិញ្ញាណ ប្រែថា សេចក្តីដឹង បានដល់សេចក្តីដឹងជាក់ច្បាស់នូវអារម្មណ៍ ក្នុងកាលដែលរូបមកប៉ះពាល់នូវអាយតនៈមានភ្នែកជាដើម ។

ចប់បញ្ហកៈ ពួក ៥

---

# ឆក្កៈពួក ៦

## គារវតា ៦ យ៉ាង

**១-ពុទ្ធគារវតា** គោរពព្រះពុទ្ធ;

**២-ធម្មគារវតា** គោរពព្រះធម៌:

**៣-សង្ឃគារវតា** គោរពព្រះសង្ឃ;

**៤-សិក្ខាគារវតា** គោរពការសិក្សារៀនសូត្រ;

**៥-អប្បមាទគារវតា** គោរពសេចក្ដីមិនប្រមាទ;

**៦-បដិសណ្ឋារគារវតា** គោរពបដិសណ្ឋារៈ ។

បុ. គារវតា ប្រែដូចម្ដេច ?

វិ. ប្រែថា សេចក្ដីគោរព ។

បុ. ចូរអធិប្បាយគារវតាទាំង ៦ យ៉ាងនោះមកមើល?

វិ. ការក្រាបសំពះបូជាគុណក៏ដោយ ការប្រព្រឹត្តតាមពាក្យប្រៀនប្រដៅរបស់ព្រះអង្គក៏ដោយ រហូតដល់ការគោរពបូជនីយវត្ថុ មានព្រះពុទ្ធបដិមាជាដើម ហៅថា គោរពព្រះពុទ្ធជាម្ចាស់ ។ ការគោរពក្នុងព្រះបរិយត្តិធម៌ គឺការរៀនសូត្រក៏ដោយ គោរពក្នុងការប្រតិបត្តិតាមធម្មវិន័យក៏ដោយ ហៅថា

គោរពព្រះធម៌ ។ ការគោរពព្រះសង្ឃពីរជំពូក គឺសម្មតិសង្ឃ១ វិសុទ្ធិសង្ឃ ១ ដោយកិច្ចទាំងឡាយមានការថ្វាយបង្គំ និងការក្រោកទទួលជាដើម ហៅថា គោរពព្រះសង្ឃ ។ ការតាំងចិត្តសិក្សាសិល្បសាស្រ្តតាមផ្លូវលោកឬផ្លូវធម៌ ដោយយកចិត្តទុកដាក់មិនមានខ្ជិលច្រអូស ហៅថា គោរពការសិក្សារៀនសូត្រ។ ការតាំងសតិមានបរិបូណ៌ មិនឱ្យភ្លេចខ្លួនក្នុងការលះសេចក្តីអាក្រក់ ប្រព្រឹត្តសេចក្តីល្អ ឬប្រុងប្រយ័ត្នចិត្តមិនឱ្យក្រោធខឹងជាដើម ហៅថា គោរពសេចក្តីមិនប្រមាទ ។ ការគោរពអាមិសប្បដិសណ្ឋារៈ គឺការទទួលដោយអាមិសក្តី ធម្មប្បដិ-សណ្ឋារៈ គឺការទទួលដោយធម៌ក្តី ហៅថា គោរពបដិសណ្ឋារៈ ។

## សារាណីយធម៌ ៦ យ៉ាង

១-មេត្តាកាយកម្ម តាំងកាយកម្មប្រកបដោយមេត្តាចំពោះភិក្ខុសាមណេរផងគ្នា ទាំងចំពោះមុខនិងកំបាំងមុខ គឺ

ជួយខ្វល់ខ្វាយក្នុងកិច្ចការៈផងគ្នាដោយកាយ មានជួយព្យាបាលក្នុងវេលាមានរោគជាដើម ដោយមេត្តា;

**២-មេត្តាវចីកម្ម** តាំងវចីកម្មប្រកបដោយមេត្តា ចំពោះភិក្ខុសាមណេរផងគ្នា ទាំងទីចំពោះមុខនិងកំបាំងមុខ គឺជួយខ្វល់ខ្វាយក្នុងកិច្ចធុរៈផងគ្នា ដោយវាចាមានប្រដៅដាស់តឿនជាដើម ដោយមេត្តា;

**៣-មេត្តាមនោកម្ម** តាំងមនោកម្មប្រកបដោយមេត្តា ចំពោះភិក្ខុសាមណេរផងគ្នា ទាំងចំពោះមុខនិងកំបាំងមុខ គឺគិតតែរបស់ដែលជាប្រយោជន៍ឱ្យដល់គ្នា;

**៤-លាភៈ** ចែកលាភដែលខ្លួនបានមកហើយដោយធម៌ឱ្យភិក្ខុសាមណេរផងគ្នា មិនហួងហែងឬក្បិតក្បៀតលាក់លៀមទុកបរិភោគតែម្នាក់ឯង;

**៥-សីលៈ** រក្សាសីលបរិសុទ្ធិ៍ស្មើគ្នានឹងភិក្ខុសាមណេរដទៃ មិនធ្វើខ្លួនឱ្យជាទីរង្កៀស ព្រោះសីលរបស់ខ្លួន;

៦-ទិដ្ឋិ មានសេចក្តីយល់ឃើញរួមគ្នានឹងភិក្ខុសាមណេរដទៃ មិនវិវាទនឹងអ្នកណា ព្រោះហេតុមានសេចក្តីយល់ខុសគ្នានោះទេ ។

បុ. សារាណីយធម៌ ប្រែដូចម្តេច ?

វិ. ប្រែថា ធម៌ជាទីតាំងនៃកិរិយារលឹក គឺអ្នកដែលប្រតិបត្តិតាមធម៌ទាំងអម្បាលនេះ រមែងបានទទួលនូវអានិសង្ស គឺជាទីស្រឡាញ់របស់អ្នកដទៃ ជាទីគោរពរបស់អ្នកដទៃ ប្រព្រឹត្តទៅដើម្បីសង្គ្រោះដល់គ្នានិងគ្នា មិនវិវាទទាស់ទែងគ្នា សាមគ្គីធម៌រមែងកើតឡើងបាន ។

## អាយតនៈខាងក្នុង ៦ យ៉ាង

១-ចក្ខុ ភ្នែក;
២-សោតៈ ត្រចៀក;
៣-ឃានៈ ច្រមុះ;
៤-ជិវ្ហា អណ្តាត;
៥-កាយៈ ខ្លួនប្រាណ;
៦-មនោ ចិត្ត ។

បុ. អាយតនៈ ប្រែដូចម្តេច ?

វិ. ប្រែថា ធម្មជាតិជាទីមកត គឺតផល ដូចជារូបមកប៉ះភ្នែក រមែងកើតផលវិញ្ញាណឡើងជាដើម ។

បុ. អាយតនៈនេះ បើមិនហៅថាអាតយនៈទេ លោកហៅថាអ្វីទៅវិញ ? ព្រោះហេតុអ្វី ?

វិ. អាយតនៈនេះ មិនហៅថាអាយតនៈទេ លោកហៅថាឥន្ទ្រិយវិញ ព្រោះឥន្ទ្រិយប្រែថា ធម្មជាតិជាធំក្នុងការឃើញរូប, ជាធំក្នុងការស្ដាប់សម្លេងជាដើម ។

បុ. អាយតនៈទាំង ៦ នេះ បើបំព្រួញឱ្យខ្លីមកមានប៉ុន្មាន? អ្វីខ្លះ ?

វិ. បើបំព្រួញឱ្យខ្លីមកមាន ២ យ៉ាងគឺ កាយ ១, ចិត្ត ១, ឬបំព្រួញចូលក្នុងខន្ធទាំង ៥ ក៏បាន ដូចជាភ្នែក, ត្រចៀក, ច្រមុះ, អណ្ដាត, កាយ ជាចំណែករូប បំព្រួញចូលក្នុងរូប, ចិត្តបំព្រួញចុះក្នុងវិញ្ញាណ ។

## អាយតនៈខាងក្រៅ ៦ យ៉ាង

រូប ១, សម្លេង ១, ក្លិន ១, រស ១, ផោដ្ឋព្វៈ ១, ធម្មារម្មណ៍ ១ ។

បុ. ចូរអធិប្បាយអាយតនៈខាងក្រៅទាំង៦ នោះមកមើល?

វិ. អាយតនៈដែលជាខាងក្រៅទាំង ៦ យ៉ាងមានរូប សម្លេងជាដើមជាអារម្មណ៍ ដែលត្រាច់ចរមកពីខាងក្រៅ ឬ ហៅថាអារម្មណ៍ក៏បាន ព្រោះជាធម្មជាតិដែលបង្អោនទាញចិត្ត ឱ្យប្រព្រឹត្តទៅផ្សេងៗ តាមវិស័យរបស់ខ្លួន អារម្មណ៍ទាំង អម្បាលនេះ ជាគូនឹងអាយតនៈខាងក្នុងតែមួយៗ ដូចជារូបជា វិស័យខាងភ្នែក សម្លេងជាវិស័យខាងត្រចៀកជាដើម, អារម្មណ៍ទាំងអម្បាលនេះ ជាទីពេញចិត្តរបស់អាយតនៈខាង ក្នុងក្តី មិនជាទីពេញចិត្តក្តី ក៏សម្រេចហើយតែនឹងអារម្មណ៍ នោះល្អឬមិនល្អ បើល្អក៏ពេញចិត្ត បើមិនល្អក៏មិនពេញចិត្ត ដូច្នោះឯង ។

## វិញ្ញាណ ៦ យ៉ាង

១-រូប ប៉ះភ្នែក កើតសេចក្តីដឹងឡើង ហៅថា ចក្ខុវិញ្ញាណ;

២-សម្លេង ប៉ះត្រចៀក កើតសេចក្តីដឹងឡើង ហៅថា សោតវិញ្ញាណ;

៣-ក្លិន ប៉ះច្រមុះ កើតសេចក្តីដឹងឡើង ហៅថា ឃានវិញ្ញាណ;

៤-រស ប៉ះអណ្តាត កើតសេចក្តីដឹងឡើង ហៅថា ជីវ្ហាវិញ្ញាណ;

៥-ផោដ្ឋព្វៈ ប៉ះកាយ កើតសេចក្តីដឹងឡើងហៅថា កាយវិញ្ញាណ;

៦-ធម៌កើតចំពោះចិត្ត កើតសេចក្តីដឹងឡើង ហៅថា មនោវិញ្ញាណ ។

បុ. ចូរអធិប្បាយវិញ្ញាណទាំង ៦ នោះមកមើល?

វិ. សេចក្តីដឹងដែលកើតមកពីអាយតនៈខាងក្នុង វេលាដែលជួបប្រទះនឹងអាយតនៈខាងក្រៅ ដូចភ្នែកឃើញរូប ត្រចៀកស្តាប់សម្លេងជាដើម ហៅថាវិញ្ញាណ; មានឈ្មោះហៅតាមអាយតនៈខាងក្នុងថា ចក្ខុវិញ្ញាណជាដើម, វិញ្ញាណនេះជាសេចក្តីដឹងមុនដំបូង ថាជាសុខឬជាទុក្ខ ជាបុណ្យជាបាបនៅមិនទាន់បាន ព្រោះកើតត្រឹមតែសេចក្តីដឹងប៉ុណ្ណោះ បើជាសុខឬជាទុក្ខ ឬប្រព្រឹត្តទៅយ៉ាងណា ត្រូវមានឈ្មោះហៅបានយ៉ាងនោះតទៅទៀត ។

បុ. ផោដ្ឋព្វៈ ប្រែដូចម្តេច ?

វិ. ផោដ្ឋព្វៈ ប្រែថាការពាក់ត្រូវ ។

បុ. សម្ផស្ស ប្រែដូចម្តេច?

វិ. សម្ផស្ស ប្រែថាការពាល់ត្រូវ ។

បុ. ផោដ្ឋព្វៈ និងសម្ផស្ស ប្រែថាការពាល់ត្រូវដូចគ្នា តើសេចក្តីផ្សេងគ្នាដូចម្តេច? ចូរអធិប្បាយ !

វិ. ផោដ្ឋព្វៈ និង សម្ផស្ស សេចក្តីផ្សេងគ្នាដូច្នេះ ចំណែកផោដ្ឋព្វៈការពាល់ត្រូវតាមផ្លូវកាយ, សម្ផស្ស ការពាល់ត្រូវគ្រប់អាយតនៈទាំង ៦ ដូចន័យថា ចក្ខុសម្ផស្សជា, សោតសម្ផស្សជា ជាដើម សេចក្តីផ្សេងគ្នាដូចវិស្សជ្ជនាមកនេះ ។

## សម្ផស្ស ៦ យ៉ាង

អាយតនៈខាងក្នុងមានភ្នែកជាដើម អាយតនៈខាងក្រៅមានរូបជាដើម វិញ្ញាណមានចក្ខុវិញ្ញាណជាដើម ទាំង ៣ នេះហៅថាសម្ផស្ស មានឈ្មោះតាមអាយតនៈខាងក្នុង ៦ គឺៈ ចក្ខុ-

សម្ផស្ស, សោតសម្ផស្ស, ឃានសម្ផស្ស, ជីវ្ហាសម្ផស្ស, កាយសម្ផស្ស, មនោសម្ផស្ស ។

បុ. ចូរអធិប្បាយសម្ផស្សទាំង ៦ មកមើល ?

វិ. ផស្សៈ បានដល់សេចក្តីពាល់ត្រូវ ឬសេចក្តីជួបប្រទះគ្នានៃធម៌ទាំង ៣ ប្រការគឺៈ អាយតនៈខាងក្នុងមានភ្នែកជាដើម១ អាយតនៈខាងក្រៅមានរូបជាដើម ១ វិញ្ញាណមានចក្ខុវិញ្ញាណជាដើម ១ ការជួបប្រទះគ្នានៃធម៌ទាំង ៣ ប្រការនេះ ចាត់ជាអង្គសំខាន់ ព្រោះជាបច្ច័យឱ្យកើតសុខទុក្ខ និងមិនសុខមិនទុក្ខបាន ។ លោកប្រដៅឱ្យសង្រួមអាយតនៈខាងក្នុងនេះ ដើម្បីឱ្យមានសតិប្រយ័ត្ន មិនបណ្តោយឱ្យចិត្តរវើរវាយទៅតាមអារម្មណ៍នោះៗ ដែលជាហេតុឱ្យមានសេចក្តីវិនាសខូតខាតផ្សេងៗ ។

## វេទនា ៦ យ៉ាង

សម្ផស្សជាបច្ច័យឱ្យកើតវេទនា គឺជាសុខខ្លះ ជាទុក្ខខ្លះ មិនសុខមិនទុក្ខខ្លះ មានឈ្មោះហៅតាមអាយតនៈខាងក្នុង ៦ គឺៈ បើកើតផ្លូវភ្នែក ហៅថា ចក្ខុសម្ផស្សជាវេទនា, កើតផ្លូវ

ត្រចៀក ហៅថា សោតសម្ផស្សជាវេទនា, កើតផ្លូវច្រមុះ ហៅថា ឃានសម្ផស្សជាវេទនា, កើតផ្លូវអណ្តាត ហៅថា ជីវ្ហា-សម្ផស្សជាវេទនា, កើតផ្លូវចិត្តហៅថាមនោសម្ផស្សជាវេទនា។

បុ. ចូរអធិប្បាយវេទនាទាំង ៦ នោះមកមើល?

វិ. អាយតនៈខាងក្នុង ១, អាយតនៈខាងក្រៅ ១, វិញ្ញាណ ១, រួមធម៌ទាំង ៣ នេះ ហៅថា ផស្សៈ, ផស្សៈជាបច្ច័យឱ្យកើតវេទនា គឺសោយអារម្មណ៍ជាសុខខ្លះ ជាទុក្ខខ្លះ មិនមែនសុខខ្លះ មិនមែនទុក្ខខ្លះ តួយ៉ាងដូចជារូបមកប៉ះភ្នែក កើតសេចក្តីដឹងឡើង ហៅថា ចក្ខុវិញ្ញាណ, ធម៌ទាំង ៣ ប្រការគឺចក្ខុ ១, រូប ១, ចក្ខុវិញ្ញាណ ១ ហៅថា សម្ផស្សឱ្យកើតវេទនា បើរូបនោះល្អគួររីករាយត្រេកអរពេញចិត្ត ការចូលចិត្តពេញចិត្តនេះឯងជាសុខវេទនា; បើផ្ទុយគ្នា គឺមិនចូលចិត្ត មិនពេញចិត្តជាទុក្ខវេទនា, បើកណ្តាលៗ គឺព្រងើយកន្តើយមិនសោមនស្សមិនទោមនស្ស ជាឧបេក្ខាវេទនា ។

# ធាតុ ៦ យ៉ាង

**១-បឋវីធាតុ** ធាតុដី;

**២-អាបោធាតុ** ធាតុទឹក;

**៣-តេជោធាតុ** ធាតុភ្លើង;

**៤-វាយោធាតុ** ធាតុខ្យល់;

៥-អាកាសធាតុ ចន្លោះដែលមានក្នុងកាយ;

៦-វិញ្ញាណធាតុ សេចក្តីដឹងអ្វីៗបនា ។

បុ. ធាតុ ប្រែដូចម្តេច ?

វិ. ប្រែថា ការទ្រទ្រង់ ឬការតាំងនៅ ។

បុ. ចូរអធិប្បាយធាតុពីរខាងចុងនោះមកមើល ?

វិ. ចន្លោះដែលមានអាកាសតាំងនៅ ដូចជារន្ធត្រចៀក, រន្ធច្រមុះជាដើម ហៅថា អាកាសធាតុៗ នេះ ជាធាតុកំណត់បានដោយពិបាកណាស់ ព្រោះជារបស់ល្អិតសុខុម តែអាចដឹងបានដោយសារតែសម្ផស្ស ហៅថា អាកាសធាតុ ។

សេចក្តីដឹងអ្វីៗបាន ដែលកើតមកអំពីការជួបជុំនៃធាតុទាំង ៤ ហៅថា វិញ្ញាណធាតុ ។ បុគ្គលអ្នកឆ្លាតប្រសប់ក្នុង

ធាតុខាងក្រៅ ដូចជាចេះនាំយកពួកធាតុផ្សេងៗ មកផ្សំគ្នា ឱ្យកើតជាភ្លើងអគ្គិសនី, វិទ្យុ, ទូរលេខ ទូរស័ព្ទជាដើម រមែងញុំាងឥដ្ឋផលឱ្យសម្រេចជាច្រើនក្រៃលែងឥតគណនាបាន ។

ចំណែកបុគ្គលដែលជាអ្នកឆ្លាតប្រសប់ ក្នុងធាតុខាងក្នុងកំណត់ដឹងតាមសភាវៈពិត រមែងបានទទួលផលដ៏ខ្ពង់ខ្ពស់ គឺលោកុត្តរធម៌បាន ។

ចប់ឆក្កៈពួក ៦

---

# សត្តកៈពួក ៧

## អបរិហានីយធម៌

បុ. អបរិហានីយធម៌ ប្រែដូចម្តេច ?

វិ. ប្រែថា ធម៌មិនជាតាំងនៃសេចក្តីសាបសូន្យ គឺប្រព្រឹត្តទៅដើម្បីសេចក្តីចម្រើន ហៅថា ‹‹អបរិហានីយធម៌›› ។

បុ. ចុះអបរិហានីយធម៌នោះមានប៉ុន្មានយ៉ាង ?

វិ. មាន ៧ យ៉ាង ។

បុ. មាន ៧ យ៉ាងនោះគឺអ្វីខ្លះ? ចូររាប់និងអធិប្បាយឱ្យសព្វគ្រប់មកមើល ?

វិ. មាន ៧ យ៉ាងនោះគឺៈ

១-ឧស្សាហ៍ប្រជុំគ្នារឿយៗ;

២-កាលប្រជុំគ្នាក៏ព្រមព្រៀងគ្នាប្រជុំ កាលលើកលែងប្រជុំក៏ព្រមព្រៀងគ្នាលើក ទាំងព្រមព្រៀងគ្នាជួយធ្វើករណីយ-កិច្ចដែលសង្ឃត្រូវធ្វើផង;

៣-វត្តប្រតិបត្តិណាដែលព្រះពុទ្ធមិនទាន់បញ្ញត្តទុក មិនបញ្ញត្តឡើង ទាំងមិនបានដកវត្តប្រតិបត្តិដែលទ្រង់អនុញ្ញាតទុកហើយ សមាទានសិក្សាតាមសិក្ខាបទដែលទ្រង់បញ្ញត្តទុកហើយនោះៗ;

៤-ភិក្ខុណាជាធំ ជាប្រធានក្នុងសង្ឃ គោរពរាប់អានភិក្ខុនោះ ជឿ ស្តាប់ពាក្យរបស់លោក;

៥-មិនលុះទៅតាមអំណាចចំណង់ដែលកើតឡើង;

៦-ត្រេកអរក្នុងសេនាសនៈស្ងាត់;

៧-តាំងចិត្តគិតថា សព្រហ្មចារី គឺភិក្ខុសាមណេរជាអ្នកមានសីលមិនទាន់មកកាន់អាវាសនេះ សូមឱ្យមក, ដែលមកហើយ សូមឱ្យនៅជាសុខសប្បាយ ។

ធម៌ ៧ យ៉ាងនេះ កាលបើបានតាំងនៅក្នុងសន្តានបុគ្គលណា បុគ្គលនោះមិនមានសេចក្តីសាបសូន្យឡើង មានតែសេចក្តីចម្រើនតែម៉្យាងប៉ុណ្ណោះ ។

## អធិប្បាយថា

ធម៌ទាំង ៧ ប្រការនេះ ព្រះមានព្រះភាគទ្រង់សំដែងដល់ពួកក្សត្រលិច្ឆវីក្នុងក្រុងវេសាលី និងទ្រង់សម្តែងដល់ភិក្ខុជាបរិស័ទ គ្រាដែលព្រះអង្គគង់ក្នុងក្រុងរាជគ្រឹះ រួមសេចក្តីថា ធម៌ទាំងអម្បាលនេះ សូម្បីគ្រហស្ថនិងបព្វជិត បើប្រព្រឹត្តឱ្យសមគួរដល់ភេទនិងកាលៈទេសៈ បានដូចគ្នាទាំងអស់ ។

ការឧស្សាហ៍ប្រជុំគ្នាជានិច្ច ជាការចងមេត្រីចិត្តឱ្យស្និទ្ធ-ស្នាល ជាគ្រឿងតោងទាញទឹកចិត្តដល់គ្នានិងគ្នា, ដើម្បីនឹងប្រឹក្សាគ្នាក្នុងកិច្ចការដែលគួរធ្វើ ជាឧបាយផ្លាស់ប្តូរសេចក្តីចេះដឹងដល់គ្នានិងគ្នា, កាលប្រជុំក៏ព្រមព្រៀងគ្នាប្រជុំ, កាលឈប់ក៏ព្រមព្រៀងគ្នាឈប់ ហើយព្រមព្រៀងគ្នាជួយដល់កិច្ចដែល

សមគ្គរ ដើម្បីឱ្យសម្រេចទៅតាមលំដាប់, មិនបញ្ញត្តខ្លួនឯង នឹងមិនដកកាត់សិក្ខាបទ ដែលព្រះអង្គទ្រង់បញ្ញត្តទុកហើយ, សមាទានសិក្សាក្នុងសិក្ខាបទដោយគោរព, វៀរលែងតែបទណាដែលព្រះអង្គទ្រង់ហាម ធ្វើតាមបទដែលទ្រង់អនុញ្ញាត ជឿ ស្តាប់ពាក្យប្រៀនប្រដៅរបស់លោក ដែលជាធំជាប្រធាន, សង្កត់សង្កិនតណ្ហា (សេចក្តីចង់បាន) ដែលកើតឡើងដោយទមរិធីនិងសញ្ញមវិធី, ត្រេកអរក្នុងសេនាសនៈព្រៃ មិនច្របូកច្របល់ដោយពួកគណៈ តាំងចិត្តឱ្យភិក្ខុសាមណេរដែលជាអ្នកមានសីលមកកាន់អាវាស កាលមកហើយសូមឱ្យនៅជាសុខសប្បាយ ។

អ្នកណាតាំងនៅក្នុងធម៌ទាំង ៧ ប្រការនេះបាន, អ្នកនោះរមែងមានសេចក្តីចម្រើនតែម៉្យាង មិនមានសេចក្តីសាបសូន្យឡើយ ។

## អរិយធន

បុ. អរិយធន ប្រែដូចម្តេច ?

វិ. ប្រែថា ទ្រព្យរបស់អរិយបុគ្គល ។

បុ. អរិយៈ មានប្រែដូចម្តេចទៀតដែរឬ ?

វិ. ប្រែថា សត្រូវ, បុគ្គលណាកំចាត់បង់នូវសត្រូវបាន បុគ្គលនោះឈ្មោះថា ‹‹អរិយៈ›› ព្រោះលោកកំចាត់បង់នូវសត្រូវបាន ។

បុ. ចុះន័យខ្លះ ប្រែថា ‹‹ប្រសើរ›› មិនខុសទៅហើយឬ?

វិ. ប្រែថា ‹‹ប្រសើរ›› នោះមិនខុសទេ, តែប្រសើរលើរូបបុគ្គលអ្នកកំចាត់បង់នូវកិលេស; កុំប្រែថា ‹‹អរិយៈ›› ថា ‹‹ប្រសើរ›› លើឈ្មោះធម៌នោះមិនត្រូវទេ, តួយ៉ាងដូចអរិយសច្ច ៤ គឺ និរោធសច្ច មគ្គសច្ច គួរថាប្រសើរចុះ ព្រោះជាតួកុសល, ដូចយ៉ាងទុក្ខសច្ច និងសមុទយសច្ច ប្រែថាប្រសើរដូចម្ដេចបាន? ព្រោះជាអកុសល, អរិយ មិនមែនជាគុណរបស់សច្ចនោះទេ, ជាគុណរបស់អ្នកកំចាត់បង់នូវកិលេស ។

បុ. ចុះ ធនៈ ប្រែថា ‹‹ទ្រព្យ›› ភោគៈ ក៏ប្រែថា ‹‹ទ្រព្យ›› បើយ៉ាងហ្នឹង តើទ្រព្យទាំងពីរនោះ មានសេចក្ដីផ្សេងគ្នាដូចម្ដេច? ចូរអធិប្បាយមកមើល !

វិ. ធនៈ ប្រែថា ‹‹ទ្រព្យ›› បានដល់មាសប្រាក់កែវកងដែលគេសម្រាប់ចាយ, គោគៈ ទ្រព្យសម្រាប់ប្រើប្រាស់បានដល់គោ, ក្របីនិងគ្រឿងស្លៀកពាក់ជាដើម ។

បុ. ទ្រព្យនិងសម្បត្តិមានសេចក្ដីផ្សេងគ្នាដូចម្ដេច ?

វិ. ទ្រព្យសំដៅយកទ្រព្យបច្ចុប្បន្ន ដូចមានប្រាក់កែវកង និងស្រែចំការជាដើម, សម្បត្តិសំដៅយកសម្បត្តិបច្ចុប្បន្ន និងសម្បត្តិបរលោក ។

បុ. អរិយធនៈ មានប៉ុន្មានយ៉ាង? អ្វីខ្លះ? ចូររាប់ !

វិ. មាន ៧ យ៉ាងគឺៈ

**១-សទ្ធាធនំ** ទ្រព្យគឺសទ្ធា;

**២-សីលធនំ** ទ្រព្យគឺសីល;

**៣-ហិរិធនំ** ទ្រព្យគឺសេចក្ដីខ្មាសបាប;

**៤-ឱត្តប្បធនំ** ទ្រព្យគឺសេចក្ដីខ្លាចអំពើបាប;

**៥-សុតធនំ** ទ្រព្យគឺការបានឮ-ស្ដាប់ច្រើន;

**៦-ចាគធនំ** ទ្រព្យគឺការលះបង់;

**៧-បញ្ញាធនំ** ទ្រព្យគឺបញ្ញា ។

បុ. ចូរអធិប្បាយអរិយធនៈទាំង ៧ ឱ្យពិស្ដារមកមើល ?

វិ. អធិប្បាយថាៈ សទ្ធា ប្រែថា សេចក្ដីជឿ ។ នោះមានពីរយ៉ាងគឺជឿដោយបានត្រិះរិះពិចារណាហេតុផល ដោយជាក់ច្បាស់ពិតប្រាកដ ហៅថា សទ្ធាញាណសម្បយុត្ត ១, ជឿ

ដោយមិនបានត្រិះរិះពិចារណាហេតុផល ហៅថា សទ្ធា-ញាណវិប្បយុត្ត ១ សទ្ធាដែលជាអរិយទ្រព្យសំដៅយកសទ្ធាដែលជាញាណសម្បយុត្ត មានសេចក្ដីបរិសុទ្ធជាទីតាំង ។

សីលមានពីរយ៉ាងគឺ អាគារិយសីល សីលរបស់គ្រហស្ថ ១, អនាគារិយសីល សីលរបស់បព្វជិត ១; សីល ៥ សីល ៨ និងកម្មបថ ១០ ហៅថា អាគារិយសីល, ចតុប្បារិសុទ្ធិសីល ហៅថា អនាគារិយសីល ។

ហិរិ និង ឱត្តប្បៈ គប្បីមើលក្នុងពួកទុកៈ ។ ពាហុសច្ចៈ គប្បីមើលក្នុងពួក វេសារជ្ជករណធម៌ ។

ចាគៈ បានដល់ការលះវត្ថុជារបស់ខ្លួន ឱ្យដល់មនុស្សដែលគួរឱ្យ ដើម្បីកំចាត់បង់លោភៈនិងមច្ឆរិយៈ ។

បញ្ញាមានពីរយ៉ាងគឺៈ លោកិយប្បញ្ញា បញ្ញារបស់បុថុជ្ជន ១ លោកុត្តរប្បញ្ញា បញ្ញារបស់ព្រះអរិយៈ ១; ផ្លូវដែលនាំឱ្យកើតបញ្ញាមាន ៣ ប្រការគឺ ការស្ដាប់ ហៅថា សុតៈ ១, ការគិតហៅថា ចិន្តៈ ១, ការអប់រំ ហៅថា ភាវនា ១ ។

អរិយទ្រព្យបានដល់គុណនៃសេចក្ដីល្អ ដែលមានក្នុងសន្ដាន មិនវិនាសទៅដោយអន្តរាយណាមួយ ដូចជាអ្នកដែល

ជួយឧបត្ថម្ភគាំទ្រនៅក្នុងទីតបន់ទាំងពួង ទើបលោកពោថាល្អជាងទ្រព្យខាងក្រៅ មានមាសប្រាក់ជាដើម ។

ហេតុនេះ សាធុជនទាំងឡាយ គួរតែស្វែងរកឱ្យមានក្នុងសន្តានកុំខាន ។

## សេចក្តីប្រៀបធៀប

ទ្រព្យសម្បត្តិក្នុងលោកនេះ បើអ្នកណាបរិបូណ៌មិនខ្វះខាត តែងមានសេចក្តីសុខក្នុងបច្ចុប្បន្ននេះ, មនុស្សដែលក្រក្សត់ទ្រព្យសម្បត្តិក្នុងបច្ចុប្បន្ននេះ តែងបានសេចក្តីទុក្ខលំបាកយ៉ាងណា, ចំណែកអ្នកដែលមានអរិយទ្រព្យនិងមិនមានអរិយទ្រព្យ ឱ្យសេចក្តីសុខទុក្ខទៅបរលោកក៏ដូច្នេះដែរ ។

# សប្បុរិសធម៌

បុ. សប្បុរិសធម៌ ប្រែដូចម្តេច ?

វិ. ប្រែថា ធម៌របស់សប្បុរស ។

បុ. បុរិសៈ ក្នុងន័យដទៃច្រើនប្រែថា មនុស្សប្រុស, ចុះក្នុងទីនេះបានដល់មនុស្សណា ?

វិ. ក្នុងសប្បុរិសធម៌នេះ បានសេចក្តីទូទៅទាំងប្រុសទាំងស្រី, ជនណារម្ងាប់នូវបាបធម៌បាន ជននោះឈ្មោះថា ‹‹សប្បុរស›› ទាំងអស់ មិនថាប្រុស មិនថាស្រី ដូចពុទ្ធភាសិតសំដែងថា:

ហិរិឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា

សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេ ។

សប្បុរសទាំងឡាយ មានចិត្តស្ងប់រម្ងាប់ហើយ ប្រកបព្រមហើយដោយហិរិនិងឱត្តប្បៈ មានចិត្តដំកល់មាំក្នុងធម៌ស អ្នកប្រាជ្ញទាំងឡាយលោកពោលថា ‹‹ទេវធម៌›› ក្នុងលោក ។

បុ. សប្បុរិសធម៌មានប៉ុន្មានយ៉ាង ?

វិ. មាន ៧ យ៉ាង គឺ:

១-ធម្មញ្ញុតា ភាពជាអ្នកស្គាល់ហេតុ ដូចស្គាល់ថា សមុទយជាហេតុឱ្យកើតសេចក្តីទុក្ខទាំង ១២ កង, មគ្គសច្ចជាហេតុឱ្យកើតសេចក្តីសុខគឺព្រះនិព្វាន;

២-អត្ថញ្ញុតា ភាពជាអ្នកស្គាល់ផល ដូចស្គាល់ថា ទុក្ខសច្ច ជាផលរបស់សមុទយសច្ច និរោធសច្ច ជាផលរបស់មគ្គសច្ច ជាដើម;

៣-អត្តញ្ញុតា ភាពជាអ្នកស្គាល់ខ្លួន ថាអាត្មាអញនេះ មានជាតិត្រកូលយសស័ក្តិសម្បត្តិបរិវារ សេចក្តីចេះដឹងនិងគុណធម៌ដែលមានក្នុងខ្លួនតែប៉ុណ្ណោះ ហើយប្រព្រឹត្តខ្លួនឱ្យគួរដល់ឋានៈរបស់ខ្លួន មិនមានការឆ្មើងឆ្មៃ ឬច្រឡើសបើសហួសហេតុ;

៤-មត្តញ្ញុតា ភាពជាអ្នកស្គាល់ប្រមាណក្នុងការស្វែងរកគ្រឿងចិញ្ចឹមជីវិតដោយផ្លូវប្រពៃ និងស្គាល់ប្រមាណក្នុងការបរិភោគជាដើម;

៥-កាលញ្ញុតា ភាពជាអ្នកស្គាល់កាលវេលាដែលគួរនឹងប្រកបកិច្ចការនោះៗ ឱ្យទាន់ពេលវេលា;

៦-បរិសញ្ញុតា ភាពជាអ្នកស្គាល់បរិស័ទក្នុងទីប្រជុំជន និងកិរិយាដែលត្រូវប្រព្រឹត្តក្នុងទីប្រជុំនោះថា ជនពួកនេះ កាល

អាត្មាអញចូលទៅរកត្រូវធ្វើកិរិយាយ៉ាងនេះៗ ត្រូវធ្វើកិរិយាយ៉ាងនោះៗ ជាដើម;

៧-បុគ្គលបរោបរញ្ញុតា ភាពជាអ្នកស្គាល់បុគ្គល ដូចស្គាល់ថា អ្នកនេះជាមនុស្សល្អគួរសេពគប់, អ្នកនេះជាមនុស្សមិនល្អ មិនគួរសេពគប់ជាដើម ។

# ពោជ្ឈង្គ

បុ. ពោជ្ឈង្គ ប្រែដូចម្ដេច ?

វិ. ប្រែថា អង្គនៃបញ្ញាជាគ្រឿងត្រាស់ដឹង ។

បុ. ចុះអង្គនៃបញ្ញាជាគ្រឿងត្រាស់ដឹងនោះមានប៉ុន្មាន?

វិ. មាន ៧ យ៉ាង ។

បុ. មាន ៧ យ៉ាងនោះតើអ្វីខ្លះ? ចូររាប់និងអធិប្បាយមកមើល !

វិ. មាន ៧ យ៉ាងនោះគឺ:

**១-សតិ** សេចក្ដីរលឹក;

**២-ធម្មវិចយៈ** សេចក្ដីពិចារណាធម៌;

**៣-វីរិយៈ** សេចក្តីព្យាយាម;

**៤-បីតិ** សេចក្តីឆ្អែតចិត្ត;

**៥-បស្សទ្ធិ** សេចក្តីស្ងប់ចិត្តនិងអារម្មណ៍;

**៦-សមាធិ** សេចក្តីតាំងចិត្តខ្ជាប់;

**៧-ឧបេក្ខា** ចិត្តព្រងើយកន្តើយ ។

បើហៅតាមប្រភេទថា សតិសម្ពោជ្ឈង្គៈ ទៅដោយលំដាប់ដល់ឧបេក្ខាសម្ពោជ្ឈង្គៈ ។

## អធិប្បាយ

កាលបើបុគ្គលបានប្រកបដោយធម៌ទាំង ៧ ប្រការនេះត្រឹមត្រូវហើយ ធម៌នេះនឹងឧបត្ថម្ភទំនុងបម្រុងដល់គ្នានិងគ្នាឱ្យសម្រេចគុណប្រយោជន៍ដ៏ធំក្រៃលែង ដូចជាមានសតិបរិបូណ៌ ហើយអាចនឹងតាំងមុខបំពេញព្យាយាម បើកាយចិត្តទោរទន់ ក៏ថែមកម្លាំងឱ្យដោយបីតិ បើកម្រើកលើសហួសប្រមាណទៅ ក៏ត្រូវកាត់កម្លាំងដោយសប្បទ្ធិ ឱ្យគង់នៅតែល្មមល្អ មិនបាច់ស្ទួយឡើងឬសង្កត់ចុះ ជាចំណែកសមាធិហើយត្រូវសម្លឹងមើលដោយឧបេក្ខា ។

ចប់សត្តកៈពួក ៧

# អដ្ឋកៈពួក ៨

## លោកធម៌

បុ. លោកធម៌ ប្រែដូចម្ដេច ?

វិ. ប្រែថា ធម៌គ្រប់សង្កត់សត្វលោក ឬថាសត្វលោកប្រព្រឹត្តទៅតាមធម៌នោះ ហៅថា ‹‹លោកធម៌›› ។

បុ. ចុះលោកធម៌មានប៉ុន្មានយ៉ាង ?

វិ. មាន ៨ យ៉ាង ។

បុ. មាន ៨ យ៉ាងនោះគឺអ្វីខ្លះ? ចូររាប់មកមើល !

វិ. មាន ៨ យ៉ាងនោះគឺៈ

**១-លាភោ** ការមានលាភ;

**២-អលាភោ** ការមិនមានលាភ;

**៣-យសោ** ការមានយស;

**៤-អយសោ** ការមិនមានយស;

**៥-និន្ទា** ការតិះដៀល ឬបន្ទុះបង្អាប់;

**៦-បសំសា** ការសរសើរ;

**៧-សុខំ** សេចក្ដីសុខ;

**៨-ទុក្ខំ** សេចក្ដីទុក្ខ ។

បុ. ព្រះអង្គទ្រង់សម្ដែងអំពីបុញ្ញកិរិយាវត្ថុជាហេតុឱ្យកើតលាភមានយស មានគេសរសើរនិងឱ្យកើតសេចក្ដីសុខ, ចុះហេតុអ្វីបានជាចាត់ជាលោកធម៌ទៅវិញ? ចូរអធិប្បាយអំពីលោកធម៌ទាំង ៨ ឱ្យសព្វគ្រប់មកមើល !

វិ. បានជាចាត់ជាលោកធម៌នោះ ព្រោះសត្វលោកកាលណាបើមានលាភកើតឡើងច្រើន ចិត្តនោះក៏ប៉ោងឡើងខុសប្រក្រតី, កាលបើខាងលាភចិត្តនោះក៏ថយចុះ, សមដូចពុទ្ធភាសិតសំដែងថា:

លាភេន ឧន្នតោ, អលាភេន ឱនតោ កាលបើមានលាភចិត្តនោះក៏ភ្លើតភ្លើនហ៊ឺហារមើលងាយគេឯង ដោយអាងខ្លួនមានបុណ្យស័ក្តិ សូម្បីតែញាតិរបស់ខ្លួនក៏មើលងាយដែរ កាលបើខូចបុណ្យស័ក្តិ ចិត្តនោះក៏ជ្រុបចុះសុបសៅអៀនខ្មាសគេ, កាលបើគេត្មះតិះដៀល ចិត្តនោះក៏ខាងនឹងពាក្យដំណិះដំណៀលនោះ កាលបើគេសរសើរ ចិត្តនោះក៏ជោរឡើង, កាលបើសេចក្ដីសុខកើតឡើង ក៏ភ្លេចទុក្ខអស់, កាលណាបើទុក្ខកើតឡើង ក៏កើតសេចក្ដីសោយសោក ។

បុ. ចុះលោកធម៌ទាំង ៨ ប្រការនេះ កើតឡើងហើយត្រូវពិចារណាដូចម្ដេចខ្លះ? ចូរតបមកមើល!

វិ. លោកធម៌ទាំង ៨ ប្រការនេះ ណានីមួយកើតឡើងហើយ គួរពិចារណាថាៈ របស់នេះកើតឡើងដល់អាត្មាអញហើយ តែថាជារបស់មិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរឱ្យដឹងពិតតាមធម្មតា កុំឱ្យមកគ្របសង្កត់ចិត្តរបស់យើងបាន គឺកុំត្រេកអរក្នុងអារម្មណ៍ដែលជាទីប្រាថ្នា កុំទោមនស្សក្នុងអារម្មណ៍ដែលជាទីមិនប្រាថ្នា ។

បុ. លោកធម៌ទាំង ៨ នេះ បើបំព្រួញឱ្យខ្លីចុះមកមានប៉ុន្មាន?

វិ. បើបំព្រួញឱ្យខ្លីចុះមកមានពីរយ៉ាង ។

បុ. ពីរនោះគឺអ្វីខ្លះ?

វិ. ពីរយ៉ាងនោះគឺៈ ឥដ្ឋារម្មណ៍ ១, អនិដ្ឋារម្មណ៍ ១ ។

បុ. ចុះលោកធម៌ណាចាត់ចូលក្នុងឥដ្ឋារម្មណ៍? ណាចាត់ចូលក្នុងអនិដ្ឋារម្មណ៍?

វិ. លាភ, យស, បសំសៈ, សុខ ចាត់ចូលក្នុងឥដ្ឋារម្មណ៍ ប្រែថា អារម្មណ៍ជាទីប្រាថ្នា; អលោភ, អយស, និន្ទា, ទុក្ខ ចាត់ចូលក្នុងអនិដ្ឋារម្មណ៍ ប្រែថា អារម្មណ៍មិនជាទីប្រាថ្នា ។

អធិប្បាយ

មនុស្សយើងគ្រប់គ្នារួមទាំងព្រះអរិយៈផង ក៏ត្រូវជួបប្រទះលោកធម៌នេះដូចគ្នា, បើបុថុជ្ជនដែលដឹងតាមសេចក្តីពិតលោកធម៌ក៏គ្រប់សង្កត់ចិត្តមិនសូវបាន, ចំណែកព្រះអរិយៈលោកមិនញាប់ញ័រដោយលោកធម៌ ដូចជាភ្នំជាវិការៈនៃថ្មតាន់រមែងមិនញាប់ញ័រដោយខ្យល់ដូច្នោះ ។

## លក្ខណៈវិនិច្ឆ័យធម៌វិន័យ

បុ. ព្រះធម៌ព្រះវិន័យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលឱ្យដឹងថា ធម៌ពិត វិន័យពិតនោះ អាស្រ័យនឹងធម៌ណាយកមកវិនិច្ឆ័យឱ្យដឹងថា នេះជាធម៌ពិត នេះជាធម៌មិនពិតទៅបាន? ឧបមាដូចជាមុខប្រទ្បាក់វត្ថុសខ្មៅ, មានកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងឱ្យឃើញស្នាមប្រទ្បាក់ត្រង់នេះ ត្រង់នោះទៅបាន ចុះចំណែកធម៌វិន័យ មានធម៌ណាសម្រាប់ឆ្លុះបញ្ចាំងឱ្យដឹងខុស

ត្រូវដែរឬទេ? បើមានតើមានប៉ុន្មាន? ចូររាប់ឱ្យសព្វគ្រប់មកមើល!

វិ. មាន, ហៅថា លក្ខណៈវិនិច្ឆ័យធម៌វិន័យ ៨ យ៉ាងគឺៈ

១-ធម៌ណាប្រព្រឹត្តទៅដើម្បីសេចក្ដីតម្រេក;

២-ធម៌ណាប្រព្រឹត្តទៅដើម្បីសេចក្ដីទុក្ខ;

៣-ធម៌ណាប្រព្រឹត្តទៅសន្សំកងកិលេស;

៤-ធម៌ណាប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាធំ;

៥-ធម៌ណាប្រព្រឹត្តទៅដើម្បីមិនសន្ដោស ដោយរបស់ដែលមាននៅ គឺមានរបស់នេះហើយ ចង់បានរបស់នោះទៀតមិនចេះល្មម;

៦-ធម៌ណាប្រព្រឹត្តទៅដើម្បីច្រឡូកច្រឡំដោយពួកគណៈ

៧-ធម៌ណាប្រព្រឹត្តដើម្បីខ្ជិលច្រអូស;

៨-ធម៌ណាប្រព្រឹត្តទៅដើម្បីចិញ្ចឹមក្រ ។

ធម៌ទាំងអម្បាលនេះ គប្បីដឹងថា មិនមែនជាធម៌ មិនមែនជាវិន័យ មិនមែនជាសាសនា, ពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដាឡើយ ។

ធម៌ណាប្រព្រឹត្តខុសគ្នានឹងលក្ខណៈ ៨ ប្រការ ដូចពោលមកហើយគឺៈ

១-ធម៌ណាប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក;

២-ប្រព្រឹត្តទៅដើម្បីប្រាសចាកទុក្ខ;

៣-ប្រព្រឹត្តទៅដើម្បីមិនសន្សំកងកិលេស;

៤-ប្រព្រឹត្តទៅដើម្បីប្រាថ្នាតិច;

៥-ប្រព្រឹត្តទៅដើម្បីសេចក្តីត្រេកអរ ដោយរបស់ដែលមាននៅ;

៦-ប្រព្រឹត្តទៅដើម្បីស្ងាត់ចាកពួកគណៈ;

៧-ប្រព្រឹត្តទៅដើម្បីតាំងសេចក្តីព្យាយាម;

៨-ប្រព្រឹត្តទៅដើម្បីគេចិញ្ចឹមងាយ ។

ធម៌ទាំងអម្បាលនេះ គប្បីដឹងថា ជាធម៌ ជាវិន័យ ជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ។

ព្រះឱវាទានុសាសនី របស់ព្រះអរហំសម្មាសម្ពុទ្ធជាម្ចាស់មានច្រើនជាអនេកប្បការ តែគង់រួមមកហៅថា ធម៌និងវិន័យ, ព្រះពុទ្ធសាសនាកន្លងមកយូរយារហើយ រមែងមានធម៌វិន័យប្លមចូលមកជ្រៀតជ្រែកនៅក្នុងពាក្យប្រៀនប្រដៅ របស់

ព្រះអង្គផងមិនខាន, កាលដែលព្រះអង្គសំដែងលក្ខណៈវិនិច្ឆ័យធម៌វិន័យទុក ក៏ដោយសារតែព្រះអង្គមានពុទ្ធបំណងចង់ឱ្យអ្នកប្រតិបត្តិប្រកាន់ទុកជាលក្ខណៈ ជាគោលនៃការបំពេញវត្តប្រតិបត្តិ ទើបនឹងបានសម្រេចផលដែលខ្លួនប្រាថ្នា បើមិនដូច្នោះទេ អ្នកប្រតិបត្តិនោះ អាចនឹងប្រតិបត្តិវង្វេងក្នុងផ្លូវខុស មានផលជាទុក្ខ ខុសចាកសេចក្តីបំណងដើមមិនខាន, បានជាព្រះអង្គទ្រង់សំដែងហេតុទាំង ៨ នេះទុកមក ។

## មគ្គមានអង្គ ៨

**១-សម្មាទិដ្ឋិ** បញ្ញាឃើញប្រពៃគឺឃើញអរិសច្ច ៤;

**២-សម្មាសង្កប្បៈ** ការត្រិះរិះប្រពៃ គឺត្រិះរិះដើម្បីនឹងចេញចាកកាម ១, ត្រិះរិះក្នុងការមិនព្យាបាទ ១, ត្រិះរិះក្នុងការមិនបៀតបៀន ១;

**៣-សម្មាវាចា** វាចាប្រពៃ គឺវៀរចាកវចីទុច្ចរិត ៤;

**៤-សម្មាកម្មន្តៈ** ធ្វើការងារប្រពៃ គឺវៀរចាកទុច្ចរិត ៣;

**៥-សម្មាអាជីវៈ** ការចិញ្ចឹមជីវិតប្រពៃ គឺវៀរចាកការចិញ្ចឹមជីវិតក្នុងផ្លូវខុសៈ

**៦-សម្មាវាយាមៈ** ការព្យាយាមប្រពៃ គឺព្យាយាមក្នុងទី ៤ ស្ថាន;

**៧-សម្មាសតិ** ការរលឹកប្រពៃ គឺរឭកក្នុងសតិប្បដ្ឋាន ៤;

**៨-សម្មាសមាធិ** ការតាំងចិត្តប្រពៃ គឺចំរើនឈានទាំង៤។

បុ. អដ្ឋង្គិកមគ្គទាំង ៨ នេះ បើចាត់ចូលក្នុងកម្មទាំងបី តើអង្គណាចូលក្នុងកម្មណា ?

វិ. សម្មាកម្មន្តៈ, សម្មាអាជីវៈ ទាំងពីរនេះចាត់ចូលក្នុងកាយកម្ម; សម្មាវាចា ចាត់ចូលក្នុងវចីកម្ម, សម្មាទិដ្ឋិ, សម្មា-សង្កប្បៈ, សម្មាវាយាមៈ, សម្មាសតិ, សម្មាសមាធិ ទាំង ៥ នេះចាត់ចូលក្នុងមនោកម្ម ។

បុ. អដ្ឋង្គិកមគ្គទាំង៨ នេះ បើចាត់ចូលក្នុងវិជ្ជា និងចរណៈ តើអង្គណាចាត់ចូលក្នុងវិជ្ជា? អង្គណាចាត់ចូលក្នុងចរណៈ?

វិ. សម្មាទិដ្ឋិ, សម្មាសង្កប្បៈ ចាត់ចូលក្នុងវិជ្ជា; សម្មាវាចា, សម្មាកម្មន្តៈ, សម្មាអាជីវៈ, សម្មាវាយាមៈ, សម្មាសតិ, សម្មា-សមាធិ ទាំង ៦ នេះ ចាត់ចូលក្នុងចរណៈ ។

បុ. ចុះបើចាត់ចូលក្នុងខន្ធទាំង ៣ វិញ តើអង្គណាចាត់ចូលក្នុងខន្ធណា? ចូរបរិយាយ!

វិ. សម្មាវាចា, សម្មាកម្មន្តៈ, សម្មាអាជីវៈ ទាំង ៣ នេះចាត់ចូលក្នុងសីលក្ខន្ធ; សម្មាវាយាមៈ, សម្មាសតិ, សម្មាសមាធិ ទាំង ៣ នេះចាត់ចូលក្នុងសមាធិក្ខន្ធ; សម្មាទិដ្ឋិ, សម្មាសង្កប្បៈ ទាំង ២ នេះចាត់ចូលក្នុងបញ្ញាខន្ធ ។

បើចាត់ចូលក្នុងត្រៃសិក្ខាវិញ ក៏ដូចខន្ធទាំង ៣ នេះដែរ ។

បុ. ចុះ មគ្គ ប្រែដូចម្ដេចទៅ?

វិ. ប្រែថា ផ្លូវ ។

បុ. ផ្លូវនោះដូចម្ដេច? ចូរអធិប្បាយ!

វិ. ផ្លូវដែលបុគ្គលនឹងធ្វើដំណើរដោយវិថីចត្ត ក្នុងការប្រតបត្តិធម៌ ដើម្បីដល់នូវទីបំផុតនៃទុក្ខ គឺព្រះនិព្វាន ។

បុ. មគ្គៈ ប្រែបានតែប៉ុណ្ណឹង ឬមានប្រែទៅទៀតដែរ? ចូរមកមើល !

វិ. មានប្រែតទៅទៀត, ដូចបទវិគ្រោះថាៈ កិលេសេ មារេតី,តិ មគ្គោ ប្រែថា សភាវៈណាសម្លាប់នូវកិលេសទាំង-ឡាយ សភាវៈនោះឈ្មោះថា ‹‹មគ្គ›› បានដល់មគ្គទាំង ៤ មានសោតាបត្តិមគ្គជាដើម ។

ចប់អដ្ឋកៈពួក ៨

# នវកៈពួក ៩

## មលៈ ៩ យ៉ាង

**១-កោធៈ** សេចក្ដីក្រោធ;

**២-មក្ខៈ** លុបគុណគេ;

**៣-ឥស្សា** ឫស្យាគេ, ច្រណែនគេ;

**៤-មច្ឆរិយៈ** សេចក្ដីកំណាញ់;

**៥-មាយា** បិទទោសទុក;

**៦-សាថេយ្យៈ** អួតអំនួត;

**៧-មុសា** និយាយកុហក;

**៨-មិច្ឆាទិដ្ឋិ** យល់ឃើញខុស ។

បុ. មលៈ ប្រែដូចម្ដេច ?

វិ. ប្រែថា សេចក្ដីសៅហ្មងនៃចិត្ត ដែលកើតព្រោះសង្កិលេសធម៌ ៩ ប្រការនេះ គ្របសង្កត់រុំស្រោប, សូម្បីគិតនឹងធ្វើអ្វី ក៏មិនស្រឡះច្បាស់លាស់ ។

បុ. គ្រឿងមន្ទិលទាំងពួ បើប្រឡាក់មានវត្ថុសម្រាប់លាងដូចជាសំពត់ប្រឡាក់មានសាប៊ូសម្រាប់ដុសជាដើម, ចុះដូច

ចិត្តប្រទ្បាក់នូវមន្ទិលទាំង ៩ នេះ តើមានធម៌ណាសម្រាប់ដុសលាងដែរឬទេ?

វិ. មន្ទិលទាំង ៩ នេះកើតឡើង មានធម៌សំរាប់កំចាត់ដូចតទៅនេះ គឺសេចក្តីក្រោធកើតឡើង គប្បីកំចាត់ដោយករុណា, សេចក្តីលុបគុណគេកើតឡើង គប្បីកំចាត់ដោយកតញ្ញូកតវេទិតាធម៌, ឬស្សាកើតឡើងគប្បីកំចាត់ដោយការចម្រើនមុទិតាចិត្ត, សេចក្តីកំណាញ់កើតឡើង គប្បីកំចាត់ដោយទានៈនិងចាគៈ, មាយាកើតឡើង គប្បីកំចាត់ដោយការមិនមានពុតត្បុត គឺសច្ចៈសេចក្តីពិត, អួតអាងកើតឡើង គប្បីកំចាត់ដោយអត្តញ្ញុតា, និយាយកុហកកើតឡើង គប្បីកំចាត់ដោយវចីសច្ចៈ, សេចក្តីប្រាថ្នាលាភកើតឡើង គប្បីកំចាត់ដោយសន្តោស, សេចក្តីឃើញខុសកើតឡើត គប្បីកំចាត់ដោយសម្មាទិដ្ឋិសេចក្តីឃើញត្រូវ ។

ចប់នវកៈពួក ៩

# ទសកៈពួក ១០

## អកុសលកម្មបថ ១០

ចាត់ជាកាយកម្ម (គឺធ្វើដោយកាយ) ៣ យ៉ាង

**១-បាណាតិបាត** ធ្វើសត្វមានជីវិតឱ្យធ្លាក់កន្លងគឺសម្លាប់សត្វ;

**២-អទិន្នាទាន** កាន់យករបស់ដែលម្ចាស់របស់គេមិនបានឱ្យ;

**៣-កាមេសុមិច្ឆាចារៈ** ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ;

*ចាត់ជាវចីកម្ម (គឺធ្វើដោយវាចា) ៤ យ៉ាង*

**៤-មុសាវាទ** និយាយកុហក;

**៥-បិសុណាវាចា** និយាយពាក្យញុះញង់;

**៦-ផរុសវាចា** និយាយពាក្យចាក់ដោតគេ;

**៧-សម្ផប្បលាបៈ** និយាយពាក្យរោយរាយឥតប្រយោជន៍;

*ចាត់ជាមនោកម្ម (គឺធ្វើដោយចិត្ត) ៣ យ៉ាង*

**៨-អភិជ្ឈា** លោភចង់បានរបស់គេ;

**៩-ព្យាបាទ** ប្រទូស្តរ៉ាយគេ;

**១០-មិច្ឆាទិដ្ឋិ** យើញខុសចាកគន្លងធម៌ ។

អកុសលកម្មបថ ១០ យ៉ាងនេះ ជាផ្លូវមិនគួរដើរឡើយ ។

បុ. ចូរអធិប្បាយ អកុសលកម្មបថ និងទុច្ចរិត ផ្សេងគ្នា ឬដូចគ្នា ?

វិ. ផ្សេងគ្នា ដូចតទៅនេះ ៖

អកុសលកម្មបថ និងទុច្ចរិត ដូចគ្នាដោយលក្ខណៈ តែផ្សេងគ្នាដោយសេចក្តីបំណង, អកុសលកម្មបថ បំណងផលនៃសេចក្តីប្រព្រឹត្តថា បុគ្គលដែលប្រព្រឹត្តនឹងទៅកាន់ទុគ្គតិ, ចំណែកទុច្ចរិត បំណងយកសេចក្តីប្រព្រឹត្តិអាក្រក់ថា ជាហេតុឱ្យបានទទួលផលអាក្រក់ ។

អ្នកដែលប្រព្រឹត្តអកុសលកម្មបថ ១០ ប្រការនេះ ឬសូម្បីតែខ្លះៗក្តី មានជីវិតរស់នៅក្នុងលោកនេះ ក៏បានទទួលផលអាក្រក់ផ្សេងៗ មានសូន្យលាភសូន្យយស ខូចឈ្មោះសម្លេងនឹងត្រូវគុកច្រវាក់ជាដើម, ដល់សូន្យអស់ជីវិតទៅហើយ កម្ម ១០ ប្រការនេះ រមែងនាំទៅកាន់ទុគ្គតិ មាននរកជាដើម មិនខាន ។

## កុសលកម្មបថ ១០

ចាត់ជាកាយកម្ម ៣ យ៉ាង

**១-បាណាតិបាតា វេរមណី** វៀរចាកការធ្វើជីវិតសត្វឱ្យធ្លាក់ចុះកន្លង;

**២-អទិន្នាទានា វេរមណី** វៀរចាកការកាន់យករបស់ដែលម្ចាស់របស់គេមិនបានឱ្យ;

**៣-កាមេសុ មិច្ឆាចារា វេរមណី** វៀរចាកការប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ ។

*ចាត់ជាវចីកម្ម ៤ យ៉ាង*

**៤-មុសាវាទា វេរមណី** វៀរចាកនិយាយពាក្យកុហក;

**៥-បិសុណាយ វាចាយ វេរមណី** វៀរចាកនិយាយពាក្យញុះញង់;

**៦-ផរុសាយ វាចាយ វេរមណី** វៀរចាកនិយាយពាក្យចាកដោត;

**៧-សម្ផប្បលាបា វេរមណី** វៀរចាកនិយាយពាក្យរោយរាយឥតប្រយោជន៍ ។

*ចាត់ជាមនោកម្ម ៣ យ៉ាង*

**៨-អនភិជ្ឈា** មិនលោភចង់បានរបស់គេ;

**៩-អព្យាបាទៈ** មិនប្រទូស្តរ៉ាយគេ;

**១០-សម្មាទិដ្ឋិ** ឃើញត្រូវតាមគន្លងធម៌ ។

កម្ម ១០ យ៉ាងនេះជាផ្លូវបុណ្យគួរដើរ, ក្នុងកុសលកម្មបថ ១០ ប្រការនេះ, អ្នកសិក្សាគប្បីសិក្សា គប្បីជ្រាប ដោយន័យដែលផ្ទុយគ្នានឹងអកុសលកម្មបថដែលបានពោលមកហើយ ។

បុ. កម្មៈ ប្រែដូចម្តេច ?

វិ. ប្រែថា អំពើដែលបុគ្គលគប្បីធ្វើ ។

បុ. ចំណែកអកុសកម្មបថ ដែលធ្វើគឺសម្លាប់សត្វ, លួចទ្រព្យគេជាដើមចុះ គួរថាអំពើដែលបុគ្គលគប្បីធ្វើ, ចុះដូចជាកុសលកម្មបថ គឺឈប់សម្លាប់សត្វ, ឈប់លួចទ្រព្យគេជាដើម, ហេតុដូចម្តេច ក៏ប្រែថាធ្វើដែរ? តើធ្វើដូចម្តេច? ចូរសំដែងហេតុផល!

វិ. កុសលកម្មបថ ក៏ជាអំពើដែលបុគ្គលគួរធ្វើ ពិតមែនតែឈប់សម្លាប់សត្វ ប៉ុន្តែធ្វើដោយចេតនាដែលវៀរ, បើទទេៗ

ហើយមិនវៀរ ក៏មិនឈ្មោះថាកុសលកម្មបថបាន ដូចមានន័យថា៖

**កាយទុច្ចរិតំ បហាយ កាយសុចរិតំ ភាវេតិ** លះកាយទុច្ចរិត ចម្រើនកាយសុចរិត, ទើបបានឈ្មោះថាកុសលកម្មបថបាន, បានជាប្រែថាធ្វើៗ ត្រង់ចម្រើនសុចរិតឱ្យកើតឡើងគ្រប់ទ្វារទាំង ៣ ([២]) ។

## បុញ្ញកិរិយាវត្ថុ ១០ យ៉ាង

១-**ទានមយៈ** បុណ្យសម្រេចដោយការបរិច្ចាគទាន;

២-**សីលមយៈ** បុណ្យសម្រេចដោយការរក្សាសីល;

៣-**ភាវនាមយៈ** បុណ្យសម្រេចដោយការចំរើនភាវនា;

៤-**អបចាយនមយៈ** បុណ្យសម្រេចដោយការប្រព្រឹត្តិបន្ទន់ខ្លួនដល់លោកអ្នកធំ;

[2] កម្មបថទាំងពីរចំណែកនេះ, ចូលមើលក្នុងប្រស្នាគិហិប្បតិបត្តិឯនោះ ទើបមានសេចក្តីពិស្តារ ។

៥-វេយ្យាវច្ចមយៈ បុណ្យសម្រេចដោយការជួយខ្វល់ខ្វាយក្នុងកិច្ចដែលត្រូវ;

៦-បត្តិទានមយៈ បុណ្យសម្រេចដោយការឱ្យចំណែកបុណ្យ;

៧-បត្តានុមោទនាមយៈ បុណ្យសម្រេចដោយការអនុមោទនាចំណែកបុណ្យ;

៨-ធម្មស្សវនមយៈ បុណ្យសម្រេចដោយការស្តាប់ធម៌;

៩-ធម្មទេសនាមយៈ បុណ្យសម្រេចដោយការសំដែងធម៌;

១០-ទិដ្ឋុជុកម្មៈ ការធ្វើសេចក្តីឃើញឱ្យត្រង់ ។

បុ. បុញ្ញកិរិយាវត្ថុទាំង ១០ បើបំព្រួញឱ្យខ្លីចុះមក មានប៉ុន្មាន ?

វិ. បើបំព្រួញឱ្យខ្លីចុះមក មាន ៣ យ៉ាង ។

បុ. មាន ៣ យ៉ាងនោះគឺអ្វីខ្លះ? ចូររាប់មកមើល !

វិ. មាន ៣ យ៉ាងនោះគឺៈ ទានមយៈ១, សីលមយៈ ១, ភាវនាមយៈ ១ ។

បុ. ចុះបុញ្ញកិរិយាវត្ថុ ៧ ដែលនៅនោះ, ណាសង្គ្រោះចូលក្នុងទាន? ណាសង្គ្រោះចូលក្នុងសីល, ណាសង្គ្រោះចូលក្នុងភាវនា?

វិ. បត្តិទានមយៈ ១, បត្តានុមោទនាមយៈ ១ ទាំងពីរនេះ សង្គ្រោះចូលក្នុងទានមយៈ; អបចាយនមយៈ ១, វេយ្យាវច្ច-មយៈ ១ ទាំងពីរនេះ សង្គ្រោះចូលក្នុងសីលមយៈ; ធម្មស្សវន-មយៈ ១, ធម្មទេសនាមយៈ ១, ទុដ្ឋុជុកម្មៈ ១ ទាំង ៣ នេះ សង្គ្រោះចូលក្នុងភាវនាមយៈ ។

បុ. បុញ្ញកិរិយាវត្ថុទាំង ១០ បើចែកដោយពិស្តារទៅទៀត តើមានប៉ុន្មាន?

វិ. បើចែកដោយពិស្តារទៅទៀតមាន ៨០ ។

បុ. មាន ៨០ នោះ តើចែកដូចម្ដេច?

វិ. ចែកដូច្នេះគឺៈ យកមហាកុសល ៨ ក្នុងអភិធម្មមកគុណនឹងបុញ្ញកិរិយាវត្ថុ ១០ ត្រូវជា ៨០ ។

## ធម៌ដែលបព្វជិតគួរពិចារណារឿយៗ ១០ យ៉ាង

១-វេវណ្ណិយម្ហិ អជ្ឈុបគតោ អាត្មាអញមានភេទផ្សេងចាកគ្រហស្ថហើយ អាការកិរិយាណារបស់សមណៈ អាត្មាអញ ត្រូវធ្វើអាការកិរិយានោះ;

២-បរប្បដិពទ្ធា មេ ជីវិកា ការចិញ្ចឹមជីវិតរបស់អាត្មាអញ អាស្រ័យដោយអ្នកដទៃ អាត្មាអញគួរធ្វើខ្លួនឱ្យគេចិញ្ចឹមងាយ;

៣-អញ្ញោ មេ អាកប្បោ ករណីយោ អាការ-កិរិយា កាយ, វាចា យ៉ាងដទៃៗ ដែលអាត្មាអញនឹងត្រូវធ្វើឱ្យល្អប្រពៃឡើងទៅជាងនេះ នៅមានទៀត មិនមែនអស់ត្រឹមប៉ុណ្ណេះទេ;

៤-កច្ចិ នុខោ មេ អត្តា សីលតោ ន ឧបវទតិ ខ្លួនអាត្មាអញ តិះដៀលខ្លួនរបស់អាត្មាអញ ដោយសីលបានឬទេ?;

៥-កច្ចិ នុខោ មំ អនុវិច្ច វិញ្ញូ សព្រហ្មចារី សីលតោ ន ឧបវទន្តិ ពួកសព្រហ្មចារី អ្នកដឹងទាំងឡាយ

ពិចារណាហើយ មិនតិះដៀលអាត្មាអញព្រោះសីល (មិនបរិបូណ៌) បានដែរឬទេ?;

៦-សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អាត្មាអញ នឹងត្រូវព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ពេញចិត្តទាំងអស់;

៧-កម្មស្សកោម្ហិ អាត្មាអញមានកម្មជារបស់ខ្លួន ធ្វើល្អ នឹងបានល្អ ធ្វើអាក្រក់នឹងបានអាក្រក់;

៨-កថម្ភូតស្ស មេ រត្តិន្ទិវា វីតិបតន្តិ ថ្ងៃនិងយប់កន្លងទៅៗ ឥឡូវនេះ អាត្មាអញបានធ្វើអ្វីខ្លះ?;

៩-កច្ចិ នុខោហំ សុញ្ញាគារេ អភិរមាមិ អាត្មាអញត្រេកអរក្នុងទីស្ងាត់ដែរឬទេ?;

១០-អត្ថិ នុ ខោ មេ ឧត្តរិមនុស្សធម្មោ គុណ-វិសេសរបស់អាត្មាអញនៅមានឬទេ? បើពួកសព្រហ្មចារីមកសួរក្នុងបច្ឆិមកាល តើអាត្មាអញនឹងមិនអៀនខ្មាសទេឬ? ។

បុ. ធម៌ ១០ ប្រការនេះ បើបព្វជិតពិចារណា មានប្រយោជន៍ដូចម្ដេចខ្លះ? ចូរអធិប្បាយ!

វិ. អធិប្បាយថាៈ ការពិចារណាធម៌ ១០ ប្រការនេះ ក៏ដើម្បីនឹងឱ្យរំពឹងដល់ភេទអាជីវចរិយា មារយាទ ស្ថានទីនិងគុណវិសេស ការរំពឹងដោយអាការៈដូច្នេះ ជាឧបាយជាគ្រឿងដាស់តឿនចិត្តឱ្យប្រព្រឹត្តល្អ, ប្រតិបត្តិត្រឹមត្រូវ ប្រកបដោយសេចក្ដីព្យាយាមជាគ្រឿងអប់រំចិត្តឱ្យស្ងប់ស្ងាត់ ឱ្យខ្វល់ខ្វាយបណ្ដុះចំណេះវិជ្ជាប្រាជ្ញា រួមសេចក្ដីទៅថា ជាប្រយោជន៍ឱ្យបានសម្រេចផលដែលជាលោកិយៈ និងលោកុត្តរៈ ។

បុ. ធម៌ទាំង ១០ យ៉ាងនេះ គួរតែពិចារណាតែបព្វជិតឬ? ឬគ្រហស្ថ?

វិ. គ្រហស្ថក៏គួរពិចារណាបានខ្លះដែរ ។

បុ. គួរពិចារណាបានខ្លះនោះតើ ខ ណាខ្លះ ចូរប្រាប់ឱ្យសព្វគ្រប់មកមើល!

វិ. ធម៌ដែលត្រូវពិចារណាបាននោះ គឺតាំងពីទី ៤ ដល់ទី ៩ ទាំង ៦ នេះ គ្រហស្ថគួរពិចារណារឿយៗ បានដូចបព្វជិតដែរ ។

# នាថករណធម៌

បុ. នាថករណធម៌ ប្រែដូចម្ដេច?

វិ. ប្រែថា ធម៌ធ្វើនូវទីពឹង ។

បុ. នាថករណធម៌នោះ តើមានប៉ុន្មានយ៉ាង? ចូររាប់ឱ្យសព្វគ្រប់មកមើល!

វិ. មាន ១០ យ៉ាងគឺៈ

**១-សីលៈ** រក្សាកាយវាចាឱ្យរៀបរយ;

**២-ពាហុសច្ចៈ** ភាពជាអ្នកបានឮបានស្ដាប់ច្រើន;

**៣-កល្យាណមិត្តតា** ភាពជាអ្នកមានមិត្រល្អ;

**៤-សោវចស្សតា** ភាពជាអ្នកប្រដៅងាយ;

**៥-កឹករណីយេសុ ទក្ខតា** ភាពជាអ្នករវៀងជួយយកចិត្តទុកដាក់ក្នុងកិច្ចធុរៈរបស់ភិក្ខុ-សាមណេរផងគ្នា;

**៦-ធម្មកាមតា** សេចក្ដីប្រាថ្នាក្នុងធម៌ដែលត្រូវ;

**៧-វីរិយៈ** ព្យាយាមដើម្បីនឹងលះបង់សេចក្ដីអាក្រក់ប្រព្រឹត្តសេចក្ដីល្អ;

**៨-សន្តោសៈ** ត្រេកអរដោយសំពត់ស្លៀកដណ្តប់ អាហារ ទីដេកនិងទីអង្គុយ តាមបានតាមមាន មិនមានការឆ្មើងឆ្មៃ;

**៩-សតិ** ចាំការដែលធ្វើនិងការដែលនិយាយ សូម្បីយូរៗបាន;

១០-បញ្ញា ដឹងក្នុងកងសង្ខារតាមសេចក្តីពិត ។

បុ. ចូរអធិប្បាយនាថករណធម៌ទាំង ១០ នោះមកមើល?

វិ. អធិប្បាយថាៈ ព្រះពុទ្ធភាសិតថាៈ អ្នកទាំងឡាយ ចូរមានធម៌ជាទីពឹងចុះ កុំឱ្យមានរបស់ដទៃក្រៅពីធម៌ ជាទីពឹងឡើយ, អ្នកដែលមិនមានទីពឹងរមែងនៅលំបាក ដូចជាមនស្សដែលមិនមានទីពឹងក្នុងបច្ចុប្បន្ននេះ រមែងមានសេចក្តីទុក្ខលំបាកយ៉ាងណា, ចំណែកមនុស្សដែលមិនមានធម៌ជាទីពឹងក៏តែងមានសេចក្តីទុក្ខលំបាកក្នុងបរលោកដូច្នោះដែរ ដូច្នេះព្រោះមានព្រះពុទ្ធបំណង ដើម្បីឱ្យបំពេញនាថករណធម៌ទាំង ១០ ប្រការនេះ អ្នកដែលបំពេញនាថករណធម៌ដោយបរិបូណ៌ ឬត្រឹមតែឯកទេសក៏ដោយ ធម៌ទាំងអម្បាលនេះ ក៏ជាទីពឹងដល់បុគ្គលនោះ តាមសមគួរដល់សេចក្តីប្រតិបត្តិតាំងអំពីជាន់ទាបរហូតដល់ជាន់ខ្ពស់ គឺលោកុត្តរធម៌ ។

# កថាវត្ថុ

បុ. កថាវត្ថុ ប្រែដូចម្ដេច?

វិ. ប្រែថា ពាក្យដែលគួរពោល គួរនិយាយ ។

បុ. កថាវត្ថុនោះ មានប៉ុន្មានយ៉ាង? ចូររាប់ឱ្យសព្វគ្រប់មកមើល !

វិ. មាន ១០ យ៉ាងគឺៈ

**១-អប្បិច្ឆកថា** ពាក្យពោលដឹកនាំឱ្យមានសេចក្តីប្រាថ្នាតិច;

**២-សន្តុដ្ឋិកថា** ពាក្យពោលដឹកនាំឱ្យមានសន្តោសត្រេកអរដោយបច្ច័យ តាមបានតាមមាន;

**៣-បវិវេកកថា** ពាក្យពោលដឹកនាំឱ្យស្ងាត់កាយស្ងាត់ចិត្ត;

**៤-អសំសគ្គកថា** ពាក្យពោលដឹកនាំមិនឱ្យច្របូកច្របល់;

**៥-វីរិយារម្ភកថា** ពាក្យពោលដឹកនាំឱ្យប្រារព្ធសេចក្តីព្យាយាម;

**៦-សីលកថា** ពាក្យពោលដឹកនាំឱ្យតាំងនៅក្នុងសីល;

**៧-សមាធិកថា** ពាក្យពោលដឹកនាំឱ្យធ្វើចិត្តឱ្យនឹង;

**៨-បញ្ញាកថា** ពាក្យពោលដឹកនាំឱ្យកើតបញ្ញា;

**៩-វិមុត្តិកថា** ពាក្យពោលដឹកនាំឱ្យធ្វើចិត្តឱ្យផុតចាកកិលេស;

**១០-វិមុត្តិញ្ញាណទស្សនកថា** ពាក្យពោលដឹកនាំឱ្យកើតសេចក្តីឃើញសភាវៈដែលចិត្តផុតចាកកិលេស ។

បុ. ចូរអាងហេតុផលនៃកថាវត្ថុទាំង ១០ យ៉ាងនោះមកមើល?

វិ. កថាវត្ថុទាំង ១០ យ៉ាងនេះអាងព្រះបុណ្ណមន្តានិបុត្តត្ថេរតាមប្រវត្តិពោលថាៈ លោកជាទីស្រឡាញ់ ជាទីគោរពរបស់បរិស័ទនិងប្រជុំជន ក៏តែលោកប្រកបដោយធម៌ទាំង ១០ ប្រការនេះ ហើយបង្រៀនប្រៀនប្រដៅបរិស័ទឱ្យតាំងនៅក្នុងធម៌ទាំងនោះៗ ផង ។

កាលបើយើងពិចារណាកថាវត្ថុ ១០ ប្រការនេះតែ១ខ១ ហើយក៏នឹងឃើញបានសុទ្ធតែផលយ៉ាងវិសេសវិសាល ឱ្យកើតប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃទាំងពីរចំណែក, ព្រោះហេតុនេះ ទើបឈ្មោះថា កថាវត្ថុ គឺពាក្យដែលគួរនិយាយដូចពោលមកហើយ ។

# អនុស្សតិ

បុ. អនុស្សតិ ប្រែដូចម្ដេច?

វិ. ប្រែថា រឭកនូវអារម្មណ៍ដែលគួរនឹក ។

បុ. អារម្មណ៍ដែលគួរនឹកនោះមានប៉ុន្មានយ៉ាង? ចូររាប់មកមើល!

វិ. មាន ១០ យ៉ាងគឺ:

**១-ពុទ្ធានុស្សតិ** រឭកដល់គុណព្រះពុទ្ធជាម្ចាស់;

**២-ធម្មានុស្សតិ** រឭកដល់គុណរបស់ព្រះធម៌;

**៣-សង្ឃានុស្សតិ** រឭកដល់គុណរបស់ព្រះសង្ឃ;

**៤-សីលានុស្សតិ** រឭកដល់សីលរបស់ខ្លួន;

**៥-ចាគានុស្សតិ** រឭកដល់ទានដែលខ្លួនបានបរិច្ចាគហើយ;

**៦-ទេវតានុស្សតិ** រឭកដល់គុណធម៌ដែលធ្វើមនុស្សឱ្យកើតជាទេវតា;

**៧-មរណានុស្សតិ** រឭកដល់សេចក្ដីស្លាប់ដែលនឹងមានមកដល់ខ្លួន;

**៨-កាយគតានុស្សតិ** រឭកទួទៅក្នុងកាយ ឱ្យឃើញថា មិនល្អ ស្មោកគ្រោក គួរខ្ពើមរអើម;

**៩-អានាបានុស្សតិ** តាំងសតិកំណត់ខ្យល់ដកដង្ហើមចូលចេញ;

**១០-ឧបសមានុស្សតិ** រឭកដល់គុណព្រះនិព្វាន ដែលជាទីរម្ងាប់កិលេស និងទុក្ខ ។

បុ. ហេតុដូចម្ដេចបានជារឭកគុណរបស់ព្រះពុទ្ធៗ នោះមានគុណដូចម្ដេច ?

វិ. បានជារឭកគុណព្រះពុទ្ធនោះ, ព្រោះព្រះពុទ្ធប្រៀនប្រដៅ សម្ដែងធម៌ទេសនាប្រោសសត្វឱ្យបានសេចក្ដីសុខ ក្នុងលោកនេះ និងលោកខាងមុខ និងព្រះនិព្វានជាទីបំផុត ។

បុ. ព្រះពុទ្ធមានគុណទៅលើសត្វលោកទាំងអស់ ឬនៅសល់ខ្លះដែរ?

បុ. ព្រះពុទ្ធមានគុណ គឺផ្សាយព្រហ្មវិហារធម៌ចំពោះសព្វសត្វទាំងអស់ឥតរើសមុខ, សត្វណាមានឧបនិស្ស័យ រមែងបានសម្រេចប្រយោជន៍ជាតិនេះ និងជាតិខាងមុខ និង

ប្រយោជន៍ព្រះនិព្វាន, សត្វណាឥតឧបនិស្ស័យ ក៏ខានបានសម្រេចប្រយោជន៍ទាំង ៣ នោះទៅ ។

បុ. ព្រះពុទ្ធប្រោសបានតែមនុស្សដែលមានឧបនិស្ស័យទេឬ?

វិ. ប្រោសបានតែមនុស្សដែលមានឧបនិស្ស័យទេ, ដូចមានក្នុងព្រះនាម ‹‹បុរិសទម្មសារថិ›› នោះស្រាប់ ។

បុ. បើព្រះពុទ្ធប្រោសបានតែមនុស្សដែលមានឧបនិស្ស័យ មនុស្សឥតឧបនិស្ស័យប្រោសមិនបាន, ចុះហេតុដូចម្តេចបានជាថាមានគុណ? បើប្រោសបានមនុស្សដែលមានឧបនិស្ស័យស្រាប់ ?

វិ. បានជាថាមានគុណនោះ ទុកជាមានឧបនិស្ស័យស្រាប់ ក៏ឧបនិស្ស័យនោះកើតដោយសារព្រះពុទ្ធ ព្រះពុទ្ធចាប់កសាងជាពុទ្ធភូមិមក សត្វមានឧបនិស្ស័យនោះ ក៏តាំងសេចក្តីប្រាថ្នាឱ្យជួបនឹងព្រះពុទ្ធ, ដូចព្រះពុទ្ធបរមគ្រូយើងនេះ លោកតាំងប្រាថ្នាពុទ្ធភូមិបញ្ញាធិក ទ្រង់ព្រះនាមថា សមណគោតមតរៀងមក ហើយសត្វណាដែលកើតខាងក្រោយ កសាងទានសីល

ក៏តាំងប្រាថ្នាថា ឱ្យជួបព្រះសមណគោតម ព្រោះព្រះពុទ្ធជាប្រមុខរបស់សត្វទាំងអស់ បានជាថាមានគុណ ។

បុ. ព្រះពុទ្ធមានគុណ សំដែងធម៌ប្រោសសត្វ និងព្រះសង្ឃលោកប្រតិបត្តិធម៌វិន័យ ហើយលោកប្រៀនប្រដៅសត្វឱ្យប្រតិបត្តិតាមធម៌វិន័យ គួរថាមានគុណចុះ, ព្រះធម៌មានគុណដូចម្ដេច បើមានគុណទៅលើព្រះពុទ្ធ និងព្រះសង្ឃឯនោះហើយ គួរតែថាព្រះធម៌នេះឥតគុណ, ប្រៀបឧបមាដូចអ្នកដំណើរតាមទៅអត់បាយ ដើរទៅជួបអ្នកស្រុកគេឱ្យបាយទទួលទាននិងឱ្យផ្ទះដេក តើមានគុណទៅលើបាយ ឬក៏មានគុណអ្នកដែលឱ្យ ? ត្រង់នេះថាមានគុណទៅលើអ្នកផ្ទះយ៉ាងណា ចំណែកព្រះពុទ្ធនិងព្រះសង្ឃគួរថាមានគុណ ព្រោះទុកដូចជាអ្នកម្ចាស់បាយនិងម្ចាស់ផ្ទះ; ចុះចំណែកព្រះធម៌នេះហេតុដូចម្ដេចក៏ថាមានគុណដែរ ? បើមានគុណតើគុណនោះដូចម្ដេច? ចូរអធិប្បាយឱ្យពិស្ដារមកមើល !

វិ. ព្រះធម៌មានគុណដល់សត្វលោកទាំងអស់ពិតប្រាកដត្រង់នេះប្រៀបដូចម្ចាស់នោះមិនសមទេ, ប្រៀបដូច្នេះទើបសម ដូចរឿងតទៅនេះ មនុស្សកំសត់ម្នាក់ដើរតាមផ្លូវទៅ

លំបាករកទីពឹងគ្មាន ដើរទៅជួបនឹងបុរសម្នាក់នៅដើមផ្លូវ គេមានមេត្តាអាណិតអាសូរ គេចង្អុលប្រាប់ផ្ទះថា នៅទិសខាងត្បូងមានសេដ្ឋីម្នាក់ គេមានចិត្តមេត្តាសង្គ្រោះអ្នកកំសត់ទុគ៌តណាស់ អ្នកក្រខ្សត់ណាដែលទៅនៅជាមួយនឹងគេហើយ តែងបានសេចក្តីសុខ ចម្រើនរាល់ៗ រូប ហេតុនេះ អ្នកឯងចូរទៅឱ្យបានឆាប់ទៅ! បុរសនោះបានស្តាប់ហើយក៏ប្រញាប់រលះរលាំងទៅ បានឃើញផ្ទះសេដ្ឋីនោះមែន ក៏គោរពប្រតិបត្តិតាមខ្លួនជាអ្នកកំសត់ទុគ៌ត សុំនៅជ្រកកោនដោយសារសេដ្ឋីនោះៗ ក៏ព្រមឱ្យនៅតាមសុំ ខ្លួនក៏យកចិត្តទុកដាក់ក្នុងកិច្ចការរបស់សេដ្ឋីនោះឥតធ្វេសប្រហែស សេដ្ឋីក៏ពេញចិត្តនឹងគំនិតមារយាទទើបគិតថា បុរសនេះមានឫកពាមារយាទល្អណាស់ គួរអញនឹងឱ្យកូនធ្វើជាភរិយា អាចនឹងរក្សាទ្រព្យមត៌ករបស់អញបាន គិតដូច្នោះហើយក៏ហៅបុរសនោះមកផ្សំផ្គុំនឹងធីតារបស់ខ្លួនឱ្យទៅជាស្វាមីភរិយា លុះអំណើះពីសេដ្ឋីនោះទៅបុរសនោះក៏បានឡើងជាសេដ្ឋី រឿងនេះយ៉ាងណា ព្រះពុទ្ធដូចជាអ្នកប្រាប់ផ្លូវ ដូចពុទ្ធភាសិតថា អក្ខាតារោ តថាគតា ព្រះតថាគតទាំងឡាយអ្នកប្រាប់ផ្លូវ ដូចជាបុរសអ្នកប្រាប់ផ្លូវ

ចំណែកព្រះធម៌ដូចជាសេដ្ឋីអ្នកទំនុកបម្រុងឱ្យបានមានឡើង រឿងនេះក៏មានឧបមេយ្យដូច្នោះដែរ, បានជាថាព្រះធម៌នេះ មានគុណដល់សត្វ ។ ប្រៀបម៉្យាងទៀត ឧបមាដូចគ្រូពេទ្យ និងថ្នាំ ចំណែកព្រះធម៌ដូចថ្នាំ ចំណែកព្រះសង្ឃដូចជាអ្នក ថែរក្សាជម្ងឺ ដូចពុទ្ធភាសិតថា **ពុទ្ធោ មហាវេជ្ជោ** ព្រះពុទ្ធដូច ជាគ្រូពេទ្យយ៉ាងធំ **ធម្មោ ឱសថោ** ព្រះធម៌ជាឱសថយ៉ាង វិសេស **សង្ឃោ បុញ្ញក្ខេត្តោ** ព្រះសង្ឃជាស្រែបុណ្យ ផ្សំហេតុ ទាំងអស់ ទើបជម្ងឺនោះជាទៅបាន បានជាថាព្រះពុទ្ធ-ធម៌-សង្ឃ មានគុណដល់សត្វលោក ។

បុ. ចូរអធិប្បាយអនុស្សតិទាំង ១០ នោះមកមើល ?

វិ. អធិប្បាយថា ការរលឹកដល់ព្រះពុទ្ធគុណ **អរហំ** ជាដើម ហៅថា រឭកដល់គុណព្រះពុទ្ធជាម្ចាស់, រឭកបទថា **ស្វាក្ខាតោ** ជាដើម ហៅថា រឭកដល់គុណព្រះធម៌, រឭកបទថា **សុប្បដិបន្នោ** ជាដើម ហៅថា រឭកដល់គុណព្រះសង្ឃ, រឭក សីលដែលខ្លួនរក្សា ហៅថា **សីលានុស្សតិ**, រឭកទានដែលខ្លួន បានបំពេញហើយ ហៅថា **ចាគានុស្សតិ**, រឭកដល់ធម៌ដែលធ្វើ

ខ្លួនឱ្យទៅជាទេវតា ហៅថា **ទេវតានុស្សតិ**, រឭកដល់សេចក្តីស្លាប់ ដែលនឹងមានមកដល់ខ្លួន ដោយឧបាយវិធីផ្សេងៗ ហៅថា **មរណានុស្សតិ**, រឭកក្នុងកាយរបស់ខ្លួននិងអ្នកដទៃ ឱ្យឃើញថាជារបស់មិនស្អាត គួរខ្ពើមរអើម ស្មោកគ្រោក ហៅថា **កាយគតានុស្សតិ**, តាំងសតិដំកល់ខ្យល់ដកដង្ហើមចេញចូល ឱ្យដឹងវែងឬខ្លី គ្រោតគ្រាតឬល្អិត ទាល់តែស្ងប់រម្ងាប់ ហៅថា **អានាបានុស្សតិ**, រឭកដល់គុណព្រះនិព្វានដែលជាទីរម្ងាប់កិលេសនិងទុក្ខ ជាបរមសុខដោយចំណែកមួយ ហៅថា **ឧបសមានុស្សតិ** ។

អនុស្សតិទាំង ១០ ប្រការនេះ ជាកុសលយ៉ាងខ្ពស់ ចាត់ចូលក្នុងចំណែកវិបស្សនាធុរៈ សូម្បីអ្នកដែលបំពេញនៅមិនទាន់បានសម្រេចមគ្គផល ក៏ឈ្មោះថា មានឧបនិស្ស័យជាប់នឹងខ្លួន ទៅក្នុងភពខាងមុខ បានឈ្មោះថាបំពេញកុសលចំណែកសមថភាវនា ។

ចប់ទសកៈពួក ១០

---

# បកិណ្ណកៈពួកកាត់កាយ

## ឧបក្កិលេស

បុ. ឧបក្កិលេស ប្រែដូចម្ដេច?

វិ. ប្រែថា វត្ថុជាគ្រឿងសៅហ្មងនៃចិត្ត ឈ្មោះថា ឧបក្កិលេស ។

បុ. ឧបក្កិលេសនោះមានប៉ុន្មានយ៉ាង ?

វិ. មាន ១៦ យ៉ាង ។

បុ. មាន ១៦ យ៉ាងនោះគឺអ្វីខ្លះ? ចូររាប់!

វិ. មាន ១៦ យ៉ាងនោះគឺៈ

១-អភិជ្ឈាវិសមលោភៈ លោភមិនត្រឹមត្រូវស្មើ គឺសម្លឹងចង់តែបាន;

២-ទោសៈ ប្រទូសរ៉ាយ;

៣-កោធៈ សេចក្ដីក្រោធ;

៤-ឧបនាហៈ ចងក្រោធទុក;

៥-មក្ខៈ លុបគុណគេ;

៦-បលាសៈ វាយឭកស្មើ គឺលើកខ្លួនផ្ទឹមលោកអ្នកមានវាសនា;

៧-ឥស្សា ឫស្យា, ច្រណែនគេ;

៨-មច្ឆរិយៈ សេចក្តីកំណាញ់;

៩-មាយាៈ បិទទោសទុក;

១០-សាថេយ្យៈ អួតអំនួត;

១១-ថម្ភៈ រឹងថ្មឹង ក្រអឺតក្រទម;

១២-សារម្ភៈ ប្រណាំងវាសនា;

១៣-មានៈ ប្រកាន់ ឬអាង;

១៤-អតិមានៈ មើលងាយគេ;

១៥-មទៈ ស្រវឹង;

១៦-បមាទៈ ប្រហែសធ្វេស ។

បុ. អភិជ្ឈាវិសមលោភៈ លោភមិនត្រឹមត្រូវ សំឡឹងចង់បាននោះតើដូចម្តេច ? ចូរអធិប្បាយ !

វិ. អធិប្បាយថា លោភចង់បានរបស់គេ ដោយហេតុណាមួយ ឥតទិញឥតដូរ គិតឱ្យបានដោយឧបាយផ្សេងៗ ដោយអនេសនៈ ២១ ឬបាបធម៌ ៥ ណាមួយ នេះប៉ែកខាងបព្វជិត, ចំណែកខាងគ្រហស្ថវិញ ដោយឧបាយគិតនឹងលួចឬបន្លំបំបាត់ដោយភ្នែកជញ្ជីង និងគម្រាមឱ្យគេខ្លាច ដើម្បីឱ្យគេឱ្យរបស់មកខ្លួន ដូច្នេះឈ្មោះថា អភិជ្ឈាវិសមលោភៈ ។

បុ. ទោសៈ, កោធៈ, ឧបនាហៈ, ថៃមព្យាបាទៈ និងកោបៈមកទៀតទាំង ៥ នេះ មានសេចក្ដីអធិប្បាយផ្សេងគ្នាដូចម្ដេច? ចូរអធិប្បាយ !

វិ. ធម៌ទាំង ៥ នេះ មានសេចក្ដីផ្សេងគ្នាដូច្នេះ ៖ ទោសៈនេះ ប្រែថា ប្រទូស្ដរ៉ាយគេ ឱ្យវិនាសជីវិតឬសម្បត្តិរបស់គេខឹងក្ដី ឥតខឹងក្ដី ហៅថា ទោសៈ, កោធៈ សេចក្ដីខឹងចំៗចំពោះដល់សត្វនិងសង្ខារ មានជេរប្រទេចជាដើម; ឧបនាហៈខឹងហើយខ្ចប់សេចក្ដីក្រោធទុក ធំដូចរងើកភ្លើងដែលគេកប់ទុក បើខឹងនឹងអ្នកណាៗ ហើយកាត់កាល់លែងរាប់រក; ព្យាបាទៈ នោះខឹងហើយរករឿងហេតុចំពោះមនុស្សដែលជាបច្ចាមិត្ត ជាគូសត្រូវនឹងខ្លួន ដើម្បីនឹងរករឿងទៅថ្ងៃមុខទៀត,

កោបៈ គ្រាន់តែខឹងបន្តិចបន្តួចហើយក៏បាត់ទៅវិញ ។ សេចក្ដីផ្សេងគ្នាដូចវិស្សជ្ជនាមកនេះ ។

បុ. មក្ខៈ លុបគុណគេ និង អកតញ្ញូ តើសេចក្ដីផ្សេងគ្នាឬដូចគ្នា?

វិ. សេចក្ដីផ្សេងគ្នាដូច្នេះ, មក្ខៈ លុបគុណគេ ដឹងថាគេមានគុណដែរ តែកើតសេចក្ដីខឹងឡើង យកទោសដែលគេខុសលើខ្លួនបន្តិចបន្តួចនោះ មកត្រដាងលុបគុណគេ ថាគេគ្មានគុណវិញ, អតញ្ញូ មិនដឹងគុណឧបការៈរបស់បុព្វការីដែលគេធ្វើដល់ខ្លួនធ្វើហឺៗ ទៅ ដូចជាមនុស្សជំពាក់បំណុលគេហើយមិនគិតគួរសងគេ, ចំណែកបុគ្គលជាអកតញ្ញូទុកជាគេឱ្យផែនដីសោយរាជ្យ ក៏នៅតែរករឿងដល់គេទៀត, ឃើញគេសុទ្ធតែខុសទាំងអស់ត្រូវតែម្នាក់ឯង ។

បុ. បលាសៈ, វាយឫកស្មើនោះ តើវាយឫកដូចម្ដេច ?

វិ. វាយឫកស្មើនោះដូច្នេះ បើខ្លួនល្ងង់ជួបនឹងអ្នកចេះនិយាយហាក់ដូចជាខ្លួននោះចេះស្មើនឹងគេ, ខ្លួនក្រទ្រព្យសម្បត្តិ និយាយហាក់ដូចជាខ្លួនមានទ្រព្យសម្បត្តិច្រើនប្រហែលនឹងគេ, បើគ្មានយសស័ក្តិអង្គុយក្ដី និយាយក្ដី ក្នុងទី

ប្រជុំគេរៀបទទួលអ្នកមានបណ្ដាស័ក្តិ ខ្លួនទៅអង្គុយក្នុងទីនោះ ហាក់ដូចជាខ្លួនមានស័ក្តិស្មើនឹងគេដែរ ដូច្នេះឈ្មោះថា បលាសៈ ។

បុ. ឥស្សា ឫស្យាគេនោះ តើដូចម្ដេច ?

វិ. ឫស្យាគេនោះដូច្នេះ បើឃើញគេមានទ្រព្យសម្បត្តិ មានយសស័ក្តិ បានសេចក្ដីសុខ-ចម្រើន មិនចង់ឱ្យគេបានយស-ស័ក្តិ សេចក្ដីសុខ-ចំរើនទេ, ចង់ឱ្យគេទាបថោកជាងខ្លួន ទើបពេញចិត្ត ។

បុ. មច្ឆរិយៈ សេចក្ដីកំណាញ់នោះ ព្រះអង្គសំដែងចំពោះអ្នកមាន ឬអ្នកក្រ ?

វិ. សេចក្ដីកំណាញ់នេះ ព្រះអង្គសម្ដែងចំពោះអ្នកមានទ្រព្យសម្បត្តិ គួរនឹងចែកចាយឱ្យដល់អ្នកកំសត់ទុគ៌តដែលគួរឱ្យបាន, ដូចលោកចែកមច្ឆរិយៈទៅជា ៥ យ៉ាងគឺ:

**១-អាវាសមច្ឆរិយៈ** កំណាញ់ទីអាវាស គឺបានដល់អាវាសគ្រប់គ្រាន់គួរនឹងឱ្យបាន តែមិនឱ្យវិញ ហួងហែងទុកនៅតែម្នាក់ឯង;

**២-លាភមច្ឆរិយៈ** កំណាញ់លាភដែលកើតឡើងក្នុងមណ្ឌលសង្ឃ គួរនឹងចាត់ចែងតាមលំដាប់លោកចាស់វស្សា ខ្ចីវស្សា ឬលាភដែលបានមកលាក់ទុក មិនឱ្យភិក្ខុសាមណេរដែលនៅជាមួយផង;

**៣-កុលមច្ឆរិយៈ** កំណាញ់ត្រកូល គឺត្រកូលណាដែលគេរាប់អានខ្លួន មិនឱ្យភិក្ខុសាមណេរណាទៅរាប់អានជាមួយផង;

**៤-វណ្ណមច្ឆរិយៈ** កំណាញ់សេចក្ដីសរសើរ, បើឃើញគេសរសើរលោកណា មិនបានទេ, បានតែសរសើរខ្លួន ទើបពេញចិត្ត;

**៥-ធម្មមច្ឆរិយៈ** កំណាញ់ធម៌ ចេះដឹងធម៌អាថ៌ មិនប្រាប់គេទេ ក្រែងគេចេះស្មើនឹងខ្លួន ឬលាក់គម្ពីរក្បួនខ្នាតទុកមិនឱ្យគេរៀនសូត្រ ។ កំណាញ់ទាំង ៥ យ៉ាងនេះ ច្រើនមានលើបព្វជិតជាងគ្រហស្ថ ។

បុ. មាយា បិទទោសទុកនោះ តើបិទទោសអ្វីខ្លះ ?

វិ. បើភេទបព្វជិតត្រូវអាបត្តិ ៧ កងណានីមួយ ហើយបិទទុកអាបត្តិណាដែលគួរសឹកចេញជាឃរាវាស ក៏មិនសឹកចេញ, អាបត្តិណាដែលគួរចូលបរិវាស ក៏មិនចូលបរិវាស, អាបត្តិណា

ដែលគួរសំដែងចំពោះមុខសង្ឃ ឬគណៈបុគ្គលក៏មិនសម្ដែង, ចំណែកខាងគ្រហស្ថ ទោសដែលប្រព្រឹត្តកន្លងខុសទាំងប៉ុន្មាន លាក់ទុកមិនប្រាប់ដល់គេឯង សំដែងតែសេចក្ដីល្អឡើង ថាខ្លួនត្រឹមត្រូវ បានជាមុននឹងចូលទៅកាន់ពុទ្ធសាសនានោះ លោកឱ្យសម្ដែងទោស គឺខមថទោសជាមុន ទើបថ្វាយខ្លួនជាឧបាសកឧបាសិកាបាន ឬដូចពួកនិគ្រន្ថតិរ្ថិយខាងក្រៅពុទ្ធ-សាសនា បើចូលក្នុងពុទ្ធសាសនា ឱ្យចូលបរិវាសជាមុនសិន ទើបចូលក្នុងព្រះពុទ្ធសាសនាបាន ដូច្នេះឈ្មោះថា មាយា ។

បុ. សាថេយ្យៈ អួតអំនួតនោះ តើដូចម្ដេច ?

វិ. អួតនោះ គឺទ្រព្យសម្បត្តិចំណេះវិជ្ជា ដែលមានតិច ចេះតិច ថាមានច្រើន ចេះច្រើន ឬថាល្អជាងគេ ដើម្បីឱ្យគេសរសើរ ។

បុ. ថម្ភៈ រឹងថ្អឹងនោះដូចម្ដេច ?

វិ. រឹងថ្អឹងនោះ គឺមិនចំណុះចុះចូលពីណា ដូចជាសសរផ្ទះ។

បុ. សារម្ភៈ ប្រណាំងវាសនានោះ តើប្រណាំងដូចម្ដេច ?

វិ. ខ្លួនមានវាសនាតិច ហើយប្រណាំងប្រជែងនឹងអ្នកដែលមានទ្រព្យសម្បត្តិ មានបុណ្យស័ក្តិច្រើន, ម្ល៉ោះហើយ ការ

ប្រណាំងប្រជែងនោះ មិនឱ្យសម្រេចទៅតាមវត្ថុបំណងខ្លួននោះទេ នាំឱ្យខូចប្រយោជន៍ទៅវិញ ដូចពាក្យបុរាណគតិថា ‹‹ឃើញដំរីជុះ កុំជុះតាមដំរី›› ។

បុ. មានះ, ប្រកាន់ខ្លួន, ឧបាទានះ ក៏ប្រកាន់ខ្លួនដែរ តើប្រកាន់ទាំងពីរនេះ មានសេចក្ដីផ្សេងគ្នាដូចម្ដេច ?

វិ. មានសេចក្ដីផ្សេងគ្នាដូច្នេះ ចំណែកមានះ ប្រកាន់ខាងក្រៅថា ខ្លួនគ្រាន់បើជាងគេ ឬអាងបុណ្យស័ក្តិទ្រព្យសម្បត្តិជាដើម ([៣]), ចំណែកឧបាទានះ ប្រកាន់ខាងក្នុង គឺប្រកាន់បញ្ចុបាទានក្ខន្ធទាំង ៥ ។

បុ. អតិមានះ មើលងាយគេនោះតើដូចម្ដេច ?

វិ. មើលងាយនោះដូច្នេះ គឺខ្លួនជាមនុស្សមាត់ឥតគ្រប ទៅកណ្ដាលជំនុំគេ ចេះតែថាឱ្យគេ បន្តុះបង្អាប់គេ ឱ្យគេបានសេចក្ដីអាប់មុខ ឬស្មានថាគេមិនកើតស្មើនឹងខ្លួន ។

បុ. មទះ ស្រវឹងនោះដូចម្ដេច ? ស្រវឹងស្រា ឬស្រវឹងអ្វី?

វិ. ស្រវឹងនោះមានច្រើន, តែក្នុងទីនេះលោកសំដៅយកតែស្រវឹង ៣ យ៉ាងគឺះ វយមទោ ស្រវឹងថាខ្លួននៅក្មេង,

---

[3] មានះ ចេះចូរមើលក្នុងពួកធម៌ ៩ ក្នុងធម្មវិភាគជាន់ទោនោះ ទើបមានសេចក្ដីពិស្ដារ ។

អរោគ្យមទោ ស្រវឹងថាខ្លួនមិនមានរោគ, ជីវិតមទោ ស្រវឹងថាខ្លួនមានអាយុវែងមិនទាន់ស្លាប់; ស្រវឹងស្រាក៏ជាស្រវឹងដែរ តែលោកមិនរាប់ចូលក្នុងឧបក្កិលេសធម៌ទេ លោកចាត់ចូលក្នុងបញ្ហាវេរា ខាងដើមរួចហើយ ។

បុ. បមាទៈ ការប្រហែសធ្វេសនោះដូចម្ដេច ?

វិ. ការប្រហែធ្វេសនោះ បានដល់ការប្រហែសធ្វេសគ្រប់យ៉ាង គ្រប់បែបទាំងអស់ លោកចាត់ជាកំពូលនៃអកុសលធម៌ មានន័យដូចលោភៈ ទោសៈ មោហៈ ទាំង ៣ នេះ ជាឫសអកុលស មានបមាទៈជាឫសកែវរបស់ឫសទាំង៣នេះទៀត ដូចន័យថាៈ បមាទមូលកា សេចក្ដីប្រមាទជាឫសគល់របស់អកុសលមូលទាំង ៣ ។

ចប់បកិណ្ណកៈពួករាត់រាយ

---

# ប្រស្នាប្រជុំកងធម៌

## ឯមត្ថ រតនត្ថយស្ស

វេលានេះ សូមពណ៌នានូវប្រស្នាប្រជុំកងធម៌ ភាគទី ២ ថ្នាក់ត្រី ដូចមានសេចក្តីតទៅនេះ ៖

បុច្ឆា **សាសនា** ប្រែថា ដូចម្តេច ?

វិស្សជ្ជនា **សាសនា** ប្រែថា ពាក្យប្រៀនប្រដៅ ។

បុ. សាសនា មានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. សាសនា មាន ២ យ៉ាង គឺ: ពាហិរសាសនា ១, ពុទ្ធសាសនា ១ ។

បុ. សាសនាទាំងពីរនេះ មានសេចក្តីអធិប្បាយដូចម្តេច ?

វិ. សាសនាទាំងពីរនេះមានសេចក្តីអធិប្បាយដូច្នេះ ពាហិរ-សាសនា បានដល់សាសនាខាងក្រៅអំពីពុទ្ធសាសនាទាំងប៉ុន្មាន មានព្រាហ្មណសាសនាជាដើម; ពុទ្ធសាសនាបានដល់សាសនា របស់ព្រះសម្មាសម្ពុទ្ធជាបរមគ្រូ ។

បុ. ពុទ្ធសាសនា សាសនរបស់ព្រះពុទ្ធនោះ បើចែកដោយសង្ខេបមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. ពុទ្ធសាសនា សាសនារបស់ព្រះពុទ្ធនោះ បើចែកដោយសង្ខេបមាន ៣ យ៉ាងគឺៈ

**១-សព្វបាបស្ស អករណំ** មិនឱ្យធ្វើអំពើបាបទាំងពួង គឺវៀរ ចាកទុច្ចរិតប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត;

**២-កុសលស្សូបសម្បទា** ញុំាងកុសលឱ្យដល់ព្រម គឺឱ្យប្រកបសុចរិតប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត;

**៣-សចិត្តបរិយោទបនំ** ជម្រះចិត្តរបស់ខ្លួនឱ្យផូរផង់ចាកគ្រឿងសៅហ្មង មានលោភៈ ទោសៈ មោហៈ ជាដើម ។

បុ. ពុទ្ធសាសនាមានត្រឹមតែប៉ុណ្ណឹងទេ ឬមានចែកទៅទៀតដែរ? បើមានចែកតើមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. ពុទ្ធសាសនាមិនមែនមានត្រឹមតែប៉ុណ្ណឹងទេ នៅមានចែកទៅ ៣ យ៉ាងទៀតគឺៈ

**១-យថាបរាធសាសនា** ពាក្យប្រៀនប្រដៅតាមសមគួរដល់ទោសកំហុសសត្វ បានដល់វិន័យបិដក;

**២-យថានុលោមសាសនា** ពាក្យប្រៀនប្រដៅអនុលោមតាមសមគួរដល់អធ្យាស្រ័យ, វិស័យ និងចរិយារបស់សត្វ បានដល់សុត្តន្តបិដក;

**៣-យថាធម្មសាសនា** ពាក្យប្រៀនប្រដៅដ៏សមគួរដល់ធមិខ្ពស់ បានដល់មគ្គនិងផល បានដល់អភិធម្មបិដក ។

## សាសនានៅមាន ៣ យ៉ាងទៀតគឺ

**១-បរិយត្តិសាសនា** ពាក្យប្រៀនប្រដៅឱ្យទន្ទេញរៀនសូធ្យក្នុងបិដកទាំង ៣;

**២-បដិបត្តិសាសនា** ពាក្យប្រៀនប្រដៅឱ្យប្រតិបត្តិតាមសមគួរដល់ធមិ ចំណែកគ្រហស្ថមានទានសីលជាដើម, ចំណែកបព្វជិតមានសីលនិងសមាធិជាដើម និងកិច្ចវត្តផ្សេងៗ;

**៣-បដិវេធសាសនា** ពាក្យប្រៀនប្រដៅឱ្យត្រាស់ដឹងនូវ មគ្គនិងផល ។

បុ. បរិយត្តិ បើចែកតាមប្រភេទមានប៉ុន្មាន? គឺអ្វីខ្លះ?

វិ. បរិយត្តិ បើចែកតាមប្រភេទមាន ៣ យ៉ាងគឺៈ

**១-អលគទ្ទូបមាបរិយត្តិ** រៀនដើម្បីលាភក្នុងបច្ចុប្បន្ន;

**២-និស្សរណបរិយត្តិ** រៀនដើម្បីរលាស់ចេញចាកទុក្ខ;

**៣-ភណ្ឌាគារិកបរិយត្តិ** រៀនដើម្បីរក្សានូវវង្សបរិយត្តិ ។

បុ. ប្រភេទនៃបរិយត្តិទាំង ៣ នេះ មានសេចក្តីអធិប្បាយដូចម្តេចខ្លះ?

វិ. មានសេចក្តីអធិប្បាយថា: បរិយត្តិមានឧបមាដូចជាពស់មានពិស គឺបរិយត្តិដែលបុគ្គលរៀនមិនល្អ មានរៀនប្រាថ្នាតែលាភ និងគ្រាន់តែប្រណាំងប្រជែងដណ្តើមយកសុខ ក្នុងបច្ចុប្បន្ន គ្រាន់តែដោះពាក្យតំណិះដំណៀលជាដើមប៉ុណ្ណោះ រៀនហើយមិនពិចារណានូវសេចក្តីនៃធម៌នោះៗ មិនពិនិត្យឱ្យជាក់ច្បាស់ ឱ្យបានគុណវិសេសដែលត្រូវបាន ត្រឡប់ជាបានសេចក្តីទុក្ខវិញ ព្រោះតែរៀនមិនល្អ ដូចបុរសឃើញពស់ហើយលូកដៃទៅចាប់ត្រង់កន្ទុយ ពស់វាងាកបែរមកចឹកវិញ ជួនកាលត្រូវកដៃជាដើម បុរសនោះរមែងដល់មរណៈ បើពុំនោះសោតទេដល់នូវសេចក្តីទុក្ខស្មើរតែស្លាប់ ព្រោះហេតុអ្វី? ព្រោះតែខ្លួនចាប់មិនល្អ ពស់វាចឹកយ៉ាងណាមិញ, មោឃបុរសក្នុងសាសនានេះ ដែលរៀនធម៌មិនល្អក៏ដូច្នោះ បរិយត្តិបែបនេះ ឈ្មោះថា អលគទ្ទូបរិយត្តិ ។ បរិយត្តិដែលបុគ្គលរៀនប្រាថ្នានឹងបំពេញនូវខន្ធ មានសីលក្ខន្ធជាដើម ដើម្បីនឹងរលាស់ខ្លួនឱ្យផុតពីវដ្តទុក្ខ បរិយត្តិបែបនេះ ឈ្មោះថា និស្សរណបរិយត្តិ ។ បរិយត្តិដែលព្រះខីណាស្រពលោករៀនដើម្បីនឹងរក្សាទុកនូវវង្សព្រះពុទ្ធសាសនាប៉ុណ្ណោះ បរិយត្តិបែបនេះ ឈ្មោះថា ភណ្ឌាគារិកបរិយត្តិ ។

# ធុរសាសនា

បុ. ធុរៈ ប្រែថា ដូចម្តេច ?

វិ. ធុរៈ ប្រែថា ទ្រទ្រង់ ។

បុ. ធុរៈក្នុងសាសនាប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. ធុរៈ ក្នុងសាសនាមាន ២ យ៉ាងគឺៈ គន្ថធុរៈ ១, វិបស្សនាធុរៈ ១ ។

បុ. គន្ថធុរៈនោះ តើទ្រទ្រង់ដូចម្តេច ?

វិ. គន្ថធុរៈនោះ គឺទ្រទ្រង់នូវគម្ពីរ គឺរៀនសូធ្យក្នុងបិដកទាំង ៣ ហើយប្រតិបត្តិតាមការដែលរៀនសូធ្យនោះ ។

បុ. វិបស្សនាធុរៈ នោះទ្រទ្រង់ដូចម្តេច ?

វិ. វិបស្សនាធុរៈនោះ លោកនៅក្នុងទីសេនាសនៈដ៏ស្ងាត់ ហើយចម្រើននូវសមថកម្មដ្ឋាន និង វិបស្សនាកម្មដ្ឋាន ។

# លំអសាសនា

បុ. លំអសាសនាមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. លំអសាសនាមាន ៣ យ៉ាងគឺៈ

១-អាទិកល្យាណោ លំអខាងដើមបានដល់សីល;

២-មជ្ឈេកល្យាណោ លំអកណ្តាលបានដល់សមាធិ;

៣-បរិយោសានកល្យាណោ លំអខាងចុងបំផុតបានដល់បញ្ញា ។

## អង្គសាសនា

បុ. អង្គរបស់សាសនាមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. អង្គរបស់សាសនាមាន ៩ យ៉ាងគឺៈ **សុត្តៈ ១**, **គេយ្យៈ ១**, **វេយ្យាករណៈ ១**, **គាថា ១**, **ឧទានៈ ១**, **ឥតិវុត្តកៈ ១**, **ជាតក ១**, **អព្ភុតធម្មៈ ១**, **វេទល្លៈ ១** ។

បុ. ចុះអង្គទាំង ៩ នេះ បានសេចក្តីយ៉ាងណាខ្លះ?

វិ. អង្គទាំង ៩ នេះ បានសេចក្តីយ៉ាងនេះថា សុត្តៈ បានដល់ឧភតោវិភង្គ និទ្ទេស ខន្ធកៈ និងបរិវារៈជាដើមផង បានដល់ពួកសុត្រក្នុងសុត្តនិបាតមានមង្គលសូត្រ រតនសូត្រ នាលកសូត្រ តវដ្តកជាដើមផង និងបានដល់ពុទ្ធវចនៈដទៃ ដែលមានឈ្មោះថាសុត្តន្តផង ។ គេយ្យៈ បានដល់សូត្រដែលប្រកបដល់គាថាទាំងអស់ និងសគាថាទាំងអស់ ក្នុងសំយុត្តនិកាយ ។ វេយ្យាករណៈ បានដល់អភិធម្មបិដក និងសូត្រដែលមិនលាយដោយគាថា ហើយនិងពុទ្ធវចនៈដទៃ ដែលមិនសង្គ្រោះចូលក្នុងអង្គទាំង ៨ នេះផង ។ គាថា បានដល់ធម្មបទថេរគាថា

ថេរីគាថា ដែលជាគាថាសុទ្ធមិនមានឈ្មោះថាសូត្រ ។ **ឧទាន:** បានដល់សូត្រទាំង ៨២ ដែលប្រកបដោយគាថា អាស្រ័យសោមនស្សញ្ញាណ ។ **ឥតិវុត្តកៈ** លោកសង្គ្រោះយកសូត្រ ១១០ ដែលពួកសាវ័កសំដែងដល់ព្រះពុទ្ធដីកាថា ‹‹*វុត្តញ្ហេតំ ភគវា*›› អាងដល់ព្រះពុទ្ធដីកានេះ ដែលព្រះមានជោគទ្រង់ត្រាស់សម្ដែងហើយដូច្នេះជាដើម ។ **ជាតក** គឺរឿងរ៉ាវដែលព្រះអង្គសំដែងស្រាវជ្រាវអំពីអតីតៈ សំដៅយកជាតក ៥៥០ មានអបណ្ណកជាតកជាដើម ។ **អព្ភូតធម្មៈ** បានដល់ព្រះសូត្រទាំងអស់ ដែលប្រកបដោយអច្ឆរិយព្ភូតធម៌ គឺធម៌ដែលព្រះសំដែងមានពាក្យថា មិនដែលកើត ឥឡូវនេះកើតឡើងហើយ គួរអស្ចារ្យស្ញើចពេក បានដល់សូត្រមានបាលីថា **ចត្តារោមេ ភិក្ខវេ អច្ឆរិយា អព្ភូតធម្មា អានន្ទេ** ម្នាលភិក្ខុទាំងឡាយ ធម៌មិនដែលកើតហើយកើតឡើងបាន គួរអស្ចារ្យ ៤ ប្រការនេះរមែងមានក្នុងអានន្ទ›› ដូច្នេះជាដើម ។ **វេទល្លៈ** គឺសូត្រដែលគេសួរបានចេះដឹង មានសេចក្ដីរីករាយ ហៅថា វេទល្ល ។ អង្គសាសនាមាន ៩ យ៉ាងដូចពណ៌នាមកនេះ ។

# ព្រះពុទ្ធសាសនារុងរឿង និង សាបសូន្យ

បុ. ព្រះពុទ្ធសាសនាដែលរុងរឿងដោយហេតុប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. ព្រះពុទ្ធសាសនាដែលរុងរឿងដោយហេតុ ៥ យ៉ាងគឺៈ

១-សក្កច្ចំ ធម្មំ សុណន្តិ បរិស័ទស្តាប់ធម៌យកចិត្តទុកដាក់ដោយគោរព;

២-សក្កច្ចំ ធម្មំ បរិយាបុណន្តិ បរិស័ទរៀនសូត្រធម៌យកចិត្តទុកដាក់ដោយគោរព;

៣-សក្កច្ចំ ធម្មំ ធារេន្តិ បរិស័ទទ្រទ្រង់ធម៌ទុកដោយគោរព;

៤-សក្កច្ចំ ធតានំ ធម្មានំ ឧបបរិក្ខន្តិ បរិស័ទចូលទៅជិតរំពឹងនូវអត្ថនៃធម៌នោះៗ ដោយគោរព;

៥-សក្កច្ចំ ធម្មានំ បដិបជ្ជន្តិ បរិស័ទប្រតិបត្តិតាមធម៌នោះៗ ដោយគោរព ។

បុ. សាសនាទាំងអស់នេះ អ្វីជាដើមសាសនា, អ្វីជាកណ្តាលសាសនា, អ្វីជាខាងចុងសាសនា ?

វិ. សាសនាទាំងអស់នេះ ខាងដើមសាសនា បានដល់សរណៈគមន៍ ៣, កណ្ដាលសាសនាគឺសីល ៥ សុចរិត ១០, ខាងចុងសាសនា គឺអរិយសច្ច ៤ ។

បុ. ហេតុដូចម្ដេចបានជាចាត់សរណគមន៍ជាខាងដើម ?

វិ. បានជាចាត់ទុកសរណគមន៍ជាខាងដើមនោះ ព្រោះទីពឹងព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាមុន ដូចយ៉ាងគ្រហស្ថដែលកាន់សាសនា ត្រូវថ្វាយខ្លួនចំពោះព្រះរតនត្រ័យ ទើបពេញជាឧបាសកឧបាសិកា ចំណែកបព្វជិតក៏គង់ប្រិតប្រៀនដោយសរណៈគមន៍ខាងដើម ទើបពេញជាសាមណេរ បានជាចាត់ថាសរណៈគមន៍ជាខាងដើមនៃសាសនា ។

បុ. ហេតុដូចម្ដេចបានជាចាត់សីលនិងសុចរិតជាកណ្ដាល?

វិ. បានជាចាត់សីលនិងសុចរិតជាកណ្ដាលនោះ ព្រោះថាបើដល់សរណគមន៍ហើយ ទើបប្រព្រឹត្តល្អទៅបាន បានជាចាត់សីលនិងសុចរិតនោះជាកណ្ដាល ។

បុ. ហេតុដូចម្ដេចបានជាចាត់អរិយសច្ចជាខាងចុង ?

វិ. បានជាចាត់អរិយសច្ចទុកជាខាងចុងនោះ ព្រោះបុគ្គលណាដែលបានឃើញសច្ចទាំង ៤ ដោយជាក់ច្បាស់ហើយ អស់កិច្ច

អ្វីនឹងសិក្សាទៅទៀតហើយ  បានជាលោកចាត់អរិយសច្ចនេះជាសោឡសកិច្ច ។

បុ. អរិយសច្ច ៤ នោះ ចាត់ជាសោឡសកិច្ចដូចម្ដេច?

វិ. អរិយសច្ច ៤ នោះ ចាត់ជាសោឡសកិច្ចដច្នេះគឺ: ទុក្ខសច្ចជាបរិញ្ញាកិច្ច  ជាកិច្ចគឺព្រះយោគាវចរ  គប្បីកំណត់ដឹងនូវទុក្ខ, សមុទសច្ចជាបហានកិច្ច  ជាកិច្ចគឺព្រះយោគាវចរគប្បីលះបង់, និរោធសច្ច  ជាសច្ឆិកាតព្វកិច្ច  ជាកិច្ចគឺព្រះយោគាវចរគប្បីធ្វើឱ្យជាក់ច្បាស់  មគ្គសច្ចជាភាវេតព្វកិច្ច  ជាកិច្ចគឺព្រះយោគាវចរគប្បីចម្រើន ។ ក្នុងកិច្ចទាំង ៤ នេះ ចែកតាមគ្គទាំង ៤ មគ្គមួយៗមាន ៤ៗ បួនៗ ដង ត្រូវជា ១៦ ។

បុ. សាសនា ពាក្យប្រៀនប្រដៅក្នុងបិដកទាំង ៣ នេះ សុទ្ធតែព្រះពុទ្ធប្រដៅ ឬមានអ្នកឯទៀតប្រៀនប្រដៅដែរ?

វិ. សាសនាទាំងអស់នេះ គេប្រដៅបានគ្រប់គ្នា ដូចសីលក៏មានគេប្រដៅបាន សមាធិគង់មានពួកព្រាហ្មណ៍ប្រដៅកើត, ធម៌ឯងទៀតគង់មានគេប្រដៅកើតដូចគ្នា ។

បុ. ចុះព្រះពុទ្ធវិសេសជាងគេត្រង់ណា?

វិ. ព្រះពុទ្ធដែលវិសេសជាងគេនោះ គឺព្រះអង្គត្រាស់ដឹងនូវអរិយសច្ចទាំង ៤ ហើយប្រដៅពុទ្ធបរិស័ទឱ្យត្រាស់ដឹងតាម ។

បុ. សាសនានឹងសាបសូន្យទៅដោយហេតុប៉ុន្មានយ៉ាង?

វិ. សាសនានឹងសាបសូន្យទៅដោយហេតុ ៥ យ៉ាង គឺៈ

**១-ន សក្កច្ចំ ធម្មំ សុណន្តិ** បរិស័ទមិនស្តាប់ធម៌ដោយយកចិត្តទុកដាក់;

**២-ន សក្កច្ចំ ធម្មំ បរិយាបុណន្តិ** បរិស័ទមិនរៀនសូធ្យធម៌ដោយគោរព;

**៣-ន សក្កច្ចំ ធម្មំ ធារេន្តិ** បរិស័ទមិនទ្រទ្រង់ធម៌ទុកដោយគោរព;

**៤-ន សក្កច្ចំ ធតានំ ធម្មានំ ឧបបរិក្ខន្តិ** បរិស័ទមិនចូលទៅជិតរំពឹងនូវអត្ថនៃធម៌នោះៗ ដោយគោរព;

**៥-ន សក្កច្ចំ ធម្មំ បដិបជ្ជន្តិ** បរិស័ទមិនប្រតិបត្តិតាមធម៌នោះៗ ដោយគោរព ។

បុច្ឆា-វិស្សជ្ជនាមកក្នុងសាសនានេះចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

# ទាន និង ចាគៈ

បុ. **ទាន** និង **ចាគៈ** ទាំងពីរនេះ មានសេចក្តីផ្សេងគ្នា ឬដូចគ្នា?

វិ. ទាន និង ចាគៈ មានសេចក្តីផ្សេងគ្នាខ្លះ ត្រូវគ្នាខ្លះ ។

បុ. ចុះផ្សេងគ្នាត្រង់ណា? ដូចគ្នាតើត្រង់ណា?

វិ. ដែលផ្សេងគ្នានោះ ផ្សេងគ្នាត្រង់ចាគៈចែកជាពីរយ៉ាងគឺៈ

អាមិសចាគៈ លះបង់អាមិស, កិលេសចាគៈ លះបង់កិលេស; ដែលត្រូវគ្នានោះ គឺអាមិសចាត់ចូលក្នុងទានដូចគ្នា ទានក៏គង់ឱ្យអាមិស, ចាគៈក៏លះបង់អាមិស ទានក៏គង់មានចាគ-ចេតនាទៅខាងក្នុងដែរ បានទៅជាទានកើត ឯទាននេះប្រកបដោយបដិគ្គាហៈអ្នកទទួលទៀត ចំណែកចាគៈបើគ្មានអ្នកទទួលគង់លះកើត ដូចយ៉ាងកិលេសចាគៈ លះកិលេសមានអ្នកណាទទួល ។

បុ. បូជា និង ទានផ្សេងគ្នា ឬដូចគ្នា ?

វិ. ផ្សេងគ្នាតែបាលី ឯសេចក្តីដូចគ្នា ប៉ុន្តែឱ្យតាមជាន់បុគ្គលអ្នកទទួល បើបូជាចំពោះព្រះពុទ្ធព្រះធម៌ព្រះសង្ឃ មានចិត្តជ្រះថ្លា ឬគ្រូឧបជ្ឈាយាចារ្យ មាតាបិតាដែលមានគុណលើខ្លួន

បូជានេះជាអសាធារណៈ មិនទូទៅដល់បុគ្គលដទៃ បើចាត់ជាទានហៅថា បូជាទាន, ចំណែកទានទទេនោះ ឱ្យទូទៅមិនមានរើសបុគ្គលណា ទានចែកជា ២ គឺ សង្គហទាន ឱ្យដោយសង្គ្រោះដល់អ្នកកំសត់ទុគ៌ត ហៅថា សង្គហទាន ឱ្យដល់អ្នកមានគុណធមិខ្ពង់ខ្ពស់ ហៅថា បូជាទាន ។

បុ. ចុះទានចែកជា ២ ជាបាដិបុគ្គលិកទាន និងសង្ឃគតាទក្ខិណាទាន ព្រះពុទ្ធទ្រង់សរសើរថាៈ សង្ឃគតាទក្ខិណាទានប្រសើរជាងបាដិបុគ្គលិកទាន សូម្បីថ្វាយដល់ព្រះពុទ្ធបានបុណ្យមិនដល់សង្ឃគតាទក្ខិណាទាន ចុះហេតុអ្វីបានជាសង្ឃគតាទក្ខិណាទាន មិនដែលឱ្យផលជាទិដ្ឋធម្មវេទនីយ៍សោះ ហាក់ដូចជាបាដិបុគ្គលិកទានបានផលច្រើនជាង?

វិ. សង្ឃគតាទក្ខិណាទាន នៅតែមានបុណ្យច្រើនជាង ឱ្យតាំងពីថ្ងៃធ្វើទៅទល់នឹងបានព្រះនិព្វានទើបអស់ ចំណែកទិដ្ឋធម្មវេទនីយ៍នោះ ឱ្យតែក្នុងមួយជាតិនេះទេ មិនជូនទៅជាតិមុខទៀតឡើយ ប្រៀបដូចជាអ្នកធ្វើស្រែធ្វើស្រូវស្រាល ៣ ខែឆាប់បាន តែមិនសូវបានផលច្រើន អ្នកធ្វើស្រូវធ្ងន់ពិតមែនតែយូរ

ប៉ុន្តែមានផលច្រើនជាង, ទិដ្ឋធម្មវេទនីយ ដូចជាស្រូវស្រោស, សង្ឃគតាទក្ខិណាទាន ដូចជាធ្វើស្រូវធ្ងន់ ។

បុ. ទាននេះប្រកបដោយធម៌ប៉ុន្មានយ៉ាងទើបបានបុណ្យ? គេឱ្យទានដទៃៗ ក្រៅសាសនាគង់គេឱ្យកើតដែរ ក៏មិនចាត់ថាបានបុណ្យផង?

វិ. ទានប្រកបដោយធម៌ ៤ យ៉ាងគឺ សទ្ធា ១, ហិរិ ១, ចាគចេតនា ១, វិរតិ ១, ទើបបានបុណ្យ, គេឱ្យទានដទៃៗ ក្រៅសាសនា បានជាចាត់ថាមិនបានបុណ្យ ព្រោះមិនប្រកបដោយធម៌ ៤ យ៉ាងនេះ ។

បុ. ចំណែកអាមិសទាន មានចែកជា ២ ជា ៣ តាមលំដាប់ទៅ ចុះធម្មទានមានចែកយ៉ាងហ្នឹងដែរ ឬគ្មានទេ?

វិ. ធម្មទានមានចែកជា ២ យ៉ាងដែរគឺ ជាលោកិយធម្មទាន ១, ជាលោកុត្តរធម្មទាន ឬជាសិក្ខិមត្តធម្មទាន ១ ពាក្យទាំង ២ ម៉ាត់នេះជាវេវចនៈនិងគ្នា ។

បុ. ចុះលោកិយធម្មទាននោះ សំដែងធម៌ដូចម្ដេច?

វិ. លោកិយធម្មទាននោះ សំដែងថា ‹‹ធម៌នេះជាកុសល ធម៌នេះជាអកុសល ធម៌នេះជាបុណ្យ ធម៌នេះជាបាប ធម៌នេះប្រកប

ដោយទោស ធម៌នេះមិនប្រកបដោយទោស ធម៌នេះជាសុចរិត›› ជាដើម ។

ទានដែលចែកជា ២ នោះ គឺចែកដោយអំណាចបដិគ្គាហកៈ អ្នកទទួលជាសង្ឃខ្លះ ជាបុគ្គលខ្លះ ។

បុ. ចែកជាពីរទៀត ជាសង្ឃទាន និងបូជាទានដោយហេតុអ្វី?

វិ. ចែកដោយអំណាចបុគ្គលថោកទាបនិងបុគ្គលជាន់ខ្ពស់ បុគ្គលថោកទាបឱ្យដោយមេត្តាចិត្ត បុគ្គលជាន់ខ្ពស់ឱ្យដោយចិត្តជ្រះថ្លាចំពោះគុណធម៌របស់លោក ។

បុ. ទានដែលចែកជាបីយ៉ាងគឺៈ ទាសទាន ១, សហាយ-ទាន ១, សាមិទាន ១ ដោយហេតុអ្វី ?

វិ. ទានទាំង ៣ នេះ ចែកដោយអំណាចទេយ្យធម៌ថោកទាប, កណ្ដាល និងជាន់ខ្ពស់ ។

បុ. ឱ្យទេយ្យធម៌ដូចម្ដេចឈ្មោះថាជាទាសទាន?

វិ. ឱ្យទេយ្យធម៌ថោកទាបជាទាន របស់ណាល្អៗលាក់ទុកដូចជាឱ្យរបស់ទៅខ្ញុំកំដរស៊ី ការឱ្យដូច្នេះ កិលេសអាចគ្របសង្កត់បាន ជាខ្ញុំតណ្ហា ។

បុ. ឱ្យទេយ្យធម៌ដូចម្ដេចដែលជាសប្បាយទាន?

វិ. ទេយ្យធម៌ណាដែលខ្លួនស្រឡាញ់ ប្រើប្រាស់បែបណា ក៏ឱ្យរបស់បែបនោះ ។

បុ. សាមីទាននោះឱ្យទេយ្យធម៌ដូចម្ដេច?

វិ. សាមិទាននោះឱ្យរបស់ខ្ពង់ខ្ពស់ថ្លៃថ្លា លើសរបស់ប្រើ-ប្រាស់របស់ខ្លួន ឬរបស់ដែលមានបន្ទិចបន្តួច ស៊ូអត់មាត់ឯង ហើយផ្តាច់ឱ្យទៅជាទាន ក៏ចាត់ថាសាមិទានដែរ ។

អានិសង្សទានថាបានភោគសម្ប័ទ អានិសង្សសីលថា បានរូបល្អ មានអាយុវែង ហេតុដូចម្ដេចបានជាអានិសង្សទានទាំង ៥ អានិសង្សទី ១ ថា បិយោ ប្រែថា ជាទីស្រឡាញ់ទៅវិញ មិនឮថាបានភោគសម្ប័ទ, អានិសង្សសីលទាំង ៥ អានិសង្សទី ១ ថា ភោគក្ខន្ធំ អធិគច្ឆតិ ប្រែថា បាននូវគំនរទ្រព្យ មិនឮថាបានអាយុវែង គួរឆ្ងល់ណាស់អានិសង្សទាំង ២ នេះ? ចូរអធិប្បាយមកមើល!

វិ. ទានថាបានភោគសម្ប័ទនោះនៅតែបាន សីលដែលថាបានអាយុវែងក៏នៅតែបាន នោះគេនិយាយសំដៅទៅជាតិមុខទេតើ ក្នុងបច្ចុប្បន្ននេះ ទានត្រូវបានគេស្រឡាញ់ ដូចអានិសង្សទី

១ ថា បិយោ នោះមែនហើយ កុំសូម្បីឡើយដល់មនុស្ស សូម្បីតែសត្វតិរច្ឆានតែឱ្យវាស៊ីហើយ ក៏វាស្រឡាញ់ដែរ ចំណែកសីលត្រូវបានភោគសម្ប័ទក្នុងបច្ចុប្បន្ននេះ ថាអ្នករក្សាសីល តែងរក្សាគំនិតមារយាទល្អ លះបង់នូវអបាយមុខ ទ្រព្យសម្បត្តិដែលរកបានមកក៏ចេះតែចម្រើនឡើងៗ បានជាចាត់ថាឱ្យមានទ្រព្យសម្បត្តិក្នុងបច្ចុប្បន្ននេះ ដូចអានិសង្សទី១ថា ភោគក្ខន្ធំ អធិគច្ឆតិ នោះមែនដែរ ។

បុ. ហេតុដូចម្ដេចបានជាភាវនាមានកម្លាំងជាងសីល ជាងទាន?

វិ. បានជាភាវនាមានកម្លាំងជាងនោះ ព្រោះភាវនាមានកម្លាំងឱ្យដល់នូវព្រះនិព្វានឆាប់ សីលសម្រាប់បិទបាំងនូវអបាយបាន ទានបិទនូវអបាយមិនបានទេ គ្រាន់តែមានទ្រព្យប៉ុណ្ណោះ ដូចពុទ្ធភាសិតថា: **ទានេន ភោគវា ហោតិ, សីលេន ហោតិ រូបវា, ភាវនា ពលេនេវ និព្វានគមិលបាកំ** ប្រែថា អ្នកណាឱ្យទានកើតជាតិមុខមានទ្រព្យ, អ្នកណារក្សាសីលកើតជាតិមុខ មានរូបល្អ-អាយុវែង, អ្នកណាចំរើនភាវនា មានកម្លាំងដល់ព្រះនិព្វានឆាប់; បានជាថា ភាវនានេះមានកម្លាំងជាងសីលជាងទាន ។

បុ. បើដូច្នោះឧស្សាហ៍ធ្វើតែភាវនាតែម៉្យាងទៅបានហើយឬ កុំចាំបាច់រក្សាសីល កុំចាំបាច់ធ្វើទានធ្វើអ្វី ព្រោះភាវនាប្រសើរជាងទាននិងសីលទៅហើយ?

វិ. មិនបានទេ ត្រូវតែធ្វើទាំង ៣ ពិតមែនតែភាវនាឱ្យដល់នូវព្រះនិព្វានឆាប់ក៏មែនហើយ តែថាគង់អាស្រ័យសីលទានដែរទើបទៅព្រះនិព្វានបាន ធ្វើទានដើម្បីឱ្យមានទ្រព្យទៅជាតិមុខចិត្តក៏ល្អមិនខ្វះខាត ធម្មតាអ្នកក្រីក្រចិត្តមិនល្អទេ មកអំពីការខ្វះខាតជានិច្ច រក្សាសីលមិនទៅកាន់អបាយ និងបានកសាងសន្សំកុលសឱ្យបានច្រើន ធម្មតាសត្វដែលទៅកើតក្នុងអបាយ មានពេលឯណានឹងសន្សំកុសលកើត ទានសីលទាំងពីរជាជំនួយដល់ភាវនា ទានសីលនេះជានិស្ស័យនិងបាននូវមគ្គ ៣ ជាងខាងក្រោម ចំណែកភាវនាបាននូវមគ្គខាងលើ បានជាថាធ្វើតែមួយៗពុំបាន លុះតែធ្វើទាំង ៣ ទើបសម្រេចដល់ព្រះនិព្វានបាន ។

បុ. ទានលះអ្វី? សីលលះអ្វី? ភាវនាលះអ្វី?

វិ. ទានលះបង់នូវសេចក្តីលោភៈ, សីលលះបង់នូវទោសៈ, ភាវនាលះបង់នូវមោហៈ ។

បុ. ទាន សីល ភាវនា និង សីល សមាធិ បញ្ញា ផ្សេងគ្នាដូចម្តេច បានជាម្តងថា ទាន សីល ភាវនា ម្តងថាសីល សមាធិ បញ្ញា ?

វិ. ធម៌ទាំងនេះផ្សេងគ្នាដោយរូបបុគ្គល ចំណែកទាន សីល ភាវនា ព្រះទ្រង់សម្តែងចំពោះគ្រហស្ថ អ្នកនៅគ្រប់គ្រងផ្ទះឯសីល សមាធិ បញ្ញា ព្រះទ្រង់សំដែងចំពោះបព្វជិត ព្រោះបព្វជិតត្រូវធ្វើតែសីល សមាធិ បញ្ញា ឱ្យបរិសុទ្ធ គ្មានកិច្ចអ្វីនឹងធ្វើទានឡើយ គ្រាន់តែជាបដិគ្គាហកៈអ្នកទទួលទានប៉ុណ្ណោះ ។

បុ. លោភៈ ទោសៈ មោហៈ និង រាគៈ ទោសៈ មោហៈ ផ្សេងគ្នាដូចម្តេច?

វិ. ផ្សេងគ្នាខ្លះ ដូចគ្នាខ្លះ រាគៈ និងលោភៈ ផ្សេងគ្នា, ទោសៈ និងមោហៈ ដូចគ្នា តែព្រះអង្គទ្រង់សំដែងចំពោះបុគ្គល, លោភៈ ទោសៈ មោហៈ ចំពោះឃរាវាស, រាគៈ ទោសៈ មោហៈ ចំពោះបព្វជិត ។

បុ. លោភៈ និង រាគៈ ផ្សេងគ្នាដូចម្តេច ?

វិ. ផ្សេងគ្នាដូច្នេះ លោភៈ គឺលោភចង់បានរបស់បុគ្គលដទៃមកជារបស់ខ្លួន តែប្រពន្ធនៅមាន ឥតមានហាមឃាត់ឡើយ តែ

កុំឱ្យប៉ះពាល់ទៅលើប្រពន្ធកូនរបស់គេ ចំណែករាគៈ វៀរទាំង-អស់ ចំពោះមេថុនធម្ម បានជាថាធម៌នេះសម្រាប់វៀរបង់ដោយដាច់ខាត ។

បុ. សីល សមាធិ បញ្ញា លះបង់អ្វីខ្លះ ?

វិ. សីលលះបង់ទោសៈ សមាធិលះបង់រាគៈ បញ្ញាលះបង់មោហៈ ។

បុ. សីលមានហើយជាហេតុឱ្យចំរើនដល់សមាធិៗ មានហើយជាហេតុឱ្យចម្រើនដល់បញ្ញាៗ មានហើយជាហេតុឱ្យចំរើនដល់វិមុត្តិ ធម៌នេះពិនិត្យទៅឃើញថា វិមុត្តិបានមកអំពីបញ្ញាៗ បានមកអំពីសមាធិៗ បានមកកើតមកអំពីសីល ចុះដូចយ៉ាងរឿងខ្លះដែលមិនទាន់បានរក្សាសីល ស្រាប់តែបានអរហត្តតែម្តង ដូចយ៉ាងអង្គុលិមាល, អរិយឧបាសក មិនដែលបានទៅសមាទានសីលវត្តណាម្តង បើដូច្នេះរឿងនេះមិនខុសទៅហើយឬ?

វិ. រឿងនេះមិនខុសទេនៅតែត្រូវពិត បើទុកជាបានអរហត្តក៏គង់កើតពីសីល សមាធិ ជាលំដាប់ដែរ សីលកើតព្រមជាមួយនឹងអរិយមគ្គ ហៅថា សមុច្ឆេទវិរតិចេតនា ។

បុ. សីល និង សុចរិត សេចក្ដីផ្សេងគ្នាដូចម្ដេច បានជាមានសីលហើយដាក់សុចរិតទៀត ?

វិ. សីល និង សុចរិត ផ្សេងគ្នាដូច្នេះ សីលមានចែកដោយឡែកៗ មានចែកជាសីល ៥ សីល ៨ សីលជាលំដាប់តទៅ សីលប៉ុណ្ណេះ មិនទាន់អស់ពួកអកុសលធម៌ផ្សេងៗ ចំណែកសុចរិតជាតែសុចរិតប៉ុណ្ណោះ ក៏ចប់ពួកកុសលធម៌ទាំងអស់ ដែលប្រព្រឹត្ដដោយកាយវាចាចិត្តទាំងប៉ុន្មាន ប្រៀបដូចគ្រឿងផ្ទះកាលដែលនៅរាយនៅឡើយ គេហៅថា ផ្ទាង បង្កង់ ដៃរណែងជាដើម ដូចជាកុសលធម៌ផ្សេងៗ ដែលរួបរួមទៅហៅថាផ្ទះតែមួយម៉ាត់ ក៏ដូចពាក្យថាសុចរិតតែមួយម៉ាត់ ក៏ចប់ពួកកុសលធម៌ទាំងអស់ដូច្នោះដែរ ។

បុ. លោភៈ និង មច្ឆរិយៈ ផ្សេងគ្នាដូចម្ដេច ?

វិ. លោភៈ និង មច្ឆរិយៈផ្សេងគ្នាដូច្នេះ លោភៈ ចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ទាំង ៥ មានរូបារម្មណ៍ជាដើម ហើយចិត្តឈ្លានពានចង់បានរបស់អ្នកដទៃ មកជាប្រយោជន៍ខ្លួន លោភៈនេះជាតួចិត្តផងជាតួចេតសិកផង ចំណែកមច្ឆរិយៈ តែងលាក់

លៀមទ្រព្យសម្បត្តិទុកមិនឱ្យអ្នកដទៃឃើញ មច្ឆរិយៈនេះជាតួចេតសិកតែម៉្យាង ។

បុ. ទោសោ និង ទោមនស្ស ផ្សេងគ្នាឬដូចគ្នា ?

វិ. ទោសោ និង ទោមនស្ស មានសេចក្តីផ្សេងគ្នា ចំណែកទោសោប្រទូស្តរ៉ាយដល់សត្វនិងសង្ខារ ដែលមិនជាទីគាប់ចិត្ត ទោសោនេះជាតួអកុសលសុទ្ធ ចំណែកទោមនស្សជាកុសលខ្លះជាអកុសលខ្លះ ជាកុសលនោះ គឺតូចចិត្តនឹងការថោកទាបជាងគេ ព្រោះមកពីបុណ្យតិចពីបុព្វជាតិមក ហើយខំប្រឹងប្រែងធ្វើការកុសលតទៅទៀត ឬដូចព្រះយោគាវចរខំចម្រើនឈានសមាបត្តិក៏នឹកតូចចិត្ត ខំប្រឹងប្រែងទាល់តែបានសម្រេចដូចសេចក្តីប្រាថ្នា; ឯទោមនស្សជាអកុសលនោះគឺ កើតបដិឃៈថ្នាំងថ្នាក់ក្នុងអារម្មណ៍ផ្សេងៗ ។

បុ. មោហៈ និង មិច្ឆាទិដ្ឋិ ជាតួមួយ ឬផ្សេងគ្នា ?

វិ. មោហៈ និងមិច្ឆាទិដ្ឋិនេះជាតួផ្សេងគ្នា មោហៈវង្វេងក្នុងអារម្មណ៍ មោហៈនេះចេញទៅជា វិចិកិច្ឆា, ឧទ្ធច្ចៈ, ចំណែកមិច្ឆាទិដ្ឋិមិនវង្វេងទេ តែគំនិតយល់ខុស មិច្ឆាទិដ្ឋិនេះចែកចេញ

ទៅជា ៣ យ៉ាងគឺៈ អកិរិយទិដ្ឋិ ១, នត្ថិកទិដ្ឋិ ១, អហេតុកទិដ្ឋិ ១, ចេញមុខផ្សេងគ្នាដូចពណ៌នាមកនេះ ។

បុ. អមោហៈ និង សម្មាទិដ្ឋិ ដូចគ្នា ឬផ្សេងគ្នា?

វិ. អមោហៈ និងសម្មាទិដ្ឋិ ផ្សេងគ្នា, អមោហៈគ្រាន់មិនវង្វេង សម្មាទិដ្ឋិជាតួបញ្ញា ។

បុ. យោនិសោមនសិការៈ និងបញ្ញា មានលក្ខណៈផ្សេងគ្នាដូចម្តេច?

វិ. យោនិសោមនសិការៈ និងបញ្ញាមានលក្ខណៈផ្សេងគ្នាដូច្នេះគឺ យោនោសោមនសិការៈ កំណត់ទុករបស់ដែលចេះចាំទាំងប៉ុន្មាន មិនឱ្យភ្លេចទៅវិញ បញ្ញាសម្រាប់អារកាត់នូវសេចក្តីផ្សេងៗ, យោនិសោមនសិការៈ ប្រៀបដូចជាដៃដែលចាប់ស្រូវប្រមូលមក បញ្ញាដូចកណ្តៀវសម្រាប់កាត់ស្រូវឱ្យដាច់ ។

បុ. សិប្បៈ និង វិជ្ជា ផ្សេងគ្នាដូចម្តេច ?

វិ. សិប្បៈ និង វិជ្ជា ផ្សេងគ្នាដូច្នេះ របស់អ្វីដែលឈ្លាសដោយហត្ថកម្មឈ្មោះថា សិប្បៈ ឯវិជ្ជាបានដល់ផ្លូវបញ្ញាដែលចាក់ធ្លុះនូវមគ្គនិងផលដូច្នេះ ឈ្មោះថា វិជ្ជា ។

បុ. បញ្ញា និង វិជ្ជា មានលក្ខណៈផ្សេងគ្នាដូចម្តេច ?

វិ. បញ្ញា និងវិជ្ជា មានលក្ខណៈផ្សេងគ្នាដូច្នេះ បញ្ញា ការពិចារណាដឹងសព្វមិនភាន់ច្រឡំ ឯវិជ្ជាការចាំស្ទាត់នូវមគ្គនិងផល បញ្ញាប្រៀបដូចភ្នែកគ្រាន់តែឃើញ ឯវិជ្ជាប្រៀបដូចអណ្ដាតដឹងរសផ្សេងៗ មានរសសាបប្រៃជាដើម ។

បុ. លោភៈ និង តណ្ហា ផ្សេងគ្នា ឬដូចគ្នា?

វិ. លោភៈ និងតណ្ហា ផ្សេងគ្នាខ្លះ ដូចគ្នាខ្លះ លោភៈ ចិត្តជាប់ជំពាក់ក្នុងកាមគុណ ៥ ហើយចេញទៅជាទិដ្ឋិទាំង ២ គឺៈ សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ, តណ្ហាក៏ប្រកបដោយកាមគុណ ៥ និងទិដ្ឋិទាំងពីរដែរ តែតណ្ហាជាអ្នករាវរកអារម្មណ៍ផ្សេងៗ លោភៈជាអ្នកទុកដាក់នូវអារម្មណ៍ ឬប្រកាននូវអារម្មណ៍ តណ្ហាដូចជាដៃចោរដែលរាវរករបស់ លោភៈដូចជារបស់ដែលបានមកហើយមិនលែងទៅវិញ ។

បុ. វិន័យ និងសីល ផ្សេងគ្នា ឬដូចគ្នា?

វិ. វិន័យ និងសីលផ្សេងគ្នា គឺ វិន័យសម្រាប់នាំបង់នូវទោស គឺទូន្មាននូវកាយ វាចា, សីលបានដល់ចេតនាសម្រាបវៀរតាមសិក្ខាបទនោះៗ អ្នកដែលឈប់ធ្វើអំពើបាបទាំងប៉ុន្មាន ហើយនៅស្ងៀមក៏មិនទាន់ចាត់ថាបានបុណ្យនៅឡើយ លុះណាតែរក្សា

សីលទៀតទើបបានបុណ្យ ហេតុនេះហើយបានជាព្រះសម្ពុទ្ធទ្រង់សំដែងថាៈ សព្វបាបស្ស អករណំ =ហាមមិនឱ្យធ្វើនូវអំពើបាបទាំងពួង, កុសលស្សូបសម្បទា=ទ្រង់តឿនឱ្យបំពេញនូវកុលសថែមទៀត, វិន័យដូចជារបង សីលដូចជាដំណាំនៅក្នុងរបង ។

បុ. ឫសអកុសលធម៌មាន ៣ គឺ លោភៈ ទោសៈ មោហៈ ហេតុអ្វីក៏បានជាសំដែងថា បមាទៈ ជាកំពូលអកុសលថែមទៀត មិនលើសហេតុទៅហើយឬ? បើហេតុអកុសលមានតែត្រឹម ៣ ទេ ?

វិ. មិនលើសទេ ហេតុទាំង ៣ នេះចេញអំពីបមាទៈជាមូលសមដូចពុទ្ធភាសិតសំដែងថា សមាទមូលតា សមាទៈនេះជាឫសគល់របស់លោភៈ ទោសៈ មោហៈ ។

បុ. ព្រះនិព្វានថាអស់បុណ្យបាបហើយ ហេតុអ្វីក៏បានជាសម្តែងថា និស្ស័យទាំង ៣ ទើបបានព្រះនិព្វាន ទានឱ្យមានទ្រព្យសម្បត្តិ, សីលឱ្យមានអាយុវែង, ភាវនាឱ្យកើតបញ្ញា, រវល់តែសោយសម្បត្តិនិងអាយុវែង ហាក់ដូចជានាំឱ្យឆ្ងាយពីព្រះនិព្វានទៅវិញ?

វិ. មិនឆ្ងាយពីព្រះនិព្វានទេ នាំឱ្យកាន់តែជិតឡើង ព្រោះទានឱ្យមានទ្រព្យ លុះមានទ្រព្យនោះច្រើនហើយ នាំឱ្យនឿយណាយក៏ងាយនឹងលះបង់ ឯសីលមានអាយុវែងនាំឱ្យស្លាប់កើតៗ ការស្លាប់កើតនេះនាំឱ្យធុញទ្រាន់ ងាយនឹងលះបង់រូបកាយចោល ហេតុនេះបានជាដាក់ភាវនា ១ ខាងចុង សម្រាប់កាប់ឆ្កាន្ទូវសត្រូវ ឧបមាដូចអ្នកដំណើរដើរទៅកាន់ផ្លូវឆ្ងាយ តោងមានស្បៀងយានជំនិះ និងគ្រឿងអាវុធទៅផង ទើបដល់ស្រុកឆ្ងាយបាន, ទានទុកដូចជាស្បៀង សីលទុកដូចជាយានជំនិះ ភាវនាទុកដូចជាអាវុធសម្រាប់ប្រហារនូវសត្រូវគឺកិលេស ព្រះនិព្វានទុកដូចជាស្រុកឆ្ងាយ ។

បុ. ព្រះពុទ្ធហេតុអ្វីក៏មិនត្រាស់ដឹងឱ្យច្រើនអង្គតែម្តង ក្នុងលោកទៅ ចាំត្រាស់មួយអង្គម្តងៗ ?

វិ. ត្រាស់ច្រើនអង្គមិនបានទេ នាំឱ្យក្រឡាប់ចក្រវាឡ ព្រោះតេជះព្រះពុទ្ធខ្លាំង ឧបមាដូចទូកតូចមួយចំណុះមនុស្សបានតែម្នាក់ តែលើសទៅមុខជានឹងលិច ហេតុនេះហើយបានជាព្រះពុទ្ធមិនត្រាស់ច្រើនអង្គតែម្តង ។

បុ. បានអរហត្តផលចំពោះតែបព្វជិតទេ ឬគ្រហស្ថក៏បានខ្លះដែរ ?

វិ. មិនបានចំពោះតែបព្វជិតទេ គ្រហស្ថក៏បានខ្លះដែរដូចជាសន្តតិមហាមាត្យ ពាហិយបុរស និងព្រះបាទសិរីសុទ្ធោទនៈជាពុទ្ធបិតាជាដើម ។

បុ. បើគ្រហស្ថគេបានព្រះអរហត្តដែរ ចុះចាំបួសធ្វើអ្វីនាំឱ្យលំបាកប្រតិបត្តិតឹងតែង?

វិ. ពិតមែនតែបានដូចគ្នា ប៉ុន្តែអ្នកបួសងាយបានជាង ព្រោះមិនមានការកង្វល់ផ្សេងៗ បើបានអរហត្តហើយនឹងទ្រទ្រង់គុណអរហត្តនោះអស់មួយជីវិតបាន ចំណែកគ្រហស្ថពិតមែនតែបាន ប៉ុន្តែចិតគ្នាណាស់ តែបានហើយត្រូវបួសទើបទ្រទ្រង់នូវគុណអរហត្តបាន បើនៅជាគ្រហស្ថ បានយ៉ាងយូរត្រឹម ៧ ថ្ងៃបរិនិព្វាន ។

បុ. គ្រហស្ថគេបានសោតា សកទាគាមី អនាគាមី គុណធមិខ្ពស់ជាងបព្វជិតជាបុថុជ្ជន ចុះលោកណាគោរពលោកណា គ្រហស្ថគោរពបព្វជិត ឬបព្វជិតគោរពគ្រហស្ថ ?

វិ. គ្រហស្ថទោះបីបានសោតា សកទាគាមី អនាគាមី ក៏ដោយ ត្រូវតែគោរពបព្វជិតជាបុថុជ្ជន ។

បុ. ហេតុអ្វីបានជាគ្រហស្ថគោរពបព្វជិត បើគ្រហស្ថគេបានគុណធមិខ្ពស់ជាង ?

វិ. បានជាគ្រហស្ថត្រូវគោរបព្វជិត ព្រោះបព្វជិតជាឧត្តម-ភេទ លោកមាកិច្ចវត្តប្រតិបត្តិធមិច្រើន ហើយព្រះសង្ឃនេះចាត់ជាបុញ្ញក្ខេត្ត ភេទគ្រហស្ថចាត់ជាបុញ្ញក្ខេត្តមិនបានទេ បានជាគ្រហស្ថគោរពព្រះសង្ឃៗ ចាត់ជាសរណគមន៏ផង ។

បុ. ចុះព្រះសង្ឃ ដែលថ្វាយបង្គំចំពោះព្រះសង្ឃដែលបានសោតាបត្តិមគ្គ, សកទាគាមិមគ្គជាលំដាប់ទៅ ព្រះសង្ឃថ្វាយបង្គំដូច្នេះមិនត្រូវលើគ្រហស្ថទៅហើយ ព្រោះគ្រហស្ថគេបានសោតាបត្តិមគ្គ សកទាគាមិមគ្គដែរ?

វិ. ព្រះសង្ឃថ្វាយបង្គំចំពោះព្រះសង្ឃគុណនោះ មិនចំពោះភេទគ្រហស្ថទេ ចំពោះតែភេទព្រះសង្ឃដូចគ្នា, ព្រះសង្ឃណាថ្វាយបង្គំគ្រហស្ថត្រូវអាបត្តិទុក្កដ ក្នុងសង្ឃគុណនេះចំពោះតែគុណព្រះសង្ឃទេ ។

បុ. បាប និង អកុសលផ្សេងគ្នា ឬដូចគ្នា?

វិ. ផ្សេងគ្នាតែព្យញ្ជនៈ តែសេចក្ដីដូចគ្នា បាបប៉ែកខាងព្រះសូត្រ, អកុសលសំដៅយកចិត្ត ប៉ែកខាងអភិធម្ម ។

បុ. បុណ្យ និងកុសលផ្សេងគ្នា ឬដូចគ្នា?

វិ. បុណ្យនិងកុសលនោះផ្សេងគ្នា ចំណែកបុណ្យសំដៅខាងក្នុងត្រង់ស្អាតចិត្ត មានបុញ្ញកិរិយាវត្ថុ ១០ ជាដើម នេះជាលោកិយគ្មានចែកជាលោកុត្តរទេ ច្រើនតែផ្លូវព្រះសូត្រ ឯកុសលសំដៅយកចិត្តដែលឆ្លៀវឆ្លាស់ ឯចិត្តនោះចែកចេញទៅមាន ៤ គឺ កាមាវចរកុសល ១, រូបាវចរកុសល ១, អរូបាវចរកុសល ១, លោកុត្តរកុសល ១ ប្លែកគ្នាត្រង់កុសលមានលោកុត្តរ កុសលនេះច្រើននិយាយតាមផ្លូវអភិធម្ម ។

បុ. ចុះអានិសង្ស និងផលជាតួមួយ ឬផ្សេងគ្នា?

វិ. អានិសង្សនិងផលជាតួមួយខ្លះ ផ្សេងគ្នាខ្លះ អានិសង្សជាលោកិយតែម្យ៉ាង ចំណែកផលជាលោកិយខ្លះ លោកុត្តរខ្លះ បានជាចាត់ថាសាមញ្ញផល ៤ នេះជាលោកុត្តរៈ ឯអានិសង្សនោះគ្មានលោកុត្តរៈទេ ។

បុ. បមាទៈ និង និយតមិច្ឆាទិដ្ឋិ បមាទៈជាកំពូលអកុសល, និយតមិច្ឆាទិដ្ឋិ ថាទោសធ្ងន់បំផុត ទាំងពីរនេះណាទោសធ្ងន់ជាងណា?

វិ. បមាទៈ និង និយតមិច្ឆាទិដ្ឋិនោះផ្សេងគ្នា គឺៈ និយតមិច្ឆា-ទិដ្ឋិ ញ៉ាំងឱ្យទៅកើតក្នុងលោកុត្តរនរក ចំណែកបមាទៈគ្រាន់តែប្រហែសបន្តិចបន្តួចរហូតដល់នយតមិច្ឆាទិដ្ឋិ ។

បុ. វិន័យ ពីរម៉ឺន ១ ពាន់ព្រះធម្មក្ខន្ធ, ព្រះសូត្រពីរម៉ឺន ១ ពាន់ព្រះធម្មក្ខន្ធ, អភិធម្មបួនម៉ឺនពីរពាន់ព្រះធម្មក្ខន្ធ ទាំងបីនេះក្នុងមួយៗ បើបង្រួញឱ្យខ្លីមកនៅត្រឹមពាក្យប៉ុន្មានម៉ាត់, ហើយមានសេចក្ដីផ្សេងគ្នាដូចម្ដេចខ្លះ ទើបនឹងដឹងថា នេះជាវិន័យនេះជាព្រះសូត្រ នេះជាអភិធម្ម ?

វិ. វិន័យរួមឱ្យខ្លីមកនៅត្រឹមតែពាក្យ ២ ម៉ាត់ គឺៈ បញ្ញត្តិ ១, អនុញ្ញាតិ ១; ព្រះសូត្ររួមឱ្យខ្លីមកនៅត្រឹមពាក្យពីរម៉ាត់ គឺៈ សំដែងអំពីទោស ១, អំពីអានិសង្ស ១ ហើយប្រាប់ពួបុគ្គលជាទីតាំង; អភិធម្មបើរួបរួមពាក្យឱ្យខ្លីមកនៅតែត្រឹម ៤ ម៉ាត់គឺ ចិត្ត ១, ចេតសិក ១, រូប ១, និព្វាន ១; វិន័យ ព្រះសូត្រ និងអភិធម្មមានសេចក្ដីផ្សេងគ្នាដូចវិស្សជ្ជនាមកនេះ ។

បុ. វិន័យជ្រៅដោយអ្វី? ព្រះសូត្រជ្រៅដោយអ្វី? អភិធម្មជ្រៅដោយអ្វី?

វិ. វិនយោ កិច្ចគម្ភិរោ ‹‹វិន័យជ្រៅដោយកិច្ច››, សុត្តន្តោ អត្ថគម្ភិរោ ‹‹ព្រះសូត្រជ្រៅដោយអត្ថ››, អភិធម្មោ សភាវគម្ភិរោ ‹‹អភិធម្មជ្រៅដោយសភាវៈ›› ។

បុ. វិន័យដែលជ្រៅដោយកិច្ចនោះ តើជ្រៅដូចម្តេច?

វិ. វិន័យដែលជ្រៅដោយកិច្ចនោះ គឺជ្រោះដោយសារធ្វើលុះតែលោកណាឆ្លាតផ្លូវព្រះវិន័យសព្វគ្រប់ ទើបប្រតិបត្តិទៅបាន ។ ដូចជាព្រះទ្រង់ហាមអំពីពីជគាម ភូតគាម យ៉ាងផ្លែត្របែក ផ្លែទទឹម សណ្តែកបណ្តុះជាដើម ជាវត្ថុដែលសមណៈមិនគួរទំពាបរិភោគ ទើបគេឆ្លាតខាងវិន័យធ្វើឧបកិច្ចតែ ១ ឬ ២ ក៏គង់ឆាន់បាន, សុរាក៏ទ្រង់ហាមជាដាច់ខាត សូម្បីតែដេកលក់ក៏ដោយ ឱ្យតែកន្ទងបំពង់កហើយក៏គង់ត្រូវអាបត្តិ តែបើសម្លឬត្រីស្ងោរជារបស់ឆ្អាប ទ្រង់អនុញ្ញាតឱ្យដាក់សុរាបាន ដើម្បីកុំឱ្យឆ្អាប តែត្រូវដាក់លៃឱ្យល្មមកុំឱ្យធុំក្លិនសុរា កិច្ចរបស់វិន័យតោឱ្យដឹងពុទ្ធបំណង ពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាតិ ប្រព្រឹត្តទៅដោយ

ត្រឹមត្រូវបាន ព្រោះហេតុនោះបានជាលោកសំដែងថា ព្រះវិន័យជ្រៅដោយកិច្ច ។

បុ. ត្រង់ដែលថាព្រះសូត្រជ្រៅដោយអត្ថនោះ តើដូចម្ដេច?

វិ. ព្រះសូត្រជ្រៅដោយអត្ថនោះ គឺជ្រៅដោយសេចក្ដីអធិប្បាយពន្យល់ឱ្យងាយដល់អ្នកស្ដាប់ ព្រោះព្រះសូត្រនេះត្រូវមានបុគ្គលជាទីតាំង បានជាលោកសំដែងថា ជ្រៅដោយមត្ថ ។

បុ. ចុះអភិធម្មដែលជ្រៅដោយសភាវៈ៧ នោះដូចម្ដេច?

វិ. ដែលថាជ្រៅដោយសភាវៈនោះ ច្រើននិយាយទៅលើរបស់ដែលឥតរូបដោយច្រើន ដូចយ៉ាងចិត្ត, ចេតសិក, រូប, និព្វាន ។

បុ. ចុះព្រហ្មវិហាររបស់មាតាបិតាទាំង ៤ នេះ កើតព្រមគ្នាឬកើតតាមលំដាប់?

វិ. ព្រហ្មវិហាររបស់មាតាបិតាទាំង ៤ នេះ កើតតាមលំដាប់ខុសគ្នា គឺមេត្តាកើតតាំងពីកូនមកចាប់បដិសន្ធិជាលំដាប់តទៅ, ឯករុណាកើតចំពោះកូនមានទុក្ខមានធុរៈមួយពេលៗ ចង់ឱ្យកូនបានសុខ ចិត្តក៏ធ្ងន់ជាងមេត្តា, មុទិតាចិត្តទោរទន់ទៅកាន់កូនឥតមានប្រកាន់ទោសកំហុសដល់កូបប្រុស-ស្រី ដែលទាស់ខុសឆ្គង

ដោយកាយ វាចា, ឧបេក្ខាចិត្តកើតឡើងក៏ព្រងើយកន្តើយ ស្មើៗ ក្នុងពេលដែលកូនមានស្វាមី-ភរិយា បើទាស់ទែងនឹងគ្នា ក៏មាតាបិតាមិនកាន់ណាជាងណា នៅជាកណ្តាលៗ ផ្សេងគ្នាដូចវិស្សជ្ជនាមកនេះ ។

បុ. ព្រហ្មវិហាររបស់មាតាបិតា និងព្រហ្មវិហារក្នុងកម្មដ្ឋាន ដូចគ្នា ឬផ្សេងគ្នា?

វិ. ផ្សេងគ្នា ព្រហ្មវិហាររបស់មាតាបិតាផ្សាយបានចំពោះតែបុត្រធីតារបស់ខ្លួនប៉ុណ្ណោះ; ឯព្រហ្មវិហារក្នុងកម្មដ្ឋាន ត្រូវផ្សាយមេត្តានិងករុណាទៅលើសត្វគ្រប់ទិស វៀរតែសត្វនិងសង្ខារដែលជាទីស្រឡាញ់ មានលក្ខណៈដូចវិស្សជ្ជនាមកនេះ ។

បុ. ព្រហ្មវិហារធម៌ ៤ នេះ មេត្តា កំចាត់បង់អកុសលណា? ករុណា កំចាត់បង់អកុសលណា?

វិ. មេត្តា កំចាត់បង់ព្យាបាទៈ, ករុណា កំចាត់បង់វិហិង្សា, មុទិតា កំចាត់បង់អរតី ([4]), ឧបេក្ខា កំចាត់បង់រាគៈ ។

បុ. សង្ខារមានច្រើនពួក សង្ខារក្នុងខន្ធ ៥ មួយពួក, សង្ខារក្នុងបដិច្ចសមុប្បាទមួយពួក, សង្ខារធម៌មួយពួក, សត្វនិងសង្ខារមួយពួក, ឧបាទិន្នកសង្ខារ និង អនុបាទិន្នកសង្ខារមួយពួក,

---

[4] អរតី គឺសេចក្តីមិនត្រេកអរ គឺទោសោ ។

សង្ខារលោកមួយពួក, សង្ខារទាំងអស់នេះ មានសេចក្ដីផ្សេងគ្នាដូចម្ដេច បានជាច្រើនដល់ម្ល៉េះ?

វិ. សង្ខារទាំងអស់នេះ មានសេចក្ដីផ្សេងគ្នាដូច្នេះ សង្ខារដែលមានក្នុងខន្ធ ៥ នោះ បានដល់ចេតសិក ៥០ លើកវេទនានិងសញ្ញាចេញ; សង្ខារក្នុងបដិច្ចសមុប្បាទនោះ បានដល់សង្ខារ-បុណ្យបាបដែលចែកចេញជា ៣ គឺៈ បុញ្ញាភិសង្ខារ ១, អនេញ្ជា-ភិសង្ខារ ១, សង្ខារធម៌នោះសំដៅយកបច្ច័យប្រជុំតាក់តែងសត្វឱ្យកើតក្នុងភព ៣ សង្ខារនេះរួមប្រមូលពួកធម៌ទាំងអស់ ដែលជាលោកិយធម៌ ប្រៀបប្រដូចជាផ្ទះ ហៅថាតែផ្ទះមួយម៉ាត់ចប់គ្រឿងផ្ទះទាំងអស់; ឯសត្វនិងសង្ខារ សត្វបានដល់កូននិងប្រពន្ធសង្ខារបានដល់គ្រឿងប្រើប្រាស់; ឧបាទិន្នកសង្ខារ សង្ខារដែលមានវិញ្ញាណចូលទៅជិតអែបនែប បានដល់មនុស្សនិងទេវតាជាដើម អនុបាទិន្នកសង្ខារ បានដល់សង្ខារដែលគ្មានវិញ្ញាណចូលទៅជិតកាន់យក; ឯសង្ខារលោកនោះ បានដល់នាមនិងរូប និងទេវតា ធាតុ កាយតនៈជាដើម សង្ខារមានសេចក្ដីផ្សេងៗ គ្នា ដូចវិស្សជ្ជនាមកនេះ បានជាថាមានច្រើនពួក ។

បុ. លោក, សត្វ, មនុស្ស, សេចក្ដីផ្សេងគ្នាដូចម្ដេច?

វិ. សេចក្ដីផ្សេងគ្នាដូច្នេះ លោកចែកទៅជា សង្ខារលោក, សត្វលោក, ឱកាសលោក; ចំណែកសត្វរាប់តាំងអំពីនរក, ប្រេត, តិរច្ឆាន, ព្រហ្ម, មនុស្សចំពោះតែមនុស្សស្ថានកណ្ដាលមិនទូទៅដល់របស់ដទៃឡើយ ។

បុ. ធ្វើទានព្រះអង្គទ្រង់សំដែងថា ធ្វើចំពោះដល់ភិក្ខុសង្ឃទើបបានបុណ្យច្រើន ឱ្យដល់ពួកដទៃ មានឱ្យដល់ពួកនិគ្រន្ថ-តិរ្ថិយ៍ជាដើម បានបុណ្យតិច ឬមិនបានបុណ្យក៏មាន ព្រះអង្គប្រកបដោយសេចក្ដីករុណា ហេតុអ្វីក៏ឱ្យដល់អ្នកដទៃថាមិនសូវបានបុណ្យ បើចំពោះសាវ័ករបស់ព្រះអង្គទើបបានបុណ្យច្រើន ហាក់ដូចជាព្រះអង្គហួងហែងចង់ឱ្យតែគេធ្វើទាន ចំពោះសាវ័ករបស់ព្រះអង្គ ព្រះសង្ឃឱ្យបុណ្យដល់គេអ្នកឱ្យឬ ?

វិ. ព្រះអង្គមិនហួងហែងចង់ឱ្យគេធ្វើទាន ចំពោះតែសាវ័ករបស់ព្រះអង្គទេ ទ្រង់ប្រកបដោយសេចក្ដីករុណាចំពោះសត្វទាំងអស់ ដែលថាធ្វើទានចំពោះព្រះសង្ឃបានបុណ្យច្រើននោះព្រោះព្រះសង្ឃមានធមិសម្រាប់សង្គ្រោះដល់ទាយក ៦ យ៉ាងគឺៈ

**១-ធាធា និវារេន្តិ** ហាមឃាត់ទាយកមិនឱ្យធ្វើបាប;

**២-កល្យាណេ និវេសេន្តិ** ញុំាងទាយកឱ្យដំកល់នៅក្នុងកុសលធម៌;

**៣-កល្យាណេន មនសា អនុកម្បន្តិ** អនុគ្រោះទាយកដោយចិត្តដ៏ល្អ;

**៤-សុតំ អនុសារេន្តិ** ញុំាំងទាយកឱ្យស្វាធ្យាយធម៌ដែលធ្លាប់ស្តាប់ធ្លាប់ឮ ហើយឱ្យរឹងរឹតតែចាំឡើងៈ

**៥-អស្សុតំ អនុសារេន្តិ** ញុំាងទាយកឱ្យស្វាធ្យាយធម៌ដែល មិនធ្លាប់បានស្តាប់ បានឮ;

**៦-មគ្គស្ស អាចិក្ខន្តិ** ប្រាប់ទាយកឱ្យដឹងថាផ្លូវនោះទៅកាន់ស្ថានសួគ៌ ផ្លូវនេះទៅកាន់ព្រះនិព្វាន ។

មានកិច្ចសម្រាប់សង្គ្រោះដល់ទាយក ៦ យ៉ាងនេះហើយបានជាព្រះអង្គទ្រង់សរសើរថា បានបុណ្យច្រើនព្រោះព្រះសង្ឃជាអ្នកកាន់សាសនាផ្ទាល់ដៃ ។ ធ្វើដល់ពួកដទៃដោយមេត្តាចិត្តមានបានបុណ្យខ្លះ បើធ្វើដោយឃើញថា ពួកនិគ្រន្ថតិរ្ថិយ៍ថាជាទក្ខិណេយ្យបុគ្គលមិនបានបុណ្យទេ ព្រោះជាប់ដោយមិច្ឆាទិដ្ឋិសម្គាល់ខុស ដោយមានហាមក្នុងវិបត្តិឧបាសកទី ៥ ថា

**ននិ្ទលោយ្យ គតេសេតិ** ឧបាសកស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅព្រះពុទ្ធសាសនាចាត់ជាវិបត្តិ ។

បុ. ឧទ្ទិសផលឱ្យទៅអ្នកដែលកាន់លោកខាងមុខ បានតែប្រេត ៣ ពួក មានបរទត្តូបជីវីប្រេតជាដើម ក្រៅអំពីនោះមានមនុស្សនិងទេវតាជាដើមថាមិនបាន ចុះដែលធ្វើបុណ្យឧទ្ទិសផលឱ្យទៅមានសូត្រ យំ កិញ្ចិ... ជាដើម ប្រយោជន៍អ្វីបើបានទេ?

វិ. ក្នុងសោណំជានិស្សូត្រ សំដែងថាបានត្រឹមតែប្រេត ៣ ពួកនេះមែន ប៉ុន្តែចំពោះតែអាហារនិងគ្រឿងស្លៀកប៉ុណ្ណោះ ដូចយ៉ាងពួកប្រេតដែលអត់អាហារ គ្មានគ្រឿងស្លៀកពាក់ ធ្វើអាហារប្រគេនដល់ភិក្ខុសង្ឃហើយឧទ្ទិសទៅបាន ធ្វើចីវរប្រគេនដល់សង្ឃហើយឧទ្ទិសផលឱ្យទៅ ប្រេតទាំងនោះទទួលបានទាំងអស់; ឧទ្ទិសទៅឱ្យពួកទេវតា មនុស្ស និងសត្វតិរច្ឆានមិនបានទេ ព្រោះអាហារនិងគ្រឿងស្លៀកពាក់ខុសគ្នា ដែលឧទ្ទិសទៅដល់ទេវតា មនុស្ស និងសត្វតិរច្ឆានបាននោះ ចំពោះផលសាធារណ៍មិនចំពោះរូបវត្ថុ ។

បុ. ឧទ្ទិសផលទៅឱ្យសត្វនរកបានដែរឬ ?

វិ. ឧទ្ទិសផលឱ្យទៅបានដែរ ។

បុ. ឧទ្ទិសផលឱ្យទៅ មានសុទ្ធតែដល់ទាំងអស់ឬមានមិនដល់ដែរ?

វិ. ឧទ្ទិសផលឱ្យទៅ មិនមែនសុទ្ធតែដល់ទាំងអស់នោះទេ មានបានខ្លះ មិនបានខ្លះ ។

បុ. ដែលបាននោះដូចម្តេច? មិនបាននោះដូចម្តេច?

វិ. ដែលបាននោះចំពោះតែនរកណាដែលស្រាលៗ ទទួលបាន នរកធ្ងន់ដែលធ្វើគរុកម្មទទួលមិនបានទេ ដូចជាទោសបច្ចុប្បន្ននេះ ទោសស្រាលៗ គេយករបស់ទៅឱ្យបាន ទោសណាដែលធ្ងន់ញាតិមិត្រយកទៅឱ្យមិនបានទេ ។

បុ. ធ្វើបុណ្យអ្នកណាធ្វើ អ្នកនោះត្រូវទទួលផលបានខ្លួនឯងសមដូចពុទ្ធភាសិតសំដែងថា សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ សេចក្តីថាៈ ការបរិសុទ្ធិនិងមិនបរិសុទ្ធិ ចំពោះតែខ្លួនឯង អ្នកដទៃមិនអាចនឹងធ្វើសេចក្តីបរិសុទ្ធិឱ្យបានទេ ចុះហេតុអ្វីក៏ចែកបុណ្យឱ្យគ្នាបាន?

វិ. សេចក្តីបរិសុទ្ធិ និងមិនបរិសុទ្ធិចំពោះតែខ្លួនឯងក៏ពិតមែនហើយ ប៉ុន្តែគង់អាចទទួលចំណែកផលបុណ្យ ដែលគេឧទ្ទិសឱ្យ

ទៅនោះបានខ្លះ ដោយអំណាចធ្វើចិត្តឱ្យរីករាយ ចំពោះចំណែកផល ដែលគេចែកឱ្យ ដូចមានក្នុងបុញ្ញកិរិយាវត្ថុថា បត្តានុមោទនា ។

បុ. មនុស្សដែលខ្លាច តើធម៌អ្វីនាំឱ្យខ្លាច?

វិ. មនុស្សដែលខ្លាចនោះ មានធម៌ ៣ យ៉ាងគឺៈ រាគៈ ១, ទោសៈ ១, មោហៈ ១ ធ្វើឱយខ្លាច ។ កាលបើមនុស្សណាមួយអស់អកុសលធម៌ទាំង ៣ នេះហើយ ឥតមានភ័យខ្លាចតក់ស្លុតអ្វីឡើយ ដូចយ៉ាងព្រះខីណាស្រពដែលអស់រាគៈ ទោសៈ មោហៈហើយ លោកឥតភ័យខ្លាចតក់ស្លុតឡើយ ។

បុ. ចុះដូចយ៉ាងចោរដែលប្រព្រឹត្តតែចោរកម្មទេ ហេតុអ្វីក៏វាមិនខ្លាច ហ៊ានទៅនៅក្នុងព្រៃស្ងាត់ម្នាក់ឯងដែរ?

វិ. ចោរដែលប្រព្រឹត្តតែចោរកម្មហើយហ៊ានទៅនៅក្នុងព្រៃស្ងាត់ម្នាក់ឯងក៏គង់នៅខ្លាច ព្រោះតែខ្លាចមិនហ៊ានចូលទៅនៅក្នុងស្រុកហើយ បានជាប្រថុយនៅក្នុងព្រៃតែម្នាក់ឯង ដោយសារទាល់គំនិតមិនដឹងទៅណា ក៏ខំអត់ធ្មត់សង្កត់ចិត្តទ្រាំនៅទៅ មិនមែននៅដោយមិនខ្លាចឡើយ ។

បុ. កាលដែលព្រះអង្គទ្រង់គង់នៅធរមាននៅឡើយ ទ្រង់សំដែងថា អាមិសបូជាមានផលច្រើន សូម្បីគ្រាន់តែបូជាផ្កា ១ ក្ដាប់ ទ្រង់សម្ដែងថា មានអានិសង្សរាប់ពុំបានប្រមាណពុំអស់ ចុះហេតុអ្វីដល់ទៅពេលដែលទ្រង់ទៀបចូលបរិនិព្វាន ទ្រង់ក៏ឃាត់អាមិសបូជាវិញ បើដូច្នេះអាមិសបូជាដែលគេធ្វើសព្វថ្ងៃនេះ មិនឥតផលទៅហើយ?

វិ. គ្រឿងអាមិសបូជានោះ មិនមែនជាឥតផលទេ គឺនៅតែមានផលដដែល ដូចន័យដែលមានមកក្នុងមង្គលត្ថទីបនីថា: ‹‹តិដ្ឋន្តេ និព្វុតេ ចាបិ សមេ ចិត្តេ សមំ ផលំ សេចក្ដីថា ទោះបីព្រះពុទ្ធកំពុងធរមាននៅក្ដី បរិនិព្វានទៅហើយក្ដី បើចិត្តរបស់ទាយកអ្នកបូជាជ្រះថ្លាស្មើគ្នា ក៏គង់មានផលស្មើគ្នា, តែបានជាទ្រង់ហាមឃាត់ក្នុងពេលទៀបចូលបរិនិព្វាននោះ ព្រោះទ្រង់យល់ឃើញទៅក្នុងកាលជាអនាគតថា បើនឹងបណ្ដែតបណ្ដោយឱ្យពុទ្ធបរិស័ទធ្វើតែអាមិសបូជាទៅ នឹងនាំឱ្យសាបសូន្យព្រះពុទ្ធ-សាសនា ព្រោះអាមិសបូជាមិនអាចនឹងទ្រទ្រង់ព្រះពុទ្ធសាសនាបានទេ សូម្បីតែត្រឹមមួយទទះស្លាប់មាន់ក៏មិនបានដែរ ព្រះអង្គមិនមែនហាមដាច់ខាតទេ តែទ្រង់លើកបដិបត្តិបូជាធំជាង

ព្រោះបដិបត្តិបូជាទើបទ្រទ្រង់ព្រះពុទ្ធសាសនា ឱ្យស្ថិតស្ថេរដល់គ្រប់ ៥ ពាន់ព្រះវស្សាបាន ។

បុ. រតនបូជាទាំង ៣ គឺ ពុទ្ធបូជា និងធម្មបូជាផ្លាស់ប្តូរគ្នាបាន យកពុទ្ធបូជាទៅបូជាព្រះធម្ម ឬយកធម្មបូជាទៅបូជាព្រះពុទ្ធបាន បូជាទាំងពីរនេះ នឹងយកពុទ្ធបូជានិងធម្មបូជាទៅបូជាព្រះសង្ឃមិនគួរទេ បើយកសង្ឃបូជាទៅបូជាព្រះពុទ្ធនិងព្រះធម៌ទើបគួរ ចុះក្នុងទក្ខិណាវិភង្គសូត្រសំដែងថា ធ្វើទានដល់ព្រះពុទ្ធបានបុណ្យមិនស្មើនឹងធ្វើទានដល់ព្រះសង្ឃ ហេតុអ្វីក៏យកពុទ្ធ-បូជាទៅបូជាព្រះសង្ឃមិនបាន ?

វិ. បានជាយកពុទ្ធបូជាទៅបូជាព្រះសង្ឃមិនបាន ព្រោះព្រះពុទ្ធនិងព្រះធម៌ជាទីគោរពរបស់ព្រះសង្ឃៗ ត្រូវគោរពចំពោះព្រះពុទ្ធនិងព្រះធម៌ បើព្រះសង្ឃត្រូវគោរពដល់ព្រះពុទ្ធនិងព្រះធម៌ហើយ ទាំងវត្ថុដែលសម្រាប់បូជាដល់ព្រះពុទ្ធនិងព្រះធម៌ ក៏ត្រូវតែកោតខ្លាចដែរ ដូចមាតាបិតា ឬគ្រូឧបជ្ឈាយាចារ្យ មានវត្ថុដែលគេយកមកសម្រាប់បូជា កូននិងកូនសិស្សមិនត្រូវយកវត្ថុនោះមកប្រើប្រាស់ឡើយ យ៉ាងណាមិញ, ព្រះសង្ឃមិនត្រូវយកពុទ្ធបូជានិងធម្មបូជាមកប្រើប្រាស់ក៏យ៉ាងនោះដែរ ។

បុ. បូជាព្រះពុទ្ធនិងព្រះសង្ឃចុះគួរបានរូបទទួល ចុះបូជាព្រះធម៌ឥតរូបមានអ្វីសម្រាប់ទទួល?

វ. បូជាព្រះធម៌នោះ ត្រូវបូជាចំពោះលោកដែលជាពហុស្សុត ដូចជាកាលជាន់ដើមមានព្រះអានន្ទត្ថេរជាដើម ។

បុ. ពាក្យខាងដើម ២ ម៉ាត់ គឺៈ ធម៌ ១, វិន័យ ១ ចុះអ្នកដល់ត្រៃសរណគមន៍ ហេតុដូចម្តេចក៏ដល់តែព្រះធម៌ ព្រះវិន័យក៏មិនដល់ផង ឬមិនត្រូវប្រតិបត្តិវិន័យទេ?

វិ. អ្នកដល់ត្រៃសរណគមន៍ត្រូវដល់វិន័យដែរ ព្រោះវិន័យនៅក្នុងផ្ទៃនៃព្រះធម៌, ពាក្យថា ធម្ម នេះគឺអដ្ឋង្គិកោ ១ ចេញទៅជាសីល សមាធិ បញ្ញា ពាក្យថា ធម៌នេះទូទៅទាំងព្រះសូត្រ ទាំងវិន័យ ទាំងអភិធម្មទាំងអស់ ព្រោះពាក្យថាធម៌នេះធំជាងពាក្យថាវិន័យ ។

បុ. ព្រះពុទ្ធ និងព្រះសង្ឃ គួរថាមានគុណដល់បរិស័ទអ្នកប្រតិបត្តិតាម ព្រោះព្រះពុទ្ធត្រាស់ដឹងនូវធម៌ ហើយព្រះអង្គសំដែងប្រាប់សត្វ ព្រះសង្ឃជាអ្នកប្រតិបត្តិតាមឱវាទដែលទ្រង់សំដែងប្រាប់ ហើយប្រដៅសត្វត១ មក ចុះហេតុដូចម្តេចក៏ព្រះធម៌មានគុណដែរ បើព្រះធម៌កើតអំពីព្រះពុទ្ធនិងព្រះសង្ឃទេ?

រ. ព្រះធម៌បានជាមានគុណដែរ ព្រោះព្រះធម៌ជួយទំនុងបម្រុងសត្វតាំងអំពីបច្ចុប្បន្នជាតិនេះដរាបដល់ព្រះនិព្វាន ព្រះពុទ្ធមានគុណត្រង់ប្រាប់ផ្លូវ ព្រះធម៌មានគុណត្រង់ជួយឱ្យសត្វបានសេចក្ដីសុខដោយសារការប្រព្រឹត្តិតាម សមដូចជាពុទ្ធភាសិតសម្ដែងថា៖

ធម្មោ ហវេ រក្ខតិ ធម្មចារឹ ធម្មោ សុចិណ្ណោ សុខមាវហាតិ
ឯសានិសំសោ ធម្មេ សុចិណ្ណេ ន ទុគ្គតឹ គច្ឆតិ ធម្មចារី ។

ធម៌ហ្នឹងឯងរមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌, ធម៌ដែលបុគ្គលសន្សំហើយ រមែងនាំមកនូវសេចក្ដីសុខ, កាលដែលបុគ្គលសន្សំធម៌ដោយប្រពៃហើយ រមែងបាននូវអានិសង្សបែបនេះមិនខាន, បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិភពឡើយ ។ ហេតុនេះហើយបានជាថាព្រះធម៌មានគុណ ។

ពុទ្ធោ មហាវេជ្ជោ=ព្រះពុទ្ធទុកដូចជាគ្រូពេទ្យធំ, ធម្មោ ឱសថោ=ព្រះធម៌ទុកដូចជាថ្នាំឱសថ; គ្រូពេទ្យគ្រាន់តែដឹងសមុដ្ឋានរបស់រោគប៉ុណ្ណោះទេ នឹងឱ្យជ្រួតជ្រាបទៅបាននោះ គឺមកអំពីថ្នាំ បានជាព្រះធម៌មានគុណ ។

បុ. ទេវទត្តធ្វើកម្ម ៣ យ៉ាងគឺៈ ញុំាងព្រះលោហិតុប្បាទព្រះពុទ្ធ ១, បបួលព្រះបាទអជាតសត្រូវឱ្យសម្លាប់បិតា១, ធ្វើសង្ឃ-ភេទ ១ ចុះកាលដែលទេវទត្តធ្លាក់ទៅអវីចិនរកនោះ តើទៅដោយកម្មណា?

វិ. កាលដែលទេវទត្តធ្លាក់ទៅអវីចិនរកនោះ គឺទៅដោយសង្ឃភេទកម្ម ។

បុ. ចុះផលកម្មទាំងពីរនោះរួចទៅណាទៅ?

វិ. ផលកម្មទាំងពីរនោះ រួចផុតទៅជាអហោសិកម្ម ព្រោះសង្ឃភេទកម្មជាកម្មធំជាងកម្មទាំងពីរនោះ ឧបមាដូចទោស ក្នុងបច្ចុប្បន្ននេះ ទោសលួចគេម្តង ទោសប្លន់គេម្តង ទោសសម្លាប់គេម្តង ដល់រាជការចាប់បាន គេកាត់តាមទោសសម្លាប់នោះយ៉ាងណាមិញ, ចំណែកកម្មទាំងពីរនោះ ក៏យ៉ាងនោះដែរ ។

បុ. ចុះគ្រហស្ថធ្វើសង្ឃភេទកម្មមានត្រូវសង្ឃភេទដែរឬទេ។

វិ. មិនត្រូវសង្ឃភេទទេ ឯសង្ឃភេទនោះត្រូវតែបព្វជិតព្រោះរូបម្ខាង ៤៧ រាប់ខ្លួនឯងមួយទៀតជា ៥ ទើបត្រូវសង្ឃ-ភេទកម្ម ។

បុ. ព្រះទ្រង់ជាសព្វញ្ញូពិតមែន ឬមិនមែនទេ?

វិ. ព្រះពុទ្ធជាសព្វញ្ញូពិតប្រាកដមែន ទ្រង់ជ្រាបនូវហេតុជាអតីត អនាគត និងបច្ចុប្បន្នឥតមានចន្លោះ ។

បុ. បើទ្រង់ជាសព្វញ្ញូពិតប្រាដកមែន ហេតុដូចម្តេចបានជាបំបួសទេវទត្តឱ្យធ្វើសង្ឃភេទកម្ម?

វិ. បានជាព្រះអង្គបំបួស ព្រោះទ្រង់យល់ឃើញទីបំផុតទុក្ខរបស់ទេវទត្តថា បើទេវទត្តនេះបានបួសហើយ ទុកណាជាធ្វើសង្ឃភេទកម្ម ក៏គង់ដល់ពេលព្រះធរណីស្រូប ទេវទត្តមុជានឹងបែរមករកតថាគតជាទីពឹងវិញមិនខាន កាលបើទេវទត្តងាកមករកព្រះអង្គជាទីពឹងហើយ លុះទៅសោយទុក្ខក្នុងអវីចិនរកអស់ហើយ ដល់កាលត្រឡប់មកវិញ នឹងបានត្រាស់ជាព្រះបច្ចេកពុទ្ធ ១ អង្គ ទ្រង់ព្រះនាមអដ្ឋិស្សរៈ ដោយឧបនិស្ស័យផលដែលបានបួសក្នុងសាសនាតថាគត ហេតុនេះហើយបានជាព្រះអង្គបំបួសប្រៀបដូចបន្លាមុត គោងយកបន្លាដូចគ្នាទៅជោះ ទើបបានបន្លានោះមកវិញ ពិតមែនតែជោះទៅឈឺ ប៉ុន្តែបើជោះបានបន្លាមកក៏បាត់ឈឺ, ទេវទត្តនេះ បើកុំតែបានព្រះអង្គបំបួសនឹងមានទុក្ខរាប់កប្បកល្បរកទីបំផុតគ្មាន ។

បុ. ចុះទេវទត្តបានធ្វើកុសលខ្លះដែរឬទេ?

វិ. បានធ្វើកុសលខ្លះដែរ ។

បុ. បើបានធ្វើកុសលខ្លះដែរ ហេតុដូចម្ដេចក៏ក្នុងរឿងរ៉ាវមិនឃើញមានល្អសោះ ឃើញសុទ្ធតែអាក្រក់ទាំងអស់ហ្ន៎?

វិ. ក្នុងគម្ពីរមិនដែលនិយាយសរសើរអំពីទេវទត្តក៏ពិតមែន ប៉ុន្តែទេវទត្តគង់មានធ្វើកុសលខ្លះ បើគ្មានកុសកទៃ ធ្វើម្ដេចនឹងបានមកកើតជាមនុស្ស ជាខត្តិយជាតិ ហើយថែមទាំងបានត្រាស់ជាព្រះបច្ចេកពុទ្ធ ១ អង្គទៀតផង ធម្មតាមនុស្សបើសិនណាមានរឿងអាក្រក់ហើយ គេយករឿងអាក្រក់នោះមកបង្គ្របរឿងល្អបាត់អស់ បានជាទេវទត្តគ្មានរឿងល្អនឹងគេ មានតែរឿងអាក្រក់ម៉្យាង ។

បុ. ព្រះពុទ្ធប្រោសមនុស្សមានឧបនិស្ស័យតែម៉្យាង ឬមនុស្សដែលគ្មានឧបនិស្ស័យក៏ទ្រង់ប្រោសបានដែរ ?

វិ. ព្រះពុទ្ធប្រោសបានតែមនុស្ស ដែលមានឧបនិស្ស័យកសាងពីបុព្វជាតិ មនុស្សដែលគ្មានឧបនិស្ស័យពីបុព្វជាតិមកទ្រង់ប្រោសមិនបានទេ ។

បុ. បើដូច្នោះព្រះពុទ្ធមិនវិសេសអ្វីទេ ប្រោសបានតែមនុស្សដែលគេមានឧបនិស្ស័យរបស់គេស្រាប់?

វិ. ព្រះអង្គប្រោសបានតែមនុស្សដែលមានឧបនិស្ស័យក៏ពិតមែន ប៉ុន្តែទ្រង់នៅមានសេចក្តីវិសេសជាងពួកមនុស្សនិងទេវតាឯទៀត ព្រោះព្រះអង្គជាអ្នកខំស្វែងរកមោក្ខធម៌ឃើញមុនគេបង្អស់ លុះទ្រង់រកឃើញហើយ មិនឱបស្រសោបទុកម្នាក់ឯងទ្រង់យកមកសម្តែងប្រោសដល់គេឯងរាល់គ្នា ប្រៀបឧបមាដូចគ្រូពេទ្យមើលជម្ងឺ មើលបានតែមនុស្សណាដែលមើលទៅជា បើជម្ងឺនោះដាក់ថ្នាំទៅមិនត្រូវ ក៏គ្រូពេទ្យមើលមិនបានដែរ ប៉ុន្តែគ្រូពេទ្យក៏គង់នៅវិសេសជាងមនុស្សធម្មតា អ្នកដែលគ្រូពេទ្យមើលជានោះៗ ក៏គង់ដឹងគុណដល់គ្រូពេទ្យមិនខាន សេចក្តីនេះយ៉ាងណាមិញ, ព្រះពុទ្ធដែលប្រោសសត្វក៏យ៉ាងនោះដែរ ។

បុ. ព្រះពុទ្ធបានត្រាស់ហើយ បើមិនបានប្រោសសត្វ តើបានព្រះនិព្វានឬទេ?

វិ. បើទ្រង់មិនប្រោសសត្វ ក៏គង់តែបានព្រះនិព្វាន ។

បុ. បើបានព្រះនិព្វានដូច្នោះដែរ ហេតុដូចម្តេចក៏មកប្រោសសត្វឱ្យលំបាកអស់ចំនួន ៤៥ ព្រះវស្សា ឱ្យនឿយព្រះអង្គ?

វិ. បានជាព្រះអង្គប្រោសសត្វ ព្រោះជាប់ឧបនិស្ស័យពីបុព្វ-ជាតិមក ប្រាថ្នានឹងប្រោសសត្វ ព្រះអង្គប្រកបដោយចរិយា ៣

ប្រការគឺៈ លោកត្ថចរិយា ទ្រង់ប្រព្រឹត្តជាប្រយោជន៏ដល់សត្វលោក ១, ញាតត្ថចរិយា ទ្រង់ប្រព្រឹត្តជាប្រយោជន៏ដល់ពួកព្រះញាតិ ១, ពុទ្ធត្ថចរិយា ទ្រង់ប្រព្រឹត្តជាប្រយោជន៏ផ្ទាលព្រះអង្គឯង ១, ព្រះអង្គប្រកបដោយសេចក្តីករុណាខ្លាំង បានប្រាថ្នាជាពុទ្ធភូមិ ដើម្បីនឹងប្រោសសត្វហ្នឹងហើយ បើកុំតែមានព្រះទ័យប្រាថ្នាប៉ុណ្ណោះ សូម្បីប្រាថ្នាជាសាវ័កក៏គង់សម្រេចព្រះនិព្វានដែរ។

បុ. អើ! បើព្រះអង្គប្រាថ្នានឹងប្រោសសត្វហើយ ចុះកាលដែលទ្រង់ទើបនឹងបានត្រាស់ម្តេចក៏មិនសំដែងធមិតែម្តងទៅ ចាំបាច់ព្រហ្មទៅអារាធនាធ្វើអ្វី?

វិ. បានជាទ្រង់ចាំឱ្យព្រហ្មទៅអារាធនានោះ ព្រោះសត្វក្នុងលោកនេះជឿព្រហ្មណាស់, ព្រោះព្រហ្មជាគ្រូលើទេវតា និងមនុស្ស គេរាប់អានច្រើន បានជារង់ចាំឱ្យព្រហ្មមកអារាធនា ព្រះអង្គនឹងងាយប្រោសពពួកសត្វ ។

បុ. ព្រះនាមព្រះពុទ្ធមាន ១០ ដល់មកដាក់ក្នុងសរណគមន៏ឃើញដាក់តែ ពុទ្ធោ មួយ នាមដទៃទៀតមិនយកមកដាក់ផងតើព្រះនាមមួយនេះប្រសើរជាងគេ ឬដូចម្តេច?

វិ. ព្រះនាមទាំង ៩ នោះ រួមចូលមកក្នុង ពុទ្ធោ ទាំងអស់ ព្រោះព្រះពុទ្ធ ប្រែថា ត្រាស់ដឹងនូវចតុរារិយសច្ច ហើយព្រះអង្គ ប្រដៅសត្វដទៃឱ្យត្រាស់ដឹងផង ឬប្រែថា ព្រះអង្គរីកពេញ គឺថា បំពេញកិច្ចដល់មនុស្សនិងទេវតា បានជាចាត់ថាព្រះនាមនេះដាក់ ក្នុងសរណគមន៍ ។

បុ. មនុស្សមានធាតុ មានអាយតនៈ មានខន្ធ ៥ ហេតុអ្វី ខ្លះទៅជាមិច្ឆាទិដ្ឋិ ហេតុដែលកើតជាមិច្ឆាទិដ្ឋិនោះមានប៉ុន្មាន យ៉ាង?

វិ. ហេតុដែលកើតមិច្ឆាទិដ្ឋិនោះ មាន ២ យ៉ាងគឺ: **បរឃោសោ** ស្តាប់អំពីសំណាក់អាចារ្យដទៃ ១, **អយោនិសោមន-សិការៈ** មិនធ្វើទុកក្នុងចិត្ត ១, ចេះតែជឿទៅៗ ទាំងពីរនេះជា ហេតុឱ្យកើតមិច្ឆាទិដ្ឋិ ។

បុ. ហេតុដែលកើតសម្មាទិដ្ឋិមានប៉ុន្មានយ៉ាង?

វិ. ហេតុដែលកើតសម្មាទិដ្ឋិមាន ២ យ៉ាងគឺ: បរឃោសោ ស្តាប់ក្នុងសំណាក់អាចារ្យដទៃ ១, យោនិសោមនសិការៈ ស្តាប់ ហើយកំណត់ធ្វើទុកក្នុងចិត្ត ១, ហេតុទាំងពីរយ៉ាងនេះដែលនាំ ឱ្យកើតជាសម្មាទិដ្ឋិ ។

បុ. ព្រះពុទ្ធទ្រង់អស់ឥច្ឆាហើយឬនៅ?

វិ. ព្រះពុទ្ធគ្មានធម៌ឥច្ឆានោះទេ លះដាច់ស្រឡះពីខន្ធសន្តានអស់លីងហើយ ។

បុ. បើព្រះអង្គទ្រង់អស់ឥច្ឆាហើយ ហេតុអ្វីក៏ដណ្ដើមយកបាត្រខ្លឹមចន្ទន៍របស់សេដ្ឋី ទាល់តែពួកគ្រូទាំង ៦ គ្នាអៀនខ្មាសសម្លាប់ខ្លួនទៅ មើលទៅហាក់ដូចជាព្រះពុទ្ធ គ្មានធម៌មេត្តាសោះ ?

វិ. ព្រះពុទ្ធគ្មានធម៌ឥច្ឆាទេ មេត្តាក៏នៅមានគ្រប់គ្រាប់ទាំង-អស់ តែព្រះអង្គយល់ឃើញប្រយោជន៍ធំ ពេលដែលសំដែងយមកប្បាដិហារ្យនោះ មនុស្សនិងទេវតាបានសម្រេចមគ្គផលជាច្រើនរាប់កោដិ, ឯគ្រូទាំង ៧ នេះ បើទ្រង់មិនសំដែងបាដិហារ្យក៏គង់ធ្លាក់ទៅក្នុងនរក ព្រោះជាមនុស្សប្រទូសរ៉ាយនឹងព្រះអង្គមកជាយូរខែឆ្នាំហើយ ។

បុ. ភ្លើងក្នុងនរកអវីចិនោះក្ដៅណាស់ សូម្បីតែប៉ុនភ្នែកមាន់ក៏គង់ក្ដៅជាងភ្លើងយើងធម្មតា ឬមួយទម្លាក់ដុំថ្មប៉ុនកំពូលផ្ទះ ក៏ឆេះអស់គ្មានសែសសល់ដែរ ហេតុដូចម្ដេចក៏សត្វដែលកើតក្នុងនរកមិនឆេះឱ្យអស់តែម្ដងទៅ?

វិ. សត្វក្នុងនរក បានជាភ្លើងនរកមិនឆេះឱ្យអស់តែម្តងទៅ ព្រោះបាបកម្មជួយទ្រទ្រង់ឱ្យសោយទុក្ខវេទនា បានជាមិនឆេះ។

បុ. *សព្វេ សត្តា អាហារដ្ឋិតិកា* សត្វទាំងអស់រស់នៅដោយអាហារ ដូចយ៉ាងមនុស្សអត់បាយយ៉ាងយូរ ៧ ថ្ងៃស្លាប់ទៅ ចុះហេតុអ្វីដូចយ៉ាងប្រេតខ្លះ អត់អាហារតាំងអំពីថ្ងៃកើតឡើងសោយទុក្ខវេទនា ម្តេចក៏មិនស្លាប់?

វិ. បានជាមិនស្លាប់នោះ ព្រោះផលកម្មឱ្យអត់អាហារហ្នឹងហើយ ឱ្យទៅសោយទុក្ខវេទនា ។

បុ. បុណ្យនិងបាបទាំងអស់កើតពីព្រោះចិត្ត សមដូចពុទ្ធ-ភាសិតថាៈ ចេតនាហំ ភិក្ខវេ បុញ្ញំ វទាមិ, ចេតនាហំ ភិក្ខវេ បាបំ វទាមិ ប្រែថា ម្នាលភិក្ខុទាំងឡាយតថាគតពោលថា ចេតនាជាតួបុណ្យ, ម្នាលភិក្ខុទាំងឡាយតថាគតពោលថា ចេតនាជាតួបាប ហេតុអ្វីក៏ព្រះអង្គប្រដៅអំពីកាយវាចាដែរ បើចេតនាជាតួបុណ្យបាបហើយ?

វិ. ចេតនាជាតួបុណ្យបាបមែនហើយ ចិត្តជាប្រធានលើកាយនិងវាចា បើទៅតែកាយចិត្តមិនជ្រះថ្លាទេ ក៏មិនអាចកើតជា

បុណ្យបាន បាបបើទៅតែកាយចិត្តមិនក្លែងក្លាយក៏ចាត់ជាបាបមិនបាន, បានជាថាចិត្តហ្នឹងហើយជាតួបុណ្យបាប ។

បុ. បើគេធ្វើបុណ្យហើយ គេមិនយកបុណ្យ តើបានបុណ្យដែរឬ?

វិ. ទុកជាធ្វើហើយមិនយកក៏គង់បានបុណ្យដែរ តែមិនសូវបានច្រើន ព្រោះខ្វះអបរាបរចេតនា ដូចជាស្រមោលជាប់តាមនឹងខ្លួន ទៅទីណាក៏ស្រមោលទៅតាម ទុកជាមិនចង់ឱ្យសមោលទៅតាមក៏ស្រមោលទៅតាម ដូចយ៉ាងបុណ្យដែលបុគ្គលធ្វើហើយ បើទុកជាមិនចង់យកក៏គង់ជាប់ទៅតាមដែរ ។

បុ. ធម៌ព្រះអង្គសំដែង ៨ ម៉ឺន ៤ ពាន់ព្រះធម្មក្ខន្ធ ពពួកសត្វដែលប្រតិបត្តិតាមនោះ គ្រប់ធម្មក្ខន្ធ ៨ ម៉ឺន ៤ ពាន់ ទើបបានសម្រេចព្រះនិព្វានឬៗ មួយមិនបានគ្រប់ទាំងអស់ ក៏បានសម្រេចព្រះនិព្វានដែរ?

វិ. ធម៌ទាំងនេះមិនចាំបាច់គ្រប់ខន្ធទេ ខន្ធណាក៏បានសំរេចព្រះនិព្វានដែរ តាមនិស្ស័យវាសនារបស់សត្វ ។

បុ. បើមិនចាំបាច់គ្រប់ទេ ហេតុអ្វីក៏ព្រះអង្គសំដែងមកច្រើនម្ល៉េះ?

វិ. បានជាសម្ដែងច្រើនដល់ម្ល៉េះ ព្រោះទ្រង់និយមតាមចរិត របស់សត្វ ប្រៀបដូចគ្រូពេទ្យ តោងមានថ្នាំច្រើនមុខ ព្រោះរោគ ច្រើនបែបច្រើនយ៉ាង ខ្លះរោគក្ដៅ ខ្លះរោគត្រជាក់ ថ្នាំខុសគ្នា បើថ្នាំ តែមួយមុខ ធ្វើម្ដេចនឹងដាក់រោគនោះឱ្យបានជាសះស្បើយ យ៉ាង ណាមិញ, ព្រះពុទ្ធទ្រង់សំដែងធម៌ក៏យ៉ាងនោះដែរ ។

បុ. កាលពីព្រះពុទ្ធទ្រង់គង់ធរមាននៅឡើយ សត្វបានស្ដាប់ ធម៌មួយគាថា បានសម្រេចមគ្គផលច្រើន ចុះឥឡូវនេះ សត្វស្ដាប់ ច្រើនគ្នាណាស់ដែរ ម្ដេចក៏មិនបានសម្រេចមគ្គផល ទាស់អំពីអ្វី?

វិ. ឥឡូវនេះ ព្រោះនិស្ស័យសត្វនៅតិចតួចស្ដួចស្ដើងណាស់ ទុកជាស្ដាប់ច្រើនដងក៏ដោយ មិនអាចនឹងបានសម្រេចបានដែរ ប្រៀបដូចស្រូវ បើមិនទាន់ដល់កំណត់កាល បើទុកជាយកទឹក ទៅស្រោចយកជីរទៅចាក់ ក៏មិនបានប្រយោជន៍អ្វីអំពីនោះដែរ យ៉ាងណា, អ្នកស្ដាប់ធម៌និស្ស័យខ្ចីនៅឡើយ ក៏ដូច្នោះដែរ ។

បុ. ពាក្យដែលហៅថាធម៌ៗ សុទ្ធតែល្អ ឬមានអាក្រក់ដែរ?

វិ. ពាក្យដែលហៅថាធម៌នេះសុទ្ធតែល្អ របស់ពិតរបស់មែន បើអាក្រក់មិនឈ្មោះថាធម៌ទេ ។

បុ. បើរបស់អាក្រក់ទាំងប៉ុន្មាន មិនមែនឈ្មោះថាធម៌ទេ ហេតុអ្វីក៏មានកមក្នុងបិដក ឱ្យឈ្មោះថាអកុសលធម៌ បាបធម៌ ទុច្ចរិតធម៌ផ្សេងៗ ដូច្នេះជាដើម? បើមិនឈ្មោះធម៌ទេ តើឈ្មោះអ្វី?

វិ. ពិតមែនតែមានឈ្មោះផ្សេងគ្នាមកក្នុងបិដក ប៉ុន្តែរួមមកហៅថា អធម៌ទាំងអស់ សមដូចពុទ្ធភាសិតថាៈ ‹‹ធម្មោ បាបេតិ សុគតឹ, អធម្មោ បាបេតិ ទុគ្គតឹ ធម៌ញុំាំងសត្វឱ្យដល់នូវសុគតិ, អធម៌ញុំាំងសត្វឱ្យដល់នូវទុគ្គតិ ។ សភាវៈឯណាដែលញុំាំងសត្វឱ្យបានសេចក្តីសុខ សភាវៈនោះឈ្មោះថាធម៌, សភាវៈឯណាដែលញុំាំងសត្វឱ្យបានសេចក្តីទុក្ខ សភាវៈនោះឈ្មោះថាអធម៌ ។

បុ. បើមិនមែនធម៌ទេ ហេតុអ្វីក៏ព្រះអង្គទ្រង់សំដែងមកធ្វើអ្វីច្រើនដល់ម្ល៉េះ? ដូចម្តេចក៏មិនសំដែងតែធម៌ៗ មក ?

វិ. អំពើសុចរិតដែលសត្វប្រព្រឹត្តទាំងប៉ុន្មាន ហើយញុំាំងសត្វឱ្យបានសេចក្តីសុខ ឈ្មោះថា ធម៌, អំពើទុច្ចរិតដែលសត្វប្រព្រឹត្តទាំងប៉ុន្មាន ហើយញុំាំងសត្វឱ្យបានសេចក្តីទុក្ខ ឈ្មោះថា អធម៌ ព្រះពុទ្ធដីកា ដែលទ្រង់សម្តែងមកទាំងពីរចំណែកយ៉ាងនេះ ឈ្មោះថាធម៌ ត្រង់អំពើបាបឈ្មោះថាអធម៌ ។

បុ. បើព្រះអង្គសំដែងតែសុចរិតមួយ កុំសំដែងទុច្ចរិតមកផង តើបានឬមិនបាន?

វិ. បើទ្រង់សំដែងតែសុចរិតម៉្យាងមិនបានទេ ត្រូវតែសំដែងទាំងពីរប្រាប់ផ្លូវឆ្វេង-ស្តាំ ត្រូវលះផ្លូវឆ្វេង កាន់យកផ្លូវស្តាំ គឺត្រូវប្រាប់អំពើអាក្រក់ឱ្យសត្វលះបង់ ប្រាប់អំពើល្អឱ្យសត្វកាន់យក បានជាត្រូវសំដែងទាំងពីរ ។

បុ. ក្នុងមហាកម្មវិភង្គសូត្រ សំដែងអំពីបុគ្គល ៤ ពួកថា បុគ្គលទី១ ប្រព្រឹត្តសុចរិត ស្លាប់ទៅកើតក្នុងសុគតិភព, បុគ្គលទី ២ ប្រព្រឹត្តទុច្ចរិតស្លាប់ទៅកើតក្នុងទុគ្គតិភព, បុគ្គលទី ៣ ប្រព្រឹត្តសុចរិត ស្លាប់ទៅកើតក្នុងទុគ្គតិភាព, បុគ្គលទី ៤ ប្រព្រឹត្តទុច្ចរិតស្លាប់ទៅកើតក្នុងសុគតិភព; ត្រង់បុគ្គលទី១-២មិនសង្ស័យទេ សង្ស័យបុគ្គលទី ៣-៤ ហេតុអ្វីក៏ឱ្យផលខុសអំពើដែលប្រព្រឹត្តទៅវិញ?

វិ. បុគ្គលទី ៣ ប្រព្រឹត្តសុចរិតស្លាប់ទៅកើតក្នុងទុគ្គតិភពនោះ បុគ្គលនោះឯង ដល់ពេលទៀបស្លាប់អំពើអកុសលមកជ្រៀតបៀតឱ្យផល បានជាទៅកាន់ទុគ្គតិភពទៅ បុគ្គលទី ៤ ប្រព្រឹត្តទុច្ចរិតស្លាប់ទៅកើតក្នុងសុគតិភពនោះ បុគ្គលនោះដល់

ពេលទៀបស្លាប់ កុសលមកជ្រៀតបៀតឱ្យផលបានជាទៅកើតក្នុងសុគតិ, បុគ្គលទី ៣ ទី ៤ នោះ ពេលដែលទៀបនឹងស្លាប់យទាសនកម្មមកឱ្យផល ។

បុ. បើសុចរិត និងទុច្ចរិតមិនទៀងដូច្នោះដដែល ចាំធ្វើសុចរិតទៀបស្លាប់តែម្តងទៅ កុំឱ្យពិបាកប្រព្រឹត្តពីដើមមកឱ្យយូរ ?

វិ. មិនបានទេ តោងតែប្រព្រឹត្តសុចរិតពីដើមទើបបាន ពីព្រោះផលទុច្ចរិតនិងសុចរិតនេះទៀងទេ ដែលប្រព្រឹត្តសុចរិតហើយទៅកាន់ទុគ្គតិនោះ ពីដើមមកប្រព្រឹត្តអំពើល្អទាំងអស់ដល់ទៅពេលជិតនឹងស្លាប់ ក៏មានអារម្មណ៍ធ្វើឱ្យថ្នាំងថ្នាក់ចិត្តហើយចុតិកន្លងពេលនោះទៅក៏ទៅកាន់ទុគ្គតិ ដូចព្រះបាទធម្មា-សោកជាដើម ហេតុដូច្នោះហើយបានជាពេលដែលជិតស្លាប់ មិនត្រូវឱ្យឮសូរសម្លេងអ្វីដទៃក្រៅពីសម្លេងធម៌ ឱ្យឮតែសម្លេងធម៌ម៉្យាង ។

ចំណែកបុគ្គលប្រព្រឹត្តអំពើទុច្ចរិត ហើយត្រឡប់បានទៅកាន់សុគតិនោះ បានតែអំពើទុច្ចរិតណាស្រាលៗទេ ទើបកុសលចូលមកជ្រៀតបៀតឱ្យផលផងបាន អំពើទុច្ចរិតធ្ងន់ៗ ដូចយ៉ាង

គោឃាតកបុរសជាដើម កុសលមិនអាចជួយឱ្យផលបានឡើយ ត្រូវតែទៅកាន់ទុគ្គតិម៉្យាង ។

បុ. ដូចយ៉ាងអង្គុលិមាល ធ្វើគរុកម្មសម្លាប់មនុស្ស ខ្វះតែ ម្រាមដៃ ១ បាន ១ ពាន់ (ម្រាមដៃ៩៩៩) ហេតុដូចម្ដេច ក៏មិន ទៅទុគ្គតិ បើកម្មធ្ងន់ជាងគោឃាតកបុរសទៅទៀត?

វិ. អង្គុលិមាលបានជាមិនទៅកាន់ទុគ្គតិ ព្រោះនិស្ស័យជា បច្ឆិមជាតិ ជាតិជាទីបំផុតត្រូវបានអរហត្តផល បានជាមិនទៅ កាន់ទុគ្គតិ ។

បុ. ចុះបាបកម្មដែលអង្គុលិមាលធ្វើទៅឯណាទៅ អ្នកណា ទទួល?

វិ. គ្មានអ្នកណាទទួលទេ ផលកម្មនោះជាអហោសិកម្ម ។

បុ. មនុស្សដែលដល់បច្ឆិមជាតិហើយ ហេតុអ្វីក៏ប្រព្រឹត្តធ្វើ បាបកម្មធ្ងន់ៗ គួរតែប្រព្រឹត្តធ្វើកុលសកម្ម ដរាបដល់បានសម្រេច ព្រះអរហត្ត?

វិ. មនុស្សដែលដល់បច្ឆិមជាតិហើយ ទៅប្រព្រឹត្តធ្វើបាបកម្ម នោះមកពីសេពគប់បាបមិត្ត បានជានាំប្រព្រឹត្តខុស ហេតុដូច្នោះ

ហើយបានជាព្រះអង្គទ្រង់ហាមផ្តាច់មិនឱ្យសេពគប់នឹងបុគ្គលពាល ។

បុ. ព្រះអង្គទ្រង់ហាមមិនឱ្យសេពគប់បុគ្គលពាល មនុស្សពាល មកសេពគប់នឹងបណ្ឌិត បើដូច្នោះធ្វើម្ដេចនឹងបានជួប្រទះគ្នា បើមួយប្រាប់ឱ្យគេច មួយប្រាប់ឱ្យរក?

វិ. ព្រះទ្រង់ហាមចំពោះតែមនុស្សណាដែលទើបនឹងប្រព្រឹត្តសុចរិតថ្មីនោះ កុំឱ្យចូលគំនិតនឹងមនុស្សពាល ដូចបណ្ឌិតមានព្រះខីណាស្រពជាដើម ត្រូវតែទៅប្រោសមនុស្សពាល ទុកណាជាទៅក្នុងចំណោមមនុស្សពាល ក៏លោកមិនប្រព្រឹត្តតាមពាលនោះឡើយ បណ្ឌិតបែបនេះ បុគ្គលពាលចូលទៅសេពគប់នឹងទៅជាបណ្ឌិតបាន ប្រៀបឧបមាដូចមនុស្សទើបនឹងជារោគថ្មីៗ គេហាមឱ្យតមចំណី បើមិនតមទេរោគនោះនឹងរើឡើងវិញ ដូចជាបុគ្គលដែលនឹងប្រព្រឹត្តសុចរិតថ្មីៗ តែសេពគប់នឹងបុគ្គលពាលមុខជានឹងក្លាយទៅជាពាលវិញមិនដដែល បុគ្គលជារោគបានសុខសប្បាយ ៤, ១០ ឆ្នាំហើយ ទើបទុកជាបរិភោគចំណីអ្វីក៏មិនលាប់ដែរ ដូចជាបុគ្គលដែលធ្លាប់ប្រព្រឹត្តសុចរិតមកយូរហើយ

បើទុកជាបានដើរចូលជាមួយនឹងបុគ្គលពាល ក៏មិនក្លាយទៅជាបុគ្គលពាលបានដែរ ។

បុ. សម្លាប់អ្វីខ្លះ បានព្រះនិព្វាន?

វិ. សម្លាប់មាតា ១, បិតា ១, ស្តេច ១, អ្នកដែន ១, នាយស្មៀន ១, សម្លាប់បុគ្គលទាំងអស់នេះ ទើបបានព្រះនិព្វាន ។

បុ. ក្នុងអនន្តរិយកម្មថា សម្លាប់មាតាបិតាត្រូវអនន្តរិយកម្មចុះក្នុងទីនេះហេតុអ្វីថាសម្លាប់មាតា បិតា ស្តេច អ្នកដែន និងនាយស្មៀននោះបានព្រះនិព្វាន មិនខុសគ្នានឹងពាក្យខាងដើមទៅហើយ?

វិ. ត្រង់ដែលថាសម្លាប់មាតា បិតា ស្តេច អ្នកដែន និងនាយស្មៀននោះ មិនមែនសម្លាប់មនុស្សមែនៗ នោះទេ ឯមាតាគឺតណ្ហា បិតាគឺអស្មិមានៈ ក្សត្រទាំងពីរគឺទិដ្ឋិទាំង ២ អ្នកដែនគឺអាយតនៈទាំង ១២ នាយស្មៀនគឺឆន្ទរាគៈ ដោយដាវគឺអរហត្តមគ្គញ្ញាណ ។

បុ. ដូចម្តេចបានជាលោកទុកមាតាដូចជាតណ្ហា?

វិ. បានជាលោកទុកមាតាដូចជាតណ្ហា ព្រោះតណ្ហាជាអ្នកញ៉ាំងសត្វឱ្យកើតក្នុងវដ្តសង្សារ មាតាជាអ្នកញ៉ាំងសត្វឱ្យកើតក្នុងបច្ចុប្បន្ននេះ ។

បុ. ហេតុអ្វីបានជាបិតាទុកដូចជាអស្មិមានះ?

វិ. បិតាតែងគ្រប់គ្រងនូវកូនប្រុស-ស្រី មិនឱ្យអ្នកណាមកបៀតបៀនបានយ៉ាងណា អស្មិមានះគឺហួងហែងថានេះជារបស់អញ នោះជារបស់អញ អ្នកណាមើលងាយមិនបាន ក៏យ៉ាងនោះដែរ ។

បុ. ទិដ្ឋិទាំងពីរហេតុអ្វីក៏ទុកដូចជាស្តេច?

វិ. ទិដ្ឋិទាំងពីរនេះបានជាទុកដូចជាស្តេច ព្រោះទិដ្ឋិនេះតែងកើតឡើងហើយ សម្លាប់នូវអកុសលធម៌ទាំងអស់ យ៉ាងណា, ចំណែកស្តេច បើបណ្តារាស្ត្រមានទោសកំហុសក៏អាចសម្លាប់បាន ហេតុដូច្នោះហើយបានជាថាទិដ្ឋិទាំងពីរទុកដូចជាស្តេច ។

បុ. អ្នកនៅក្នុងដែនហេតុអ្វីក៏ទុកដូចជាអាយតនៈទាំង ១២?

វិ. បានជាទុកដូចជាអាយតនៈ១២ នោះ ព្រោះដំណឹងអ្វីៗដែលចូលមកក្នុងនគរ ដោយអំណាចអ្នកនៅក្នុងដែនយ៉ាងណា,

ចំណែកអាយតនៈ ១២ ក៏តែងនាំដំណឹងទៅដល់ចិត្តខាងក្នុង ដូច្នោះដែរ ។

បុ. នាយស្មៀនហេតុអ្វីក៏ទុកដូចជាឆន្ទាគៈ?

វិ. នាយស្មៀនបានជាទុកដូចជាឆន្ទាគៈនោះ ព្រោះនាយស្មៀនជាអ្នកកត់ត្រារបស់ចេញចូលនៅក្នុងព្រះរាជវាំង ឯឆន្ទាគៈនេះនៅខាងក្នុងព្រះរាជវាំង គឺនគរកាយ កើតឡើងតែម្នាក់ឯងស្ងាត់ៗ ។

បុ. ព្រះពុទ្ធអង្គទ្រង់បរិនិព្វានជាធម្មតាពិតៗ ចុះព្រះធម៌ទ្រង់យាងចូលព្រះនិព្វានដែរឬ?

វិ. ព្រះពុទ្ធអង្គទ្រង់យាងចូលព្រះនិព្វាន ឯព្រះធម៌មិនបរិនិព្វានទេ ។

បុ. បើព្រះធម៌មិនបរិនិព្វានទេ ចុះហេតុអ្វីក៏ដល់កំណត់ប្រាំពាន់ (៥០០០) ព្រះវស្សាក៏អស់សាសនាទៅ?

វិ. ដែលថាអស់សាសនានោះមិនអស់ធម៌ទេ គឺអស់ពួកបរិស័ទអ្នកប្រតិបត្តិតាម ។

បុ. ដែលហៅថាអស់អ្នកប្រតិបត្តិនោះ តើអស់ដូចម្ដេច គ្មានមនុស្សកើតទៀតឬអ្វី?

វិ. មនុស្សមិនអស់ទេ ប៉ុន្តែអស់អ្នកមានសទ្ធាជ្រះថ្លានឹងប្រតិបត្តិ, ព្រះធម៌នៅដដែល ឧបមាដូចគ្រូពេទ្យចេះថ្នាំ ឯគ្រូពេទ្យស្លាប់អស់ទៅ ចំណែកខាងដើមថ្នាំនៅពាសពេញដដែល ប៉ុន្តែគ្មានអ្នកណាមួយសួររក គ្រូពេទ្យដូចជាអ្នកប្រតិបត្តិ ដើមថ្នាំដូចជាព្រះធម៌ ។

បុ. ព្រះធម៌ទាំង ៨៤.000 ធម្មក្ខន្ធ បើរួមឱ្យខ្លីចុះមកមានប៉ុន្មាន? គឺអ្វីខ្លះ?

វិ. ព្រះធម៌ទាំង ៨៤.000 ធម្មក្ខន្ធ បើរួមឱ្យខ្លីចុះមកមានតែត្រឹម ៣ គឺៈ សីល ១, សមាធិ ១, បញ្ញា ១ ។

បុ. សីលសម្រាប់ប្រដៅអ្វី? សមាធិសម្រាប់ប្រដៅអ្វី? បញ្ញាសម្រាប់ប្រដៅអ្វី?

វិ. សីលសម្រាប់ប្រដៅទូន្មានកាយវាចា, សមាធិសម្រាប់ប្រដៅចិត្ត, បញ្ញាសម្រាប់កាប់ឆ្ការនូវកិលេស ។

បុ. សីលសម្រាប់លះអ្វី? សមាធិសម្រាប់លះអ្វី? បញ្ញាសំរាប់លះអ្វី?

វិ. សីលសម្រាប់លះនូវទុច្ចរិតតាំង ៣ សមាធិសម្រាប់លះនូវនីវរណៈទាំង ៥, បញ្ញាសម្រាប់លះបង់នូវសំយោជនៈទាំង ១០ យ៉ាង ។

បុ. សីលឱ្យប្រយោជន៍ដល់អ្នកប្រតិបត្តិដូចម្តេច? សមាធិឱ្យប្រយោជន៍ដូចម្តេច? បញ្ញាឱ្យប្រយោជន៍ដូចម្តេច?

វិ. សីលឱ្យប្រយោជន៍បានវិជ្ជា ៣, សមាធិឱ្យបានអភិញ្ញា ៦, បញ្ញាឱ្យបាននូវបដិសម្ភិទា ៤ ។

បុ. បើសីលឱ្យបានវិជ្ជា ៣ ហាក់ដូចជាបានមគ្គផលក្នុងពេលនោះទៅហើយ ព្រោះវិជ្ជាទាំង ៣ នេះចាក់ធ្លុះនូវមគ្គផល គួរណាស់តែបញ្ញាចុះនឹងបានវិជ្ជា ៣ ?

វិ. វិជ្ជាទាំង ៣ នេះមិនមែនចាក់ធ្លុះនូវមគ្គនិងផលទេ គ្រាន់តែដឹងប៉ុណ្ណោះ មិនទាន់បានលះកិលេសទាំងអស់ ដែលបានយ៉ាងនេះដោយអំណាចកម្លាំងសីល ទុកជាសមាធិនិងបញ្ញា ក៏គង់មានកម្លាំងខ្សោយជាងសីលដែរ ។

បុ. អរិយសច្ចទាំង ៤ នេះ ជាលោកុត្តរទាំងអស់ឬ? ឬក៏ថាជាលោកិយដែរ?

វិ. អរិយសច្ចទាំង ៤ នេះ ជាលោកិយ ២ ជាលោកុត្តរ ២ គឺ ទុក្ខសច្ចនិងសមុទយសច្ចជាលោកិយ និរោធសច្ចនិងមគ្គសច្ចជា លោកុត្តរ ។

បុ. ធម៌ដទៃៗ សំដែងហេតុមុន ទើបសំដែងផលជាខាង ក្រោយ ចុះអរិយសច្ចហេតុអ្វីក៏សំដែងផលមុន! ដូចយ៉ាងទុក្ខសច្ច ជាផល និរោធសច្ចក៏ជាផលដែរ?

វិ. បានជាសំដែងផលមុននោះ គឺឱ្យដឹងទុក្ខមុន ទើបស្វែង រកហេតុដែលឱ្យកើតទុក្ខខាងក្រោយ ប្រាប់ទីរំលត់ទុក្ខ ប្រាប់ ដំណើរទៅកាន់ទីរំលត់ទុក្ខ ប្រៀបឧបមាដូចមនុស្សកើតរោគ ហើយស្វែងរកសមុដ្ឋានរោគនោះ បើដឹងជាក់ដូច្នេះហើយ គប្បី ស្វែងរកថ្នាំមកដាក់ឱ្យជា បានជាសំដែងហេតុមុនដូច្នេះ ។

បុ. សោមនស្សចិត្តសុទ្ធតែបុណ្យ ឬមានបាបខ្លះដែរ?

វិ. សោមនស្សចិត្តមិនសុទ្ធតែបុណ្យ ឬសុទ្ធតែបាបនោះទេ មានបុណ្យក៏មាន បាបក៏មាន ។

បុ. សោមនស្សជាបុណ្យដូចម្តេច?

វិ. សោមនស្សដែលរីករាយចំពោះទៅលើបុញ្ញកិរិយាវត្ថុ ទាំង ១០ ចាត់ជាបុណ្យ, សោមនស្សដែលរីករាយចំពោះទៅលើអំពើបាបផ្សេងៗ មានបាណាតិបាតជាដើម ចាត់ជាបាប ។

បុ. ឧបេក្ខាមានបុណ្យ-បាបឬ ឬសុទ្ធតែបុណ្យ?

វិ. ឧបេក្ខាមានបុណ្យ-បាបដូចគ្នានឹងសោមនស្សដែរ ។

បុ. មនុស្សដែលប្រព្រឹត្តអាក្រក់មានអ្វីជាមូលហេតុ?

វិ. មនុស្សដែលប្រព្រឹត្តអាក្រក់មាន លោភោ ទោសោ មោហោ ទាំង ៣ នេះជាមូលហេតុ ។

បុ. ចុះមនុស្សដែលប្រព្រឹត្តល្អមានអ្វីជាមូលហេតុ?

វិ. មនុស្សដែលប្រព្រឹត្តល្អមាន អលោភោ អទោសោ អមោហោ ទាំង ៣ នេះជាមូលហេតុ ។

បុ. ចុះមនុស្សខ្លះប្រព្រឹត្តល្អរហូតដល់បាត់បង់ជីវិតទៅ មានអ្វីជាមូលហេតុ?

វិ. មនុស្សខ្លះ ដែលប្រព្រឹត្តល្អរហូតដល់បាត់បង់ជីវិតទៅ ពរោះមានកល្យាណមិត្តជាមូលហេតុ ។

បុ. អ្នកដែលរក្សាសីលមិនស្ថិតស្ថេរ ប្រែក្រឡាប់ថយក្រោយវិញ មានអ្វីជាមូលហេតុ?

វ. មានការសេពគប់នឹងបាបមិត្តជាមូលហេតុ ។

បុ. ពាក្យថា កម្មៗ នេះ សុទ្ធតែបាបទាំងអស់ ឬមានបុណ្យខ្លះដែរ?

វិ. ពាក្យថា កម្មៗ នេះ ជាពាក្យកណ្តាល ជាបុណ្យក៏មាន ជាបាបក៏មាន, កម្មជាបុណ្យដូចពាក្យថា បុញ្ញកម្ម ឬកុសលកម្ម កម្មជាបាបដូចពាក្យថា បាបកម្ម ឬអកុសលកម្មជាដើម ។

បុ. មនុស្សបុថុជ្ជន និងព្រះអរិយៈបើនៅជាមួយគ្នា តើត្រូវសម្គាល់ដូចម្តេច ទើបដឹងថានេះជាព្រះអរិយៈ នេះជាបុថុជ្ជនបាន ?

វិ. ព្រះអរិយៈ និងបុថុជ្ជននោះ ត្រូវសំគាល់ត្រង់អារម្មណ៍ដែលមកប៉ះពាល់ គឺថាព្រះអរិយៈបើទុកជាអារម្មណ៍មកប៉ះពាល់ក៏នៅដដែល លោកមិនថ្នាំងថ្នាក់ជាប់ជំពាក់នឹងអារម្មណ៍ឡើយ ឯបុថុជ្ជនវិញ បើអារម្មណ៍មកប៉ះពាល់ រមែងញាប់ញ័រទៅតាមអារម្មណ៍ជាទីពេញចិត្ត និងអារម្មណ៍មិនជាទីពេញចិត្ត អារម្មណ៍ទាំងពីរយ៉ាងនេះ ជាហេតុឱ្យស្គាល់បានថា នេះជាព្រះអរិយៈ នេះជាបុថុជ្ជន ។

បុ. ព្រះពុទ្ធតាំងពីទ្រង់កសាងឡើងរហូតបានត្រាស់ ដែលបានសោតា សកទាគាមី អនាគាមីខ្លះដែរឬ?

វិ. ព្រះពុទ្ធតាំងពីទ្រង់កសាងឡើង រហូតបានត្រាស់ មិនដែលបានសោតា សកទាគាមី អនាគាមី ក្នុងជាតិណាម្តងទេ ។

បុ. ចុះហេតុអ្វីបានជាមិនដែលបាន បើព្រះអង្គខំកសាងលើសលុបណាស់ដែរ?

វិ. ពិតមែន, ព្រះអង្គខំកសាងដ៏លើសលុប ប៉ុន្តែនៅតែមិនបាន ព្រោះព្រះអង្គមានព្រះទ័យជាប់ជំពាក់នឹងសត្វ គឺចង់ចម្លងសត្តនិករឱ្យផុតពីវដ្តសង្សារដូចព្រះអង្គដែរ ។

បរិច្ឆេទកបញ្ហា ចប់តែប៉ុណ្ណេះ

---

# គិហិប្បដិបត្តិ

## ចតុក្កៈពួក ៤

### កម្មកិលេស

បុ. កម្មកិលេស ប្រែដូចម្តេច ?

វិ. កម្មកិលេស ប្រែថា កម្មជាគ្រឿងសៅហ្មង ឬថាអំពើជាគ្រឿងប្រឡាក់ប្រឡូស ។

បុ. កម្មកិលេសនោះ មានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. កម្មកិលេសនោះ មាន ៤ យ៉ាង គឺ:

**១-បាណាតិបាត** ធ្វើជីវិតសត្វឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ;

**២-អទិន្នាទាន** កាន់យករបស់ដែលគេមិនបានឱ្យ;

**៣-កាមេសុ មិច្ឆាចារៈ** ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ;

**៤-មុសាវាទៈ** និយាយពាក្យកុហក ។

បុ. កម្មកិលេសទាំង ៤ យ៉ាងនេះ មានសេចក្តីអធិប្បាយដូចម្តេច? ចូរអធិប្បាយមកមើល!

វិ. កម្មកិលេសទាំង ៤ យ៉ាងនេះ មានសេចក្តីអធិប្បាយដូច្នេះថា: ព្រោះហេតុដូចម្តេចបានជាលោកចាត់កម្ម ៤ យ៉ាងនេះថាជា

គ្រឿងសៅហ្មង? ព្រោះមនុស្សយើងគ្រប់គ្នារមែងមានសេចក្តីប្រព្រឹត្តិជាសំខាន់ មានសេចក្តីប្រព្រឹត្តិជាគ្រឿងសម្គាល់ ដែលបង្ហាញសេចក្តីបរិសុទ្ធិ ឬសេចក្តីសៅហ្មងឱ្យគេដឹង បានដល់បុគ្គលណាមានសេចក្តីប្រព្រឹត្តិល្អ គឺប្រព្រឹត្តជាសុចរិត បុគ្គលនោះឈ្មោះថាជាអ្នកបរិសុទ្ធ ។ បុគ្គលណាមានសេចក្តីប្រព្រឹត្តិអាក្រក់ គឺប្រព្រឹត្តជាទុច្ចរិត គឺបុគ្គលនោះឈ្មោះថាជាអ្នកសៅហ្មង ។ កម្ម ទាំង ៤ យ៉ាងនេះឯងជាកម្មអាក្រក់ ជាកម្មទុច្ចរិត ជាគ្រឿងទំនុកបម្រុងសេចក្តីប្រព្រឹត្តិឱ្យជាទុច្ចរិត ។ កាលបុគ្គលបានប្រព្រឹត្តនូវកម្ម ៤ យ៉ាងនេះហើយ ឈ្មោះថាជាអ្នកសៅហ្មងប្រាកដ ។ កម្ម ៤ យ៉ាងនេះ សូម្បីតែកម្មមួយៗ ក៏សុទ្ធតែជាកម្មដែលប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួននិងអ្នកដទៃ ដោយហេតុនេះកម្ម ៤ យ៉ាងទើបឈ្មោះថាជាកម្មក្កិលេស ។

ពាក្យថា ធ្វើជីវិតសត្វឱ្យធ្លាក់ចុះនេះ ប្រែតាមស័ព្ទថា ‹‹បាណាតិបាត›› ដែលជាវោហារមួយយ៉ាង ប្រើក្នុងព្រះពុទ្ធសាសនា សម្គាល់សេចក្តីថា សម្លាប់សត្វនោះឯង ។

ពាក្យថា កាន់យករបស់ដែលម្ចាស់គេមិនបានឱ្យ បានដល់ការកាត់កម្មសិទ្ធិរបស់អ្នកដទៃ គឺលួចនោះឯង ។

ពាក្យថា ប្រព្រឹត្តខុសក្នុងកាមទាំងឡាយនេះ សំគាល់សេចក្តីថា ធ្វើសវនកិច្ចនឹងស្ត្រីដែលនៅក្នុងការហួងហែងរបស់អ្នកដទៃ ដូចជាបុត្រីនិងភរិយារបស់គេជាដើម ។

ពាក្យថា និយាយកុហកនេះ សម្គាល់សេចក្តីថា និយាយមិនពិត ដោយចេតនានឹងឱ្យអ្នកដទៃចូលចិត្តខុស ឬឱ្យកាន់ជំនឿ ។

បុ. អបាយមុខ ប្រែដូចម្តេច?

វិ. អបាយមុខ ប្រែថា ហេតុជាគ្រឿងវិនាស ឬប្រធាននៃសេចក្តីវិនាស ។

បុ. អបាយមុខនោះ មានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. អបាយមុខនោះ មាន ៤ យ៉ាង គឺៈ

**១-ឥត្ថីធុត្តៈ** ជាអ្នកលេងស្រី;

**២-សុរាធុត្តៈ** ជាអ្នកលេងស្រា;

**៣-អក្ខធុត្តៈ** ជាអ្នកលេងល្បែងភ្នាល់ ឬល្បែងស៊ីសង;

**៤-បាបមិត្តៈ** យកមនុស្សអាក្រក់ជាមិត្ត ។

បុ. អបាយមុខ ៤ នោះ មានសេចក្តីអធិប្បាយដូចម្តេចខ្លះ? ចូរអធិប្បាយមកមើល!

វិ. អបាយមុខ ៤ នោះ មានសេចក្ដីអធិប្បាយដូច្នេះថាៈ ហេតុជាគ្រឿងវិនាសនោះ អ្នកសិក្សាត្រូវយល់ដូចតទៅនេះ អបាយមុខ ប្រែថា ផ្លូវនៃសេចក្ដីវិនាស សម្គាល់សេចក្ដីថា ទោស ៤ ប្រការនេះ ជាផ្លូវនៃសេចក្ដីវិនាស ។ បុរសណាជាមនុស្សល្ងង់ខ្លៅអប្បឥតប្រាជ្ញា ឈានជើងចុះទៅក្នុងផ្លូវអមង្គលនេះ បុរសនោះរមែងមានសេចក្ដីវិនាសជាខាងមុខ រមែងមានជីវិតរស់នៅដោយសេចក្ដីទ័ល បើជាមនុស្សមានទ្រព្យៗ រមែងអស់ទៅ បើជាមនុស្សមានយសៗ រមែងសាបសូន្យទៅ នឹងបានសោយផលគឺសេចក្ដីទុក្ខរហូតមួយជាតិ ដោយហេតុនេះ ទោស ៥ ប្រការទើបមានឈ្មោះថាអបាយមុខ ។

ពាក្យថា ស្រី ក្នុងពាក្យ ជាអ្នកលេងស្រីនោះចែកចេញជា ២ ប្រការ គឺស្រីដែលមានគេហួងហែង ១, ស្រីពេស្យា ១ ។ បុរសណាមានចិត្តជាប់នៅក្នុងស្រី ២ ប្រការនេះ ប្រភេទណាមួយក៏ដោយ ងប់មិនមានពេលលះបង់ មិនមានពេលស្វាង និងមិនមានកាលៈទេសៈ បុរសនោះឈ្មោះថាជាអ្នកលេងស្រី ។

ពាក្យថា ជាអ្នកលេងស្រានោះ គឺជាអ្នកផឹកជាប់ ផឹកគ្មានពេលស្រាក ស្រវឹងជានិច្ច ពោលតាមសាមញ្ញវោហារថា ជាអ្នកស្រវឹងខ្ចូបនោះឯង ។

ពាក្យថា ជាអ្នកលេងល្បែងភ្នាល់ ឬល្បែងស៊ីសងនោះ សម្គាល់សេចក្តីថា ការភ្នាល់មានច្រើនយ៉ាង ដូចបៀរ, ប៉ោ, ធូ, បាស្កាវជាដើម តែបើពោលដោយសរុបល្បែងឯណា មានការបានប្រាក់ បង់ប្រាក់ ល្បែងនោះចាត់ជាការភ្នាល់ បុរសណាកាន់យកការលេងល្បែងភ្នាល់ជាត្រីមុខ មិនមានរើសមិនមានឈប់ខំប្រឹងលែងមែនៗ បុរសនោះឈ្មោះថាជាអ្នកលេងល្បែងភ្នាល់ ឬល្បែស៊ីសង ។

ពាក្យថា យកមនុស្សអាក្រក់ជាមិត្រនោះ ត្រូវយល់លក្ខណៈរបស់មនុស្សអាក្រក់ជាមុន ។ មនុស្សអាក្រក់នោះ ពោលតាមគោលបានដល់ឃើញតែខាងបានអំពីគេ ១, មនុស្សល្អតែមាត់ ១, មនុស្សប្រចុប ១, មនុស្សដឹកនាំក្នុងផ្លូវវិនាស ១ ។ បុគ្គលអ្នកប្រកបដោយទោស ៤ ប្រការនេះ ឈ្មោះថាមនុស្សអាក្រក់ ។ បុរសណាគប់នឹងបុគ្គលមានសភាពដូច្នេះយកមកជាមិត្រសំឡាញ់ បុរសនោះឈ្មោះថាជាអ្នកយកមនុស្សអាក្រក់ជាមិត្រ ។

២៣

# ទិដ្ឋធម្មិកត្ថ

បុ. ទិដ្ឋធម្មិកត្ថ ប្រែដូចម្ដេច?

វិ. ទិដ្ឋធម្មិកត្ថ ប្រែថា ប្រយោជន៍ក្នុងបច្ចុប្បន្ន ។

បុ. ទិដ្ឋធម្មិកត្ថ នោះមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. ទិដ្ឋធម្មិកត្ថ នោះមាន ៤ យ៉ាងគឺៈ

១-**ឧដ្ឋានសម្បទា** ដល់ព្រមដោយសេចក្ដីព្យាយាម គឺព្យាយាមក្នុងការប្រកបកិច្ចការចិញ្ចឹមជីវិតក្ដី ក្នុងការសិក្សារៀនសូត្រក្ដី ក្នុងកិច្ចធុរៈ ជាមុខការនាទីរបស់ខ្លួនក្ដី;

២-**អារក្ខសម្បទា** ដល់ព្រមដោយការរក្សា គឺរក្សាទ្រព្យដែលរកបានមកដោយសេចក្ដីព្យាយាម មិនឱ្យអន្តរាយទៅក្ដី រក្សាការងារមិនឱ្យសាបសូន្យទៅក្ដី;

៣-**កល្យាណមិត្តតា** ភាពជាអ្នកមានមិត្តល្អ មិនសេពគប់មិត្រអាក្រក់;

៤-**សមជីវិតា** ការចិញ្ចឹមជីវិតតាមសមគួរដល់កម្លាំងទ្រព្យដែលបានមក គឺមិនត្បិតត្បៀតពេក មិនខ្ជះខ្ជាយពេក ។

បុ. ទិដ្ឋធម្មិកត្ថទាំង ៤ នោះ មានសេចក្ដីអធិប្បាយដូចម្ដេច? ចូរអធិប្បាយមកមើល!

វិ. ទិដ្ឋធម្មិកត្ថទាំង ៤ នោះ មានសេចក្ដីអធិប្បាយដូច្នេះថា ទិដ្ឋធម្មិកត្ថ គឺប្រយោជន៍ក្នុងបច្ចុប្បន្ននោះ អ្នកសិក្សាត្រូវយល់ថា លោកមិនមានបំណងយកតែធម៌ ៤ ប្រការ មានឧដ្ឋានសម្បទាជាដើមនោះថាជាតួទិដ្ឋធម្មិកត្ថប្រយោជន៍ដោយពិតទេ ធម៌ ៤ ប្រការនោះគ្រាន់តែជាបដិបទា ជាមេនាំផ្លូវឱ្យបានសម្រេចនូវទិដ្ឋធម្មិកត្ថប្រយោជន៍ផ្សេងៗ តទៅទៀត ។ កាលបើដូច្នេះ អ្វីសោតជាតួទិដ្ឋធម្មិកត្ថប្រយោជន៍? ទិដ្ឋធម្មិកត្ថប្រយោជន៍គឺទ្រព្យ យស និងមេត្រីជាឥដ្ឋផល ដែលសាមញ្ញជនត្រូវប្រាថ្នា ជនឯណាធ្វើខ្លួនឱ្យបានសម្រេចនូវផលទាំង ៣ ប្រការនោះហើយ ជននោះចាត់ថាតាំងខ្លួនបាន និងបានឈ្មោះថា តាំងទុកនូវទិដ្ឋធម្មិកត្ថប្រយោជន៍បានដោយពិត ។ ក៏ឯបុគ្គលដែលបានសម្រេចនូវផលទាំងនោះ ត្រូវប្រកបដោយធម៌ ៤ ប្រការនេះ មានឧដ្ឋានសម្បទាជាដើមដែរ ។

បុ. ឧដ្ឋានសម្បទា ដល់ព្រមដោយសេចក្ដីព្យាយាម តើបានសេចក្ដីដូចម្ដេច?

វិ. ឧដ្ឋានសម្បទា ដែលថាដល់ព្រមដោយសេចក្ដីព្យាយាមនោះ បានសេចក្ដីថា ខ្លួនមាននាទីយ៉ាងណាដែលគួរធ្វើ មានការ

សិក្សារៀនសូធ្យ ធ្វើស្រែចំការជួញប្រែជាដើម ក៏មិនមានកោសជ្ជៈខ្ជិលច្រអូស ខំប្រកបនាទីយ៉ាងនោះ ដោយសេចក្តីព្យាយាម ដែលមានកម្លាំងក្លៀវក្លាមិនរួញរាត្រឡប់ថយក្រោយចំពោះឧបស័គ្គដែលរារាំងខ្ទាំងខ្ទាស់ក្នុងចន្លោះ ប្រាថ្នាឱ្យតែនាទីនោះបានសម្រេចដោយរៀបរយជាដើម ។

បុ. អារក្ខសម្បទា ដល់ព្រមដោយការរក្សានោះ បានសេចក្តីដូចម្តេច?

វិ. អារក្ខសម្បទា បានសេចក្តីថា ចេះរក្សាទ្រព្យដែលរកបានមកដោយសេចក្តីព្យាយាមនោះ មិនឱ្យវិនាសបាត់បង់ដោយអន្តរាយផ្សេងៗ មានអន្តរាយដោយភ្លើងឆេះ ទឹកលិច ចោរលួចជាដើម ។ ឯការដែលចេះរក្សាទ្រព្យនោះ ចែកចេញដោយអាការៈ ៩ យ៉ាង គឺចេះទុកដាក់ ដូចទុកក្នុងទីមាំមួនឱ្យផុតចាកអន្តរាយ ១, ចេះថ្នមដូចរបស់ដែលមានការបែកធ្លាយជាប្រក្រតីមានគ្រឿងចានកែវជាដើម នឹងចាប់កាន់ប្រយ័ត្នមិនឱ្យភ្លាត់ធ្លាក់ ១, ចេះជួសជុលអបស្វុបដូចគ្រឿងយន្ត គ្រឿងចក្រមាននាឡិកាជាដើម ដែលខូចក៏កែត្រឡប់ឱ្យល្អដូចដើមវិញ ១, ចេះស្តាយដូចជារបស់មិនគួរខូចមិនបណ្តោយឱ្យខូច របស់ដែលល្មមនៅ

ប្រើប្រាស់បានមិនចោល ១, ចេះធ្វើឱ្យកើតផលដូចមានស្រែមានសួនច្បារ ធ្វើខ្លួនឯងខ្លះ ជួលឱ្យគេខ្លះ រួមជា ៥ ប្រការ ។

បុ. កល្យាណមិត្តតា ភាពជាអ្នកមានមិត្រល្អនោះ បានសេចក្ដីដូចម្ដេច?

វិ. កល្យាណមិត្តតា បានសេចក្ដីថា ភាពជាអ្នកសេពគប់មិត្តល្អមិនសេពគប់មិត្រអាក្រក់ ។ ការសេពគប់ជាសំខាន់បំផុត ដូចពោលហើយក្នុងស្ថានខ្លះថា សេពគប់មិត្រអាក្រក់ក៏ធ្វើអាក្រក់ទៅតាមផង សេពគប់មិត្រល្អ ក៏គង់ធ្វើឱ្យល្អទៅតាមផង ពោលដោយចំពោះការសេពគប់នឹងមិត្រល្អ គេរមែងជួយទំនុកបម្រុងការស្វែងរកទ្រព្យបានស្រួល គេធ្លាក់ក្នុងផ្លូវណា ក៏គង់ជួយប្រកបមិត្រក្នុងផ្លូវនោះ ។

បុ. សមជីវិតា ការចិញ្ចឹមជីវិតតាមសមគួរដល់កម្លាំងទ្រព្យដែលរកបានមក តើបានសេចក្ដីដូចម្ដេច?

វិ. សមជីវិតានោះ បានសេចក្ដីថាចេះចាយ គឺមិនមែនចាយឱ្យត្បិតត្បៀតពេក មិនមែនចាយខ្ជះខ្ជាយពេក ។ ការចេះចាយដូច្នេះនេះ គប្បីកំណត់ដឹងចំណូលចំណាយជាមុនថា ចំណាយរាល់ថ្ងៃក្ដី ចំណាយរាល់ខែរាល់ឆ្នាំក្ដី អស់ប៉ុន្មាន ប្រើការចាយបរិភោគ

មិនឱ្យលើសចំណូល ។ បើរកបានមកតិច ក៏ស្វិតស្វាញរឹតត្បិតឱ្យល្មមតែចិញ្ចឹមអាត្មា គួរអត់ធ្មត់កុំទិញរបស់ដែលថ្លៃៗ បរិភោគឡើយ បើរកបានមកច្រើន ក៏ពង្រីកការចិញ្ចឹមជីវិតឱ្យល្មមបានសេចក្តីសុខសម្រាន្តតាមកម្លាំងទ្រព្យ តែគួរបែងទុកដាក់ជាទុនឱ្យនៅស្ងៀមមួយចំណែក ដើម្បីបង្ការក្រែងមានហេតុការអាសន្នទៅ ដូចមានការឈឺចាប់ជាដើម និងបានចាយជាការត្រាច់ទៅរកគ្រូពេទ្យ ឬរកថ្នាំផ្សេងៗ ។ អ្នករៀវចាកការត្បិតត្បៀតនិងខ្ជះខ្ជាយ អ្នកចេះបន្ធូរបន្ថយការចិញ្ចឹមខ្លួនគ្រាន់តែល្មមឱ្យកើតសុខដូច្នេះឯងហៅថា អ្នកចេះចាយវាយ ។

# សម្បរាយិកត្ថ

បុ. សម្បរាយិកត្ថ ប្រែដូចម្តេច?

វិ. សម្បរាយិកត្ថ ប្រែថា ប្រយោជន៍ក្នុងលោកខាងមុខ ឬប្រយោជន៍ប្រព្រឹត្តទៅក្នុងសម្បរាយភព ។

បុ. សម្បរាយិកត្ថនោះមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. សម្បរាយិកត្ថនោះ មាន ៤ យ៉ាង គឺះ

*១-សទ្ធាសម្បទា* ការដល់ព្រមដោយសទ្ធា គឺជឿរបស់ដែលគួរជឿ ដូចជឿថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ជាដើម;

*២-សីលសម្បទា* ការដល់ព្រមដោយសីល គឺការរក្សាកាយវាចាឱ្យរៀបរយ ឱ្យផុតចាកទោស;

*៣-ចាគសម្បទា* ការដល់ព្រមដោយការបរិច្ចាគទាន ជាការចែកសុខដល់អ្នកដទៃ;

*៤-បញ្ញាសម្បទា* ការដល់ព្រមដោយបញ្ញា គឺស្គាល់បាបបុណ្យគុណទោស ប្រយោជន៍និងឥតប្រយោជន៍ជាដើម ។

បុ. សម្បរាយិកត្ថទាំង ៤ នេះ មានសេចក្ដីអធិប្បាយយ៉ាងណា? ចូរអធិប្បាយមកមើល!

វិ. សម្បរាយិកត្ថទាំង ៤ នេះ មានសេចក្ដីអធិប្បាយយ៉ាងនេះថា: ប្រយោជន៍ក្នុងលោកខាងមុខ គឺមនុស្សសម្បត្តិ សួគ៌សម្បត្តិ និព្វានសម្បត្តិ ។ សម្បត្តិទាំងបីប្រការនេះ ជាសម្បត្តិដែលមនុស្សប្រាថ្នាក្រៃពេក តែលោកពោលថាមិនបានសម្រេច ដោយត្រឹមតែការបន់ស្រន់សុំនោះទេ ត្រូវដល់ព្រមដោយការប្រព្រឹត្តិ គឺជាអ្នកបរិបូណ៌ដោយសទ្ធា ដោយសីល ដោយការបរិច្ចាគទាន ដោយបញ្ញា លោកប្រាប់ថាសមដូចបំណងមែន មិនតែប៉ុណ្ណោះ

អ្នកដល់ព្រមដោយគុណធម៌ ដូចពោលមកហើយនេះ សូម្បីក្នុងបច្ចុប្បន្ននេះ ក៏គេបានទទួលសេចក្ដីសុខ ព្រោះសេចក្ដីល្អដែលធ្វើនោះគ្រប់គ្រងរក្សា រាងកាយរបស់អ្នកនោះរាប់ថាមានសារៈ មិនឥតប្រយោជន៍, ហេតុនេះ លោកពោលថាជាប្រយោជន៍ក្នុងលោកខាងមុខ ។

## មិត្តដែលមិនគួរសេពគប់មាន ៤ ប្រភេទ

**១-អញ្ញទត្ថុហរៈ** មនុស្សឃើញតែខាងបានអំពីគេ;
**២-វចីបរមៈ** មនុស្សល្អតែមាត់;
**៣-អនុប្បិយភាណី** មនុស្សប្រចុប;
**៤-អបាយសហាយៈ** មនុស្សដឹកនាំក្នុងផ្លូវវិនាស ។

បុ. ពាក្យថា មិត្ត ប្រែដូចម្ដេច?

វិ. ពាក្យថា មិត្ត ប្រែថា អ្នកដែលរាប់អានគ្នាជិតដិត ឬថាសម្លាញ់ ។

បុ. ចុះមិត្តទាំង ៤ ពួកនេះ ហេតុអ្វីបានជាហាមមិនឱ្យសេពគប់?

វិ. មិត្តទាំង ៤ ពួកនេះ បានជាហាមមិនឱ្យសេពគប់ ព្រោះលោកចាត់ជាមិត្តប្បដិរូប ‹‹មនុស្សប្លមមិត្ត›› ឬ ‹‹មិត្របួម›› មិនមែនមិត្រពិតប្រាដកទេ ។

បុ. ចុះមិត្តទាំង ៤ នេះ ក្នុងខនីមួយៗ មានលក្ខណៈសម្រាប់សម្គាល់ដូចម្ដេចខ្លះ? ចូរអធិប្បាយមកមើល!

វិ. មិត្រទាំង ៤ នេះ ក្នុងខនីមួយៗ មានលក្ខណៈសម្រាប់សំគាល់ដូចសេចក្ដីអធិប្បាយតទៅនេះ ៖

**១-អញ្ញទត្ថុហរៈ** មនុស្សឃើញតែខាងបានអំពីគេ មានលក្ខណៈជាគ្រឿងសម្គាល់ ៤ យ៉ាងគឺៈ គិតតែពីខាងបាន ១, ឱ្យតិចចង់បានច្រើន ១, កាលមានភ័យដល់ខ្លួន ទើបជួយធ្វើការរបស់មិត្រ ១, សេពគប់នឹងមិត្តព្រោះតែឃើញប្រយោជន៍ខ្លួនឯង ១ ។

**២-វចីបរមៈ** ‹‹មនុស្សល្អតែមាត់›› មានលក្ខណៈជាគ្រឿងសម្គាល់ ៤ យ៉ាងគឺៈ រើសយករឿងហេតុដែលកន្លងទៅហើយមកពណ៌នា ១, អាងយករឿងហេតុដែលមិនទាន់មាន មកពណ៌នា ១, សង្គ្រោះដោយរបស់ឥតប្រយោជន៍ ១, កាលមានកិច្ចកើតឡើងពឹងប្រាស្រ័យពុំបាន ១ ។

**៣-អនុប្បិយភាណី** ‹‹មនុស្សប្រចុប›› មានលក្ខណៈជាគ្រឿងសំគាល់ ៤ យ៉ាងគឺៈ មិត្រធ្វើអាក្រក់ក៏បណ្តោយតាម ១, មិត្រធ្វើល្អក៏បណ្តោយតាម១, ចំពោះមុខសរសើរ១, កំបាំងមុខនិន្ទា១ ។

**៤-អបាយសហាយៈ** ‹‹មនុស្សដឹកនាំផ្លូវវិនាស›› មានលក្ខណៈជាគ្រឿងសម្គាល់ ៤ យ៉ាងគឺៈ ដឹកនាំឱ្យផឹកទឹកស្រវឹង ១, ដឹកនាំឱ្យដើរលេងយប់ ១, ដឹកនាំឱ្យចូលចិត្តលេង ឬមើលមហោស្រព ១, ដឹកនាំឱ្យលេងល្បែងភ្នាល់ ឬល្បែងស៊ីសង ១ ។

## មិត្រដែលគួរសេពគប់មាន ៤ ប្រភេទ

**១-ឧបការមិត្ត** មិត្រមានឧបការៈ;

**២-សុខទុក្ខមិត្ត** មិត្តរួមសុខរួមទុក្ខ;

**៣-អត្ថក្ខាយិមិត្ត** មិត្រប្រាប់ផ្លូវប្រយោជន៍ឱ្យ;

**៤-អនុកម្បកមិត្ត** មិត្រមានសេចក្តីអាណិត ។

បុ. មិត្តដែលគួរសេពគប់ទាំង ៤ ប្រភេទនោះ មានសេចក្តីយ៉ាងណាខ្លះ? ចូរអធិប្បាយមកមើល!

វិ. មិត្រដែលគួរសេពគប់ទាំង ៤ ប្រភេទនេះ មានសេចក្ដីអធិប្បាយយ៉ាងនេះ ៖

**១-ឧបការមិត្ត** ‹‹មិត្រមានឧបការៈ›› មានលក្ខណៈជាគ្រឿងសម្គាល់ ៤ យ៉ាងគឺៈ ការពារមិត្តដែលប្រហែសហើយ ១, ការពារទ្រព្យរបស់មិត្រដែលប្រហែសហើយ ១, កាលមានភ័យជាទីពឹងបាន ១, កាលមានធុរៈកើតឡើងជួយចេញទ្រព្យលើសជាងមិត្តនិយាយខ្ចី ១ ។

**២-សុខទុក្ខមិត្ត** ‹‹មិត្ររួមសុខរួមទុក្ខ›› មានលក្ខណៈជាគ្រឿងសំគាល់ ៤ យ៉ាងគឺៈ បញ្ចេញសេចក្តីកំបាំងរបស់ខ្លួនប្រាប់ដល់មិត្ត ១, បិទសេចក្តីកំបាំងរបស់មិត្រមិនឱ្យសាយភាយ ១, មិនលះចោលគ្នាកាលមានភ័យ១, សូម្បីជីវិតក៏លះជំនួសបាន១ ។

៣-អត្ថក្ខាយិមិត្ត ‹‹មិត្រប្រាប់ផ្លូវប្រយោជន៍ឱ្យ›› មានលក្ខណៈជាគ្រឿងសម្គាល់ ៤ យ៉ាងគឺៈ ហាមមិនធ្វើសេចក្តីអាក្រក់ ១, ដឹកនាំឱ្យតាំងនៅក្នុងសេចក្តីល្អ ១, ដឹកនាំឱ្យបានស្តាប់សេចក្តីដែលមិនទាន់បានស្តាល់ ១, ប្រាប់ផ្លូវសួគ៌ស្ថាប់ ១ ។

៤-អនុកម្បកមិត្ត ‹‹មិត្តមានសេចក្តីអាណិត›› មានលក្ខណៈជាគ្រឿងសំគាល់ ៤ យ៉ាងគឺៈ មិនត្រេកអរក្នុងវេលាដែលមិត្រសាប

សូន្យ ១, ត្រេកអរចំពោះមិត្រអ្នកបានសេចក្ដីចម្រើន ១, ហាមឃាត់មនុស្សអ្នកនិយាយតិះដៀលមិត្ត ១, សរសើរមនុស្សអ្នកនិយាយលើកមិត្រ ១ ។

## ការបែងទ្រព្យជាចំណែក ៤

បុ. ការបែងទ្រព្យជាចំណែក ៤ តើព្រះសម្មាសម្ពុទ្ធប្រដៅចំពោះបុគ្គលពួកណា?

វិ. ព្រះសម្មាសម្ពុទ្ធទ្រង់ប្រដៅចំពោះបុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ គឺគ្រហស្ថ ។

បុ. ការបែងទ្រព្យជាចំណែក ៤ នោះ តើដូចម្ដេចខ្លះ?

វិ. ការបែងទ្រព្យជាចំណែក ៤ នោះគឺៈ

១-ការបែងចំណែកទុកចាយប្រើប្រាស់ចិញ្ចឹមជីវិត;

២-ការបែងចំណែកទុកធ្វើការកុសលផង;

៣-ការបែងចំណែកទុកសម្រាប់បប្រកបការរបរផ្សេងៗ;

៤-ការបែងចំណែកទុកការពារក្នុងវេលាមានធុរៈ មានឈឺចាប់ជាដើម ។

# សង្គហវត្ថុ

បុ. សង្គហវត្ថុ ប្រែដូចម្ដេច? បានសេចក្ដីដូចម្ដេច?

វិ. សង្គហវត្ថុ ប្រែថា វត្ថុជាគ្រឿងសង្គ្រោះដល់គ្នានិងគ្នា បានសេចក្ដីថា ប្រជុំជនដែលរួមគ្នានៅជាពួកក្រុមតាំងអំពីគ្រួសារមួយ ត្រកូលមួយ ស្រុកមួយ តំបន់មួយ ភូមិមួយ រហូតដល់ប្រទេសមួយ ជាតិមួយ ត្រូវសង្គ្រោះដល់គ្នានិងគ្នាតាមឱកាសដ៏សមគួរ ។

បុ. សង្គហវត្ថុ នោះ មានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. សង្គហវត្ថុនោះ មាន ៤ យ៉ាង គឺះ

**១-ទាន:** ការបែងវត្ថុរបស់ខ្លួនឱ្យដល់មនុស្សដែលគួរឱ្យ;

**២-បិយវាចា** ពោលពាក្យពិរោះជាទីស្រឡាញ់;

**៣-អត្ថចរិយា** ប្រព្រឹត្តក្នុងការជាប្រយោជន៍ដល់អ្នកដទៃ;

**៤-សមានត្តតា** ជាអ្នកតាំងខ្លួនស្មើ មិនប្រកាន់ខ្លួន ។

បុ. សង្គហវត្ថុនេះ មានសេចក្ដីអធិប្បាយដូចម្ដេច?

វិ, សង្គហវត្ថុនេះ មានសេចក្ដីអធិប្បាយថា: សង្គហវត្ថុទាំង ៤ នេះ កាលបើពោលដោយអានិសង្ស បានដល់ការញ៉ាំងសាមគ្គីរបស់មនុស្សទាំងឡាយឱ្យមាំមួននិងឱ្យប្រព្រឹត្តទៅដោយមូលមិត្តគ្នា ។ បើសង្គហឧបាយទាំងនេះមិនមានទេ គឺគ្មានមនុស្សអើ

ពើនឹងធ្វើ ដូចមាតាបិតាមានបុត្រធីតាហើយមិនសង្គ្រោះ ឈ្មោះថាមិនបានទទួលបដិការៈរបស់បុត្តធីតាឡើយ ។ បណ្ឌិតទាំង-ឡាយពិចារណាឃើញសង្គហឧបាយនេះ ថាជាកិច្ចល្អប្រពៃ បានប្រព្រឹត្តធ្វើសមគួរតាមកម្លាំងហើយ ទើបលោកបានដល់នូវសេចក្តីធំថ្កើង និងសេចក្តីសរសើរអំពីប្រជុំជន ។

**ទានៈ** ‹‹ការបែងវត្ថុរបស់ខ្លួនឱ្យ គឺចែករំលែកទេយ្យវត្ថុ ឬទ្រព្យសម្បត្តិរបស់ខ្លួន ទំនុងបម្រុងផ្គុងផ្គើមដល់មនុស្សទាំង-ឡាយដោយអធ្យាស្រ័យប្រកបដោយមេត្តាករុណា ។ ទាននេះជាចំណងសម្រាប់ចងមិត្តភាពរវាងមនុស្សផងគ្នា ឱ្យជាប់មាំមួនសមដូចពុទ្ធភាសិតថា ‹‹ទទំ មិត្តា និគន្ថតិ បុគ្គលអ្នកឱ្យទានរមែងចងមិត្របាន›› ។ ការឱ្យទានជាសាធារណប្រយោជន៍ឈ្មោះថាសង្គហៈទី ១ សម្រាប់ឃឹតយោងស្រោចស្រង់ទាញចិត្តនរជនទូទៅឱ្យមានសាមគ្គីរួបរួមគ្នា និងជាឧបាយនាំឱ្យបាននូវសេចក្តីសុខក្នុងលោកនេះ និងលោកខាងមុខ ។

**បិយវាចា** ពោលវាចាពិរោះជាទីស្រឡាញ់ គឺសំដីពីរោះផ្អែមល្ហែម គួរឱ្យចង់ឮ ឬចង់ស្តាប់ ជាសំដីអាចទាញចិត្តមនុស្សក្នុងលោកឱ្យមានមេត្រីរាប់រកគ្នា ឱ្យមូលមិត្តគ្នាបាន ។ ឯការ

ពោលពាក្យពីរោះ គួរជាទីស្រឡាញ់ពេញចិត្តនេះ បានខាងការវៀរចាកពោលពាក្យទ្រគោះបោះបោក គំហកគំហើន ខ្ទោះខ្ទរមិនគួរស្តាប់ ឬពាក្យជេរប្រទេចផ្តាសា ដោយប៉ងប្រាថ្នានឹងឱ្យអ្នកដទៃច្រឡោតខឹងនឹងសម្តីរបស់ខ្លួន ។ ការពោលពាក្យពីរោះគួរឱ្យចង់ស្តាប់ ដូចបានអធិប្បាយមកដោយសង្ខេបប៉ុណ្ណេះ ចាត់ជាសង្គហវត្ថុទី ២ សម្រាប់សង្គ្រោះស្រោចស្រង់ប្រជាជនគ្រប់ប្រភេទ ឱ្យមានមេត្រីភាពមូលមតិគ្នាអង្វែងតទៅ ។

**អត្ថចរិយា** ប្រព្រឹត្តក្នុងការជាប្រយោជន៍ដល់អ្នកដទៃ គឺការប្រព្រឹត្តឱ្យកើតផលប្រយោជន៍ ឬឱ្យកើតសេចក្តីចម្រើនដល់គ្នានិងគ្នា ជាគុណដ៏សំខាន់បំផុត អាចសង្គ្រោះឱ្យបានសេចក្តីសុខចំរើនទៅបាន ។ ការសង្គ្រោះគ្នាដោយឱ្យប្រយោជន៍ ឬសេចក្តីចំរើនដល់គ្នានិងគ្នានេះ បានដល់ការមិនមើលបំណាំគ្នា ។ កល្យាណជនអ្នកមានសីលធម៌ល្អ ហើយជួយណែនាំពន្យល់ប្រាប់ជនអ្នកមិនមានសទ្ធា ឱ្យមានសទ្ធាជ្រះថ្លាឡើង ជនអ្នកមិនមានសីលឱ្យមានសីលឡើង អ្នកមានសេចក្តីកំណាញ់ឱ្យមានការបរិច្ចាគទ្រព្យធ្វើបុណ្យឱ្យទានឡើង អ្នកឥតប្រាជ្ញាឱ្យមានប្រាជ្ញាឡើង យ៉ាងនេះឯងហៅថា ការប្រព្រឹត្តជាប្រយោជន៍ដល់គ្នានិង

គ្នា ។ ម្យ៉ាងទៀត ការប្រព្រឹត្តិជាប្រយោជន៍ដល់គ្នានិងគ្នាតាមឱកាសដ៏សមគួរ គឺខ្វល់ខ្វាយក្នុងប្រយោជន៍របស់គេ ដូចក្នុងពេលដែលគេមានជម្ងឺឈឺចាប់ គឺជួយព្យាបាលនិងរកថ្នាំ ឬរកគ្រូពេទ្យមកឱ្យ ។ កាលបើមានមនុស្សដែលប្រាសចាកញាតិបងប្អូនដល់នូវមរណកាល មិនមានអ្នកណានឹងធ្វើឈាបនកិច្ចសពនោះទេ ក៏ជួយចាត់ការឱ្យ និងបំពេញទក្ខិណានុប្បទានកិច្ចឧទ្ទិសឱ្យតាមដែលគួរនឹងធ្វើបាន ឬកិច្ចការឯណាដែលត្រូវជួយដោយវាចាបានក៏ជួយតាមកម្លាំងនៃសេចក្ដីអង់អាច ឬសូម្បីមិនមានឱកាសដែលជួយកាយនិងវាចាបានទេ ក៏គង់ជួយដោយមេត្តាមនោកម្ម មិនធ្វើមិនជាមនុស្សមានចិត្តអាក្រក់ចំពោះគុណ មិត្រសម្លាញ់ក្នុងស្រុកភូមិជាមួយគ្នាឡើយ ។ ការប្រព្រឹត្តិឱ្យកើតផលប្រយោជន៍ដល់គ្នានិងគ្នា ដូចន័យដែលបានពណ៌នាមកនេះ ចាត់ជាសង្គហវត្ថុទី ៣ សម្រាប់សង្គ្រោះប្រជាជន ឱ្យមានមេត្រីមូលមិត្តគ្នាជាអង្វែងតទៅ ។

**សមានត្តតា** ភាពជាអ្នកធ្វើខ្លួនស្មើមិនប្រកាន់ខ្លួន គឺតាំងខ្លួនឱ្យនៅស្មើៗ ឬតាំងខ្លួនជាកណ្ដាលៗ ចំពោះជនដែលជាញាតិមិត្តក្នុងគ្រាដែលខ្លួនមានអំណាចវាសនា គឺចំរើនដោយ

ឥស្សរិយយសបុណ្យស័ក្តិភោគទ្រព្យ និងបរិវារជាដើម ក៏មិនសំដែងអាការៈ មើលងាយគេ ឬធ្វើឫកពាក្រអឺតក្រអោង ព្រហើនកោងកាច លែងស្គាល់ញាតិមិត្រឡើយ ។ ម៉្យាងទៀត កាលញាតិមិត្ររបស់ខ្លួន បានលាភយសសរសើរសុខ ក៏មានមុទិតាចិត្តរីករាយ មិនលះបង់ព្រងើយកន្តើយ មិនមានអធ្យាស្រ័យប្រកបដោយឫស្យានៅក្នុងសន្តានចិត្តឡើយឯង ។ ក្នុងគ្រាដែលញាតិមិត្ររបស់ខ្លួនមានភ័យវិបត្តិ ឬត្រូវមានទុក្ខ ក៏មិនលះបង់ព្រងើយកន្តើយធ្វើដូចជា មនុស្សដទៃមិនធ្លាប់ស្គាល់គ្នានោះទេ ។ ការដែលប្រកាន់មានះ ក្អេងក្អាងមើលងាយគេរមែងបានផលទៅជាលែងរាប់អានគ្នា នាំឱ្យសាបសូន្យសេចក្តីរាប់អានទៅវិញ ជាហេតុនាំឱ្យវិនាសក្នុងលោក សមដូចព្រះពុទ្ធដីកាក្នុងបរាភវសូត្រថាៈ ជនដែលប្រកាន់ជាតិ ប្រកាន់ទ្រព្យ ប្រកាន់ត្រកូល ហើយមើលងាយញាតិសន្តានរបស់ខ្លួន ហេតុនោះជាប្រធានរបស់បុគ្គលអ្នកមានសេចក្តីវិនាស។ ដូច្នេះសាធុជនត្រូវអប់រំការប្រព្រឹត្តិតាំងខ្លួនឱ្យស្មើ ចំពោះបុគ្គលនោះ តាមសមគួរ ទើបសេចក្តីស្រឡាញ់រាប់អានគ្នា មានកម្លាំងតាំងនៅជាអង្វែងតទៅ ។

# សេចក្តីសុខរបស់គ្រហស្ថ

បុ. សេចក្តីសុខរបស់គ្រហស្ថមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. សេចក្តីសុខរបស់គ្រហស្ថមាន ៤ យ៉ាងគឺ ៖

១-សុខកើតអំពីការមានទ្រព្យ;

២-សុខកើតអំពីចាយទ្រព្យបរិភោគ;

៣-សុខកើតអំពីការមិនជំពាក់បំណុលគេ;

៤-សុខកើតអំពីការប្រកបការងារប្រាសចាកទោស ។

បុ. សុខរបស់គ្រហស្ថទាំង ៤ យ៉ាងនេះ មានសេចក្តីអធិប្បាយដូចម្តេច? ចូរអធិប្បាយមកមើក!

វិ. សុខរបស់គ្រហស្ថទាំង ៤ យ៉ាងនេះ មានសេចក្តីអធិប្បាយដូច្នេះថា: មែនពិត គ្រហស្ថគឺបុគ្គលអ្នកគ្រប់គ្រងផ្ទះ គ្រហស្ថណាប្រកបដោយលក្ខណៈ ៤ យ៉ាងនេះ គ្រហស្ថនោះឈ្មោះថា មានសុខដល់ព្រមដោយសេចក្តីសុខ ជារបស់ដែលមហាជនគួរប្រាថ្នាក្រៃពេក ។ លក្ខណៈ ៤ ប្រការនោះ កាលបើបំព្រួញឱ្យខ្លីមក នៅត្រឹមតែការមានទ្រព្យមួយយ៉ាងប៉ុណ្ណោះ ព្រោះជនអ្នកមានទ្រព្យរមែងមាសេចក្តីរីករាយក្នុងចិត្តថា ទ្រព្យរបស់ខ្លួនដែលមានហើយ នឹងបានចាយទ្រព្យនោះចិញ្ចឹមខ្លួន និងទំនុងបំរុងមនុស្ស

ដែលគួរចិញ្ចឹម រមែងបានសេចក្តីសុខកាយសប្បាយចិត្ត កាលឃើញខ្លួនជាអ្នកជា មិនជំពាក់បំណុលអ្នកដទៃ រមែងមានចិត្តស្រឡះស្រឡំ និងត្រិះរិះក៏បានស្រួល មិនតក់ស្លុតខ្លាំងខ្លាស់ឡើយ កាលបានអាស្រ័យភោគៈជាកម្លាំងឱ្យរស់ដោយប្រពៃហើយ មិនត្រូវប្រកបដោយការដែលជាចំណែកទុច្ចរិត រមែងបានផលនៃជីវិត សុទ្ធតែប្រព្រឹត្តទៅដោយសេចក្តីចម្រើនទាំងអស់ ។ តែទ្រព្យដែលរកបានមកក្នុងផ្លូវខុស មិនមានឱ្យសម្រេចកិច្ចទាំងអម្បាលនោះបានឡើយ ព្រោះដូច្នោះ ការស្វែងរកទ្រព្យ ទើបគេឱ្យប្រព្រឹត្តទៅក្នុងផ្លូវដែលប្រពៃ ។ ការស្វែងរកក្នុងការបំផ្លាញកម្មសិទ្ធិចំពោះភោគៈទ្រព្យរបស់អ្នកដទៃ ដែលធ្វើដោយអាការៈលួចក្តី ដោយប្រលោមក្តី ដោយប្លន់ដណ្តើមក្តី ដោយប្រើអំណាចក្តី ដោយអាការៈទុច្ចរិតដទៃៗ ទៀតក្តី ដូច្នេះឈ្មោះថា អនេសនាការស្វែងរកមិគួរទាំងអស់ ។ អ្នកប្រាជ្ញទាំងឡាយមានព្រះសម្មាសម្ពុទ្ធជាដើមតិះដៀលថា ការងារដែលប្រព្រឹត្តទៅដើម្បីទោសមិនមែនជាការងារដែលញុំាងប្រយោជន៍ឱ្យកើតឡើង ដល់បុគ្គលអ្នកប្រព្រឹត្តទេ ។ ឯការស្វែងរកដោយប្រាសចាកអាការៈដូចខាងលើនេះ ហើយប្រព្រឹត្តទៅដោយសចក្តីឧស្សាហ៍បញ្ចេញ

កម្លាំងកាយ កម្លាំងគំនិត កម្លាំងទ្រព្យរបស់ខ្លួន រាប់អានកម្មសិទ្ធិរបស់អ្នកដទៃ ចំពោះភោគៈរបស់គេដូច្នេះ ឈ្មោះថាសុបរិយសនា ការស្វែងរកដ៏ប្រពៃ ។ ម្យ៉ាងទៀត ហៅថាឧដ្ឋានសម្បទាដល់ព្រមដោយសេចក្តីឧស្សាហ៍ អ្នកប្រាជ្ញមានព្រះពុទ្ធជាប្រធានសរសើរថាការងារមិនមានទោស ញ៉ាំងប្រយោជន៍ឱ្យសម្រេចដល់បុគ្គលអ្នកប្រព្រឹត្ត ។

## សេចក្តីកម្រ

បុ. សេចក្តីប្រាថ្នារបស់បុគ្គលក្នុងលោក ដែលបានដោយកម្រនោះ មានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. សេចក្តីប្រាថ្នារបស់បុគ្គលក្នុងលោក ដែលបានដោយកម្រនោះមាន ៤ យ៉ាងគឺៈ

១-សូមឱ្យយសកើតមានដល់អាត្មាអញដោយផ្លូវប្រពៃ;

២-សូមឱ្យយសកើតដល់អាត្មាអញ និងញាតិរបស់អាត្មាអញ;

៣-សូមឱ្យអាត្មាអញមានអាយុវែង;

៤-កាលបើអាត្មាអញអស់ជីវិតទៅ សូមឱ្យទៅកើតក្នុងស្ថានសួគ៌ ។

បុ. ចុះសេចក្ដីប្រាថ្នារបស់បុគ្គលក្នុងលោក ដែលបានដោយកម្រ ៤ យ៉ាងនោះ មានសេចក្ដីអធិប្បាយយ៉ាងណា?

វិ. មានសេចក្ដីប្រាថ្នាយ៉ាងនេះថា បុគ្គលក្នុងលោកនេះមានសេចក្ដីប្រាថ្នានូវធម៌ ៤ យ៉ាងនេះដូចគ្នាទាំងអស់ តែសេចក្ដីប្រាថ្នានោះកម្រដែលបុគ្គលបានសមតាមបំណងណាស់ ព្រោះមិនមែនបានដោយការអង្វរសុំទេ បើនឹងបានក៏ដោយសារតែការខំបំពេញកុសលប៉ុណ្ណោះ ត្រូវយល់ថាសត្វទាំងឡាយសុទ្ធតែប្រាថ្នាអាយុ វណ្ណ សុខ យស ដូចៗ គ្នា លុះទម្លាយខន្ធទៅហើយ តែងនឹងបានទៅកើតក្នុងស្ថានសួគ៌ទាំងអស់ ន័យនេះមិនមែនដូច្នោះទេ ។ ធម៌ ៤ ប្រការនោះ បុគ្គលមិនមែនបានដោយគ្រាន់តែប្រាថ្នា និងការសុំមួយយ៉ាងប៉ុណ្ណោះទេ លុះណាតែអរិយសាវ័កបានប្រតិបត្តិនូវផ្លូវជាទីមកនៃអាយុ វណ្ណ សុខ យសផង ទើបសម្រេចដូចបំណង ។ កាលអរិយសាវ័កបានប្រតិបត្តិនូវធម៌ដែលនឹងឱ្យកើតក្នុងស្ថានសួគ៌ដោយល្អហើយ រមែងបានសុគតិភព ជាផលដោយសារតែវត្តប្រតិបត្តិនោះ ។ បដិបទាដែលនឹងឱ្យធម៌ ៤ ប្រការមានអាយុជាដើម ប្រព្រឹត្តទៅដោយល្អនោះ លុះណាតែមានកុសលសុចរិតដែលកើតអំពីអលោភៈ អទោសៈ អមោហៈ

ប្រព្រឹត្តទៅក្នុងកាយវាចាចិត្ត ដែលសម្រេចដោយទាន សីល ភាវនា ទើបឱ្យសម្រេចបាន ។

បុ. ធមិជាហេតុឱ្យបានសម្រេចផល ដូចសេចក្ដីប្រាថ្នានោះ មានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. ធមិជាហេតុឱ្យបានសម្រេចផល ដូចសេចក្ដីប្រាថ្នានោះ មាន ៤យ៉ាងគឺ:

*១-សទ្ធាសម្បទា* ដល់ព្រមដោយសទ្ធា;

*២-សីលសម្បទា* ដល់ព្រមដោយសីល;

*៣-ចាគសម្បទា* ដល់ព្រមដោយការបរិច្ចាគទាន;

*៤-បញ្ញាសម្បទា* ដល់ព្រមដោយបញ្ញា ។

បុ. ធមិទាំង ៤ ប្រការនេះ មានសេចក្ដីអធិប្បាយដូចម្ដេច? ចូរអធិប្បាយមកមើល!

វិ. ធមិទាំង ៤ ប្រការនេះ មានសេចក្ដីអធិប្បាយដូច្នេះថា: សេចក្ដីប្រាថ្នារបស់បុគ្គល ដែលនឹងបានសម្រេចដូចបំណងដោយងាយស្រួល ក៏បានដោយសារតែមានសម្បទា ៤ យ៉ាងនេះ ។ មែនពិត សម្បទា ៤ យ៉ាងនេះ សំដៅយកទាន សីល ភាវនា ដែលជាហេតុឱ្យបានអាយុ វណ្ណ សុខ យស សួគ៌នោះឯង ព្រោះ

ដូច្នោះបានជាលោកថា បុគ្គលណាប្រកបដោយសម្បទាទាំង ៤ យ៉ាង បុគ្គលនោះឈ្មោះថាបរិបូណ៌ដោយទាន សីល ភាវនា បុគ្គលណាបរិបូណ៌ដោយ ទាន សីល ភាវនា បុគ្គលនោះឈ្មោះថា ប្រកបដោយសម្បទា ៤ យ៉ាងនេះឯង ។

## ត្រកូលស្តុកស្តម្ភដែលតាំងយូរមិនបាន

បុ. ត្រកូលស្តុកស្តម្ភដែលតាំងនៅយូរមិនបាន ព្រោះស្ថានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. ត្រកូលស្តុកស្តម្ភដែលតាំងនៅយូរមិនបាន ព្រោះស្ថាន ៤ យ៉ាងគឺៈ

១-មិនស្វែងរករបស់ដែលបាត់ទៅហើយ;

២-មិនជួសជុលរបស់ចាស់ដែលគ្រាំគ្រា;

៣-មិនដឹងប្រមាណក្នុងការចាយវាយប្រើទ្រព្យធន;

៤-តាំងស្ត្រីឬបុរសទ្រុស្តសីលឱ្យជាមេផ្ទះ ។

បុ. អ្នកដែលចង់ឱ្យត្រកូលគង់វង់នៅយូរ តើត្រូវធ្វើដូចម្តេច?

វិ. អ្នកដែលចង់ឱ្យត្រកូលគង់វង់នៅយូរ ត្រូវលះបង់វៀរស្ថានទាំង ៤ យ៉ាងខាងលើនេះចេញ ។

បុ. ស្ថានទាំង ៤ យ៉ាងនេះ មានសេចក្តីអធិប្បាយដូចម្តេច? ចូរអធិប្បាយមកមើល!

វិ. មានសេចក្តីអធិប្បាយថា ស្ថាន ៤ យ៉ាងនេះ ជាមូលហេតុនៃសេចក្តីវិនាសរបស់ត្រកូល ។ ត្រកូលដែលធ្លាប់ស្តុកស្តម្ភចំរើនរុងរឿងអំពីមុន លុះខាងក្រោយមកក៏ត្រឡប់ធ្លាក់ថោកទាបរៀវរោយទៅវិញនោះ ក៏ព្រោះតែប្រកបដោយស្ថាន ៤ ប្រការនេះឯង ។

ពាក្យថា មិនស្វែងរករបស់ដែលបាត់ទៅហើយនោះ បានសេចក្តីថាៈ របស់ឯណានីមួយដែលបាត់ទៅហើយ បើឧស្សាហ៍ព្យាយាមរកក៏គង់បានឃើញមកវិញខ្លះ តែបើមិនឧស្សាហ៍ព្យាយាមរកទេ បណ្តោយឱ្យបាត់បង់ទៅ ឬទិញជាថ្មី ដូច្នេះឈ្មោះថា ការបាត់ទៅមិនល្អ ជាផ្លូវនៃសេចក្តីវិនាសរបស់ត្រកូលស្ថាន ១ ព្រោះរបស់ដែលមាននៅហើយ ក៏ចេះតែវិចរិលទៅសព្វកាល ។

ពាក្យថា មិនជួសជុលរបស់ដែលចាស់គ្រាំគ្រានោះ បានសេចក្តីថា របស់ឯណានីមួយដែលចាស់គ្រាំគ្រា នៅល្មមនឹងជួសជុលអបស្មបប្រើប្រាស់បាន តែមិនយកទៅជួសជុលឡើងវិញ

ត្រឡប់ជាបណ្ដោយឱ្យខូចខាតទៅ ដូចគ្រឿងចក្រមាននាឡិកា ឬចង្កៀងជាដើមខូច ឬទ្រុឌទ្រោមបាក់បែកយ៉ាងណានីមួយ បើចាត់ការជួសជុលឡើងវិញ ក៏គង់ប្រើប្រាស់បានដូចដើមដែរ តែបើមិនចាត់ការធ្វើយ៉ាងនោះទេ បណ្ដោយឱ្យខូចទ្រុឌទ្រោមទៅ ហើយនឹងយកមកប្រើប្រាស់ក៏មិនកើត ក្នុងទីបំផុតត្រូវទិញជាថ្មី ដូច្នេះទុកជាសេចក្ដីវិនាសរបស់ត្រកូលស្ថាន ១ ។

ពាក្យថា មិនដឹងប្រមាណក្នុងការចាយប្រើប្រាស់ទ្រព្យធននោះបានសេចក្ដីថា មិនដឹងប្រមាណក្នុងចាយប្រើ គឺចាយខ្ជះខ្ជាយពេក ចំណាយហួសចំណូល ការមិនគួរចាយប្រើ ក៏ប្រើចាយឥតសណ្ដាប់ធ្នាប់ កាលបើដូច្នេះហើយ ទ្រព្យធនដែលមានហើយ ក៏ចេះតែអស់រលោះទៅជានិច្ច នេះឯងជាផ្លូវនៃសេចក្ដីវិនាសស្ថានមួយ ។

ពាក្យថា តាំងស្ត្រីឬបុរសទ្រុស្តសីលជាមេផ្ទះនោះ បានសេចក្ដីថា ធម្មតាមេផ្ទះឬអ្នកកាន់ការមេផ្ទះជាសំខាន់បំផុត បើមេផ្ទះ ឬអ្នកកាន់ការផ្ទះជាមនុស្សល្អ ក៏ជាសិរីសួស្ដីដល់ត្រកូល ជាផ្លូវនាំមកនូវសេចក្ដីចម្រើនរុងរឿងដល់ត្រកូល ។ បើមេផ្ទះ ឬអ្នកកាន់ការផ្ទះជាមនុស្សទ្រុស្តសីល គឺជាមនុស្សថោកទាបអាក្រក់ ជាអ្នក

លេងល្បែងផ្សេងៗ មានលេងល្បែងភ្នាល់ជាដើម ក៏ជាផ្លូវនាំមកនូវសេចក្តីវិនាសដល់ត្រកូល គឺបំផ្លាញទ្រព្យសម្បត្តិឱ្យវិនាស និងជាចង្រៃដល់ត្រកូលដែលឱ្យកើតអពមង្គល ដូចបញ្ញើក្អែកដុះនៅដើមឈើណា ក៏មានតែធ្វើដើមឈើនោះឱ្យវិនាស ដោយហេតុនេះ បានជាលោកចាត់មេផ្ទះអាក្រក់ ថាជាសេចក្តីវិនាសដល់ត្រកូលស្ថានមួយ ហើយជាការសំខាន់ជាងស្ថានដទៃៗ យ៉ាងក្រៃលែង ។

## ឃរាវាសធម៌

បុ. ឃរាវាសធមិ ប្រែដូចម្តេច?

វិ. ឃរាវាសធមិ ប្រែថា ធមិរបស់បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ ឬធមិរបស់ជនអ្នកមានគ្រួសារ ។

បុ. ឃរាវាសធមិ មានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. ឃរាវាសធមិមាន ៤ យ៉ាងគឺៈ

**១-សច្ច** ពិតត្រង់ដល់គ្នានិងគ្នា;

**២-ទម:** ទូន្មានចិត្ត;

**៣-ខន្តិ** អត់ធន់;

**៤-ចាគៈ** លះវត្ថុរបស់ខ្លួនដល់បុគ្គលដែលគួរឱ្យ ។

បុ. ឃរាវាសធម៌ទាំង ៤ យ៉ាងនេះ មានសេចក្តីអធិប្បាយដូចម្តេច? ចូរអធិប្បាយមកមើល!

វិ. ឃរាវាសធម៌ទាំង ៤ យ៉ាងនេះ មានសេចក្តីអធិប្បាយដូច្នេះថា: ឃរាវាស គឺបុគ្គលអ្នកតាំងខ្លួនដោយការនៅគ្រប់គ្រងផ្ទះ តាមពិតមានមនុស្សជាចំនួនច្រើននៅក្នុងគ្រួសារនោះៗ តែមនុស្សទាំងនោះមិនមានអធ្យាស្រ័យ និងសេចក្តីប្រព្រឹត្តិដូចគ្នាទាំងអស់ទេ តែងមាននិស្ស័យខុសគ្នាជាធម្មតា ។ មនុស្សខ្លះមាននិស្ស័យច្រើនខាងនិយាយកុហកបោកប្រាស ជាមនុស្សមិនមានការស្មោះត្រង់ទៀងទាត់ជាក់លាក់ពិតៗ កាលបើដូច្នេះហើយគ្រួសារនោះមិននៅយូរថ្ងៃប៉ុន្មានទេ មុខជានឹងបែកបាក់គ្នាជាមិនខាន ។ ដោយហោចទៅ សូម្បីតែប្តីប្រពន្ធរបស់ខ្លួនដែលមិនស្មោះត្រង់ដល់គ្នានិងគ្នា ធ្លាប់ស្រឡាញ់គ្នាមកហើយត្រឡប់ជាស្អប់គ្នាទៅវិញ ព្រោះតែមិនស្មោះត្រង់នឹងគ្នាដូច្នេះ ការនៅគ្រប់គ្រងផ្ទះត្រូវអាស្រ័យសច្ចធម៌ដល់គ្នានិងគ្នាជាទីតាំងប្រការមួយ ។ មនុស្សខ្លះជាអ្នកឆាប់ក្រោធខឹងងាយៗ កាលបើជួបនឹងប្រទះហេតុដែលមិនពេញចិត្តរបស់ខ្លួន ក៏កើតសេចក្តីក្រោធខឹងភ្លាមដោយឥតពិចារណា កាលបើដូច្នេះគ្រួសារនោះនឹងទៅជាយ៉ាង

ណា មុខជាតាំងនៅមិនបានចំរើនទេ ហេតុនេះត្រូវអាស្រ័យទមៈ ការទូន្មានចិត្តកុំឱ្យរហ័សក្រោធខឹងប្រការ ១ ។ គ្រួសារដែលតាំងនៅមាំមួន ក៏ព្រោះមានសេចក្ដីអត់ធន់ចំពោះរឿងផ្សេង ១ មិនមានការញាប់ញ័រ កាលបើដូច្នេះ ត្រូវអាស្រ័យខន្តី សេចក្ដីអត់ធន់ប្រការ ១ ។ កាលបើខន្តី អត់ធន់ជួយទប់ទល់មិនឱ្យមានការញាប់ញ័រហើយ បានប្រើបញ្ញាពិចារណាទៅក្នុងរឿងដែលមិនឱ្យកើតសេចក្ដីចង្អៀតចង្អល់ ដើម្បីបន្ទោបង់នូវសេចក្ដីទុក្ខ ។ ការយកចិត្តទុកដាក់ដល់គ្នានិងគ្នាជារបស់សំខាន់ គឺការលះចែកវត្ថុរបស់ខ្លួនឱ្យដល់បុគ្គលដទៃដែលគួរឱ្យ បើឃើញមនុស្សណាគួរនឹងជួយទំនុងបម្រុងដោយប្រការណា ឱ្យរបស់ទ្រព្យបែបណាទើបនឹងបានទទួលសេចក្ដីសុខ ក៏ប្រតិបត្តិធ្វើយ៉ាងនោះ ។ ព្រោះមនុស្សយើងមានចំណែកមិនស្មើគ្នាទេ មនុស្សអ្នកមានត្រូវទំនុកបម្រុងអ្នកទ័លក្រតាមសមគួរ កាលបើដូច្នេះត្រកូលនោះ រមែងបានសេចក្ដីរុងរឿង ។ ស្វាមីនិងភរិយាត្រូវយកចិត្តទុកដាក់សង្គ្រោះដោយការឱ្យរបស់ទ្រព្យ ។ មាតាបិតានិងបុត្តធីតាក៏ត្រូវសង្គ្រោះគ្នាដោយគ្រឿងនេះដែរ ។ ហេតុនេះ គឺជាគុណធម៌សំខាន់ប្រការ ១ ។ បើពោលដោយរួបរួមថា គុណធម៌ទាំង ៤

ប្រការនេះ រមែងធ្វើបុគ្គលអ្នកប្រព្រឹត្តឱ្យល្អក្នុងពួកគណៈ គ្រួសាររបស់ខ្លួនទាំងជាហេតុឱ្យដល់នូវឥដ្ឋគុណវិបុលផល តាមសមគួរដល់សេចក្ដីប្រាថ្នាដោយប្រការដូច្នេះ ។

# បញ្ហាៈពួក ៥

## ការប្រើប្រាស់ទ្រព្យសម្បត្តិដោយស្មាន

បុ. ការប្រើប្រាស់ទ្រព្យសម្បត្តិដោយស្មាននោះ មានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. ការប្រើប្រាស់ទ្រព្យសម្បត្តិដោយស្មាននោះ មាន ៥ យ៉ាង គឺៈ

១-ចិញ្ចឹមខ្លួន និងមាតាបិតា បុត្តភរិយាទាសកម្មករឱ្យជាសុខ;

២-ចិញ្ចឹមមិត្រសម្លាញ់ឱ្យជាសុខ;

៣-បំបាត់អន្តរាយដែលកើតអំពីហេតុផ្សេងៗ;

៤-ធ្វើពលី ៥ យ៉ាង;

៥-បរិច្ចាគទានដល់សមណព្រាហ្មណ៍អ្នកប្រព្រឹត្តល្អ ។

បុ. ធម៌ទាំង ៥ យ៉ាងនេះ មានសេចក្ដីអធិប្បាយដូចម្ដេច? ចូរអធិប្បាយមកមើល!

វិ. ធម៌ទាំង ៥ យ៉ាងនេះ មានសេចក្ដីអធិប្បាយដូចតទៅៈ

ទី ១-អ្នកស្វែងរកទ្រព្យសម្បត្តិបានមកដោយផ្លូវល្អហើយ គួរតែកាន់យកប្រយោជន៏នៃទ្រព្យនោះទុកឱ្យបាន ។ បុគ្គលណាចាយប្រើប្រាស់ទ្រព្យចិញ្ចឹមខ្លួន និងមាតាបិតាជាដើម បុគ្គលនោះឈ្មោះថាកាន់យកនូវប្រយោជន៏នៃទ្រព្យទុកបាន ។ បើប្រើចាយទ្រព្យនោះក្នុងផ្លូវឥតប្រយោជន៏ ដូចជាលេងល្បែងភ្នាល់ និងផ្កាប់ផ្ទុនស្រីជាដើម ឈ្មោះថាមិនកាន់យកនូវប្រយោជន៏នៃទ្រព្យនោះឡើយ ។

ទី ២-ចិញ្ចឹមមិត្តសម្លាញ់ឱ្យជាសុខនោះ គឺបុគ្គលណាល្អតែមាត់ម៉្យាង មានតែវាចាប្រាស្រ័យតែមិនសង្គ្រោះពិត និយាយប្រចុបប្រចែងឡែបឡប ដឹកនាំក្នុងផ្លូវអបាយមុខ បុគ្គលនោះហៅថាមិត្រអាក្រក់ មិនគួរគប់រកទេ ។ បុគ្គលណាជាអ្នកមានឧបការៈដល់ខ្លួន រួមសុខរួមទុក្ខគ្នា បុគ្គលនោះហៅថាមិត្តល្អ គួររាប់រកព្រះមានព្រះភាគទ្រង់សំដែងកិច្ចដែលមិត្តគប្បីធ្វើដល់មិត្រដោយស្ថាន ៥ យ៉ាងគឺៈ ១-ចែកចាយរបស់ខ្លួនដែលគួរសមឱ្យ, ២-ពោលពាក្យពីរោះទៅរក, ៣-ប្រព្រឹត្តប្រយោជន៏ឱ្យ, ៤-ជាអ្នកមានខ្លួនស្មើនឹងមិត្រ, ៥-មិនក្លែងពោលឱ្យឃ្លាតចាកសេចក្តីពិតត្រង់ នេះឯងជាកិច្ចដែលមិត្រគប្បីធ្វើចំពោះមិត្ត ។ ទ្រព្យដែល

បុគ្គលរកបានមក យកមកប្រើចាយធ្វើមិត្តធម៌ដូច្នេះ ចាត់ថាបានកាន់យកប្រយោជន៍ដែលកើតអំពីទ្រព្យប្រការ ១ ។

ទី ៣-បំបាត់អន្តរាយដែលកើតអំពីហេតុផ្សេងៗ នោះ គឺ បំបាត់អន្តរាយដែលកើតអំពីរាជភ័យ ចោរភ័យ អគ្គិភ័យ ឧទក-ភ័យ និងជនអ្នករួមមត៌ក ។ ការដែលព្រមចេញទ្រព្យពិន័យក្នុងវេលាដែលខ្លួនប្រព្រឹត្តខុសនឹងច្បាប់ ហៅថាបំបាត់អន្តរាយដែលកើតអំពីរាជភ័យ ។ ការចាយទ្រព្យដើម្បីការពារចោរ ដូចធ្វើរបងធ្វើផ្ទះឱ្យមាំមួន រកហឹបរកទូរដ៏មាំសម្រាប់ទុកដាក់របស់ទ្រព្យ ហៅថាបំបាត់អន្តរាយដែលកើតអំពីចោរភ័យ ។ ចាយទ្រព្យដើម្បីការពារភ្លើង ដូចជីអណ្តូង ឬរកគ្រឿងសម្រាប់លត់ភ្លើងហៅថាបំបាត់អន្តរាយដែលកើតអំពីអគ្គិភ័យ ។ ការចាយទ្រព្យដើម្បីការពារទឹក ដូចធ្វើទំនប់ទឹក ឬរកគ្រឿងសម្រាប់បាចទឹក ហៅថាបំបាត់អន្តរាយដែលកើតអំពីឧទកភ័យ ។ មួយទៀត បុគ្គលអ្នកមានមេត្តាករុណាចំពោះអ្នកស្រុក ចែកចាយទ្រព្យរបស់ខ្លួន មិនឱ្យបែកសាមគ្គី កើតសត្រូវនឹងគ្នាកាលមានចោរមានភ្លើងឆេះ ឬទឹកលិចក៏បានព្រមព្រៀងគ្នាជួយកំចាត់ចោរ ភ្លើង ឬបាចទឹក បើជាការហួសវិស័យ គេបានជួយជញ្ជូនអីវ៉ាន់ឱ្យផុតចាកអន្តរាយ

ដូច្នេះហៅថាបំបាត់អន្តរាយដែលកើតអំពីចោរភ័យ អគ្គិភ័យ ឧទកភ័យ ។ ការដែលចេះថ្នាក់ថ្នមទាញទឹកចិត្តរបស់ជនអ្នករួមមតិកដោយសង្គហវិធី មិនឱ្យបែកសាមគ្គី គួរបែងចែកឱ្យ ក៏បែងចែកឱ្យ មិនចង់បានតែម្នាកឯង ហៅថាបំបាត់អន្តរាយដែលកើតអំពីជនអ្នករួមមតិក ។ ទ្រព្យសម្បត្តិដែលបុគ្គលរកបានមកហើយ យកមកចាយប្រើក្នុងការបំបាត់អន្តរាយដូច្នេះ ចាត់ថាបានកាន់យកប្រយោជន៍ដែលកើតអំពីទ្រព្យសម្បត្តិប្រការ ១ ។

ទី ៤-មនុស្សដែលរួមខ្សែលោហិតជាមួយគ្នា ខាងមាតាឬបិតា ហៅថា ញាតិ[5] ។ អ្នកដែលជាញាតិគួរតែសង្គ្រោះគ្នាតាមថ្នាក់ញាតិដោយអាមិសខ្លះ ដោយធម៌ខ្លះ តាមសមគួរ ។ អ្នកដែលមានញាតិ តែមិនមានសេចក្តីសាមគ្គីរាបរកគ្នា មិនទៅមករកគ្នា មិនសង្គ្រោះគ្នា តាមថ្នាក់ដែលគួរ លោកពោលថាដូចជាព្រះចន្ទខាងរនោច ។ បើមានសេចក្តីសាមគ្គីមូលមិត្តទៅមករកគ្នា

[5] -ញាតិតាមន័យក្នុងគម្ពីរព្រះពុទ្ធសាសនា លោកឱ្យរាប់ថ្នាក់ខាងលើ ៣ ជាន់ គឺថ្នាក់ខាងមាតាបិតា ១, ថ្នាក់ជីដូនជីតា ១, ថ្នាក់តាទួតយាយទួត ១, ថ្នាក់ខាងក្រោម ៣ ជាន់ទៀតគឺ ថ្នាក់កូន ១, ថ្នាក់ចៅ ១, ថ្នាក់ចៅទួត ១ រួមជា ៦ ជាគំរប់ ៧ នឹងខ្លួនយើង ។ មនុស្សទាំងប៉ុណ្ណេះហៅថាញាតិ ៧ សន្តាន ឬញាតិ ៧ ជួរ ។ តាមន័យក្នុងក្រមរដ្ឋប្បវេណីឱ្យរាប់ដូច្នេះថាៈ អ្នកដែលកើតចេញមកអំពីត្រកូល ឬគោត្រតែមួយ ហៅថា ញាតិៗ នេះ មាន ២ យ៉ាងគឺៈ ញាតិជួរខ្សែផ្ទាល់ម៉្យាង, សាខាញាតិម៉្យាង ។ ញាតិជួរខ្សែផ្ទាល់នោះគឺដែលកើតតគ្នាពី ១ ទៅ ១ តាមលំដាប់ គឺឪពុក កូន ចៅ ចៅទួត ។ល។ រហូតដល់ជាន់ទី ៧ ។ ឯសាខាញាតិនោះ គឺអ្នកដែលកើតចេញអំពីគោត្រជាមួយគ្នាដែរ តែបែកទៅជាមែកដទៃដូចយ៉ាងបងប្អូនបង្កើត, មាមីងនិងក្មួយ, បងប្អូនជីដូនមួយ ជីទួតមួយចុះរៀងមក... ។

សង្គ្រោះគ្នាតាមថ្នាក់ដែលគួរ លោកពោលថា ដូចព្រះចន្ទខាងខ្នើត ការសង្គ្រោះដល់ញាតិយ៉ាងនេះ ហៅថា ញាតិពលី ។ ជនណាដែលមកកាន់សំណាក់ខ្លួន មកសួររក មកលេង ឬអ្នកដែលម្ចាស់ផ្ទះអញ្ជើញហៅរកឱ្យមកដោយការជាមង្គលណាមួយ ឈ្មោះថាភ្ញៀវៗ ម្ចាស់ផ្ទះ ឬម្ចាស់ទីកន្លែងមិនគួរមើលងាយទេ គប្បីទទួលរាកទាក់ប្រាស្រ័យតាមថ្នាក់ដែលគួរយ៉ាងណា ព្រោះការទទួលជាផ្លូវឱ្យកើតសេចក្ដីល្អបាន ហេតុនេះទើបលោកប្រដៅឱ្យគោរពដោយយកចិត្តទុកដាក់ ការទទួលភ្ញៀវយ៉ាងនេះ ហៅថា អតិថិពលី ។ ការឧទ្ទិសផលបុណ្យ បញ្ជូនទៅដល់បុព្វបុរសជាអ្នកមានគុណូបការៈដល់ខ្លួន ដែលលោកក្ស័យជីវិតទៅហើយ ហៅថា បត្តិទានមយៈ ប្រកាមួយ ។ ការធ្វើបុណ្យឧទ្ទិសផលដល់អ្នកចែកឋានទៅហើយយ៉ាងនេះ ហៅថា បុព្វប្បេតពលី ។ រាជរដ្ឋាភិបាលអ្នកចាត់ការ គ្រប់គ្រងប្រជារាស្ត្រ ឱ្យផុតចាកសេចក្ដីបៀតបៀននិងក្ដៅក្រហាយមានប្រការផ្សេងៗ តាមសមគួរដល់ហេតុគួរតែប្រជារាស្ត្រអ្នកនៅក្នុងការរក្សាគ្រប់គ្រងធ្វើពលិកិច្ចឧទ្ទិសថ្វាយដល់ម្ចាស់ផែនដី ដោយនាទីដែលខ្លួនត្រូវតបគុណ នេះក៏ជាកិច្ចដ៏សមគួរប្រការ ១ ។ ការថ្វាយសួយសារអាករដល់ម្ចាស់

ផែនដី មានបង់ពន្ធដារជាដើម យ៉ាងនេះ ហៅថា រាជពលី ។ ទេវតាអ្នកដល់ព្រមដោយកុសលសម្បត្តិ កើតក្នុងសាកលលោក-ធាតុ ដែលគ្រប់គ្រងរក្សាទីកន្លែងនៃបុគ្គលផ្សេងៗ ឱ្យនៅជាសុខ ឱ្យប្រាសចាកភ័យអន្តរាយតាមសមគួរដល់ហេតុការណ៍ ។ ហេតុនេះ គួរតែអ្នកជាម្ចាស់ទីកន្លែង ត្រូវធ្វើបុណ្យឧទ្ទិសឱ្យតាមគតិ-និយម ។ កាលណាធ្វើបុណ្យឧទ្ទិសផលដល់ទេវតាយ៉ាងនេះ ហៅថា ទេវតាពលី ។

ទី ៥-សមណព្រាហ្មណ៍អ្នកប្រព្រឹត្តល្អដោយសីលាចារវត្ត ជាអ្នកបំពេញកិច្ចខាងផ្លូវព្រះពុទ្ធសាសនា ឬជាអ្នកបំពេញសាធារ-ណប្រយោជន៍ដល់មហាជនទូទៅ គួរណាស់តែជនអ្នកមានសទ្ធាបរិច្ចាគទាន ចំពោះលោក ព្រោះលោកជាអ្នកគួរដល់ទានសម្បត្តិប្រការ ១ ។

# សីល

បុ. សីល ក្នុងទីនេះសំដៅយកសីលប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. សីល ក្នុងទីនេះសំដៅយកសីល ៥ យ៉ាងគឺ:

**១-បាណាតិបាតា វេរមណី** វៀរចាកធ្វើជីវិតសត្វឱ្យធ្លាក់ចុះកន្លង;

**២-អទិន្នាទានា វេរមណី** វៀរចាកកិរិយាកាន់យកនូវទ្រព្យដែលម្ចាស់គេមិនបានឱ្យ;

**៣-កាមេសុមិច្ឆាចារា វេរមណី** វៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ;

**៤-មុសាវាទា វេរមណី** វៀរចាកកិរិយាពោលពាក្យកុហក;

**៥-សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី** វៀរចាកកិរិយាផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាហេតុជាទីតាំងនៃសេចក្ដីប្រមាទ ។

បុ. សីលទាំង ៥ នេះ ជាសីលរបស់បុគ្គលណា ពួកណា?

វិ. សីលទាំង ៥ នេះ ជាសីលរបស់គ្រហស្ថអ្នកគ្រប់គ្រងផ្ទះ ។

បុ. ចុះ សីល ស័ព្ទ ១ ម៉ាត់នេះ ប្រែបានប៉ុន្មានយ៉ាង? ប្រែថាដូចម្ដេចខ្លះ?

វិ. សីល ស័ព្ទ ១ ម៉ាត់នេះ ប្រែបាន ៧ យ៉ាងគឺៈ

១-គុណជាតជាហេតុចងនូវចិត្តនៃជន;

២-គុណជាតទ្រទ្រង់មាំនូវបុគ្គល ដែលប្រកបនឹងសភាវធម៌នោះ ដោយអំណាចនៃកិរិយាការពារការកើតក្នុងអបាយទាំងឡាយ;

៣-គុណជាតដែលពួកសប្បុរសទ្រទ្រង់មាំ គឺថានាំចូលទៅកាន់ចន្លោះនៃសាច់ គឺបេះដូងហើយទ្រទ្រង់;

៤-គុណជាតនឹងនួន ឬជានឹងធឹង គឺថាមិនរាត់រាយដោយអំណាចនៃភាពរបស់កម្ម មានកាយកម្មជាដើម មានទម្លាប់យ៉ាងល្អ;

៥-គុណជាតជាគ្រឿងសម្រិតសម្រាំង គឺថាតាំងទុកដោយល្អដូចចិត្ត;

៦-គុណជាតទ្រទ្រង់មាំនូវកុសលធម៌;

៧-គុណជាតទ្រទ្រង់មាំនូវពួកកុសលធម៌នៃជន ។

បុ. ចុះសីលទាំង ៥ នេះ បើមិនហៅថាសីលទេ នឹងហៅថានិច្ចសីល ដូច្នេះវិញ បានឬទេ?

វិ. សីលទាំង ៥ នេះ បើមិនហៅថាសីល ៥ ទេ នឹងហៅថានិច្ចសីលដូច្នេះវិញក៏បាន ព្រោះជាសីលដែលបុគ្គលត្រូវរក្សាជានិច្ចគ្មានប្រកាន់ពេលវេលា ពេលណាក៏ត្រូវតែរក្សា ឥតមានកំណត់ពេល ។

បុ. សីលទាំង ៥ នេះ លុះតែរក្សាគ្រប់ទាំង ៥ ទើបហៅថានិច្ចសីលឬ? ឬក៏រក្សាតែមួយៗ ហៅថានិច្ចសីលបានដែរ?

វិ. សីលទាំង ៥ នេះ លុះតែរក្សាគ្រប់ទាំង ៥ ទើបបាន បើរក្សាតែមួយៗ មិនគ្រប់ទាំង ៥ ហៅថានិច្ចសីលមិនបានទេ ។

បុ. សីលទាំង ៥ នេះ មានសេចក្តីអធិប្បាយយ៉ាងណា? ចូរអធិប្បាយមកមើល!

វិ. សីលទាំង ៥ នេះ មានសេចក្តីអធិប្បាយដូចតទៅ ៖

សីល ៥ នេះ បើពិចារណាឱ្យល្អិតសព្វគ្រប់ទៅ ឃើញថាលោកហាមឃាត់មិនឱ្យមានការបៀតបៀនគ្នានិងគ្នាប៉ុណ្ណោះឯង ព្រោះការធ្វើអាក្រក់ដល់គ្នានិងគ្នាក្តី ការបំផ្លាញកម្មសិទ្ធិរបស់គ្នានិងគ្នាក្តី ការបង្ខំចិត្តគ្នាក្តី មិនស្មោះត្រង់ដល់គ្នាក្តី នេះឯងសុទ្ធតែជាការបៀតបៀនគ្នានិងគ្នាទាំងអស់ ។ កាលបើមនុស្សយើងនៅមានការបៀតបៀនគ្នានិងគ្នាដរាបណា សេចក្តីសុខដែលជារបស់គួរប្រាថ្នាណាស់ ក៏គង់មិនមានដរាបនោះ ដោយហេតុនេះឯងអ្នកប្រាជ្ញក្នុងពុទ្ធសាសនា ទើបប្រដៅមហាជនឱ្យតាំងនៅក្នុងសីល ៥ នេះ ។

## កល្យាណធម៌

បុ. កល្យាណធម៌ ប្រែដូចម្តេច?

វិ. កល្យាណធម៌ ប្រែថា ធម៌ដ៏ល្អ ។

បុ. កល្យាណធមិនេះ មានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. កល្យាណធមិនេះ មាន ៥ យ៉ាងគឺៈ

**១-មេត្តា** គិតចង់ឱ្យគេបានសុខ និងករុណាចង់ឱ្យគេប្រាស-ចាកទុក្ខ;

**២-សម្មាអាជីវៈ** ចិញ្ចឹមជីវិតប្រពៃ;

**៣-សទារសន្តោសៈ** សន្តោសគឺត្រេកអរចំពោះភរិយារបស់ខ្លួន;

**៤-សច្ចៈ** ប្រព្រឹត្តខ្លួនជាមនុស្សស្មោះត្រង់;

**៥-សតិ** មានស្មារតីបរិបូណ៌ ។

បុ. កល្យាណធមិទាំង ៥ យ៉ាងនេះ មានសេចក្តីអធិប្បាយយ៉ាងណា?

វិ. អធិប្បាយថាៈ កល្យាណធមិ ៥ យ៉ាងនេះជាគូគ្នានឹងសីល ៥ គឺៈ ១-មេត្តា ជាគូគ្នានឹងបាណាតិបាត, ២-សម្មាអាជីវៈ ជាគូគ្នានឹងអទិន្នាទាន, ៣-សទារសន្តោសៈ ជាគូគ្នានឹងកាមេសុមិច្ឆា-ចារៈ, ៤-សច្ចៈ ជាគូគ្នានឹងមុសាវាទ, ៥-សតិជាគូគ្នានឹងសុរា-មេរយៈ ។ កល្យាណធមិទាំង ៥ យ៉ាងនេះ បុគ្គលត្រូវបំពេញឱ្យបរិបូណ៌ដើម្បីធ្វើសីល ៥ ឱ្យបរិសុទ្ធ ។

# មិច្ឆាវាណិជ្ជា

បុ. មិច្ឆាវាណិជ្ជា ប្រែដូចម្ដេច?

វិ. មិច្ឆាវាណិជ្ជា ប្រែថា ជំនួញខុសគន្លងធម៌ ឬការលក់ដូរខុសចាកធម៌ ។

បុ. ជំនួញខុសចាកធម៌នេះ មានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. ជំនួញខុសចាកធម៌នោះ មាន ៥ យ៉ាងគឺៈ

**១-សត្ថវាណិជ្ជា** លក់គ្រឿងសស្ត្រាវុធសម្រាប់ប្រហារជីវិត;

**២-សត្តវាណិជ្ជា** លក់មនុស្សមានជាតិស្មើគ្នាឱ្យដាច់ថ្លៃ;

**៣-មំសវាណិជ្ជា** លក់សត្វដែលគេចិញ្ចឹមយកសាច់ជាអាហារ;

**៤-មជ្ជវាណិជ្ជា** លក់គ្រឿងស្រវឹង;

**៥-វិសវាណិជ្ជា** លក់ថ្នាំពិស សម្រាប់បំពុលសត្វ ។

បុ. ជំនួញ ៥ ប្រការនេះ មានសេចក្ដីអធិប្បាយដូចម្ដេច?

វិ. អធិប្បាយថាៈ ជំនួញ ៥ ប្រការនេះ ឧបាសកឧបាសិកាត្រូវវៀរឱ្យស្រឡះ ព្រោះកិច្ចជំនួញនោះៗ សុទ្ធតែជាគ្រឿងបណ្ដាលឱ្យកើតបាណាតិបាតខ្លះ ឱ្យកើតសេចក្ដីទាបថោកខ្លះ បើឧបាសកឧបាសិកាធ្វើជំនួញនេះហើយ ជាការមុខគួរឱ្យគេស្អប់ខ្ពើមណាស់ ។ គ្រឿងសស្ត្រាវុធនោះសំដៅយកគ្រឿងប្រហារគ្រប់

បែប ដែលជារបស់ធ្វើរាងកាយរបស់មនុស្សនិងសត្វតិរច្ឆាន ឱ្យវិនាសអន្តរាយ, កាំភ្លើង, លំពែង, ដាវ, ចម្រូង, សំណាញ់, អួន, លបជាដើម ។ លក់សត្វ គឺសម្លាប់យកមនុស្សលក់ ឯសាច់សំដៅយកសាច់សត្វតិរច្ឆានរស់ដែលមានសាច់ជាភក្សាហារ ដែលខ្លួនសម្លាប់គ្រប់បែបនោះ ។ ទឹកស្រវឹង សំដៅយកទឹកស្រវឹងគ្រប់បែប ដែលធ្វើអ្នកផឹកឱ្យស្រវឹងប្រមាទ ។ ថ្នាំពិសសំដៅយកថ្នាំពិសគ្រប់បែប ដែលធ្វើអ្នកបរិភោគឱ្យវិនាសជីវិត និងរាងកាយបាន ។

## សម្បត្តិរបស់ឧបាសក

បុ. ដូចម្ដេចហៅថាសម្បត្តិរបស់ឧបាសក?

វិ. សីលសម្បទា ច អាជីវសម្បទា ច កិរិយាបរិបូណ៌ដោយសីលផងបរិបូណ៌ដោយការចិញ្ចឹមជីវិតផង ហៅថា សម្បត្តិរបស់ឧបាសក ។

បុ. សម្បត្តិរបស់ឧបាសកនោះ មានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. សម្បត្តិរបស់ឧបាសកនោះ មាន ៥ យ៉ាង គឺ៖

**១-សទ្ធា** ជាអ្នកជឿគុណព្រះរតនត្រ័យជាដើម;

**២-សីលវា** ជាអ្នកមានសីលបរិសុទ្ធផូរផង់;

**៣-ន គោត្ុហលមង្គលិកោ** ជាអ្នកមិនជឿមង្គលភ្ញាក់ផ្អើល;

**៤-កម្មំ បច្ចេតិ នោ មង្គលំ** ជាអ្នកជឿកម្មផល មិនជឿមង្គលភ្ញាក់ផ្អើល មានការបន់ស្រន់ជាដើម ។

**៥-ន ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសេតិ ឥធេវ បុព្វការំ ករោតិ** ជាអ្នកមិនស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅពុទ្ធសាសនា ប្រព្រឹត្តធ្វើឧបការៈតែក្នុងព្រះពុទ្ធសាសនានេះ ។

បុ. ចុះសម្បត្តិទាំង ៥ យ៉ាងនេះ មានសេចក្តីអធិប្បាយយ៉ាងណា? ចូរអធិប្បាយមកមើល!

វិ. សម្បត្តិទាំង ៥ យ៉ាងនេះ មានសេចក្តីអធិប្បាយថាៈ ពាក្យថា ជាអ្នកប្រកបដោយសទ្ធានោះ គឺជឿវត្ថុដែលគួរជឿ ដូចជឿថាធ្វើល្អបានល្អ, ធ្វើអាក្រក់បានអាក្រក់ ឬជឿថាសត្វមានកម្មជារបស់ខ្លួន, មានកម្មជាកំណើត, មានកម្មជាផៅពង្ស, មានកម្មជាទីពឹងពាក់អាស្រ័យ, ធ្វើល្អនឹងបានល្អ ធ្វើអាក្រក់នឹងបានអាក្រក់នឹងត្រូវទទួលផលរបស់កម្មនោះៗ ជាអ្នកមិនជឿដំណឹងដែលមិនពិត ឬដំណឹងក្លែងក្លាយ ដោយមិនបានពិចារណារកហេតុផលជាមុន ។

ពាក្យថា ជាអ្នកមានសីលបរិសុទ្ធផូរផង់នោះ គឺជាអ្នកមានកាយវាចាមានមារយាទរៀបរយស្ងប់ស្ងៀម ជាអ្នកមានសីលមិនដាច់ពពាលពព្រុស គឺនៅគ្រប់បរិបូណ៌ តាមដែលខ្លួនបានសមាទានមកមិនខ្វះកន្លះឡើយ ។

ពាក្យថា មិនជឿមង្គលភ្ញាក់ផ្អើលនោះ សំដៅសេចក្តីថា មិនជឿឫក្សយាម មិនជឿគ្រោះល្អ គ្រោះអាក្រក់ ដូចជឿថាព្រះនោះព្រះនេះសោយអាយុ នឹងបានទទួលជោគល្អ ឬជោគអាក្រក់ដូច្នោះជាដើម មិនត្រូវជឿដូច្នោះទេ ត្រូវជឿកម្ម គឺសេចក្តីប្រព្រឹត្តដែលខ្លួនធ្វើជាគោលកំណត់ គឺបុគ្គលណាប្រព្រឹត្តហេតុល្អក៏បានទទួលផលល្អ បុគ្គលណាប្រព្រឹត្តហេតុអាក្រក់ ក៏បានផលអាក្រក់ សេចក្តីល្អ សេចក្តីអាក្រក់ដែលបានប្រព្រឹត្តហើយនោះជាហេតុហើយ នឹងតាមឱ្យផលវិញមិនមែនគ្រោះល្អ ឬគ្រោះអាក្រក់ឱ្យផលឡើយ លោកឱ្យជឿតាមពុទ្ធភាសិតនេះថាៈ កល្យាណការី កល្យាណំ ធ្វើហេតុល្អ រមែងបានល្អ; បាបការី ច បាបកំ ធ្វើហេតុអាក្រក់រមែងបានផលអាក្រក់ ដូច្នេះ ។

ពាក្យថា ជាអ្នកជឿកម្មផល មិនជឿមង្គលភ្ញាក់ផ្អើល មានការបន់ស្រន់ជាដើមនោះ សំដៅសេចក្តីថា បុណ្យឯណាៗ ដែល

សាសនាដទៃ គេនាំគ្នានិយមថាជាផ្លូវធ្វើបុណ្យរបស់គេ ដូចគ្រិស្ត-សាសនា ឬឥស្លាមសាសនាជាដើម យើងមិនត្រូវនិយមតាមគេដូច្នោះឡើយ គឺមិនត្រូវធ្វើតាមលទ្ធិរបស់សាសនាដទៃៗ ។

ពាក្យថា ជាអ្នកមិនស្វែងរកទក្ខិណេយ្យបុគ្គលដទៃ ប្រព្រឹត្តធ្វើតែកុសលក្នុងព្រះពុទ្ធសាសនានោះ សំដៅសេចក្ដីថា បុញ្ញកិរិយា-វត្ថុឯណា ដែលច្បាប់ក្នុងព្រះពុទ្ធសាសនានិយមហើយ ក៏បំពេញបុញ្ញកិរិយាវត្ថុនោះៗ ដូចឱ្យទានរក្សាសីលចំរើនភាវនាជាដើម ។

# ឆក្កៈពួក ៦

## ទិស ៦

បុ. ទិសទាំង ៦ នោះ គឺអ្វីខ្លះ? ចូររាប់!

វិ. ទិសទាំង ៦ នោះ គឺ៖

**១- បុរត្ថិមទិស** ទិសបូព៌ ទុកជាមាតាបិតា;

**២-ទក្ខិណទិស** ទិសទក្សិណ ទុកជាគ្រូអាចារ្យ;

**៣-បច្ឆិមទិស** ទិសបស្ចិម ទុកជាភរិយា;

**៤-ឧត្តរទិស** ទិសឧត្តរ ទុកជាមិត្រ;

**៥-ហេដ្ឋិមទិស** ទិសខាងក្រោម ទុកជាទាសកម្មករ;

**៦-ឧបរិមទិស** ទិសខាងលើ ទុកជាសមណព្រាហ្មណ៍ ។

បុ. ទិសទាំង ៦ នេះ មានសេចក្តីអធិប្បាយដូចម្តេចខ្លះ?

វិ. ទិសទាំង ៦ នេះ មានសេចក្តីអធិប្បាយដូច្នេះថា: ព្រោះហេតុបានជាលោកប្រៀបមាតាបិតាជាដើមទៅនឹងទិសផ្សេងៗ ជាបញ្ហាដែលគួរដឹងដូចតទៅនេះ ៖

មាតាបិតា ដែលលោកប្រៀបនឹងទិសបូព៌ (ទិសខាងកើត) នោះ ដោយអត្ថថា មានគុណូបការៈ ដល់បុត្តធីតាច្រើនជាងមនុស្សដទៃ និងមុខបំផុតជាងគេ ។

គ្រូអាចារ្យដែលលោកប្រៀបនឹងទិសទក្សិណ (ទិសខាងត្បូង) នោះ ដោយអត្ថថា ដូចដៃស្តាំដែលនឹងធ្វើឱ្យសម្រេចប្រយោជន៍នោះៗ ។

ភរិយាដែលលោកប្រៀបនឹងទិសបស្ចិម (ទិសខាងលិច) នោះ ដោយអត្ថថា ជាស្ត្រីដើរ ឬធ្វើតាមក្រោយស្វាមី ។

មិត្តដែលលោកប្រៀបនឹងទិសឧត្តរ (ទិសខាងជើង) នោះ ដោយអត្ថថា ដូចដៃឆ្វេងដែលសម្រាប់ជួយដៃស្តាំឱ្យសម្រេចប្រយោជន៍នោះៗ បាន ។

ទាសកម្មករដែលលោកប្រៀបនឹងទិសខាងក្រោម ដោយអត្ថ ថា ជាអ្នកទាបថោកជាងចៅហ្វាយនាយ ឬនៅក្រោមបង្គាប់ចៅហ្វាយនាយ ។

សមណព្រាហ្មណ៍ ដែលលោកប្រៀបនឹងទិសខាងលើ ដោយអត្ថថា ជាអ្នកមានគុណខ្ពស់ជាងគ្រហស្ថ ។

បុ. បរត្ថិមទិស មាតាបិតាទុកជាទិសខាងកើត បុត្តធីតាត្រូវទំនុងបម្រុងដោយស្ថានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. បុរត្ថិមទិស មាតាបិតាទុកជាទិសខាងកើត បុត្រធីតាត្រូវទំនុកបម្រុងលោកដោយស្ថាន ៥ យ៉ាង គឺ៖

**១-ភតោ នេសំ ភរិស្សាមិ** លោកបានចិញ្ចឹមខ្លួនមកហើយត្រូវចិញ្ចឹមលោកវិញ;

**២-កិច្ចំ នេសំ ករិស្សាមិ** ធ្វើកិច្ចការរបស់លោក;

**៣-កុលវំសំ ឋបេស្សាមិ** ទំនុងបម្រុងវង្សត្រកូលមិនឱ្យសាបសូន្យ;

**៤-ទាយជ្ជំ បដិបជ្ជាមិ** ប្រតិបត្តិឱ្យសមគួរជាអ្នកទទួល;

**៥-ទក្ខិណំ អនុប្បទស្សាមិ** កាលបើលោកធ្វើកាលកិរិយាទៅហើយ ត្រូវធ្វើបុណ្យឧទ្ទិសផលជូនទៅលោក ។

បុ. មាតាបិតា ត្រូវសង្គ្រោះបុត្តធីតាដោយស្ថានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. មាតាបិតាត្រូវសង្គ្រោះបុត្រធីតាដោយស្ថាន ៥ យ៉ាងគឺ៖

**១-បាបា និវារេន្តិ** ហាមឃាត់មិនឱ្យធ្វើសេចក្តីអាក្រក់;

**២-កល្យាណេ និវេសេន្តិ** ឱ្យតាំងនៅក្នុងសេចក្តីល្អ;

**៣-សិប្បំ សិក្ខាបេន្តិ** ឱ្យសិក្សាសិល្បវិជ្ជា;

**៤-បដិរូបេន ទារេន សំយោជេន្តិ** រៀបចំកូនឱ្យមានផ្ទះសម្បែង;

**៥-សមយេ ទាយជ្ជំ និយ្យាទេន្តិ** ប្រគល់ទ្រព្យមតិកឱ្យក្នុងសម័យដ៏គួរ ។

បុ. ទក្ខិណទិស គ្រូអាចារ្យទុកជាទិសខាងត្បូង សិស្សានុសិស្សត្រូវប្រតិបត្តិដោយស្ថាន ៥ យ៉ាងគឺ:

**១-ឧដ្ឋានេន** ក្រោកទទួលក្នុងវេលាដែលគ្រូអាចារ្យដើរមក;

**២-ឧបដ្ឋានេន** ចូលទៅចាំបម្រើលោក;

**៣-សុស្សូសាយ** ជឿស្តាប់ឱវាទលោក;

**៤-បារិចរិយាយ** ឧបដ្ឋាកបម្រើលោក;

**៥-សក្កច្ចំ សិប្បំ បដិគ្គហណេន** រៀនសិល្បវិជ្ជាដោយគោរព។

បុ. គ្រូអាចារ្យ ត្រូវអនុគ្រោះសិស្ស ដោយស្ថានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. គ្រូអាចារ្យត្រូវអនុគ្រោះសិស្សដោយស្ថាន ៥ យ៉ាងគឺ ៖

**១-សុវិនីតំ វិនេន្តិ** ណែនាំឱ្យល្អ;

**២-សុគហិតំ គាហាបេន្តិ** ឱ្យរៀនល្អ;

**៣-សព្វសិប្បស្សុតំ សមក្ខាយិនោ ភវន្តិ** ប្រាប់សិល្បវិជ្ជាឱ្យអស់ចំណេះមិនលាក់ទុក;

**៤-មិត្តាមច្ចេសុ បដិវេទេន្តិ** លើកដំកើងក្នុងទីចំពោះមុខមិត្តអមាត្យទាំងឡាយ;

**៥-ទិសាសុ បរិត្តាណំ ករោន្តិ** ធ្វើសេចក្ដីការពារក្នុងទិសទាំង-ឡាយ ។

បុ. បច្ឆិមទិស ភរិយាទុកជាទិសខាងលិច ស្វាមីត្រូវទំនុកបំរុងដោយស្ថានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. បច្ឆិមទិស ភរិយាទុកជាទិសខាងលិច ស្វាមីត្រូវទំនុកបំរុងដោយស្ថាន ៥ យ៉ាងគឺ ៖

**១-សម្មាននាយ** រាប់អានលើកមុខថាជាភរិយា;

**២-អវិមាននាយ** មិនមើលងាយ;

**៣-អនតិចរិយាយ** មិនប្រព្រឹត្តកន្លងចិត្ត គឺមិនក្បត់ចិត្តភរិយា;

**៤-ឥស្សរិយវោស្សគ្គេន** ប្រគល់ភារៈជាធំក្នុងផ្ទះឱ្យ;

**៥-អលង្ការានុប្បទានេន** ឱ្យគ្រឿងតែងខ្លួន ។

បុ. ភរិយាត្រូវប្រតិបត្តិស្វាមីដោយស្ថានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. ភរិយាត្រូវប្រតិបត្តិស្វាមីដោយស្ថាន ៥ យ៉ាងគឺៈ

**១-សុសំវិហិតកម្មន្តា** ចាត់ចែងការងារដោយល្អ;

**២-សុសង្គហិតបរិជនា** សង្គ្រោះញាតិខាងស្វាមីដោយល្អ;

**៣-អនតិចារិនី** មិនប្រព្រឹត្តកន្លងចិត្តស្វាមី គឺមិនក្បត់ចិត្តប្តី;

**៤-សម្ភតញ្ច អនុរក្ខតិ** រក្សាទ្រព្យដែលស្វាមីរកបានមក;

**៥-ទក្ខា ច ហោតិ អនលសា សព្វកិច្ចេសុ** ឧស្សាហ៍មិនខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង ។

បុ. ឧត្តរទិស មិត្រទុកជាទិសខាងជើង កុលបុត្រដែលមានសេចក្តីស្រឡាញ់ ត្រូវទំនុងបម្រុងដោយស្ថានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. ឧត្តរទិស មិត្តទុកជាទិសខាងជើង កុលបុត្រដែលមានសេចក្តីស្រឡាញ់ត្រូវទំនុងបម្រុងដោយស្ថាន ៥ យ៉ាង គឺៈ

**១-ទានេន** ចែកចាយរបស់ដែលសមគួរឱ្យ;

**២-បិយវាចេន** ពោលពាក្យពិរោះ;

**៣-អត្ថចរិយាយ** ប្រព្រឹត្តប្រយោជន៍ឱ្យ;

**៤-សមានត្តតាយ** ជាអ្នកមានខ្លួនស្មើនឹងមិត្រ;

**៥-អវិសំវាទនតាយ** មិនក្លែងពោលឱ្យឃ្លាតចាកសេចក្ដីពិតត្រង់ ។

បុ. មិត្តត្រូវទំនុងបម្រុងកុលបុត្រវិញដោយស្ថានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. មិត្រត្រូវទំនុកបម្រុងកុលបុត្រវិញដោយស្ថាន ៥ យ៉ាងគឺះ

**១-បមត្តំ រក្ខន្តិ** រក្សាមិត្តអ្នកប្រហែសធ្វេស;

**២-បមត្តស្ស សាបតេយ្យំ រក្ខន្តិ** រក្សាទ្រព្យសម្បត្តិរបស់មិត្រមិនប្រហែសធ្វេស;

**៣-ភីតស្ស សរណំ ហោន្តិ** កាលបើមិត្តមានភ័យហើយយក ជាទីពឹងពុំនាក់បានះ

**៤-អាបទាសុ ន វិជហន្តិ** មិនលះចោលមិត្តក្នុងវេលាមានទុក្ខមកបៀតបៀន;

**៥-អបរបជំបិសស្ស បជិបូជេន្តិ** រាប់អានមិត្ររហូតដល់វង្សត្រកូលរបស់មិត្ត ។

បុ. ហេដ្ឋិមទិស ទាសកម្មករទុកជាទិសខាងក្រោម ចៅហ្វាយនាយត្រូវទំនុងបម្រុងដោយស្ថានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. ហេដ្ឋិមទិស ទាសកម្មករទុកជាទិសខាងក្រោម ចៅហ្វាយនាយត្រូវទំនុកបម្រុងដោយស្ថាន ៥ យ៉ាង គឺៈ

**១-យថាពលំ កម្មន្តំ សំវិធានេន** ចាត់ចែងការឱ្យធ្វើតាមសមគួរដល់កម្លាំង;

**២-ភត្តវេត្តនានុប្បទានេន** ឱ្យភោជនាហារនិងរង្វាន់;

**៣-គិលានុប្បដ្ឋានេន** ព្យាបាលក្នុងពេលវេលាមានជម្ងឺ;

**៤-អច្ឆរិយានំ រសានំ សំវិភាគេន** ចែកភោជនាហារដែលមានឱជារសប្លែកៗ ឱ្យបរិភោគ;

**៥-សមយេ វោសជ្ជនេន** បើកឱ្យសប្បាយក្នុងកាលគួរ ។

បុ. ទាសកម្មករ ត្រូវប្រតិបត្តិចៅហ្វាយនាយ ដោយស្ថានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. ទាសកម្មករត្រូវប្រតិបត្តិចៅហ្វាយនាយដោយស្ថាន ៥ យ៉ាងគឺៈ

**១-បុព្វុដ្ឋាយិនោ ច ហោន្តិ** ក្រោកធ្វើការមុនចៅហ្វាយនាយ;

**២-មច្ឆា និបាតិនោ** លែងធ្វើការងារខាងក្រោយចៅហ្វាយនាយ;

**៣-ទិន្នាទាយិនោ** កាន់យកតែរបស់ដែលចៅហ្វាយនាយឱ្យ;

**៤-សុកតកម្មការកោ** ធ្វើការងារដោយយកចិត្តទុកដាក់;

**៥-កិត្តិវណ្ណហរោ** នាំកិត្តិគុណរបស់ចៅហ្វាយនាយទៅពោលសរសើរក្នុងទីដទៃៗ ។

បុ. ឧបរិមទិស សមណព្រាហ្មណ៍ទុកជាទិសខាងលើ គ្រហស្ថត្រូវទំនុងបម្រុងដោយស្ថានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. ឧបរិមទិស សមណព្រាហ្មណ៍ទុកជាទិសខាងលើ គ្រហស្ថត្រូវទំនុងបម្រុងដោយស្ថាន ៥ យ៉ាងគឺ:

**១-មេត្តាកាយកម្ម** ធ្វើអ្វីៗ ប្រកបដោយមេត្តា;

**២-មេត្តាវចីកម្ម** និយាយអ្វីៗ ប្រកបដោយមេត្តា;

**៣-មេត្តាមនោកម្ម** គិតអ្វីៗ ប្រកបដោយមេត្តា;

**៤-អនាវដទ្វារតាយ** ជាអ្នកមិនបិទទ្វារ គឺពុំបានហាមមិនឱ្យចូលផ្ទះ;

**៥-អាមិសានុប្បទានេន** ផ្តល់អាមិសទានឱ្យ ។

បុ. សមណព្រាហ្មណ៍ ត្រូវអនុគ្រោះគ្រហស្ថដោយស្ថានប៉ុន្មានយ៉ាងវិញ? គឺអ្វីខ្លះ?

វិ. សមណព្រាហ្មណ៍ ត្រូវអនុគ្រោះគ្រហស្ថដោយស្ថាន ៦ យ៉ាង គឺ៖

**១-បាបា និវារេន្តិ** ដឹកនាំមិនឱ្យធ្វើអំពើអាក្រក់;

**២-កល្យាណេ និវេសេន្តិ** ដឹកនាំឱ្យតាំងនៅក្នុងអំពើល្អ;

**៣-កល្យាណេន មនសា អនុកម្បន្តិ** អនុគ្រោះដោយទឹកចិត្តដ៏ស្អាតល្អ;

**៤-អស្សុតំ សាវេន្តិ** ឱ្យបានស្តាប់ធម៌ដែលមិនធ្លាប់បានស្តាប់;

**៥-សុតំ បរិយោទបេន្តិ** ពន្យល់ធម៌ដែលមិនធ្លាប់ស្តាប់ដោយឱ្យរឹងរឹតតែច្បាស់ឡើង;

**៦-សគ្គស្ស មគ្គំ អាចិក្ខន្តិ** ប្រាប់ផ្លូវឋានសួគ៌ឱ្យគេបានដឹង ។

## អបាយមុខ

បុ. អបាយមុខ ប្រែដូចម្តេច?

វិ. អបាយមុខ ប្រែថា ហេតុដែលធ្វើឱ្យវិនាស ឬជាប្រធាននៃសេចក្តីវិនាស ។

បុ. អបាយមុខនោះ មានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

វិ. អបាយមុខនោះ មាន ៦ យ៉ាង គឺៈ

**១-មជ្ជបានៈ** ផឹកទឹកស្រវឹង;

**២-វិកាលចរណៈ** ដើរលេងយប់ គឺដើរខុសកាល;

**៣-សមជ្ជាភិចរណៈ** ដើរមើលល្បែងមហោស្រព;

**៤-ជូតានុយោគៈ** លេងល្បែងភ្នាល់ ឬល្បែងស៊ីសង;

**៥-បាបមិត្តានុយោគៈ** សេពគប់មនុស្សអាក្រក់ជាមិត្ត;

**៦-អាលស្សានុយោគៈ** ខ្ជិលធ្វើការងារ ។

បុ. អបាយមុខទាំង ៦ នេះ មានសេចក្តីអធិប្បាយដូចម្តេច?

វិ. អបាយមុខទាំង ៦ នេះ មានសេចក្តីអធិប្បាយដូចតទៅៈ

**១-មជ្ជបានៈ** ការផឹកទឹកស្រវឹងមានទោស ៦ យ៉ាងគឺៈ នាំឱ្យខូចទ្រព្យសម្បត្តិ ១, បង្កបង្កើតសេចក្តីឈ្លោះទាស់ទែងគ្នា ១, ជាអណ្តូងកើតនៃរោគ ១, ញ៉ាំងសេចក្តីនិន្ទាឱ្យកើត ១, ញ៉ាំងកេរ្តិ៍ខ្មាស់ឱ្យប្រាជកមិនអៀនអន់ ១, ធ្វើបញ្ញាឱ្យទន់ថយ ១ ។

**២-វិកាលចរណៈ** ដើរលេងយប់មានទោស ៦ យ៉ាងគឺៈ មិនរក្សាខ្លួន ១, មិនរក្សាកូនប្រពន្ធ ១, មិនរក្សាទ្រព្យសម្បត្តិ ១, ជាទីរង្កៀសរបស់មនុស្សទាំងឡាយ ១, ច្រើនតែត្រូវគេប្រកាន់ទោស ១, បានសេចក្តីលំបាកច្រើន ១ ។

**៣-សមជ្ជាភិចរណៈ** ការដើរមើលល្បែងមហោស្រពមានទោសតាមវត្ថុដែលទៅមើល ៦ យ៉ាងគឺៈ រាំនៅទីណាទៅកាន់ទីនោះ ១, ច្រៀងនៅទីណាទៅកាន់ទីនោះ ១, ដេញដំប្រគំនៅទីណាទៅកាន់ទីនោះ ១, គេនិយាយលេងសើចនៅទីណាទៅកាន់ទីនោះ ១, ល្បែងច្រៀងទះដៃនៅទីណាទៅកាន់ទីនោះ ១, ពិណពាទ្យរនាតគងស្រឡៃប៉ីអនៅទីណា ទៅកាន់ទីនោះ ១ ។

**៤-ជូតានុយោគៈ** ការលេងល្បែងភ្នាល់មានទោស ៦ យ៉ាងគឺកាលឈ្នះរមែងបង្កឱ្យកើតពៀរ ១, កាលចាញ់រមែងសោកស្តាយទ្រព្យ ១, ទ្រព្យសម្បត្តិរមែងវិនាសទៅ ១, មិនមានអ្នកណាមួយជឿពាក្យរបស់ខ្លួន ១, ជាទីមើលងាយរបស់មិត្រ ១, មិនមានអ្នកណាមួយត្រូវការនឹងចងពន្ធផង ១ ។

**៥-បាបមិត្តានុយោគៈ** ការសេពគប់មនុស្សអាក្រក់ជាមិត្តមានទោស ៦ យ៉ាង គឺៈ នាំឱ្យជាអ្នកលេងល្បែងភ្នាល់ ឬល្បែងស៊ីសង ១, នាំឱ្យជាអ្នកលេងស្រី ១, នាំឱ្យជាអ្នកលេងស្រា ១, នាំឱ្យជាអ្នកបោកប្រាសគេចំពោះមុខ ១, ជាអ្នកលួចប្លន់ឆក់ដណ្តើមយកទ្រព្យសម្បត្តិគេ ១ ។

**៦-អាលស្សានុយោគៈ** ការខ្ជិលធ្វើការងារមានទោស ៦

យ៉ាង គឺៈ អតិសីតំ អាងថារងាណាស់ ហើយមិនធ្វើការងារ ១, អតិឧណ្ហំ អាងថាក្តៅណាស់ ហើយមិនធ្វើការងារ ១, អតិសាយំ អាងថា ល្ងាចណាស់ ហើយមិនធ្វើការងារ ១, អតិបាតោ អាងថាព្រឹក ណាស់ ហើយមិនធ្វើការងារ ១, អតិច្ឆាតោ អាងថាឃ្លានណាស់ ហើយមិនធ្វើការងារ ១, អតិបិបាសិតោ អាងថាស្រេកណស់ ហើយមិនធ្វើការងារ ១ ។

អ្នកដែលចង់បានសេចក្តីចម្រើន ដោយទ្រព្យសម្បត្តិ ត្រូវលះបង់អបាយមុខទាំង ៦ យ៉ាងនេះចេញ ។

ប្រស្នាប្រជុំកងធម៌ ភាគទី ២
ផ្ទាកត្រី ចប់តែប៉ុណ្ណេះ ។

---

# សុភាសិត

ពាលខ្លៅចូលនៅផងបណ្ឌិត ត្រាអស់ជីវិតលង់អនេក
មិនដឹងរសធម៌អាថ៌ជាឯង ដូចវែកមិនដឹងរសសម្ល ។

វាយចម្លងដោយភិក្ខុបញ្ញាបទីបោ ប៉ាត សុផល
ថ្ងៃអង្គារ ១២ រោច ខែទុតិយាសាឍ ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០១២
August 14, 2012